សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មិថុនា ឆ្នាំ 2013

# លីអាហូណា



## របៀបប្រាំបួនយ៉ាងដើម្បីពង្រឹងក្រុមគ្រួសាររបស់អ្នក ទំព័រ 26

ការអធិស្ឋានដោយមានអត្ថន័យ ៖ ពុំមែនធន្នះរបស់ខ្ញុំ តែរបស់ផងទ្រង់វិញ ទំព័រ 38, 48

ទេ្វគ្រោះចំពោះកូនមិនល្អ ទំព័រ 60

ខ្ញុំបានមានចិត្តភ័យខ្លាចនឹងទទួលបុណ្យជ្រមុជទឹក ទំព័រ 66



*« អាពាហ៍ពិពាហ៍នាំមកនូវសេក្តីនុពលកាន់តែធំសម្រាប់សុភមង្គលលើសពីទំនាក់ទំនងនៃមនុស្សលោកដទៃទៀតនាំមក »។*

អែលឌើរ រ័សុល អិម. ណិលសុន នៃកូរ៉ុមសាវកដប់ពីរនាក់ « ការថែទាំចំណងអាពាហ៍ពិពាហ៍ » *ទស្សនាវដ្ដីលីអាហូណា*និង *Ensign ខែឧសភា* ឆ្នាំ 2006, ទំព័រ 36 ។

# លីអាហូណា ខែ មិថុនា ឆ្នាំ 2013



22

## សារលិខិត


**4** **សារលិខិតគណៈប្រធានទីមួយ ៖ការដើរចុះដើរឡើងនៅកន្លែងដដែល**
ដោយប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ

**7** **សារលិខិតសួរសុខទុក្ខ ៖សេចក្ដីអំណរនៅក្នុងពង្សប្រវត្តិ**


## អត្ថបទពិសេសៗ


**14** **កូនចៀមដែលវង្វេងបាត់មានតម្លៃបំផុត**
ដោយប្រធាន ជេមស៍ អ៊ី. ហ្វោស្ដ
*សារលិខិតមួយនៃសេចក្ដីសង្ឃឹមសម្រាប់ឪពុកម្ដាយនៃកូនចៅដែលវង្វេង*

**22** **ការពង្រឹងក្រុមគ្រួសារ និងសាសនាចក្រតាមរយៈបព្វជិតភាព**
ដោយ រីឆាដ អិម. រ៉មនី
*សារលិខិតទាំងឡាយដកស្រង់ចេញពីការបំពាក់បំប៉នភាពជាអ្នកដឹកនាំទូទៅពិភពលោកថ្មីៗនេះកំពុងប្រទានដល់សមាជិកម្នាក់ៗ ក្រុមគ្រួសារ វួដ និងស្ដេក ។*

**26** **គោលការណ៍ទាំងប្រាំបួនសម្រាប់អាពាហ៍ពិពាហ៍ និងក្រុមគ្រួសារដ៏ជោគជ័យ**
ដោយចិននីហ្វឺរ ហ្រ្គេស យ៉ូនស៍
*តើគោលការណ៍ទាំងឡាយនៅក្នុងសេចក្ដីប្រកាសដល់ក្រុមគ្រួសារអាចយកមកអនុវត្តចំពោះក្រុមគ្រួសាររបស់អ្នកបានយ៉ាងដូចម្ដេចខ្លះ ?*


## ផ្នែកទាំងឡាយ


**8** **យើងនិយាយអំពីព្រះគ្រីស្ទ: « យើងនឹងមិនភ្លេចអ្នកឡើយ »**
ដោយ បេគី សក្វែអឺ

**10** **ដំណឹងល្អពីបុរាណ: ថ្វាយបង្គំព្រះដ៏ពិត ហើយមានព្រះជន្មរស់នៅ**
ប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឹល

**13** **ការបម្រើក្នុងសាសនាចក្រ: ការបម្រើដល់ជនពិការ**
ដោយ បេគី យ៉ង ហ្វសេត

**34** **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**74** **ព័ត៌មានសាសនាចក្រ**

**80** **លុះត្រាជួបទៀត: សេចក្ដីជំនឿរបស់ប្រជាជនរស់នៅលើកោះ**
ដោយ យូស្វេ ដេ ផាកកឺ


**នៅលើគម្រប**
ខាងមុខ ៖ រចនារូបថតដោយដាវីឌ ស្ដុកឃើ ។ ខាងក្រោយ ៖ រចនារូបថតដោយដាវីឌ ស្ដុកឃើ ។ ខាងក្នុងកម្របខាងមុខ ៖ ថតរូបដោយ យ៉ុស្ទិន យ៉ូហាន សូដឺរឃ្វីស្ដ ។

## មជ្ឈឹមវ័យវ័យក្មេង




**40 ពួកគេបាននិយាយមកកាន់យើង៖ ការកែលំអរការអធិស្ឋានផ្ទាល់ខ្លួនរបស់អ្នក**
អែលឌើរ យេវិន ដ័បុលយូ ភាសុន
*ការអធិស្ឋានផ្ទាល់ខ្លួនរបស់យើង គឺជារង្វាស់មួយនៃកម្លាំងខាងវិញ្ញាណរបស់យើង និងជាសញ្ញាមួយនៃសុខមាលភាពខាងវិញ្ញាណរបស់យើង ។*



*ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ ពាក្យណែនាំ៖ ចូរអត់ធ្មត់ពេលអ្នកស្រាវជ្រាវរក ។*

## យុវវ័យ

**42 សំណួរ និងចម្លើយ**
*បងប្រុសរបស់ខ្ញុំមានបញ្ហានឹងរូបអាសគ្រាម ។ គាត់កំពុងតែដោះស្រាយជាមួយនឹងប៊ីស្សពរបស់យើង អំពីរឿងនោះ ដូច្នេះខ្ញុំចង់គាំទ្រគាត់ ប៉ុន្តែវាមានឥទ្ធិពលលើទំនុកចិត្តរបស់ខ្ញុំទៅលើគាត់ ។ តើខ្ញុំនឹងប្រឈមមុខចំពោះរឿងនេះដោយរបៀបណា ?*

**44 ការធ្វើតុល្យភាពក្នុងប្រវត្តិសាស្ត្រសាសនាចក្រ**
អែលឌើរ ស្ទីវិន អ៊ី ស្នូ

**48 ការបំផុសគំនិតយ៉ាងខ្លាំងក្លានៃព្រះវិញ្ញាណ**
ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន
*តើយើងអាចធ្វើអ្វីខ្លះដើម្បីស្ថិតនៅក្នុងស្ថានភាពដ៏ត្រឹមត្រូវ ដើម្បីទទួលបានការបំផុសគំនិតពីព្រះវិញ្ញាណ ?*

**51 ឱផែនការនៃព្រះរបស់យើងធំណាស់ហ្ន៎!**
ដោយអាម៉ាសានា អ៊ី
*កាលដែលកុប្បកម្មមួយបានចាប់ផ្តើមនោះ បងប្រុសរបស់ខ្ញុំ ហើយនិងខ្ញុំបានចែកផ្លូវគ្នា ។ តើខ្ញុំនឹងបានជួបគាត់ម្តងទៀតដែរទេ ?*

**54 វិធីប្រាំយ៉ាងក្នុងការអនុវត្តតាមពាក្យទូន្មានពីអ្នកដឹកនាំបព្វជិតភាព**

**56 ដើម្បីកម្លាំងនៃយុវជន៖ ការដឹងគុណ**
ដោយដេវីឌ អេល បើក

**58 អំណោយសម្រាប់លោកយាយ**
ដោយគិមបឺលី សាប៊ីន
*តើអ្វីទៅជាអំណោយដ៏ល្អឥតខ្ចោះសម្រាប់លោកយាយរបស់ខ្ញុំ ដែលគាត់មាន អ្វីៗគ្រប់យ៉ាងនោះ ?*




## កុមារ




**60 ខ្សែភាពយន្តអាក្រក់**
ដោយយូលីអា វូដប៊ីរី
*សិស្សក្នុងថ្នាក់បានបោះឆ្នោត។ តើខ្ញុំត្រូវធ្វើយ៉ាងណា ?*

**62 សាក្សីពិសេស៖ តើព្រះវរបិតាសួគ៌ស្រឡាញ់សមាជិកនៃសាសនាចក្រនេះលើសពីមនុស្សដទៃទៀតមែនដែរឬទេ ?**
ដោយ អែលឌើរ យ៉្វនចិន អិល យុក

**63 ការអធិស្ឋានដោយចិត្តអំណត់**
អែលឌើរ ហូសេ អិល អាឡូនសូ
*ចម្លើយចំពោះការអធិស្ឋានមិនប្រាកដថានឹងកើតឡើងភ្លាមៗនោះទេ ប៉ុន្តែចម្លើយទាំងនោះនឹងមកយ៉ាងពិតប្រាកដ ។*

**64 ការនាំមេរៀនថ្នាក់កុមារមកក្នុងលំនៅដ្ឋាន៖ ខ្ញុំនឹងធ្វើតាមផែនការរបស់ព្រះវរបិតាសួគ៌ តាមរយៈការទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់**

**66 ពរជ័យនៃបុណ្យជ្រមុជទឹក**
ដោយ យេសុី អែ
*ការជ្រមុជចុះទៅក្នុងទឹកធ្វើឲ្យត្រេវើរភ័យខ្លាច ។ តើគាត់អាចទទួលបុណ្យជ្រមុជទឹកបានយ៉ាងដូចម្តេច ?*

**68 សួស្តី! ខ្ញុំឈ្មោះ អេងជិន អា. មកពីប្រទេសម៉ុងហ្គោលី**
*រៀនពី អេងជិន គ្រួសាររបស់នាង ហើយនិងសកម្មភាពដែលនាងចូលចិត្ត ។*

**70 សម្រាប់កុមារតូចៗ**

**81 រូបគំនូរព្យាការី៖ ឡូរ៉ែនសូ ស្នូ**

**ខែ មិថុនា ឆ្នាំ 2013 ច្បាប់ 13 លេខ. 3**
**លីអាហូណា 10786 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង,ឌៀថើរ អេស្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** បិយដ៍ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូប៊ើត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល ៖** ក្រេក អេ. ខារដុន
**អ្នកប្រឹក្សា ៖** ស្ទេន អិម. បូរិន, ប្រ៊ែដលី ឌី. ហ្វូស្ទើរ, គ្រីស្ទូហ្វែល ហ្គូលឌិន ជុញ្ញ័រ, អាន់ថូនី ឌី. ភើរគីន

**នាយកគ្រប់គ្រង ៖** ដេវីឌ ធី. វ៉ នើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ាញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយប៊ិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉េអិន ខារ, ឡារិននេ ផតជើរ ហ្គន
**ជំនួយការផ្នែកបោះពុម្ព ៖** មេលីស្សា ស្មិនតេណ្វូ
**និពន្ធ និងកែសម្រួល ៖** ស៊ូសាន បារ៉េត, ដេវីដ ឌិកសុន, ដេវីដ អេ. អែដវ៉ដ, ម៉ាថាយ ឌី. ហ្វលិតតុន, មិនឌី រ៉េ ហ្វ្រីដមែន, ហ្គែរី អេច. ហ្គាហ្វ, ជេនីហ្វើរ ហ្គេស ជូនស៍, ហ៊ីការី លូហ្វធើស, ម៉ៃឃើល អ័រ. ម៉ូរីស, រីឆាដ អិម. រ៉មនី, ប៉ុល វែនដិនប៊ើដ, ជូលៀ វូដប៊ឺរី

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជេនែត អែនឌ្រូ, ហ្វែ ភី អែនឌ្រើស, ស៊ី. ឃិមបល ប៊ិត, ថូម៉ាស ឆាលដ៍, ឃើរី លីន ស៊ី. ហើរិន, ខូលីន ហ៊ីងគ្លី, អ៊ីរីក ភី. ចនសិន, ស្កត អិម. មួយ, ប្រេដ ធារ៉េ

**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នែបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខននី ប៊ូស្រ្ទប ប្រ៊ីដ, ហាវ៉ដ ជី. ប្រោន, ជូលី ប៊ើដែត, ប្រាយអែន ដបុលយូ. ជីគី, ខាលីន ហាវ៉ដ, ដេនីស គើបៃ, ហ្គីននី ជេ. នីលសុន, ថាយ ភីធើ, ហ្គេលី ថេត រ៉ាហ្វើជី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ. សែតវីគ
**នាយកផ្នែកចែកចាយ ៖** អ៊ីវ៉ាន ឡាសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វ៊ីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2013 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្ម តាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
June 2013 Vol. 13 No. 3. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send address changes to Salt Lake Distribution Center, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368.

# យោបល់ទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះគឺមាននូវអត្ថបទ និងសកម្មភាពទាំងឡាយ ដែលអាចយកមកប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន ។*


រូបថតដោយ ខូឌី បេល © IRI

**« អំណោយសម្រាប់លោកយាយ »** ទំព័រ 58 ៖ សូមគិតពីការអាន អំពីអំណោយរបស់គិមបឺលី ចំពោះលោកយាយរបស់គាត់ ។ ដើម្បីជួយអ្នកឲ្យពិភាក្សាសាច់រឿងនេះ អ្នកអាចប្រើសំណួរដូចតទៅ ៖ ហេតុអ្វីអ្នកគិតថា សំបុត្ររបស់នាងមានអត្ថន័យសំខាន់ចំពោះលោកយាយ ? តើអ្នកមានអារម្មណ៍ដូចម្ដេច នៅពេលមាននរណាម្នាក់ អរគុណអ្នកចំពោះអ្វីមួយនោះ ? តើអ្នកគិតថា ព្រះវរបិតាសួគ៌មានអារម្មណ៍បែបណាចំពោះការដឹងគុណ ? អ្នកអាចអានអំពីការដឹងក្នុង*ដើម្បីកម្លាំងនៃយុវជន* នៅក្នុងទំព័រ 18 ។ សូមពិចារណាប្រាប់អំពីរឿងដែលព្រះយេស៊ូវគ្រីស្ទប្រោសមនុស្សកើតឃ្លង់10 នាក់ឲ្យជា នៅក្នុងលូកា 17:11–19 ហើយពិភាក្សាអំពីអ្វីដែលរឿងនេះបង្រៀនអំពីការដឹងគុណ ។ សម្រាប់សកម្មភាព សមាជិកក្រុមគ្រួសារម្នាក់ៗអាចសរសេរលិខិតថ្លែងអំណរគុណមួយ ហើយផ្ញើទៅឲ្យនរណាម្នាក់ក្នុងសប្ដាហ៍នោះ ។

**« ពរជ័យនៃបុណ្យជ្រមុជទឹក »** ទំព័រ 66៖ អ្នកអាចចាប់ផ្ដើមធ្វើរាត្រីជួបជុំគ្រួសាររបស់អ្នកដោយការច្រៀង «Nephi's Courage» (*Children' s Songbook* ទំព័រ120 ) ។ រួចហើយ អានរឿងរបស់ត្រេវើរយកឈ្នះលើការខ្លាចទឹករបស់គាត់ ហើយគិតពីសំណួរដូចតទៅនេះ ៖ តើអ្នកធ្លាប់ភ័យខ្លាចនឹងធ្វើអ្វីមួយដែរទេ ? តើអ្វីទៅដែលបានជួយអ្នកមិនឲ្យខ្លាចទៀត ? អញ្ជើញសមាជិកក្រុមគ្រួសារទាំងឡាយឲ្យចែកចាយអំពីអ្វី ដែលពួកគេត្រូវតែធ្វើដែលពួកគេបានព្រួយបារម្ភ ។ សូមពិភាក្សានូវវិធីទាំងឡាយដែលអ្នកអាចជួយបង្កើតនូវសេចក្ដីក្លាហានដល់គ្នាទៅវិញទៅមកជាគ្រួសារ ។ សម្រាប់សកម្មភាពមួយ អ្នកអាចបង្កើតនូវល្បែងជាផ្លូវឧបសគ្គនៅក្នុងបន្ទប់ ។ ចងកន្សែងបិទភ្នែកនរណាម្នាក់ នៅក្នុងគ្រួសាររបស់អ្នក ។ ដើម្បីជួយគាត់ឲ្យរៀនទុកចិត្ត ដោយការដើរដោយសុវត្ថិភាពតាមល្បែងផ្លូវឧបសគ្គ ដោយការស្ដាប់តាមពាក្យណែនាំ ។ អ្នកអាចពិភាក្សា អំពីរបៀបដែលព្រះវិញ្ញាណនឹងដឹកនាំយើង ហើយលួងលោមយើងនៅក្នុងស្ថានភាពទាំងឡាយណាដែលយើងមានអារម្មណ៍ភ័យខ្លាច ។

## ជាភាសារបស់អ្នក

លីអាហូណា និងធនធានផ្សេងទៀតរបស់សាសនាចក្រមានជាច្រើនភាសានៅលើគេហទំព័រ languages.lds.org ។

## ប្រធានបទទាំងឡាយក្នុងច្បាប់នេះ

*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

*ការគោរពប្រតិបត្តិ 54*
*ការគាំទ្រ 54*
*ការដឹងគុណ 56, 58*
*ការថ្វាយបង្គំ 10*
*ការបម្រើ 13, 14, 36*
*ការរាំរែក, 35*
*ការហៅក្នុងសាសនាចក្រ 13, 14*
*ការអធិស្ឋាន 34, 36, 38, 63*
*ការអភ័យទោស 42*
*កិច្ចការព្រះវិហារបរិសុទ្ធ 7, 14*
*ក្រុមគ្រួសារ 8, 22, 26, 42, 51, 58, 68*
*គំរូ 14*
*ទីបន្ទាល់ 48, 80*
*បទដ្ឋាន 35, 60*
*បព្វជិតភាព 54*
*ប្រព័ន្ធផ្សព្វផ្សាយ 60*
*ប្រវត្តិសាស្ត្រសាសនាចក្រ 44*
*ផែនការនៃសេចក្ដីសង្គ្រោះ 51*
*ពង្សប្រវត្តិ 7, 37*
*ពិធីបុណ្យជ្រមុជទឹក 64, 66*
*ព្រះគម្ពីរ 4*
*ព្រះយេស៊ូវគ្រីស្ទ 8, 14, 70*
*ព្រះវិញ្ញាណបរិសុទ្ធ 64*
*ភក្ដីភាព 14*
*ភាពពិការ 13*
*រូបអាសគ្រាម 42*
*សន្និសីទទូទៅ 4*
*សេចក្ដីជំនឿ 10, 14, 66, 80*
*សេចក្ដីលំបាក 8, 51*
*សេចក្ដីស្រឡាញ់ 62*
*ស្មីធ យ៉ូសែប 48*
*ឥរិយាបថ 14*

**សារលិខិតគណៈប្រធានទីមួយ**



**ដោយ ប្រធាន**
**ឌៀថើរ អេហ្វ. អុជដូហ្វ**
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

# ការដើរចុះដើរឡើង នៅកន្លែងដដែល

តើអ្នកធ្លាប់ដែលឮសុភាសិតមួយនិយាយថាមនុស្សដែលវង្វេងផ្លូវ ច្រើនតែដើរចុះដើរឡើងនៅកន្លែងដដែល ដែរឬទេ ?

ជែន អិល. ស៊ូមែន ជាអ្នកចិត្តវិទ្យា សញ្ជាតិអាឡឺម៉ង់ម្នាក់ បានមានបំណងចង់ដឹងថាតើរឿងនេះពិត ដែរឬទេ ។ គាត់បានពិសោធ ដោយយកមនុស្សម្នាក់ចូលទៅកាន់ព្រៃដ៏ធំមួយ និងទៅកាន់វាលខ្សាច់សាហារ៉ា ហើយបានប្រើប្រព័ន្ធត្រីវិស័យ ជី.ភី.អេស. ដើម្បីនឹងតាមដានទីកន្លែង ដែលពួកគេបានទៅ ។ ពួកគេគ្មានត្រីវិស័យឬ ឧបករណ៍ណាទៀតឡើយ ។ ដោយប្រាប់ឲ្យពួកគេធម្មតាៗថា ៖ ដើរតាមគំនូសទិសដៅ ដែលបានគូសបង្ហាញ ។

ក្រោយមក ចិត្តបណ្ឌិត ស៊ូមែន បានពិពណ៌នាអំពីអ្វីដែលបានកើតឡើង ។ ពួកគេ [ ខ្លះ ] បានដើរក្រោមថ្ងៃដែលមានពពកងងឹត ព្រោះពពកបាំងព្រះអាទិត្យ [ ហើយគ្មានចំណុចយោងឡើយ ] ។ . . . [ ពួកគេ ] វាល់គ្នាបានដើរចុះដើរឡើងនៅកន្លែងដដែល ដោយមានពួកគេខ្លះបានខ្វែងផ្លូវរបស់ខ្លួន ម្ដងហើយម្ដងទៀតដោយមិនដឹងខ្លួន » ។ មនុស្សខ្លះទៀត បានដើរកាលដែលព្រះអាទិត្យកំពុងតែភ្លឺចិញ្ចែងចិញ្ចាំង ដោយមានគំនូសយោងចង្អុលប្រាប់អាចមើលឃើញពីចម្ងាយ ។ « ពួកគេទាំងនេះ. . . បានដើរស្ទើរតែតាមផ្លូវត្រង់ដូចជាបន្ទាត់ ទាំងអស់ » ។[1]

ការពិសោធនេះបានធ្វើឡើងម្ដងហើយម្ដងទៀត ដោយប្រើវិធីសាស្រ្តទីទៃជាច្រើន ។[2] ពួកគេទាំងអស់គ្នា បានត្រឡប់មកវិញដោយមានលទ្ធផលស្រដៀងៗគ្នា ។

ដោយគ្មាននូវសញ្ញាដំណើរចរណ៍ មនុស្សលោកតែងតែដើរចុះដើរឡើងនៅកន្លែងដដែល ។

### ឥទ្ធិពលរបស់ព្រះគម្ពីរ

ដោយគ្មានឥទ្ធិពលខាងវិញ្ញាណ នោះមនុស្សលោកក៏វង្វេងវង្វាន់ដែរ ។ ដោយគ្មានព្រះបន្ទូលរបស់ព្រះ យើងដើរចុះដើរឡើងនៅកន្លែងដដែល ។

យើងមើលឃើញគំរូនេះ កើតឡើងច្រំដែលៗ ម្ដងហើយម្ដងទៀត នៅក្នុងរាល់គ្រាកាន់កាប់ត្រួតត្រា តាំងពីដើមមក ទាំងជាបុគ្គល និង សង្គម ។ នៅពេលយើងបាត់បង់ព្រះបន្ទូលរបស់ព្រះ យើងតែងតែវង្វេង ។

នេះគឺជា មូលហេតុដ៏ជាក់ច្បាស់ ដែលព្រះអម្ចាស់បានបញ្ជាឲ្យលីហៃបញ្ជូនកូនរបស់គាត់ ត្រឡប់ទៅក្រុងយេរូសាឡិមវិញ ដើម្បីយកផ្ទាំងលង្ហិន ។ ព្រះអម្ចាស់បានជ្រាបដឹងថា កូនចៅរបស់លីហៃ នឹងត្រូវការពឹងផ្អែកទៅលើសញ្ញាដំណើរចរណ៍—ចង្អុលប្រាប់—ដែលនឹងផ្ដល់ជាការដឹកនាំដល់ពួកគេអាចប្រើ ដើម្បីនឹងសម្រេចប្រសិនបើពួកគេស្ថិតនៅលើផ្លូវត្រូវឬអត់ ។

ព្រះគម្ពីរទាំងឡាយ គឺជាព្រះបន្ទូលរបស់ព្រះ ។ ព្រះគម្ពីរគឺជា សញ្ញាដំណើរចរណ៍ដែលបង្ហាញផ្លូវ ដែលយើងត្រូវធ្វើដំណើរ ដើម្បីខិតចូលទៅកាន់តែជិតព្រះអង្គសង្គ្រោះ ហើយទៅដល់ទីដៅ ។

### ឥទ្ធិពលនៃសន្និសិទទូទៅ

ដំបូន្មានដែលត្រូវបានផ្ដល់ឲ្យនៅឯសន្និសិទទូទៅ គឺជាឥទ្ធិពលមួយទៀត ដែលអាចជួយយើងឲ្យដឹងថា ប្រសិនបើយើងស្ថិតនៅលើផ្លូវឬអត់ ។

យូរៗម្ដង ខ្ញុំសួរខ្លួនឯងថា « តើខ្ញុំបានស្ដាប់តាមពាក្យពេចន៍ទាំងឡាយ ដែលបានផ្ដល់ដោយពួកបុរស និងស្ត្រី ដែលបានបន្លឺឡើងក្នុងសន្និសិទទូទៅថ្មីៗនេះ នៃសាសនាចក្រឬទេ ? តើខ្ញុំបានអានពាក្យពេចន៍របស់ពួកគាត់ម្ដងហើយម្ដងទៀត ដែរឬទេ ? តើខ្ញុំបានសញ្ជឹងគិតពាក្យទាំងនោះ ហើយបានអនុវត្តតាមនៅក្នុងជីវិតរបស់ខ្ញុំដែរឬទេ ? ឬតើខ្ញុំគ្រាន់តែចូលចិត្តព្រោះតែជាសន្ទរកថាល្អ ហើយមិនអើពើក្នុងការអនុវត្តតាមសារលិខិតដ៏បំផុសគំនិតនោះ នៅក្នុងជីវិតខ្ញុំឬ ?

ប្រហែលជា ក្នុងពេលអ្នកកំពុងតែស្ដាប់ ឬអាន អ្នកអាចសរសេរកំណត់សារមួយ ឬពីរទុក ។ ប្រហែលអ្នកបានធ្វើការប្ដេជ្ញាចិត្ត ដើម្បីនឹងធ្វើទង្វើណាមួយឲ្យកាន់តែល្អប្រសើរ



ឡើង ឬកាន់តែមានប្រសិទ្ធិភាពឡើង ។ ចូរគ្រាន់តែគិតអំពីសារដំណឹងនៃសន្និសិទ្ធទូទៅថ្មីៗនេះ ។ សារជាច្រើននេះអញ្ជើញយើងឲ្យពង្រឹងក្រុមគ្រួសារយើង និងធ្វើឲ្យអាពាហ៍ពិពាហ៍របស់យើងកាន់តែល្អប្រសើរឡើង ។ ច្បាប់នៃទស្សនាវដ្ដី*លីអាហូណា*នេះក៏ផ្ដោតទៅលើគោលតម្លៃដ៏អស់កល្បទាំងនេះ ជាមួយនឹងអនុសាសន៍ចាំបាច់ជាច្រើនដើម្បីនឹងផ្ដល់ជាពរដល់ជីវិតរបស់យើង ។

តើយើងកំពុងសម្គាល់ ហើយយកដំបូន្មានតាមការប្រឹក្សាដ៏សំខាន់នេះឬទេ ? តើយើងកំពុងតែស្គាល់ ហើយដើរឆ្ពោះទៅរកសញ្ញាដំណើរចរណ៍ ដ៏ពិត និង មានតម្លៃទាំងនេះឬទេ ?

### ដំណោះស្រាយចំពោះការដើរវង្វេងផ្លូវ

សញ្ញាដំណើរចរណ៍ខាងវិញ្ញាណ គឺសំខាន់ក្រៃលែងដើម្បីនឹងជួយយើងឲ្យស្ថិតនៅលើផ្លូវត្រង់ និងចង្អៀត ។ វាផ្ដល់ជាសេចក្ដីណែនាំយ៉ាងច្បាស់លាស់ អំពីផ្លូវដែលយើងត្រូវតែធ្វើដំណើរ ប៉ុន្តែលើកលែងតែបើយើងស្គាល់សញ្ញាទាំងនោះ ហើយដើរសំដៅទៅរកប៉ុណ្ណោះ ។

ប្រសិនបើយើងបដិសេធមិនយកការដឹកនាំដោយសញ្ញាដំណើរចរណ៍ទាំងនេះ វានឹងក្លាយទៅជាស្មុគស្មាញគ្មានអត្ថន័យ និង តុបតែងលំអរ ដែលគ្មានគោលបំណងប៉ុន្តែនឹងបំបាក់បំបែកទំនាបនៃជើងមេឃ ។

វាមិនគ្រប់គ្រាន់ទេបើគ្រាន់តែអនុវត្តតាមសុភាវគតិរបស់យើងប៉ុណ្ណោះនោះ ។

វាមិនគ្រប់គ្រាន់ទេ បើគ្រាន់តែមានចេតនាដ៏ល្អឥតខ្ចោះនោះ ។

វាមិនគ្រប់គ្រាន់ទេ ដើម្បីនឹងសំអាងទៅលើអារម្មណ៍ធម្មជាតិរបស់យើងតែប៉ុណ្ណោះនោះ ។

ថ្វីបើនៅពេលយើងគិតថា យើងកំពុងតែដើរតាមផ្លូវខាងវិញ្ញាណដ៏ត្រង់ ដោយគ្មានសញ្ញាដំណើរចរណ៍ពិត ដើម្បីនឹងដឹកនាំយើងក៏ដោយ បើគ្មានការដឹកនាំនៃព្រះវិញ្ញាណ—យើងនឹងវង្វេងផ្លូវ ។

ហេតុដូច្នេះហើយចូរយើងបើកភ្នែករបស់យើង ហើយសម្លឹងមើលសញ្ញាដំណើរចរណ៍ ដែលព្រះអម្ចាស់បានប្រទានដល់កូនចៅរបស់ទ្រង់ ។ ចូរយើងអាន ស្ដាប់ ហើយនិងអនុវត្តតាមព្រះបន្ទូលរបស់-ព្រះអម្ចាស់ចុះ ។ ចូរយើងអធិស្ឋាន ដោយមានដួងចិត្តស្មោះ ហើយស្ដាប់តាម ហើយនិងអនុវត្តតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។ កាលណាយើងបានស្គាល់សញ្ញាណដំណើរចរណ៍ដ៏អស្ចារ្យទាំងឡាយដែលបានប្រទានមកដោយព្រះវរបិតាសួគ៌ជាទីស្រឡាញ់នៃយើង ដែលយើងត្រូវតែស្ថាបនានៅលើផ្លូវតាមសញ្ញាទាំងនោះ ។ យើងក៏ត្រូវតែធ្វើការកែតម្រូវផ្លូវធម្មតាផងដែរ ក្នុងពេលយើងបង្វែរខ្លួនយើងទៅកាន់សញ្ញាដំណើរចរណ៍ខាងវិញ្ញាណទាំងនេះ ។

នៅក្នុងរបៀបនេះ យើងនឹងមិនវង្វេងចុះឡើងនៅកន្លែងដដែលៗនោះទេ ប៉ុន្តែដើរដោយទំនុកចិត្ត ហើយមានភាពជាក់ច្បាស់ទៅកាន់ពរសួគ៌ាដ៏ធំនោះ ដែលជាអំណាចមរតកចំពោះអស់អ្នកដែលដើរនៅលើផ្លូវត្រង់ ហើយចង្អៀតនៃភាពជាសិស្សរបស់ព្រះគ្រីស្ទ ។ ■

**កំណត់សម្គាល់**

1. សូមមើលជែន អិល ស៊ូមែននិងអ្នកឯទៀត "Walking Straight into Circles," *Current Biology* vol. 19 (Sept. 29, 2009), 1538 ។
2. សូមមើលជាឧទាហរណ៍ « សេចក្ដីអាថ៌កំបាំង ៖ ហេតុអ្វីយើងមិនអាចដើរត្រង់ ? » npr.org/blogs/krulwich/2011/06/01/131050832/a-mystery-why-can-t-we-walk-straight.

**ការបង្រៀនចេញពីសារលិខិតនេះ**

កាលដែលអ្នករៀបចំដើម្បីបង្រៀនពីសារលិខិតនេះ អ្នកអាចស្វែងរកក្នុងព្រះគម្ពីរនូវឧទាហរណ៍ទាំងឡាយអំពីប្រជាជន ដែលត្រូវបានដឹកនាំ ដោយសញ្ញាដំណើរចរណ៍ខាងវិញ្ញាណ ឬប្រជាជនដែលបានដើរវង្វេងចុះឡើងនៅកន្លែងដដែលៗ ។ អ្នកអាចចាប់ផ្ដើមការសិក្សារបស់អ្នក ជាមួយបទគម្ពីរទាំងនេះ ៖ជនគណនា 14:26–33 នីហ្វៃ 1 16:28–29; អាលម៉ា 37:38–47 ។ ប្រសិនបើអ្នកមានអារម្មណ៍បំផុសគំនិត អ្នកអាចចែករំលែកពីអារម្មណ៍របស់អ្នកនូវគំរូទាំងនេះជាមួយនឹងអ្នកកំពុងរៀន ។ សួរពួកគេអំពីអ្វីដែលយើងអាចរៀនអំពីរឿងទាំងនេះ ។

រូបភាព © Thinkstock/iStockphoto

## សញ្ញាដំណើរចរណ៍សម្រាប់អ្នក

ប្រធាន អុជដូហ្វ ពិពណ៌នាថា សន្និសិទ្ធទូទៅ និង ព្រះគម្ពីរទុកជាឥទ្ធិពល ដែលជួយយើងឲ្យចៀសវាងពីការវង្វេងខាងវិញ្ញាណ ។ សញ្ជឹងគិតនូវឥទ្ធិពលខាងវិញ្ញាណឯទៀត ដែលមានអានុភាព និង បានដឹកនាំជីវិតរបស់អ្នក ។ សរសេរបទពិសោធន៍របស់អ្នកនៅក្នុងកំណត់ហេតុរបស់អ្នក។ ពាក្យសម្រង់ទាំងនេះ មកពីប្រធាន ម៉នសុន ប្រហែលជាអាចជួយអ្នកបាន ៖



« ពរជ័យរបស់អ្នក មិនមែនត្រូវបត់ទុកឲ្យស្អាត ហើយមូរទុកចោលនោះទេ ។ វាមិនមែនត្រូវដាក់ស៊ុមទុក ឬ បោះពុម្ពទុកនោះទេ ។ ប៉ុន្តែ វាត្រូវយកមកអាន ។ វាត្រូវតែទទួលបានក្ដីស្រឡាញ់ ។ វាត្រូវតែបានធ្វើតាម » ។ ពរជ័យអយ្យកោរបស់អ្នកនឹងជួយអ្នកនៅក្នុងគ្រាដ៏ងងឹត ។ វានឹងដឹកនាំអ្នកឆ្លងកាត់គ្រោះថ្នាក់ក្នុងជីវិត » ។

**“Your Patriarchal Blessing: A Liahona of Light” *Ensign* ខែ វិច្ឆិកា ឆ្នាំ 1986 ទំព័រ 66 ។**

« ព្រះវរបិតាសួគ៌របស់យើងមិនបានជំរុញយើង ទៅលើការធ្វើដំណើរដ៏អស់កល្ប ដោយមិនបានប្រទានមធ្យោបាយទាំងឡាយ ដែលថាតាមមធ្យោបាយទាំងនេះ យើងអាចទទួលការដឹកនាំពីទ្រង់ ដើម្បីបញ្ជាក់នូវការត្រឡប់មកវិញដោយសុវត្ថិភាពរបស់យើងនោះឡើយ ។ ខ្ញុំនិយាយអំពីការអធិស្ឋាន ។ ខ្ញុំក៏និយាយអំពីការខ្សិបប្រាប់ចេញពីសំឡេងតូចរហៀងៗនោះ ។ »

**« ការរត់ប្រណាំងនៃជីវិត » *លីអាហូណា* និង *Ensign* ខែ ឧសភាព ឆ្នាំ 2012 ទំព័រ 92 ។**



## ខ្ញុំអាចរកផ្លូវរបស់ខ្ញុំឃើញ

ប្រធាន អុជដូហ្វ មានប្រសាសន៍ថា យើងត្រូវការដើរតាមសញ្ញាដំណើរចរណ៍ខាងវិញ្ញាណ ពីព្រោះសញ្ញាទាំងនេះ នឹងជួយយើងឲ្យជ្រើសត្រូវ ហើយចូលមករកព្រះគ្រីស្ទកាន់តែជិត ។ សញ្ញាដំណើរចរណ៍មួយចំនួនទាំងនេះ គឺជាជាការអធិស្ឋាន ព្រះគម្ពីរ សន្និសិទ្ធទូទៅ ហើយនិងទស្សនាវដ្ដី*លីអាហូណា* ។

ស្វែងរកផ្លូវរបស់អ្នកឆ្លងកាត់ភាពច្របូកច្របល់ ដោយការដើរតាមសញ្ញាដំណើរចរណ៍ទាំងនេះ ។

សូមអានសន្ទរកថា ពីសន្និសិទ្ធទូទៅចុងក្រោយជាមួយក្រុមគ្រួសាររបស់អ្នក ។ តើអ្នកថ្លែងសន្ទរកថាផ្ដល់ជាយោបល់អ្វីខ្លះ ដែលយើងគួរតែធ្វើ ដើម្បីស្ថិតនៅលើផ្លូវត្រូវ ? សូមដាក់គោលដៅជាមួយក្រុមគ្រួសារអ្នក ដើម្បីនឹងយកមកអនុវត្តនូវអ្វីដែលអ្នកបានរៀន ។




រចនារូបភាពដោយ ស្កត ហ្វ្រៀ

**សារលិខិតការបង្រៀនសួរសុខទុក្ខ**

*សូមសិក្សាឯកសារនេះប្រកបដោយការអធិស្ឋាន តាមដែលគួរសម សូមធ្វើការពិភាក្សាអំពីកិច្ចការនេះ ជាមួយនឹងបងប្អូនស្ត្រីដែលអ្នកទៅសួរសុខទុក្ខ ។ សូមប្រើសំណួរនានាដើម្បីជួយអ្នកពង្រឹង ដល់បងប្អូនស្ត្រី និងដើម្បីធ្វើឲ្យថ្នាក់សមាគមសង្គ្រោះក្លាយជាផ្នែកដ៏សកម្មមួយនៅក្នុងជីវិតផ្ទាល់របស់អ្នក ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ reliefsociety.lds.org ។*

# សេចក្តីអំណរនៅក្នុងពង្សប្រវត្តិ



អែលឌើរ រ័សុល អិមណិលសុននៃកូរ៉ុមសាវកដប់ពីរនាក់ បានបង្រៀនថា វិញ្ញាណរបស់អេលីយ៉ា គឺជា « ការបង្ហាញព្រះអង្គខ្លួននៃព្រះវិញ្ញាណបរិសុទ្ធ ថ្លែងជាសាក្សីអំពីនិស្ស័យដ៏ទេវភាពនៃក្រុមគ្រួសារ ។ »[1]

ក្នុងនាមជាសមាជិកនៃសាសនាចក្រដែលបានស្ដារឡើងវិញរបស់ព្រះគ្រីស្ទ យើងមានទំនួលខុសត្រូវដែលភ្ជាប់ជាមួយសេចក្តីសញ្ញា ដើម្បីនឹងស្រាវជ្រាវស្វែងរកដូនតារបស់យើង ហើយធ្វើពិធីបរិសុទ្ធនៃការសង្គ្រោះក្នុងដំណឹងល្អដល់ពួកគាត់ ។ បើគ្មានពួកយើងទេនោះ ពួកគាត់មិនអាច « បានគ្រប់លក្ខណ៍ឡើយ » ( ហេព្រើរ 11:40 ) និង « រីឯយើងក៏ពុំអាចបានល្អឥតខ្ចោះក្រៅពីមនុស្សស្លាប់របស់យើងដែរ » ( គ. និង ស. 128:15 )

កិច្ចការពង្សប្រវត្តិរៀបចំយើងដើម្បីទទួលពរជ័យនៃជីវិតអស់កល្បជានិច្ច ហើយជួយយើងឲ្យបង្កើនសេចក្តីជំនឿ និង សុចរិតភាពរបស់យើងផ្ទាល់ ។ ពង្សប្រវត្តិគឺជាផ្នែកយ៉ាងសំខាន់នៃបេសកកម្មរបស់សាសនាចក្រ ហើយជម្រុញនូវកិច្ចការនៃសេចក្តីសង្គ្រោះ និង ការដំកើងចំពោះជនគ្រប់រូប ។

ប្រធាន ប៊ិយដ៍ ឃេ. ផាកកឺ ជាប្រធាននៃកូរ៉ុមសាវកដប់ពីរនាក់បានមានប្រសាសន៍ថា ៖ « នៅពេលយើងស្រាវជ្រាវ ខ្សែពង្សស្រឡាយយើងផ្ទាល់ យើងប្រែទៅជាមានចំណូលចិត្ត លើសពីការស្វែងរកឈ្មោះនៃមរណជនទាំងឡាយទៅទៀត ។ . . . ចំណូលចិត្តរបស់យើងនឹងបង្វែរចិត្តរបស់យើងទៅរកដូនតារបស់យើង—យើងខំប្រឹងប្រែងស្វែងរកពួកគេ ហើយស្គាល់ពួកគេ ហើយនិងបំរើពួកគេ »។ [2]

### *ចេញពីព្រះគម្ពីរ*

ម៉ាឡាគី 4:5–6; កូរិនថូសទី 1 15:29;គ. និង ស. 124:28–36; 128:15

**កំណត់សម្គាល់**

1. រ័សុល អិម. ណិលសុន « A New Harvest Time » *Liahona* ខែ វិច្ឆិកា ឆ្នាំ 1998 ទំព័រ 34; *Ensign* ខែ ឧសភា ឆ្នាំ 1998 ទំព័រ 34 ។
2. ប៊ិយដ៍ ឃេ. ផាកឺ « ពង្សប្រវត្តិរបស់អ្នក ៖ ចាប់ផ្តើមទៅ » *លីអាហូណា* និង *Ensign* ខែ វិច្ឆកា ឆ្នាំ 2011 ទំព័រ 17 ។
3. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស៊្មីធ* ( ឆ្នាំ 2007 ) ទំព័រ 267 ។
4. សូមមើល *Daughters in My Kingdom ៖ The History and Work of Relief Society* ( ឆ្នាំ 2011 ) ទំព័រ 92–95 ។

**សេចក្តីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ**

### *ចេញពីប្រវត្តិសាស្ត្ររបស់យើង*

ព្យាការីយ៉ូសែប ស៊្មីធបានបង្រៀនថា ៖ « ទំនួលខុសត្រូវដ៏ធំបំផុតនៅក្នុងផែនដីនេះគឺថា ព្រះអម្ចាស់បានផ្ទុកមកលើយើងគឺដើម្បីនឹងស្វែងរកមរណជនរបស់យើង »។ [3] យើងអាចបម្រើជាអ្នកប្រព្រឹត្តិជំនួស នៅក្នុងព្រះវិហារបរិសុទ្ធ សម្រាប់ដូនតាដែលបានស្លាប់ ហើយធ្វើពិធីបរិសុទ្ធចាំបាច់សម្រាប់ពួកគេ ។

សាលីវែនដុល មកពីក្រុងណាវូ រដ្ឋអៀលិណ្ណយ ដែលកូនប្រុស 14ឆ្នាំរបស់គាត់បានស្លាប់ ហើយបានរកឃើញការលួងលោមនៅក្នុងសេចក្តីសន្យានៃក្រុមគ្រួសារដ៏អស់កល្បជានិច្ច ។ បន្ទាប់ពីស្វាមីគាត់បានទទួលបុណ្យជ្រមុជទឹកជំនួសកូនរបស់ពួកគេ គាត់បានសរសេរទៅសាច់ញាតិរបស់គាត់ថា ៖ « ឱ អ្វីដែលរុងរឿងនោះគឺថា យើង . . . អាចទទួលបុណ្យជ្រមុជទឹក សម្រាប់ [ ដូនតា ] ដែលបានស្លាប់ទាំងអស់របស់យើង ហើយសង្គ្រោះពួកគាត់តាមតម្រិះ ដែលយើងអាចមានអំពីពួកគាត់ » ។ រួចហើយគាត់បានស្នើសុំឲ្យញាតិសន្តានរបស់គាត់បញ្ជូនព័ត៌មានអំពីដូនតារបស់ពួកគេមកគាត់ដោយនិយាយថា ៖ « ខ្ញុំមានចេតនានឹងធ្វើអ្វីៗដែលខ្ញុំអាចធ្វើបានដើម្បីនឹងសង្គ្រោះ [ គ្រួសារយើង ] » ។ [4]

**តើខ្ញុំអាចធ្វើអ្វីបាន ?**

1. តើខ្ញុំអាចជួយបងប្អូនស្រីៗ ដែលខ្ញុំមើលខុសត្រូវដើម្បីនឹងធ្វើពង្សប្រវត្តិដូចម្តេច ?
2. តើខ្ញុំកំពុងតែចម្លងទុកពង្សប្រវត្តិផ្ទាល់ខ្ញុំដែរឬទេ ?

រចនារូបភាព ដោយក្រេក ឌែរ៉ូស៊ី និងខ្ញី ប៉េល © IRI

# « យើងនឹងមិនអភ័យទោសឲ្យឯងទេ »

**ដោយបេគី ស្មែអឺរ៍**

ក្នុងពេលខ្ញុំបានដើរចូលទៅការណាត់ជួបនឹងវេជ្ជបណ្ឌិតជាប្រចាំ ខ្ញុំមានចិត្តសោមនស្ស និងសេចក្ដីសង្ឃឹមយ៉ាងធំក្រៃលែង ។ ខ្ញុំបានឃើញចង្វាក់បេះដូងនៃទារកដ៏តូចរបស់ខ្ញុំ ប៉ុន្តែឥឡូវនេះពីរបីអាទិត្យក្រោយមក ទារកដ៏តូចនៅក្នុងផ្ទៃពោះរបស់ខ្ញុំកាន់តែមានទំហំធំឡើង ។ ខ្ញុំមិនដែលឈប់មានចិត្តអស្ចារ្យ ចំពោះបទពិសោធន៍នៃអព្ភូតហេតុ ចំពោះការមានផ្ទៃពោះបីដងរួចទៅហើយឡើយ ។

ដប់នាទីក្រោយមកខ្ញុំបានយំតែម្នាក់ឯង នៅក្នុងឡានរបស់ខ្ញុំ—ទ្រង់ទ្រាយនៃទារកមិនកម្រើក ដែលគ្មានចង្វាក់បេះដូង បានដិតជាប់នៅក្នុងគំនិតរបស់ខ្ញុំជានិរន្តរ៍ ។

ខ្ញុំបានមានស្មារតីស្រឡាំងកាំងភ្លេចភ្លាំង ក្នុងអំឡុងពេលប៉ុន្មានថ្ងៃក្រោយបន្ទាប់មក ។ ខ្ញុំបានមានអារម្មណ៍ហួតហែង និង ឯកោនៅក្នុងចិត្ត ស្វាមីខ្ញុំបានត្រឡប់ទៅធ្វើការវិញ ហើយកូនទាំងបីនាក់របស់យើងបានរត់ជុំវិញផ្ទះ ក្នុងពេលដែលខ្ញុំបានរៀបអាហារដល់ពួកគេទទួលទាន ហើយខិតខំរក្សាផ្ទះឲ្យបានស្អាតដោយចិត្តអួលអាក់ ។ ប៉ុន្តែខ្ញុំហាក់ដូចជាគ្មានអារម្មណ៍នៅក្នុងខ្លួនឡើយ ។ នៅពេលខ្ញុំបានមកផ្ទះពីការធ្វើដំណើរ ទៅបំពេញធុរៈនៅកន្លែងនេះ កិច្ចការដំបូង ដែលខ្ញុំតែងតែធ្វើនោះ គឺត្រូវពិនិត្យមើល ថាតើមាននរណាខ្លះបានទូរសព្ទ័មកខ្ញុំ ដែលខ្ញុំមិនបានទទួល ។ គ្មានទេ ។ ខ្ញុំតែងតែចូលមើលអ៊ីមែលរៀងរាល់ម៉ោង ។ គ្មានអ្វីទាំងអស់ ។ ខ្ញុំបានចាប់ផ្ដើមមានចិត្តងឿងឆ្ងល់ ប្រសិនបើមិត្តភក្តិ និងអ្នកជិតខាងខ្ញុំយកចិត្តទុកដាក់នឹងខ្ញុំឬអត់ ។ តើពួកគេពិតជាមិត្តរបស់ខ្ញុំឬទេ ? ខ្ញុំមិនបានសង្កេតដឹងអំពីរបៀបដែលសាតាំងបានធ្វើសកម្មភាពមកលើខ្ញុំ ។

ខ្ញុំកំពុងតែចែកចាយអារម្មណ៍ខ្ញុំ ជាមួយស្វាមីខ្ញុំក្នុងរាត្រីមួយ ហើយគាត់បានមើលឃើញអ្វីដែលកំពុងតែកើតឡើងដល់ខ្ញុំមួយរំពេច ។ គាត់បានចែកវគ្គគម្ពីរនីហ្វៃទី 1 21:15–16 ជាមួយនឹងខ្ញុំថា ៖

« ឱវង្សអ៊ីស្រាអែលអើយយើង[នឹង]មិនដែលភ្លេចអ្នកឡើយ ។

« មើលចុះ យើងបានចារិកអ្នកទុក នៅផ្ទៃបាតដៃរបស់យើងហើយ អស់ទាំងកំផែងអ្នកនៅចំពោះភ្នែកយើងជានិច្ច » ។

ខ្ញុំបានរៀនដឹង និងសិក្សាអំពីដង្វាយធួនពីមុនមក ។ ខ្ញុំបានគិតថា ខ្ញុំបានដឹងថាអ្វីទៅជាដង្វាយធួនរួចទៅហើយ ។ ប៉ុន្តែខ្ញុំមិនបានអនុវត្តដង្វាយធួនឲ្យបានត្រឹមត្រូវ នៅក្នុងជីវិតរបស់ខ្ញុំនោះទេ ។ ព្រះយេស៊ូវ បានរងទុក្ខឈឺចាប់ចំពោះទុក្ខសោកទាំងអស់របស់ខ្ញុំរួចទៅហើយ ។ ទ្រង់ពិតជាដឹងអំពីអារម្មណ៍របស់ខ្ញុំ ។

« ដង្វាយធួនដែលជាទង្វើគំរូដ៏ល្អបំផុតរបស់ទ្រង់ គឺតម្រូវឲ្យព្រះយេស៊ូវ ‹ បានយាងក្រោមគ្រប់ទាំងអស់ › (គ. និង ស. 88:6 ) ហើយបានរងទុក្ខឈឺចាប់ ‹ នៃមនុស្សលោកទាំងអស់ › ( នីហ្វៃទី 1 9:21) ។ ហេតុដូច្នេះហើយយើងយល់ឃើញថា ដង្វាយធួនមានគោលបំណងដ៏ទូលំទូលាយជាជាងការផ្ដល់នូវមធ្យោបាយដើម្បីយកឈ្នះលើអំពើបាប ។ ការសម្រេចដ៏ធំបំផុតនៅលើផែនដីនេះ ផ្ដល់ដល់ព្រះអង្គសង្គ្រោះ នូវអំណាចដើម្បីបំពេញសេចក្ដីសន្យានេះ ៖ ‹ បើសិនជាអ្នករាល់គ្នាបែរត្រឡប់មករកព្រះអម្ចាស់ដោយស្មោះពីចិត្ត ទ្រង់នឹង. . .ដោះលែងអ្នកឲ្យរួច › ( ម៉ូសាយ 7:33 ) » ។[1]



**ទ្រង់យល់**

« គ្មានអ្វីដែលយើងកំពុងតែស៊ូទ្រាំ ដែលព្រះយេស៊ូវមិនយល់នោះឡើយ ហើយទ្រង់រង់ចាំយើងឲ្យចូលទៅឯព្រះវរបិតាសួគ៌របស់យើងនៅក្នុងការអធិស្ឋាន ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ប្រសិនបើយើងគោរពប្រតិបត្តិតាម ហើយប្រសិនបើយើងខំប្រឹងប្រែង នោះការអធិស្ឋានរបស់យើងនឹងត្រូវបានឆ្លើយតបបញ្ហារបស់យើងនឹងបានស្រាកស្រាន្តសេចក្ដីភ័យខ្លាចយើងនឹងរសាត់បាត់ ពន្លឺនឹងបានបំភ្លឺដល់យើង ភាពងងឹតនៃក្ដីអស់សង្ឃឹមនឹងខ្ចាត់ខ្ចាយទៅ ហើយយើងនឹងនៅជិតព្រះអម្ចាស់ ហើយមានអារម្មណ៍នៃសេចក្ដីស្រឡាញ់ និងការលួងលោមនៃព្រះវិញ្ញាណបរិសុទ្ធទៀតផង »។

**អែលឌើរ រ៉ូបឺត ឌី. ហែលស៍នៃកូរ៉ុមសាវកដប់ពីរនាក់ « Behold, We Count Them Happy Which Endure » *Ensign* ខែ ឧសភា ឆ្នាំ 1998 ទំព័រ 77 ។**



*ស្វាមីខ្ញុំបានចែកចាយ នីហ្វៃទី 1 21:15–16ជាមួយខ្ញុំ ។ ខ្ញុំបានដឹងថា ខ្ញុំបានត្រូវការព្រះអង្គសង្គ្រោះរបស់ខ្ញុំ ដើម្បីជួយខ្ញុំឲ្យយកឈ្នះលើទុក្ខសោករបស់ខ្ញុំ ។*

*តើខ្ញុំគួរមានមិត្តភក្តិបែបណា ដែលល្អប្រសើរក្នុងអំឡុងពេលមោឃៈនេះ ជាងមិត្តភក្តិដែលចូលរួមមានចិត្តអាណិតមេត្តាចំពោះខ្ញុំនោះ ? ខ្ញុំបានដឹងថា ខ្ញុំត្រូវការព្រះអង្គសង្គ្រោះរបស់ខ្ញុំ ជួយខ្ញុំយកឈ្នះលើទុក្ខសោករបស់ខ្ញុំ ។ កាលដែលខ្ញុំបានទៅរកព្រះអម្ចាស់នោះ ខ្ញុំបានឃើញសេចក្ដីស្រឡាញ់របស់ទ្រង់មានសម្រាប់ខ្ញុំមួយរំពេច ។ ខ្ញុំបានមានអារម្មណ៍ស្ងប់ និង សុខសាន្ត ហើយខ្ញុំបានមានអារម្មណ៍ថា ព្រះយេស៊ូវបានជ្រាបដឹងអំពីអ្វីដែលខ្ញុំមិនដែលជឿថា អាចកើតឡើង ។ ទ្រង់ពិតជាមិត្តមួយប្រភេទ ដែលខ្ញុំទន្ទឹងរង់ចាំនៅក្នុងបណ្ដាថ្ងៃទាំងនេះ បន្ទាប់ពីការរលូតកូនរបស់ខ្ញុំ—ជាមិត្តម្នាក់ដែលខ្ញុំត្រូវការជាងគេ ។*

*ខ្ញុំបានដឹងថាខ្ញុំតែងតែអាចបែរទៅរកព្រះអង្គសង្គ្រោះ មិនត្រឹមតែនៅពេលខ្ញុំត្រូវតែប្រែចិត្តប៉ុណ្ណោះទេ ប៉ុន្តែក៏នៅពេលដែលខ្ញុំត្រូវការការលួងលោមផងដែរ ។ ទ្រង់តែងតែនៅទីនោះជានិច្ច ។ នៅពេលយើងកំពុងតែស្វែងរកនរណាម្នាក់ ឲ្យយល់អំពីការឈឺចាប់ និងទុក្ខសោករបស់យើង ចូរយើងកុំភ្លេចមិត្តដ៏ស្មោះត្រង់បំផុតរបស់យើង គឺជាព្រះយេស៊ូវគ្រីស្ទ ។ ■*

*អ្នកនិពន្ធរស់ក្នុង រដ្ឋយូថា ស.ហ.រ*

**កំណត់សម្គាល់**

1. ដាណុលដ៍ អិល. ហលស្ត្រម « បែរទៅរកព្រះអម្ចាស់ » *លីអាហូណា* និង *Ensign,* ខែ ឧសភា ឆ្នាំ 2010 ទំព័រ 80 ។

## តើយើងអាចទទួលបានសេចក្ដីសុខដូចម្ដេច ?

ប្រធាន ថូម៉ាស អេស. ម៉នសុនបានមានប្រសាសន៍អំពីរបៀបបីយ៉ាងដើម្បីនឹងរកបានសេចក្ដីសុខ នៅក្នុងជីវិតរបស់យើង ។

« ខ្ញុំមិនចង់បានសេចក្ដីសុខ ដែលត្រូវបានតំកើងដោយមនុស្សលោកឡើយ ប៉ុន្តែជាសេចក្ដីសុខដែលបានសន្យា ដោយព្រះអម្ចាស់វិញ ។ ខ្ញុំនិយាយអំពីសេចក្ដីសុខ នៅក្នុងគេហដ្ឋានរបស់យើង សេចក្ដីសុខនៅក្នុងដួងចិត្តរបស់យើង ព្រមទាំងសេចក្ដីសុខ នៅក្នុងជីវិតរបស់យើងទៀតផង ។ សេចក្ដីសុខ បន្ទាប់ពីផ្លូវរបស់មនុស្សលោកបានវិនាសបាត់បង់ទៅ ។ សេចក្ដីសុខតាមរបៀបរបស់ព្រះអម្ចាស់ នឹងគង់វង់ជានិច្ច ។ . . .

« ***ទីមួយ ៖ ស្វែងរកខាងក្នុង ។*** . . . នឹងគ្មានសេចក្ដីសុខឡើយ លុះត្រាតែបុគ្គលម្នាក់ៗចិញ្ចឹមបីបាច់ព្រលឹងរបស់ខ្លួន នូវគោលការណ៍ នៃសច្ចភាព សុចរិតភាព និង លក្ខណៈ ដែលបណ្ដុះការអភិវឌ្ឍន៍សេចក្ដីសុខ ។ . . .

«***ទីពីរ ៖ ការបង្ហាញនៅសំបកក្រៅ ។*** . . . សមាជិកភាពនៅក្នុងសាសនាចក្រអំពាវនាវឲ្យមាននូវការប្ដេជ្ញាចិត្ត ដើម្បីនឹងបម្រើ ។ . . .

«***ទីបី ៖ សម្លឹងទៅសួគ៌ា ។*** កាលណាយើងធ្វើបែបនេះ យើងរកឃើញថា ការធ្វើបែបនេះជួយលួងលោម និង ជាទីគាប់ចិត្តដើម្បីនឹងធ្វើទំនាក់ទំនងជាមួយព្រះវរបិតាសួគ៌យើង តាមរយៈការអធិស្ឋានដែលជាផ្លូវឆ្ពោះទៅឯអំណាចខាងវិញ្ញាណ—នោះពិតជាសេចក្ដីចម្លង ទៅកាន់សេចក្ដីសុខ » ។

**ដកស្រង់ចេញពី « Finding Peace » *លីអាហូណា* និង *Ensign* ខែ មិនា ឆ្នាំ 2004 ទំព័រ 3–7 ។**

*តើយោបល់ណាមួយនៃយោបល់ទាំងបីនេះ ដែលអនុវត្តន៍បានកាន់តែប្រសើរនៅក្នុងជីវិតអ្នក ?*

រូបថតប្រថិត ដោយ ដេវិឌ ស៊ី. អាន់ឌើរសុន



**ប្រធាន ស្ពែនស៊ើរ ដបុលយូ.ឃីមបឹល (1895–1985)**
ប្រធានទីដប់ពីរនៃសាសនាចក្រ

# ការថ្វាយបង្គំព្រះអម្ចាស់ដ៏ពិត និង កំពុងតែមានព្រះជន្មរស់

*តើយើងភ័យខ្លាចអ្វីទៅ នៅពេលដែលព្រះអម្ចាស់គង់ជាមួយយើងនោះ ?*

យើងរៀនពីព្រះគម្ពីរថា ព្រោះតែការអនុវត្តតាមសេចក្ដីជំនឿ តែងតែហាក់ដូចជាពិបាកជាជាង ការពឹងផ្អែកទៅលើអ្វីដែលងាយៗដែលមនុស្សលោកតែងតែដាក់ទំនុកចិត្ត នៅលើព្រះអម្ចាស់របស់ខ្លួន ទៅលើរបស់របរខាងលោកីយ៍វិញ ។ ហេតុដូច្នេះហើយ នៅក្នុងគ្រប់សម័យទាំងអស់ មនុស្សលោកបានធ្លាក់ចុះក្រោមអំណាចរបស់សាតាំង ហើយបាត់បង់សេចក្ដីជំនឿ ពួកគេបានផ្ទុកជំនួសនូវសេចក្ដីសង្ឃឹមនៅក្នុង « ដៃរបស់មនុស្សលោក » ហើយនិងនៅក្នុង « ព្រះដែលធ្វើពីប្រាក់មាសសង្ហិនដែកឈើនិងថ្មដែលមើលមិនឃើញស្ដាប់មិនឮក៏មិនដឹងអ្វីសោះ » ( ដានីយ៉ែល 5:23 )—នោះហើយ គឺជាព្រះក្លែងក្លាយ ។ នេះគឺជាអ្វីដែលខ្ញុំរកឃើញថា បាវចនាដ៏ធំនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ អ្វីក៏ដោយដែលមនុស្សម្នាក់បានដាក់ដួងចិត្តខ្លួន និងទំនុកចិត្តខ្លួនទៅលើច្រើនបំផុតនោះ គឺជាព្រះរបស់គេ ហើយប្រសិនបើព្រះរបស់គេ ពុំមែនជាព្រះដ៏ពិត និងកំពុងតែមានព្រះជន្មរស់របស់អ៊ីស្រាអែលទេនោះមនុស្សនោះកំពុងតែធ្វើការក្នុងអបីយជំនឿហើយ ។

នេះគឺជាជំនឿដ៏ជឿជាក់របស់ខ្ញុំថា នៅពេលយើងអានវគ្គគម្ពីរទាំងនេះ ហើយខិតខំ « ប្រៀបធៀបពាក្យទាំងនេះទៅនឹងខ្លួន [ យើង ] » ( នីហ្វៃទី 1 19:24 ) ដូចដែលនីហ្វៃបាននិយាយប្រាប់ យើងនឹងភាពស្រដៀងគ្នាច្រើនរវាងរបៀបពួកបុរាណថ្វាយបង្គំរូបសំណាក និងគំរូឥរិយាបថនៅក្នុងបទពិសោធន៍របស់យើងផ្ទាល់ ។

ព្រះអម្ចាស់បានប្រទានពរដល់យើង . . . ធនធានទាំងឡាយដែលត្រូវបានដាក់នៅក្នុងអំណាចរបស់យើងគឺល្អ និង ចាំបាច់ចំពោះកិច្ចការរបស់យើងនៅលើផែនដីនេះ ។ ប៉ុន្តែខ្ញុំព្រួយបារម្ភដល់យើងរាល់គ្នាជាច្រើន . . . ដែលបានចាប់ផ្ដើមថ្វាយបង្គំព្រះក្លែងក្លាយ ហើយព្រះទាំងនេះ មានអំណាចលើយើងរាល់គ្នា ។ តើយើងមានអ្វីៗល្អទាំងនេះច្រើនជាងសេចក្ដីជំនឿរបស់យើងដែលយើងអាចមានជំហរឬ ? មនុស្សជាច្រើនរូបចំណាយពេលវេលាភាគច្រើនរបស់ខ្លួន នៅក្នុងការបម្រើរូបបដិមារបស់ខ្លួន ដែលមានរួមជាមួយ លុយកាក់ដ៏សន្ធឹកសន្ធាប់ ភាគហ៊ុនផលបត្រ ទ្រព្យសម្បត្តិ ប័ណ្ណឥនទាន គ្រឿងសង្ហារឹមរថយន្ត ហើយនិងទ្រព្យស្រដៀងទាំងនេះជាច្រើនទៀតដើម្បី*ធានានូវ*សុវត្ថិភាពខាងសាច់ឈាម។ . . .

### កិច្ចការរបស់យើង

ការបំភ្លេចគឺជាការពិតដែលថាកិច្ចការរបស់យើងគឺដើម្បីនឹងប្រើប្រាស់ធនធានជាច្រើនទាំងនេះ នៅក្នុងគ្រួសារ និង កូរ៉ុមរបស់យើង ដើម្បីសាងនគររបស់ព្រះ—ដើម្បីជម្រុញកិច្ចការផ្សព្វផ្សាយសាសនា និងកិច្ចការពង្សាវតា ហើយនិង ព្រះវិហារបរិសុទ្ធ ដើម្បីចិញ្ចឹមកូនរបស់យើងឲ្យធំឡើង ដើម្បីធ្វើជាអ្នកបម្រើដែលបង្កើតផលផ្លែចំពោះព្រះអម្ចាស់ ដើម្បីប្រទានពរដល់អ្នកដទៃ តាមវិធីជាច្រើន ដែលពួកគេក៏អាចបង្កើតផលផ្លែផងដែរ ។ ផ្ទុយទៅវិញ យើងលាតសន្ធឹងពរជ័យទាំងនេះ តាមបំណងប្រាថ្នារបស់យើងហើយដូចដែលមរ៉ូណៃបាននិយាយថា ៖ « ហេតុអ្វីបានជាអ្នករាល់គ្នាតុបតែងខ្លួន ជាមួយនឹងអ្វីដែលគ្មានជីវិត តែទុកឲ្យពួកអ្នកអត់ឃ្លាន និងអ្នកទូររគតនិងអ្នកអាក្រាត និងអ្នកឈឺ និងអ្នកដែលរងទុក្ខវេទនាដើរទៅហួសដោយពុំយកចិត្តទុកដាក់ដល់ពួកគេដូច្នេះ » ( មរមន 8:39 ) ។

ដូចដែលព្រះអម្ចាស់ទ្រង់ផ្ទាល់ បានមានបន្ទូលនៅក្នុងសម័យរបស់យើងដែរថា ៖ « ពួកគេពុំស្វែងរកព្រះអម្ចាស់ ដើម្បីតាំងសេចក្ដីសុចរិតរបស់ទ្រង់ឡើយ ប៉ុន្តែមនុស្សគ្រប់រូបដើរតាមផ្លូវរបស់ខ្លួនគេផ្ទាល់ ហើយតាមរូបភាពនៃព្រះរបស់ខ្លួនគេផ្ទាល់ដែលមានរូបភាពដូចជារូបរាងនៃលោកីយ ហើយ*សារជាតិដូចជារូបព្រះ*ដែលនឹងទៅជាចាស់ហើយនិងវិនាសនៅក្រុងបាប៊ីឡូនគឺជាក្រុងបាប៊ីឡូនដ៏ធំ ដែលនឹងរំលំនោះ » ( គ. និង ស. 1:16; សេចក្ដីបញ្ជាក់បញ្ចូលបន្ថែម ) ។

### ដំណួរមោឃៈ

បុរសម្នាក់ខ្ញុំស្គាល់ត្រូវបានហៅឲ្យបម្រើមុខងារនៅក្នុងសាសនាចក្រ ប៉ុន្តែគាត់បានមានអារម្មណ៍ថា គាត់មិនអាចទទួលបានឡើយ ព្រោះគាត់ត្រូវចំណាយពេលច្រើនលើការវិនិយោគរបស់គាត់ . . . ជាជាងចំណាយពេលវេលាធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។ គាត់បានចាកចេញពីការបម្រើរបស់ព្រះអម្ចាស់ ទៅរកទ្រព្យខាងលោកីយ៍វិញ ហើយគាត់ជាសេដ្ឋីសព្វថ្ងៃនេះ ។

ប៉ុន្តែថ្មីៗនេះខ្ញុំបានដឹងនូវការពិតគួរឲ្យចាប់អារម្មណ៍មួយថា ៖ ប្រសិនបើបុរសមានមាសមានតម្លៃស្មើរាប់លានដុល្លា . . . នោះគាត់មានមាសប្រមាណជាតិចបំផុតនៃមាសដែលមាននៅក្នុងស្រទាប់ផែនដីទាំងអស់តែប៉ុណ្ណោះ ។ នេះគឺជាចំនួនដ៏តូចបំផុតក្នុងចំណែកដែលគំនិតមនុស្សមិនអាចយល់បាន ។ ប៉ុន្តែមានមតិកាន់តែច្រើននៅក្នុងរឿងនេះ ៖ ព្រះអម្ចាស់ដែលបានបង្កើត ហើយដែលមានអំណាចលើផែនដីទាំងមូលដែលបានបង្កើត « ពិភពលោកដ៏ច្រើនឥតគណនា » ( ម៉ូសេ 1:33 ); និងនៅពេលបុរសនេះ បានទទួលសម្បថ និង

សេចក្ដីសញ្ញា នៃបព្វជិតភាព ( សូមមើល គ. និង ស. 84:33–44 ) គាត់បានទទួលសេចក្ដីសន្យាពីព្រះអម្ចាស់ នៃ « គ្រប់អ្វីៗទាំងអស់ដែលព្រះវរបិតាយើងមាន » ( គ. និង ស. 84:38 ) ។ ដើម្បីនឹងដាក់សេចក្ដីសន្យាដ៏ធំទាំងអស់នេះចោលមួយឡែក ដោយដេញតាមទំនោរចិត្តទៅលើហឹបមាសហើយនិងវិញ្ញាណនៃសុវត្ថិភាពខាងសាច់ឈាម គឺជាកំហុសនៅក្នុងទស្សនៈ នៃទំហំដ៏ធំក្រៃលែង ។ ដោយគិតថាគាត់បានសម្របសម្រួលចិត្តទៅនឹងរបស់ដ៏ស្តួចស្តើង គឺជាទស្សនៈយ៉ាងសោកសៅ និងគួរឲ្យអាណិតក្រៃលែង ព្រលឹងរបស់មនុស្សគឺមានតម្លៃថ្លៃជាងនេះទៅទៀត ។

មានយុវជនម្នាក់នៅពេលដែលត្រូវបានហៅឲ្យបម្រើបេសកកម្ម បានឆ្លើយតបថា ខ្លួនពុំមានទេពកោសល្យគ្រប់គ្រាន់សម្រាប់ធ្វើការងារបែបនេះទេ ។ ទេពកោសល្យដែលគេមានគឺជាការថែរក្សារថយន្ដដែលមានថាមពលដ៏ខ្លាំងក្លាថ្មីរបស់គាត់ ឲ្យនៅល្អដដែលប៉ុណ្ណោះ ។ . . . ឪពុករបស់គេតែងតែមានចិត្តសោមនស្សនឹងនិយាយថា « គេចូលចិត្តធ្វើអ្វីៗជាមួយនឹងដៃ របស់គេផ្ទាល់ ។ វាល្អគ្រប់គ្រាន់ហើយសម្រាប់គាត់ ។

ល្អយ៉ាងគ្រប់គ្រាន់សម្រាប់បុត្រារបស់ព្រះឬទេ ? យុវជនរូបនេះមិនបានដឹងថា កម្លាំងនៃរថយន្តរបស់គាត់ពិតជាតូចបំផុតប្រសិនបើប្រៀបទៅនឹងអំណាចនៃសមុទ្រ ឬ ព្រះអាទិត្យ ដែលគ្រប់គ្រងដោយច្បាប់ និងដោយបព្វជិតភាព នៅទីបំផុត—អំណាចបព្វជិតភាព ដែលគាត់ប្រហែលជាអាចបណ្ដុះបង្កើន នៅក្នុងការបម្រើចំពោះព្រះអម្ចាស់ ។ គាត់បានទុកចិត្តទៅលើរូបសំណាកដ៏គួរឲ្យអាណិត ជាដែក និងកៅស៊ូ នឹងកមលោហធាតុភ្លឺវិញ ។

ប្ដីប្រពន្ធចំណាស់មួយគូបានចូលរ៉ឺត្រែត ពីពិភពនៃការងារ ហើយក៏មានលទ្ធភាពបម្រើដល់សាសនាចក្រដែរ ។ ពួកគាត់បានទិញរថយន្តដឹកជញ្ជូនមួយ និងឡានបោះជំរំ . . . ដើម្បីចេញដំណើរទៅទស្សនាពិភពលោក ។ . . . ពួកគាត់គ្មានពេលវេលាសម្រាប់ព្រះវិហារបរិសុទ្ធទេ ដោយជាប់រវល់ខ្លាំងពេកចំពោះ ការស្រាវជ្រាវរកខាងពង្សាវតា និងសម្រាប់ការបម្រើខាងការផ្សព្វផ្សាយសាសនា ។ គាត់បានដាច់ទំនាក់ទំនងជាមួយនឹងកូរ៉ុមសង្ឃជាន់ខ្ពស់របស់គាត់ ហើយក៏មិនបាននៅផ្ទះគ្រប់គ្រាន់ ដើម្បីនឹងធ្វើពង្សប្រវត្តិរបស់ខ្លួនដែរ ។ បទពិសោធន៍ និងភាពជាអ្នកដឹកនាំរបស់ពួកគាត់ គឺពិតជាត្រូវការនៅក្នុងសាខារបស់ពួកគាត់ ប៉ុន្តែ . . . ពួកគាត់ពុំមានពេលវេលាសោះ ។ . . .

ប្រសិនបើយើងចង់ចំណាយពេល និង ធនធានទាំងអស់របស់យើងលើការស្ថាបនាពិភពខាងសាច់ឈាម នោះមរតករបស់យើងពិតជាអ្វីដែលយើងចំណាយពេលទៅលើហើយ ។

**បោះបង់ចោលវត្ថុខាងលោកីយ៍**

ប្រសិនបើសេចក្ដីរីករាយរបស់យើងក្នុងការស្វែងរកអត្តសញ្ញាណរបស់យើង ថាទាន់សម័យនិងទំនោចិត្តរបស់








គំនូរដោយ ជេ. ប៊េត ចិបសុន




យើងដោយគិតថា យើងមានភាពសមសួនជាជាងប្រជាជននៅក្នុងអតីតកាល មិនដែលមាន—ថ្វីបើ អ្វីៗទាំងនេះជាអត្តសញ្ញាណនៃប្រជាជនដែលខ្ជិលច្រអូស—ជាស្ថានភាពដែលខ្ពើមឆ្អើមបំផុតចំពោះព្រះអម្ចាស់ ។

យើង . . . ងាយស្រួលនឹងភ្លេចភ្លាំងពីការងារ នៃការរៀបចំខ្លួន សម្រាប់ការយាងមកវិញលើកទីពីររបស់ព្រះអម្ចាស់ ។ . . . យើងបានភ្លេចថា ប្រសិនបើយើងសុចរិត នោះព្រះអម្ចាស់នឹងមិនទុកឲ្យមច្ចាមិត្រចូលមករំខានយើងឡើយ . . . ឬទ្រង់នឹងវាយចម្បាំងជំនួសយើង ( សូមមើល និក្ខមនំ 14:14; គ. និង ស. 98:37, គ្រាន់តែជ្រើសចេញពីសេចក្ដីយោងពីរចេញពីសេចក្ដីយោងជាច្រើន ) . . . ។

តើយើងគួរតែភ័យខ្លាចអ្វីនៅពេលដែលព្រះអម្ចាស់ គង់ជាមួយយើងនោះ ? តើយើងមិនអាចទទួលព្រះអម្ចាស់តាមរយៈព្រះបន្ទូលរបស់ទ្រង់ ហើយអនុវត្តចំណែកមួយនៃសេចក្ដីជំនឿទៅលើទ្រង់ទេឬអី ? កិច្ចការរបស់យើងគឺជាវិជ្ជមាន ៖ ដើម្បីនឹងបោះបង់ចោលវត្ថុនៃលោកីយ៍ថាជាវត្ថុឥតប្រយោជន៍ ដើម្បីនឹងបោះបង់ចោលនូវរូបសំណាកហើយបោះជំហានទៅមុខក្នុងសេចក្ដីជំនឿ ដើម្បីនឹងយកដំណឹងល្អ ទៅកាន់មច្ចាមិត្ររបស់យើង ដើម្បីមិនឲ្យពួកគេធ្វើមច្ចាមិត្រទៀត ។

## ការអនុវត្តសេចក្ដីជំនឿយ៉ាងធំ

យើងត្រូវតែបោះបង់ចោល ការថ្វាយបង្គំរូបព្រះ ក្នុងសម័យនេះ ហើយក៏មិនសំអាងទៅលើ « សាច់ឈាម » ដ្បិតព្រះអម្ចាស់បានមានបន្ទូលចំពោះពិភពលោកទាំងមូលនៅក្នុងសម័យរបស់យើងថា ៖ « យើងនឹងមិនប្រណីនរណាមួយដែលនៅក្នុងក្រុងបាប៊ីឡូនឡើយ » ( គ . និង ស . 64:24) ។ . . . យើងជឿថា របៀបដែលមនុស្សម្នាក់ៗ និងក្រុមគ្រួសារនីមួយៗអាចរៀបចំដូចដែលព្រះអម្ចាស់បានបង្គាប់ ឲ្យចាប់ផ្ដើមអនុវត្តសេចក្ដីជំនឿយ៉ាងធំ ដើម្បីប្រែចិត្ត និងចូលទៅក្នុងកិច្ចការនៃនគររបស់ទ្រង់នៅលើផែនដី ដែលជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ដំបូងវាហាក់ដូចជាពិបាកបន្តិច ប៉ុន្តែ នៅពេលដែលមនុស្សម្នាក់ចាប់ផ្ដើមយល់ថាទស្សនៈវិស័យនៃកិច្ចការមួយពិត នៅពេលគេចាប់ផ្ដើមមើលឃើញអ្វីមួយនៃភាពអស់កល្បជានិច្ចនៃទិដ្ឋភាពពិតរបស់វា ពរជ័យនឹងចាប់ផ្ដើមមានទម្ងន់ធ្ងន់ជាជាងតម្លៃនៃការបោះបង់ចោល « លោកិយ » ។

តាមបែបនេះគឺមាននូវសុភមង្គលពិត ហេតុដូច្នេះហើយ យើងអញ្ជើញ និង ស្វាគមន៍ទទួលមនុស្សគ្រប់រូបគ្រប់ទីកន្លែង ឲ្យចូលរួមក្នុងកិច្ចការនេះ ។ ចំពោះអស់អ្នកដែលបានប្ដេជ្ញាចិត្តដើម្បីនឹងបម្រើព្រះអម្ចាស់ដោយលះបង់អ្វីៗទាំងអស់ នេះគឺជាផ្លូវទៅកាន់ជីវិតអស់កល្បជានិច្ច ។ អ្វីៗទាំងអស់គ្រាន់តែជាមធ្យោបាយទៅកាន់ទីបញ្ចប់ប៉ុណ្ណោះ ។ ■

*អនុចំណងជើងត្រូវបានបញ្ចូលបន្ថែម ៖ ការប្រកបអក្សរ វណ្ណយុត្តហើយនិងការសរសេរអក្សរធំ ត្រូវបានប្រើជាបទដ្ឋាន ។*

*បានស្រង់ចេញពី « The False Gods We Worship »* Tambuli *ខែ សីហា ឆ្នាំ 1977 ទំព័រ 1–4;* Ensign *ខែ មិថុនា ឆ្នាំ 1976 ទំព័រ 3–6 ។*

# ការបម្រើ ដល់ជនពិការ

**ដោយ ប៊េគី យ៉ង់ហ្វសេត**
*ការបម្រើដល់ពិការភាពក្នុងសាសនាចក្រ*

នៅពេលដែលលិន ផាសុន ត្រូវបានហៅឲ្យធ្វើជាអ្នកឯកទេសខាងពិការភាពនៅក្នុង ស្តេក ហ៊ីស្ត រដ្ឋតិចសាស គាត់ចង់បំពេញការហៅរបស់គាត់នៅតាមរបៀបមួយ ដែលនឹងផ្តល់ជាពរដល់ជីវិតរបស់សមាជិកទាំងឡាយនៃស្តេករបស់នាង ជាពិសេសពួកសមាជិកដែលពិការ និងក្រុមគ្រួសាររបស់ពួកគេ ។

ទង្វើដំបូងមួយដែលលិន បានធ្វើ គឺធ្វើស្រាវជ្រាវព័ត៌មានអំពីការហៅរបស់គាត់នៅក្នុង គេហទំព័រ LDS .org (lds.org/callings/disability-specialist) ហើយគាត់បានប្រើប្រាស់ *ក្បួនខ្នាតភាគ 2 ៖ Administering the Church* ដើម្បីយល់នូវគោលនយោបាយផ្លូវច្បាប់នៃសាសនាចក្រ អំពីភាពពិការទាំងនោះ ។ គេហទំព័រសម្រាប់ជនពិការធនធានមាននៅ(lds.org/disability) ក៏បានបម្រើជាធនធានមួយដែរ ។ វាបានជួយគាត់ឲ្យយល់អំពីពិការភាពផ្សេងៗ ហើយបានដើរតួជាធនធានមួយ ដើម្បីចែករំលែកជាមួយសមាជិកទាំងឡាយនៅក្នុងស្តេករបស់គាត់ ។

*ក្បួនខ្នាតភាគ 2* ចែងថា « គណៈប៊ីស្សព ឬគណៈប្រធានស្តេក អាចហៅអ្នកឯកទេសខាងពិការភាពប្រចាំវួដ ឬស្តេក ដើម្បីជួយដល់បុគ្គលម្នាក់ៗ និងក្រុមគ្រួសាររបស់គេផងដែរ » ។ [1] LDS.org ផ្តល់ព័ត៌មានបន្ថែមទៀតអំពីការហៅឲ្យបម្រើនេះ ដោយពន្យល់ថា « តួនាទីរបស់អ្នកឯកទេសខាងពិការភាព គឺដើម្បីជួយរៀបចំឲ្យមានការចូលរួមកាន់តែច្រើន ហើយនិងឲ្យសមាជិកនៃសាសនាចក្រចូលរួមជាមួយនឹងពួកជនពិការ » ។ [2]

ជាមួយនឹងការយល់ដឹងនេះ លិន និយាយថា គាត់ចង់ « ជួយអ្នកដឹកនាំឲ្យបំពេញការហៅរបស់ខ្លួន ដោយការស្វែងរកឧបករណ៍ទាំងឡាយដែលពួកគេត្រូវការ ដើម្បីបម្រើអស់អ្នកដែលមានភាពពិការ » ។

លិន ក៏បានរកឃើញព័ត៌មានតាមរយៈធនធានដែលមាននៅក្នុងសហគមន៍ និងប្រទេសជាតិ អិនធឺណែត ហើយនិងសមាជិកក្នុងវួដ និងស្តេក ដែលមានអាជីពធ្លាប់ធ្វើការជាមួយនឹងជនពិការ ។ លិន ប្រើធនធានទាំងនេះ ក្នុងពេលគាត់ស្វែងរកដំណោះស្រាយចំពោះការប្រឈមដែលពួកអ្នកដឹកនាំ និងក្រុមគ្រួសារកំពុងតែប្រឈមមុខនៅក្នុងស្តេករបស់ខ្លួន ។ គាត់មិនតែងតែដឹងអំពីទីកន្លែងដែលគាត់អាចរកបានព័ត៌មាន ឬជំនួយនោះទេ គាត់និយាយថា « ប៉ុន្តែបើគាត់ពិតជាស្វែងរកចម្លើយតាមរយៈការអធិស្ឋាន នោះគាត់នឹងត្រូវបានបំផុសគំនិតឲ្យស្វែងរកចម្លើយ ក្នុងទីកន្លែងផ្សេងទៀតវិញនោះ » ។

**ការយល់ដឹងអំពីសេចក្តីត្រូវការ**

លិន ក៏ធ្វើការដើម្បីយល់ដឹងអំពីតម្រូវការរបស់ជនពិការ នៃអ្នកដឹកនាំនៅតំបន់របស់គាត់ដែរ ។ ដើម្បីធ្វើដូច្នេះ លីន បានស្នើឲ្យពួកអ្នកដឹកនាំស្តេករបស់គាត់ ផ្ញើលិខិតមួយច្បាប់ ទៅប៊ីស្សព ជំរាបដល់ពួកលោកនូវការហៅរបស់នាង ហើយថា នាងនឹងរង់ចាំជួយ ។ គាត់ក៏បានជួបជាមួយនឹងគណៈប្រធានថ្នាក់អង្គការបឋមសិក្សា ដើម្បីរៀនយល់អំពីការប្រឈមទាំងឡាយ ហើយគាត់បានដាក់ផែនការ ដើម្បីជួយពួកអ្នកដឹកនាំក្រុមឯទៀតដែរ ។ គាត់បាននិយាយថា ៖ « ខ្ញុំចង់ផ្សព្វផ្សាយឲ្យគេដឹង » ។ « ខ្ញុំចង់ឲ្យគេដឹងថាតើអាចរកបានជំនួយនៅទីកន្លែងណា » ។

តាមរយៈការជម្រាបឲ្យសមាជិកស្តេកដឹង នោះគាត់បានត្រៀមខ្លួនជាស្រេចដើម្បីបម្រើ លិន បានមិនយូរប៉ុន្មាន បានរកឃើញឱកាសដើម្បីនឹងជួយពួកអ្នកដឹកនាំ ។ ក្នុងអំឡុងពីរបីខែដំបូងនៅក្នុងការហៅ ឲ្យធ្វើជាអ្នកឯកទេសផ្នែកជនពិការ គាត់ត្រូវបានអញ្ជើញឲ្យជួបជាមួយនឹងក្រុមប្រឹក្សាវួដ ដើម្បីនិយាយអំពីលក្ខណៈទាំងឡាយនៃជនពិការណាម្នាក់ ។ គាត់បានបម្រើតាមរបៀបផ្សេងៗទៀត ដូចជាការជួយគ្រូបង្រៀនម្នាក់យល់អំពីរបៀបក្មេងម្នាក់ដែលមានជម្ងឺខួរក្បាល ហើយបានផ្តល់ជាយោបលថា ជំនួយការគ្រូបង្រៀនបឋមសិក្សា នឹងត្រូវបានហៅ ដើម្បីឲ្យកុមារពិការរូបនោះអាចទៅថ្នាក់រៀនបាន ។

ដោយបោះជំហានទៅមុខ លិន គ្រោងនឹងជួយពួកអ្នកដឹកនាំបំពេញការហៅរបស់ខ្លួន ។ កាលគាត់ធ្វើបែបនេះ គាត់កំពុងតែជួយសមាជិកទាំងឡាយ នៃស្តេករបស់គាត់ឲ្យធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ដោយក្តីស្រឡាញ់ និងឈោងដៃទៅរកអ្នកឯទៀត រួមជាមួយអស់ជនពិការ ។ ■



រចនារូបភាពដោយ ជេរ៉េម អ៊ិម វ៉ៃថាកឃឺ

**កំណត់សម្គាល់**
1. *ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* ( ឆ្នាំ 2010 ) ចំណុច 21.1.26 ។
2. "Disability Specialist," www.lds.org/callings/disability-specialist.





**ដោយប្រធាន ជែមស៍ អ៊ី. ហ្វោស្ត ( ឆ្នាំ 1920–2007 )**
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

# កូនចៀមដែលវង្វេងបាត់មានតម្លៃបំផុត

*ចំពោះឪពុកម្ដាយទាំងឡាយដែល ខូចចិត្ត ហើយ មានសេចក្ដីសុចរិត ឧស្សាហ៍ព្យាយាម និងពោរពេញដោយការអធិស្ឋានក្នុងការបង្រៀន កូនចៅរបស់ខ្លួនដែលពុំស្ដាប់បង្គាប់ នោះយើងសូមនិយាយទៅកាន់អ្នកថា អ្នកគង្វាលចៀមដ៏ល្អកំពុងឃ្លាំមើលពួកគេ ។*

*ប្រធាន ជែមស៍ អ៊ី. ហ្វោស្ត ត្រូវបានគាំទ្រជាទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយនៅថ្ងៃទី 12 ខែ មិនា ឆ្នាំ 1995 ហើយបានបម្រើក្នុងការហៅបម្រើនោះរហូតដល់លោកបានទទួលមរណភាពនៅថ្ងៃទី 10 ខែ សីហា ឆ្នាំ 2007 ។ សុន្ទរកថានេះត្រូវបានធ្វើឡើងនៅក្នុងសន្និសីទទូទៅខែ មេសា ឆ្នាំ 2003 ត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ចេញផ្សាយនេះ ជាអត្ថបទមួយក្នុងចំណោមអត្ថបទមួយចំនួនស្ដីពីការពង្រឹងគ្រួសារ ។*

បងប្អូនប្រុសស្រី និងមិត្តជាទីស្រឡាញ់របស់ខ្ញុំ សារលិខិតរបស់ខ្ញុំនាព្រឹកនេះគឺជាសេចក្ដីសង្ឃឹម និង ការលួងលោមចិត្តមួយចំពោះឪពុកម្ដាយដែលមានការខូចចិត្ត ជាអ្នកដែលបានធ្វើអស់ពីលទ្ធភាពរបស់ខ្លួនដើម្បីចិញ្ចឹមបីបាច់កូនចៅរបស់ពួកគេក្នុងសេចក្ដីសុចរិតដោយសេចក្ដីស្រឡាញ់ និងការលះបង់ ប៉ុន្តែបានទទួលមកវិញនូវភាពសោកសៅ ដោយសារតែកូនចៅរបស់ពួកគេបានបះបោរ ឬត្រូវបានដឹកនាំឲ្យវង្វេងក្នុងការដើរតាមផ្លូវរបស់អារក្ស និងសេចក្ដីបំផ្លិចបំផ្លាញ ។ ដោយពិចារណាពីភាពសោកសៅដ៏ធំធេងរបស់អ្នក ខ្ញុំបាននឹកចាំពីពាក្យរបស់យេរេមាថា ៖ « មានឮសូរសំឡេងនៅរ៉ាម៉ា . . . រ៉ាជែលយំនឹងកូននាង ហើយមិនព្រមកម្សាន្តចិត្ត » ។ ចំពោះការណ៍នេះ ព្រះអម្ចាស់ទ្រង់បានប្រទាននូវការអះអាងដ៏រីករាយនេះថា ៖ « ចូរទប់សំឡេងឯងមិនឲ្យយំ . . .ត្បិត . . .ការរបស់ឯងនឹងបានរង្វាន់ជាពិត . . . វារាល់គ្នានឹងវិលមកពីស្រុកខ្មាំងសត្រូវវិញ » ។[1]

ខ្ញុំត្រូវចាប់ផ្ដើមដោយការថ្លែងទីបន្ទាល់ថា បន្ទូលរបស់ព្រះអម្ចាស់ចំពោះឪពុកម្ដាយទាំងឡាយក្នុងសាសនាចក្រនេះគឺមាននៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា កណ្ឌ 68 នៅក្នុងសេចក្ដីណែនាំដ៏អស្ចារ្យនេះថា ៖ « ហើយជាថ្មីទៀត ដរាបណាឪពុកម្ដាយមានកូនចៅនៅក្នុងក្រុងស៊ីយ៉ូន ឬ នៅក្នុងស្តេកណាមួយដែលបានរៀបចំ

លក្ខណៈពិសេសដកស្រង់ពី *THE PRODIGAL SON* ( កូនប្រុសដែលខ្ជះខ្ជាយ ) ដោយ វិលសុន អុង ទទួលសិទ្ធិអនុញ្ញាតពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ

*មនុស្សដែលវង្វេង « នឹងរងទុក្ខចំពោះអំពើបាបរបស់ខ្លួន ហើយអាចដើរលើផ្លូវមួយដែលមានបន្លា ប៉ុន្តែប្រសិនបើការណ៍នេះដឹកនាំពួកគេទៅកេដួងចិត្តរបស់ឪពុកជាទីស្រឡាញ់ និងចេះអភ័យទោស ហើយត្រឡប់ទៅផ្ទះវិញ នោះបទពិសោធន៍ដ៏ឈឺចាប់នេះនឹងពុំឥតប្រយោជន៍ឡើយ » ។*



ឡើងក្ដី ដែលពុំបានបង្រៀនកូនចៅឲ្យយល់នូវគោលលទ្ធិអំពីការប្រែចិត្ត សេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ និង អំពីបុណ្យជ្រមុជទឹក ហើយនិងអំពីអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់ដៃលើ កាលមានអាយុ ៨ ឆ្នាំទេ នោះអំពើបាបនឹងធ្លាក់មកលើក្បាលរបស់ឪពុកម្ដាយវិញ » ។[2] ឪពុកម្ដាយទាំងឡាយត្រូវបានណែនាំឲ្យ « បង្រៀនកូនចៅរបស់ខ្លួនឲ្យអធិស្ឋាន និង ឲ្យដើរដោយទៀងត្រង់នៅចំពោះព្រះអម្ចាស់ » ។[3] ក្នុងនាមជាឪពុក ជីតា ជីតាទួតម្នាក់ ខ្ញុំសូមទទួលយកពាក្យនេះជាបន្ទូលរបស់ព្រះអម្ចាស់ ហើយក្នុងនាមជាអ្នកបម្រើម្នាក់នៃព្រះយេស៊ូវគ្រីស្ទ នោះខ្ញុំសូមជំរុញឲ្យឪពុកម្ដាយទាំងឡាយធ្វើតាមពាក្យទូន្មាននេះដោយប្រុងប្រយ័ត្នតាមដែលពួកគេអាចធ្វើទៅបាន ។

តើឪពុកម្ដាយល្អជានរណាទៅ ? ពួកគាត់ជាមនុស្សដែលបានព្យាយាមបង្រៀនកូនចៅរបស់ខ្លួនដោយសេចក្ដីស្រឡាញ់ ពោរពេញដោយការអធិស្ឋាន និង ដោយសេចក្ដីស្មោះត្រង់តាមរយៈគំរូ និង គោលការណ៍ « ឲ្យអធិស្ឋាន និង ឲ្យដើរដោយទៀងត្រង់នៅចំពោះព្រះអម្ចាស់ » ។[4] រឿងនេះជាការពិត ទោះបីជាកូនចៅរបស់ពួកគេមួយចំនួនពុំស្ដាប់បង្គាប់ ឬ រក់រីនឹងលោកិយក្ដី ។ ក្មេងៗដែលកើតមកក្នុងពិភពលោកនេះជាមួយនឹងវិញ្ញាណ និងឥរិយាបថផ្ទាល់ខ្លួនរបស់ពួកគេផ្សេងៗពីគ្នា ។ កូនចៅមួយចំនួន « នឹងធ្វើឲ្យឪពុកម្ដាយគ្រប់រូបប្រឈមមុខនឹងកាលៈទេសៈគ្រប់បែបយ៉ាង ។ . . . ប្រហែលជាមានកូនចៅដទៃទៀតដែលនឹងប្រទានពរដល់ជីវិតឪពុក ឬម្ដាយស្ទើតែគ្រប់រូប ហើយក្លាយជាសេចក្ដីអំណរមួយចំពោះពួកគេ » ។[5] ឪពុកម្ដាយដ៏មានជោគជ័យគឺជាមនុស្សដែលបានលះបង់ ហើយនិងពុះពារដើម្បីធ្វើឲ្យអស់ពីលទ្ធភាពនូវអ្វីដែលពួកគេអាចធ្វើទៅបាននៅក្នុងកាលៈទេសៈរបស់គ្រួសារពួកគេផ្ទាល់ ។

ជម្រៅនៃសេចក្ដីស្រឡាញ់របស់ឪពុកម្ដាយចំពោះកូនចៅរបស់ខ្លួនពុំអាចវាស់វែងបានឡើយ ។ វាពុំដូចជាទំនាក់ទំនងដទៃទៀតឡើយ ។ វាលើសពីជីវិតទៅទៀត ។ សេចក្ដីស្រឡាញ់របស់ឪពុកម្ដាយចំពោះកូនម្នាក់គឺបន្តជានិច្ច ហើយវាលើសពីការខូចចិត្ត និងការខកចិត្តទៅទៀត ។ ឪពុកម្ដាយគ្រប់រូបសង្ឃឹម ហើយនិងអធិស្ឋានថាកូនចៅរបស់ខ្លួននឹងធ្វើការសម្រេចចិត្តដោយឈ្លាសវៃ ។ កូនចៅដែលស្ដាប់បង្គាប់ ហើយនិងទទួលខុសត្រូវនាំមកនូវមោទនភាព និងភាពរីករាយដ៏គ្មានទីបញ្ចប់ដល់ឪពុកម្ដាយរបស់ខ្លួន ។

ចុះចំពោះកូនចៅដែលទទួលការបង្រៀនពីឪពុកម្ដាយ

*THE PRODIGAL SON* ( កូនប្រុសដែលខ្ជះខ្ជាយ ) ដោយ វិលសុន អុង ទទួលសិទ្ធិអនុញ្ញាតពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ ។ ថតរូបដោយ ឌូគី បើល

ដែលស្មោះត្រង់ ដែលពេញដោយក្ដីស្រឡាញ់បានបះបោរ ឬនាំឲ្យវង្វេងផ្លូវវិញនោះ ? តើមានសង្ឃឹមទេ ? ភាពឈឺចាប់របស់ឪពុកម្ដាយម្នាក់ចំពោះកូនម្នាក់ដែលរឹងរូសគឺជារឿងដែលស្ទើរតែពុំអាចលួងលោមចិត្តបាន ។ បុត្រាទីបីរបស់ស្ដេច ដាវីឌ ឈ្មោះ អាប់សាឡុំម បានសម្លាប់បងប្អូនប្រុសម្នាក់របស់ខ្លួន ហើយក៏បានដឹកនាំឲ្យមានការបះបោរប្រឆាំងនឹងបិតារបស់ខ្លួនផងដែរ ។ អាប់សាឡុំមត្រូវបានយ៉ូអាប់សម្លាប់ ។ ដោយបានឮពីការស្លាប់របស់អាប់សាឡុំម ស្ដេចដាវីឌបានទួញយំ ហើយសម្ដែងនូវសេចក្ដីសោកសៅរបស់ខ្លួនថា ៖ « ឱ អាប់សាឡុំម កូនអញ កូនអញអើយ ឱ អាប់សាឡុំម កូនអញអើយ ! ស៊ូឲ្យអញបានស្លាប់ជំនួសឯង ឱ អាប់សាឡុំម កូនអញ កូនអញអើយ ! »[6]

សេចក្ដីស្រឡាញ់របស់ឪពុកម្ដាយនេះ ក៏បានបង្ហាញនៅក្នុងរឿងប្រៀបធៀបពីកូនប្រុសដែលខ្ជះខ្ជាយផងដែរ ។ នៅពេលកូនដែលរឹងរូសរបស់ខ្លួនបានត្រឡប់មកផ្ទះវិញ បន្ទាប់ពីបានចាយវាយខ្ជះខ្ជាយនូវមរតករបស់ខ្លួនក្នុងការរស់នៅដ៏ហ៊ឺហាមក ឪពុកបានសម្លាប់កូនគោដ៏ថ្លោសមួយ ដើម្បីអបអរដល់ការវិលត្រឡប់របស់កូនប្រុសដែលខ្ជះខ្ជាយរូបនោះ ដោយនិយាយទៅកាន់កូនប្រុសដែលស្ដាប់បង្គាប់ដែលមានការតូចចិត្តថា « គួរឲ្យយើងស៊ីលៀងដោយអរសប្បាយទៅពីព្រោះប្អូនឯងនេះបានស្លាប់ ឥឡូវរស់ឡើងវិញ ក៏បាត់បង់ តែបានឃើញមកវិញហើយ » ។[7]

ខ្ញុំជឿ ហើយសូមទទួលស្គាល់ពាក្យលួងលោមចិត្តរបស់អែលឌើរ អ័រសុន អែហ្វ. វិតនី [ ឆ្នាំ 1855–1931 ] ថា ៖

« ព្យាការី យ៉ូសែប ស្ម៊ីធ បានប្រកាស—ហើយលោកពុំដែលបង្រៀនពីគោលលទ្ធិលួងលោមចិត្តច្រើនឡើយ—ថាការផ្សារភ្ជាប់ដ៏នៅអស់កល្បជានិច្ចរបស់ឪពុកម្ដាយស្មោះត្រង់គ្រប់រូប និងសេចក្ដីសន្យាដ៏ទេវភាពដែលបានកើតមានចំពោះពួកគេសម្រាប់ការបម្រើដ៏ក្លាហានក្នុងបុព្វហេតុនៃសេចក្ដីពិតនេះនឹងសង្គ្រោះពុំត្រឹមតែខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្ដែនឹងសង្គ្រោះដល់កូនចៅរបស់ពួកគេផងដែរ ។ ទោះជាមានកូនចៀមមួយចំនួនអាចនឹងវង្វេងផ្លូវក្ដី ប៉ុន្ដែព្រះនេត្រនៃអ្នកគង្វាលចៀមគឺ ឃ្លាំចាំមើលពួកគេ ហើយមិនយូរប៉ុន្មានទេ ពួកគេនឹងទទួលអារម្មណ៍នូវព្រះហស្តនៃព្រះវរបិតាសួគ៌ឈោងទៅរកពួកគេ ហើយដឹកនាំពួកគេមកកាន់ក្រោលវិញ ។ មិនថានៅក្នុងជីវិតនេះ ឬជីវិតខាងមុខនោះទេ ពួកគេនឹងត្រឡប់មកវិញ ។ ពួកគេនឹងត្រូវបង់សងបំណុលរបស់ខ្លួនចំពោះសេចក្ដីយុត្តិធម៌ ។ ពួកគេនឹងរងទុក្ខចំពោះអំពើបាបរបស់ខ្លួន ហើយអាចដើរលើផ្លូវមួយដែលមានបន្លា ប៉ុន្ដែប្រសិនបើការណ៍នេះដឹកនាំពួកគេទៅរកដួងចិត្តរបស់ឪពុក

*សេចក្ដីស្រឡាញ់របស់ឪពុក ឬម្ដាយម្នាក់ចំពោះកូនមានបន្តជានិច្ច ហើយវាពុះពារការខូចចិត្ត និងការខកបំណង ។ ឪពុកម្ដាយគ្រប់រូបសង្ឃឹម ហើយអធិស្ឋានថាកូនរបស់ខ្លួននឹងធ្វើការសម្រេចចិត្តដ៏ឈ្លាសវៃ ។*





*កូនប្រុសដែលខ្ជះខ្ជាយត្រូវបានស្វាគមន៍ឲ្យចូលទៅក្នុងគ្រួសារវិញ ប៉ុន្តែកេរមរតករបស់គាត់ត្រូវបានចំណាយអស់រលីងហើយ ។ សេចក្ដីមេត្តាករុណានឹងពុំកោងយកសេចក្ដីយុត្តិធម៌ឡើយ ហើយអំណាចនៃការផ្សារភ្ជាប់របស់ឪពុកម្ដាយស្មោះត្រង់គ្រប់រូបនឹងជួយដល់កូនចៅដែលចចេសក្នុងលក្ខខណ្ឌតែមួយគត់ គឺការប្រែចិត្តរបស់ពួកគេ និងដង្វាយធួនរបស់ព្រះគ្រីស្ទ ។*

ជាទីស្រឡាញ់ និង ចេះអភ័យទោស ហើយនិងត្រឡប់ទៅផ្ទះវិញ នោះបទពិសោធន៍ដ៏ឈឺចាប់នេះនឹងពុំឥតប្រយោជន៍ឡើយ ។ សូមអធិស្ឋានសម្រាប់កូនចៅរបស់អ្នកដែលធ្វេសប្រហែស ហើយនិងពុំស្ដាប់បង្គាប់ ។ សូមឱបក្រសោបពួកគេដោយសេចក្ដីជំនឿរបស់អ្នក ។ សូមមានសេចក្ដីសង្ឃឹម ទំនុកចិត្ត រហូតដល់អ្នកឃើញនូវសេចក្ដីសង្គ្រោះរបស់ព្រះ » ។[8]

គោលការណ៍មួយក្នុងសុន្ទរកថានេះ ដែលជារឿយៗត្រូវបានគេមើលរំលងនោះគឺថា ពួកគេត្រូវប្រែចិត្តទាំងស្រុង ហើយនិង « រងទុក្ខចំពោះអំពើបាបរបស់ខ្លួន » ហើយ « បង់សងបំណុលរបស់ខ្លួនចំពោះសេចក្ដីយុត្តិធម៌ » ។ ខ្ញុំដឹងថា ពេលនេះគឺជាពេល « ប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ » ។[9] ប្រសិនបើការប្រែចិត្តនៃកូនដ៏វង្វេងរូបនេះពុំបានធ្វើឡើងក្នុងជីវិតនេះ តើចំណងនៃការផ្សារភ្ជាប់នៅតែមានភាពរឹងមាំល្មមគ្រប់គ្រាន់សម្រាប់ពួកគេដើម្បីធ្វើការប្រែចិត្តរបស់ខ្លួនដែរឬទេ ? នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញាបានប្រាប់យើងថា ៖

« ពួកអ្នកស្លាប់ណាដែលប្រែចិត្ត នោះនឹងបានប្រោសលោះតាមរយៈការគោរពតាមពិធីទាំងឡាយនៃដំណាក់របស់ព្រះ

« ហើយបន្ទាប់ពីពួកគេបានសងទោសនៃអំពើរំលងទាំងឡាយរបស់ពួកគេ ហើយត្រូវបានសំអាតឲ្យបានស្អាត នោះនឹងបានទទួលរង្វាន់តាមការដែលគេបានប្រព្រឹត្ត ព្រោះពួកគេជាអ្នកគ្រងសេចក្ដីសង្គ្រោះទុកជាមរតក » ។[10]

យើងចងចាំថា កូនប្រុសដែលខ្ជះខ្ជាយបានបំផ្លាញកេរមរតករបស់ខ្លួនអស់ ហើយទើបគាត់ត្រឡប់មកផ្ទះឪពុករបស់គាត់វិញ ។ នៅពេលនោះគាត់ត្រូវបានស្វាគមន៍ឲ្យចូលទៅក្នុងគ្រួសារវិញ ប៉ុន្តែកេរមរតករបស់គាត់ត្រូវបានចំណាយអស់រលីងហើយ ។[11] សេចក្ដីមេត្តាករុណានឹងពុំកោងយកសេចក្ដីយុត្តិធម៌ឡើយ ហើយអំណាចនៃការផ្សារភ្ជាប់របស់ឪពុកម្ដាយស្មោះត្រង់គ្រប់រូបនឹងជួយដល់កូនចៅដែលចចេសក្នុងលក្ខខណ្ឌតែមួយគត់ គឺការប្រែចិត្តរបស់ពួកគេ និង ដង្វាយធួនរបស់ព្រះគ្រីស្ទ ។ កូនចៅដែលចចេសដែលមានការប្រែចិត្តនឹងរីករាយនឹងសេចក្ដីសង្គ្រោះ និង រាល់ពរជ័យដែលភ្ជាប់មកជាមួយនោះ ប៉ុន្តែរឿងដ៏សំខាន់ជាងនេះទៅទៀតនោះគឺភាពតម្កើងឡើង ។ វានឹងត្រូវបានផ្ដល់ឲ្យយ៉ាងពេញលេញ ។ សំណួរសួរថាតើនរណានឹងត្រូវបានតម្កើងឡើងនោះ ត្រូវទុកឲ្យព្រះអម្ចាស់ស្របតាមសេចក្ដីមេត្តាករុណារបស់ទ្រង់ ។

*PRODIGAL SON* ( កូនប្រុសដែលខ្ជះខ្ជាយ ) ដោយ ក្លាក ខេល្លី ប្រ៉ាយ © 1989 IRI ។ រចនារូបថតដោយ ខូឌី ប៊េល



មានមនុស្សមួយចំនួនដែលមានទង្វើរឹងរូស និង អាក្រក់ដែលមានសភាពធំធេងរហូតធ្វើឲ្យពួកគេ « បាត់បង់នូវអំណាចក្នុងការប្រែចិត្ត » ។[12] ការកាត់សេចក្ដីនោះក៏ត្រូវទុកឲ្យព្រះអម្ចាស់ជាអ្នកសម្រេចផងដែរ ។ ទ្រង់មានបន្ទូលប្រាប់យើងថា « យើងជាព្រះអម្ចាស់នឹងអត់ទោសដល់អ្នកណាដែលយើងនឹងអត់ទោស ប៉ុន្ដែរីឯអ្នកវិញគឺតម្រូវឲ្យអត់ទោសដល់មនុស្សទាំងអស់ » ។[13]

ប្រហែលជានៅក្នុងជីវិតនេះ យើងពុំបានយល់ពេញលេញថា តើចំណងផ្សារភ្ជាប់របស់ឪពុកម្ដាយសុចរិតជាមួយកូនចៅរបស់ពួកគេមានស្ថិរភាពបែបណានោះទេ ។ វាប្រហែលជាការល្អខ្លាំងណាស់ ដោយមានធនធានជាជំនួយបន្ថែមទៀតដែលកំពុងធ្វើឡើងលើសពីយើងដឹងទៅទៀត ។[14] ខ្ញុំជឿថា មានការចងភ្ជាប់ក្រុមគ្រួសារមួយដ៏រឹងមាំ ដោយសារតែឥទ្ធិពលនៃបុព្វការីជនជាទីស្រឡាញ់បន្តនៅជាមួយយើងពីភពម្ខាងទៀត ។

ប្រធាន ហារីដ ដបុលយូ. ហ៊ឹនធើរ [ ឆ្នាំ 1907–95 ] បានសង្កេតឃើញថា « ការប្រែចិត្តគ្រាន់តែជាការនឹកផ្ទះរបស់ដួងព្រលឹងមួយប៉ុណ្ណោះ ហើយការមើលថែជាបន្តបន្ទាប់ និង ដោយប្រុងប្រយ័ត្នរបស់ឪពុកម្ដាយគឺជាគំរូដែលយុត្តិធម៌បំផុតនៅលើផែនដីនៃការអភ័យទោសដែលពុំចេះរលត់របស់ព្រះ » ។ តើគ្រួសារពុំមែនជានិមិត្តរូបដ៏ជិតដិតបំផុតដែល បេសកកម្មរបស់ព្រះអង្គសង្គ្រោះបានព្យាយាមដើម្បីស្ថាបនាទេឬ ?[15]

យើងរៀនច្រើនពីការប្រែចិត្តមកពីឪពុកម្ដាយរបស់យើងផ្ទាល់ ។ សេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះឪពុករបស់ខ្ញុំបានដក់ជាប់ក្នុងចិត្តយ៉ាងខ្លាំង ពេលគាត់មានសន្ដានចិត្តល្អអត់ធ្មត់ ហើយយោគយល់ ។ ពេលខ្ញុំធ្វើឲ្យឡានប្រចាំគ្រួសារខូច គាត់នៅតែទន់ភ្លន់ ហើយអត់អោន ។ ប៉ុន្ដែកូនប្រុសរបស់គាត់ទាំងអស់អាចនឹងរងនូវការដាក់វិន័យដ៏តឹងរឹង ប្រសិនបើពួកគេពុំបានប្រាប់ការពិតទាំងអស់ ឬ បន្តធ្វើខុសនឹងវិន័យ ជាពិសេសការបង្ហាញការមិនគោរពដល់អ្នកម្ដាយរបស់យើង ។ ឪពុករបស់ខ្ញុំបានចែកឋានទៅជាងកន្លះសតវត្សហើយ ប៉ុន្ដែខ្ញុំនៅតែនឹកដល់ការទៅរកគាត់សម្រាប់ពាក្យទូន្មានដ៏ឈ្លាសវៃ និង ដោយក្ដីស្រឡាញ់ជាខ្លាំង ។ ខ្ញុំសូមសារភាពថា ពេលខ្លះខ្ញុំមានការសង្ស័យចំពោះពាក្យទូន្មានរបស់គាត់ ប៉ុន្ដែខ្ញុំពុំធ្លាប់សង្ស័យពីសេចក្ដីស្រឡាញ់របស់គាត់ចំពោះខ្ញុំឡើយ ។ ខ្ញុំពុំដែលគិតចង់ធ្វើឲ្យគាត់ខកចិត្តឡើយ ។

កត្តាដ៏សំខាន់មួយនៃការធ្វើឲ្យអស់ពីលទ្ធភាពរបស់យើងក្នុងនាមជាឪពុកម្ដាយ នោះគឺការផ្ដល់សេចក្ដីស្រឡាញ់ ប៉ុន្ដែត្រូវមានការដាក់វិន័យដ៏ម៉ឺងម៉ាត់ ។ ប្រសិនបើយើងពុំដាក់វិន័យដល់កូនចៅរបស់យើងនោះទេ សង្គមអាចនឹងធ្វើ តាមរបៀបដែលយើង ឬ កូនចៅរបស់យើងពុំចូលចិត្ត ។ ផ្នែកមួយនៃការដាក់វិន័យដល់កូនចៅនោះគឺការបង្រៀនពួកគេឲ្យធ្វើការ ។ ប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី [ ឆ្នាំ 1910–2008 ] បានមានប្រសាសន៍ថា ៖ « តម្លៃមួយដ៏ធំធេងជាងគេបំផុត . . . គឺជាគុណធម៌នៃការងារស្មោះត្រង់ ។ មានចំណេះដឹងតែគ្មានការងារគឺគ្មានប្រយោជន៍ឡើយ ។ មានចំណេះដឹងហើយមានការងារគឺជារឿងដ៏ប្រពៃ » ។[16]

អន្ទាក់ដែលរីករាលដាលរបស់សាតាំងកំពុងមានការកើនឡើង ហើយការចិញ្ចឹមបីបាច់កូនគឺកាន់តែមានភាពលំបាកដោយសារតែរឿងនេះ ។ ដូច្នេះហើយ ឪពុកម្ដាយទាំងឡាយត្រូវធ្វើឲ្យអស់ពីលទ្ធភាពរបស់ខ្លួន ហើយត្រូវទទួលយកជំនួយដែលការបម្រើ និងសកម្មភាពក្នុងសាសនាចក្រអាចផ្ដល់ឲ្យបាន ។ ប្រសិនបើឪពុកម្ដាយគ្រប់រូបប្រកាន់នូវកិរិយាមិនល្អ ហើយវង្វេងផ្លូវ សូម្បីតែជាការបណ្ដោះអាសន្នក្ដី នោះកូនចៅមួយចំនួនរបស់ពួកគេអាចគិតថាគំរូនោះអាចទទួលយកបាន ។

ឥឡូវនេះ មានផ្នែកមួយទៀតដែលត្រូវលើកឡើង ។ ខ្ញុំសូមធ្វើការស្នើសុំមួយដល់កូនចៅទាំងឡាយដែលបានឃ្លាតឆ្ងាយពីឪពុកម្ដាយរបស់ខ្លួនឲ្យងាកទៅរកពួកគាត់ សូម្បីតែពួកគាត់ពុំបានធ្វើឲ្យល្អដូចជាអ្វីដែលពួកគាត់គួរតែធ្វើក្ដី ។ កូនចៅដែលរិះគន់ពីឪពុកម្ដាយរបស់ខ្លួនអាចចងចាំបានយ៉ាងល្អនូវពាក្យទូន្មានដ៏ឈ្លាសវៃរបស់ម៉ូរ៉ូណៃ នៅពេលលោកបានមានប្រសាសន៍ថា « ចូរកុំថ្កោលទោសខ្ញុំ ពីព្រោះមកពី

*ឪពុកម្ដាយល្អជាមនុស្សដែលបានព្យាយាមបង្រៀនកូនចៅរបស់ខ្លួនដោយសេចក្ដីស្រឡាញ់ ពោរពេញដោយការអធិស្ឋាន និង ដោយសេចក្ដីស្មោះត្រង់តាមរយៈគំរូ និង គោលការណ៍ « ឲ្យអធិស្ឋាន និង ឲ្យដើរដោយទ្រង់ត្រង់នៅចំពោះព្រះអម្ចាស់ » ។ រឿងនេះជាការពិត ទោះបីជាកូនចៅរបស់ពួកគេមួយចំនួនពុំស្ដាប់បង្គាប់ ឬ រក់រវីនឹងលោកិយក្ដី ។*

*ខ្ញុំសូមធ្វើការស្នើសុំមួយដល់កូនចៅទាំងឡាយដែលបានឃ្លាតឆ្ងាយពីឪពុកម្ដាយរបស់ខ្លួនឲ្យងាកទៅរកពួកគាត់ ... ខ្ញុំសង្ឃឹមថា នៅទីបំផុតកូនចៅគ្រប់រូប នឹងបង្វែរដួងចិត្តរបស់ខ្លួនមករកពួកឪពុករបស់ពួកគេ ហើយក៏មករកម្ដាយរបស់ពួកគេផងដែរ ។*



ភាពមិនល្អឥតខ្ចោះរបស់ខ្ញុំ ឬក៏ឪពុកខ្ញុំ ពីព្រោះមកពីភាពមិនល្អឥតខ្ចោះរបស់លោក ឬក៏ពួកគេដែលបានសរសេរមុនឪពុកខ្ញុំឡើយ ប៉ុន្តែចូរថ្លែងអំណរគុណដល់ព្រះវិញ ដែលទ្រង់បានសម្ដែងឲ្យអ្នកឃើញនូវការឆ្គាំឆ្គងរបស់ពួកយើង ដើម្បីឲ្យអ្នករាល់គ្នាអាចរៀនឲ្យមានប្រាជ្ញាជាងយើងទៀត » ។[17]

នៅពេល ម៉ូរ៉ូណៃ បានមកជួបនឹងព្យាការីវ័យក្មេង យ៉ូសែប ស្ម៊ីធ ក្នុងឆ្នាំ 1823 លោកបានដកស្រង់នូវខគម្ពីរដូចតទៅនេះស្ដីពីបេសកកម្មរបស់អេលីយ៉ា ៖ « ហើយលោកនឹងដាក់នៅក្នុងចិត្តនៃកូនចៅនូវសេចក្ដីសន្យាដែលបានធ្វើដល់ពួកឪពុក ហើយចិត្តនៃកូនចៅនឹងបានបង្វែរមករកពួកឪពុករបស់ពួកគេវិញ » ។[18] ខ្ញុំសង្ឃឹមថា នៅទីបំផុតកូនចៅគ្រប់រូប នឹងបង្វែរដួងចិត្តរបស់ខ្លួនមករកពួកឪពុករបស់ពួកគេ ហើយក៏មករកម្ដាយរបស់ពួកគេផងដែរ ។

មានស្វាមីភរិយាដ៏ប្រពៃមួយគូដែលខ្ញុំស្គាល់កាលពីខ្ញុំនៅក្មេង ពួកគាត់មានកូនប្រុសម្នាក់ដែលចចេសរឹងរូស ហើយបានដកខ្លួនគាត់ឃ្លាតឆ្ងាយពីគ្រួសារ ។ លុះប៉ុន្មានឆ្នាំក្រោយមក គាត់បានផ្សះផ្សាជាមួយនឹងពួកគាត់ ហើយបានក្លាយជាមនុស្សដែលមានការខ្វល់ខ្វាយ និង យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះកូនចៅរបស់ខ្លួន ។ នៅពេលយើងកាន់តែចាស់ នោះឥទ្ធិពលមកពីឪពុកម្ដាយ និង ជីដូនជីតារបស់យើងនៅភពម្ខាងទៀតកាន់តែមានភាពរឹងមាំ ។ វាជាបទពិសោធន៍មួយដ៏ផ្អែមល្ហែម ពេលពួកគាត់មកជួបយើងក្នុងសុបិន ។

វាជារឿងដ៏អយុត្តិធម៌ ហើយអសប្បុរសធម៌បំផុតដើម្បីកាត់សេចក្ដីដល់ឪពុកម្ដាយដែលមានមនសិការ ហើយស្មោះត្រង់ ដោយសារតែកូនចៅរបស់ពួកគេមួយចំនួនមានចិត្តរឹងរូស ឬវង្វេងចេញពីការបង្រៀន និង សេចក្ដីស្រឡាញ់របស់ឪពុកម្ដាយខ្លួននោះ ។ ស្វាមីភរិយាដែលមានកូន និង ចៅដែលនាំមកឲ្យពួកគាត់នូវការលួងលោមចិត្ត និងភាពរីករាយនោះជាភ័ព្វសំណាងណាស់ ។ យើងគួរតែគិតពិចារណាដល់ឪពុកម្ដាយដែលសក្ដិសម ហើយសុចរិតដែលបានព្រួយ និង រងទុក្ខដោយសារកូនចៅដែលពុំស្ដាប់បង្គាប់ ។ មានមិត្តរបស់ខ្ញុំម្នាក់ធ្លាប់និយាយថា « ប្រសិនបើអ្នកពុំធ្លាប់មានបញ្ហាណាមួយជាមួយនឹងកូនចៅទេ នោះរង់ចាំមើលបន្តិចទៀតទៅ » ។ គ្មាននរណាម្នាក់អាចនិយាយដោយភាពច្បាស់លាស់ចំពោះអ្វីដែលកូនចៅរបស់ខ្លួននឹងធ្វើក្រោមស្ថានភាពជាក់លាក់នានានោះឡើយ ។ នៅពេលម្ដាយក្មេកដ៏ឈ្លាសវៃរបស់ខ្ញុំបានឃើញកូនចៅផ្សេងទៀតមានកិរិយាមិនល្អ នោះគាត់បាននិយាយថា « ខ្ញុំពុំដែលនិយាយថាកូនរបស់ខ្ញុំនឹងពុំធ្វើការណ៍នោះទេ ពីព្រោះពួកគេអាចចេញទៅខាងក្រៅធ្វើវាខណៈ

រចនាដោយប៉ូល ម៉ែន ។ រចនារូបថតដោយ ម៉ាថាយ រៀ

ដែលខ្ញុំកំពុងតែនិយាយនៅពេលនេះក៏ថាបាន ! » នៅពេលឪពុកម្ដាយទួញយំចំពោះកូនដែលមិនស្ដាប់បង្គាប់ ហើយចចេស ដោយក្ដីអាណិតអាសូរ នោះយើងត្រូវតែ « ឈប់ចោលគាត់នឹងថ្មជាមុន » ។[19]

សមាជិកសាសនាចក្រមិនស្គាល់ឈ្មោះម្នាក់បានសរសេរពីការខូចចិត្តជាបន្តបន្ទាប់ដែលប្អូនប្រុសរបស់នាងបានធ្វើចំពោះឪពុកម្ដាយនាង ។ គាត់បានជាប់ពាក់ព័ន្ធនឹងថ្នាំញៀន ។ គាត់បានបដិសេធនូវរាល់ការទប់ស្កាត់ និង ការដាក់វិន័យ ។ គាត់បានកុហក ហើយជម្នះ ។ មិនដូចជាកូនប្រុសដែលខ្ជះខ្ជាយនោះទេ កូនប្រុសដ៏ចចេសម្នាក់នេះពុំបានត្រឡប់មកផ្ទះដោយឯកឯងនោះឡើយ ។ ផ្ទុយទៅវិញ គាត់ត្រូវបាននគរបាលចាប់ ហើយត្រូវបានបង្ខំឲ្យប្រឈមមុខនឹងលទ្ធផលនៃទង្វើរបស់ខ្លួន ។ អស់រយៈពេលពីរឆ្នាំឪពុកម្ដាយគាត់បានគាំទ្រដល់កម្មវិធីព្យាបាលរបស់ប៊ិល ដែលនៅទីបំផុតបានធ្វើឲ្យជាសះស្បើយពីការញៀនថ្នាំ ។ សង្ខេបមក បងស្រីរបស់ប៊ិលបានសង្កេតឃើញថា ៖ « ខ្ញុំគិតថាឪពុកម្ដាយរបស់ខ្ញុំជាមនុស្សវិសេសវិសាលណាស់ ។ ពួកគាត់ពុំដែលងាករេក្នុងការផ្ដល់សេចក្ដីស្រឡាញ់របស់គាត់ចំពោះប៊ិលឡើយ ទោះបីជាពួកគាត់ពុំយល់ស្រប ហើយស្អប់នូវអ្វីដែលប៊ិលបានធ្វើចំពោះខ្លួនគាត់ និងចំពោះគ្រួសារក្ដី ។ ប៉ុន្តែពួកគាត់បានតាំងចិត្តល្មមគ្រប់គ្រាន់ចំពោះគ្រួសារដើម្បីជួយប៊ិលគ្រប់វិធីដ៏ចាំបាច់ដែលអាចធ្វើទៅបាន ដើម្បីជួយគាត់ឲ្យឆ្លងកាត់គ្រាដ៏លំបាកនេះ ហើយឈរនៅលើទីដែលរឹងមាំជាងនេះ ។ ពួកគាត់បានអនុវត្តនូវដំណឹងល្អនៃព្រះគ្រីស្ទកាន់តែស៊ីជម្រៅទន់ភ្លន់ និង ច្រើនឡើង ដោយការស្រឡាញ់មនុស្សដែលបានវង្វេងផ្លូវ » ។[20]

ចូរយើងកុំធ្វើជាមនុស្សក្រអឺតក្រទម ប៉ុន្តែផ្ទុយទៅវិញសូមធ្វើជាមនុស្សដែលមានអំណរគុណដោយរាបសា ប្រសិនបើកូនចៅរបស់យើងពុំស្ដាប់បង្គាប់ ហើយខ្វះការគោរពចំពោះការបង្រៀនរបស់យើងពីផ្លូវនៃព្រះអម្ចាស់ ។ ចំពោះឪពុកម្ដាយទាំងឡាយដែលមានការខូចចិត្តយ៉ាងខ្លាំង ហើយដែលមានសេចក្ដីសុចរិត ឧស្សាហ៍ព្យាយាម និងពោរពេញដោយការអធិស្ឋានក្នុងការបង្រៀនកូនចៅរបស់ខ្លួនដែលពុំស្ដាប់បង្គាប់ យើងសូមនិយាយទៅកាន់អ្នកថា អ្នកគង្វាលចៀមដ៏ល្អកំពុងឃ្លាំមើលពួកគេ ។ ព្រះទ្រង់ជ្រាប ហើយយល់ពីទុក្ខសោកដ៏ធំធេងរបស់អ្នក ។ នៅមានសេចក្ដីសង្ឃឹម ។ សូមទទួលយកការលួងលោមចិត្តតាមពាក្យសម្ដីរបស់យេរេមា ថា ៖ « ការរបស់ឯងនឹងបានរង្វាន់ជាពិត » ហើយកូនចៅរបស់អ្នកអាច « វិលមកពីស្រុកខ្មាំងសត្រូវវិញ » ។[21] ខ្ញុំសូមថ្លែងទីបន្ទាល់ពីការណ៍នេះ ហើយអធិស្ឋានក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។ ■

**កំណត់ចំណាំ**

1. យេរេមា 31:15–16 ។
2. គោលលទ្ធិ និង សេចក្ដីសញ្ញា 68:25 ។
3. គោលលទ្ធិ និង សេចក្ដីសញ្ញា 68:28 ។
4. គោលលទ្ធិ និង សេចក្ដីសញ្ញា 68:28 ។
5. ហាវើដ ដបុលយូ. ហ៊ុនធើរ « Parents' Concern for Children » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1983 ទំព័រ 65 ។
6. សាំយូអែលទី 2 18:33 ។
7. លូកា 15:32 ។
8. អូសុន អែហ្វ. វិតនី នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1929 ទំព័រ 110 ។
9. អាលម៉ា 34:32 ។
10. គោលលទ្ធិ និង សេចក្ដីសញ្ញា 138:58–59 ។
11. សូមមើល លូកា 15:11–32 ។
12. អាទ្បុនហ្ស អេ. ហ៊ិងគ្លី នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1919 ទំព័រ 161 ។
13. គោលលទ្ធិ និង សេចក្ដីសញ្ញា 64: 10 ។
14. សូមមើល ចន ខេ. ខាម៉ាក « When Our Children Go Astray » *Liahona* ខែ មិនា ឆ្នាំ 1999 ទំព័រ 28–37 *Ensign* ខែ កុម្ភៈ ឆ្នាំ 1997 ទំព័រ 7–13 ។
15. *The Teachings of Howard W. Hunter* បានបោះពុម្ពដោយ ក្លេដ ជេ. វិល្លាម ( ឆ្នាំ 1997 )ទំព័រ 32 ។
16. *Teachings of Gordon B. Hinckley* ( ឆ្នាំ 1997 ) ទំព័រ 704 ។
17. មរមន 9:31 ។
18. យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:39 ។
19. ហារ៉ូល ប៊ី. លី *Decisions for Successful Living* ( ឆ្នាំ 1973 ) ទំព័រ 58 ។
20. « With Love—from the Prodigal's Sister » *Ensign* ខែ មិថុនា ឆ្នាំ 1991 ទំព័រ 19 ។
21. យេរេមា 31:16 ។

*ស្វាមីភរិយាដែលមានកូន និងចៅដែលនាំមកឲ្យពួកគាត់នូវការលួងលោមចិត្ត និង ភាពរីករាយ នោះជាភ័ព្វសំណាងណាស់ ។ យើងគួរតែគិតពិចារណាដល់ឪពុកម្ដាយដែលសក្ដិសម ហើយសុចរិតដែលបានពុះពារ និងរងទុក្ខដោយសារកូនចៅដែលពុំស្ដាប់បង្គាប់ ។*



# ការពង្រឹង ក្រុមគ្រួសារ និង សាសនាចក្រ តាមរយៈបព្វជិតភាព

*មាតាបិតា ក្រុមគ្រួសារ និង បុគ្គលទាំងឡាយគឺត្រូវបានប្រទានពរជ័យ កាលណាពួកគេសិក្សា ហើយពិភាក្សាគ្នា អំពីសារលិខិតដ៏បំផុសគំនិតទាំងនេះ ។*

**ដោយ វីឆាត អិម. រ៉មនី**
ទស្សនាវដ្ដីសាសនាចក្រ

តើអ្នកចងចាំពីសេចក្ដីសន្យាទាំងនេះដែរឬទេ ? អ្នកប្រហែលជាបានឮនូវសេចក្ដីសន្យាទាំងនេះ ពីសេចក្ដីដកស្រង់ វីដេអូដែលបានបង្ហាញនៅក្នុងការប្រជុំក្រុមប្រឹក្សា ការប្រជុំនៅសប្ដាហ៍ទីប្រាំ ឬ មេរៀនក្នុងថ្នាក់សមាគមសង្គ្រោះ ឬ កូរ៉ុមកូរ៉ុមបព្វជិតភាព ។ ឬអ្នកប្រហែលជាបានពិភាក្សាពីសេចក្ដីសន្យាទាំងនោះនៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ។ សេចក្ដីសន្យាគឺ ៖

- ស្វាមី និងភរិយានឹងបាននៅជាមួយគ្នាម្ដងទៀត ។
- បិតា និងមាតានឹងផ្ដល់នូវការដឹកនាំខាងវិញ្ញាណដ៏ប្រសើរដល់ ក្រុមគ្រួសារខ្លួន ។
- យុវវ័យនឹងត្រូវបានរៀបចំខ្លួនដើម្បីចុះ និង រក្សាសេចក្ដីសញ្ញាពិសិដ្ឋទាំងឡាយ ហើយនឹងបម្រើព្រះអម្ចាស់ដោយធ្វើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង និងដរាបអស់មួយជីវិត ។
- សមាជិកដែលនៅលីវនឹងត្រូវបាន គាំទ្រ ដើម្បីទទួលបានពរជ័យទាំងឡាយនៃបព្វជិតភាពនៅក្នុងគេហដ្ឋានរបស់ខ្លួន និង ត្រូវ ចូលរួមចំណែកយ៉ាងសកម្មក្នុងការស្ថាបនានគរនៃព្រះ ។
- កូរ៉ុម និង ក្រុមប្រឹក្សាទាំងឡាយនឹងធ្វើការរួមគ្នា ដើម្បីបម្រើដល់កូនចៅរបស់ព្រះវរបិតាសួគ៌ ។
- សាសនាចក្រនឹងត្រូវបានពង្រឹង ។

ការសន្យាទាំងនោះត្រូវបានធ្វើឡើងក្នុងខែមិនា ខណៈដែលគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់បានចេញផ្សាយសារលិខិតនានាក្នុងឌី.វី.ឌី.មួយដែលមានចំណងជើងថា*ការពង្រឹងដល់គ្រួសារ និង សាសនាចក្រ តាមរយៈបព្វជិតភាព ។* នៅពេលនោះ ក្រុមប្រឹក្សាវួដ និង ស្ដេកត្រូវបានអញ្ជើញឲ្យពិនិត្យមើល សារលិខិតទាំងនោះ រួចហើយប្រឹក្សារួមគ្នាពីរបៀបដើម្បីប្រើសារលិខិតទាំងនោះ ។ ទន្ទឹមគ្នានោះ ក្រុមគ្រួសារត្រូវបានអញ្ជើញឲ្យមើលវគ្គទាំងឡាយនៃវីដេអូនោះតាមអ៊ិនធើរណែតនៅhttp://wwlt.lds.org រួមទាំងពាក្យដកស្រង់ខ្លីៗនៅពេលវាត្រូវបានគេដាក់ឲ្យប្រើ ។ បណ្ដាអ្នកដឹកនាំ និង គ្រូបង្រៀនត្រូវបានលើកទឹកចិត្តឲ្យផ្ដល់ឱកាសដល់សមាជិកទាំងឡាយក្នុងការប្រជុំ និង ថ្នាក់នានាដើម្បីមើលវគ្គមួយចំនួន ហើយចែកនូវចំណាប់អារម្មណ៍ ពីបទពិសោធន៍ និង ទីបន្ទាល់ផ្ទាល់ខ្លួន តាមការបំផុសដោយព្រះវិញ្ញាណ ។ មាតាបិតាទាំងឡាយត្រូវបានអញ្ជើញឲ្យធ្វើកិច្ចការដូចគ្នានេះផងដែរនៅក្នុង

រចនារូបថតដោយ ខូឌី ប៊ើល និងក្រេហ្គ ដាយម៉ុន

គេហដ្ឋានជាមួយនឹងក្រុមគ្រួសាររបស់ខ្លួន ។

វគ្គ « របៀបប្រើប្រាស់ការបំពាក់បំប៉ននេះ » បានលើកឡើងថា « ព្រះវិញ្ញាណបរិសុទ្ធនឹងបង្រៀនសមាជិកទាំងឡាយពីរបៀបដែលពួកគេអាចទទួលបានការពង្រឹងតាមរយៈអំណាចនៃបព្វជិតភាពក្នុងតួនាទី និង ទំនួលខុសត្រូវរបស់គេផ្ទាល់ » ។

## ការពិភាក្សាដ៏រស់រវើក

ទោះបីជាសារលិខិតនេះ បានចេញផ្សាយកាលពីបីខែមុនក៏ដោយ ក៏ការសិក្សា និងការពិភាក្សា—និងពរជ័យដែលកើតមានមកជាមួយនោះ—នៅតែបន្តមានមកដល់សព្វថ្ងៃនេះដែរ ហើយវិធីសាស្ត្រនេះនឹងផ្តល់នូវទិដ្ឋភាពថ្មីមួយចំពោះលក្ខណៈនៃការបំពាក់បំប៉នក្នុងសាសនាចក្រ ។ មិនដូចជាការបំពាក់បំប៉ន មុនៗទេ ដែលជាការបំពាក់បំប៉នសំខាន់ដែលចាក់ផ្សាយតែមួយដង សម្រាប់បណ្តាអ្នកដឹកនាំវួដ និងស្តេក ប៉ុន្តែការបំពាក់បំប៉ននេះមានគោលបំណងដើម្បីធ្វើវាម្តងហើយម្តងទៀត ។ នោះជាហេតុផលដែលវគ្គវីដេអូទាំងនោះត្រូវបានដាក់នៅលើអ៊ិនធើរណែតក្នុងwwlt.lds.org។ គេហទំព័រស្រដៀងគ្នានេះដែរleadershiplibrary.lds.org ផ្តល់នូវតំណភ្ជាប់មួយទៅវីដេអូទាំងនោះ រួមទាំងធនធានបន្ថែមទៀតដើម្បីជួយក្រុមគ្រួសារ បុគ្គលម្នាក់ៗ កូរ៉ុម ថ្នាក់ និងក្រុមប្រឹក្សាទាំងឡាយឲ្យយល់កាន់តែច្បាស់ថែមទៀត ហើយអនុវត្តអ្វីដែលពួកគេបានរៀន ។

វគ្គនៃវីដេអូនីមួយៗផ្តោតសំខាន់លើទិដ្ឋភាពផ្សេងមួយនៃបព្វជិតភាព ។ សមាជិកនៃគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ រួមជាមួយនឹងពួកអ្នកមានសិទ្ធិអំណាចទូទៅ ព្រមទាំងអ្នកមានតំណែងទូទៅទាំងឡាយ ផ្តល់នូវការណែនាំដ៏បំផុសគំនិតស្តីអំពី ៖

### ត្រូវស្វែងរកវីដេអូ និងធនធាននៅឯណា

វគ្គវីដេអូ និងសម្ភារជំនួយគឺមាននៅhttp://wwlt.lds.org ។ នៅពេលទស្សនាវគ្គវីដេអូពី អ៊ិនធើរណែតនៅក្នុងសាលាប្រជុំ នោះពួកអ្នកដឹកនាំគឺត្រូវបានលើកទឹកចិត្ត ឲ្យទាញយកវីដេអូចេញពីអ៊ិនធើរណែត រួចហើយយកមកចាក់នៅលើកុំព្យូទ័រ ជាជាងចាក់វីដេអូដែលមានភ្ជាប់អិនធើរណែត ។



- របៀបដែលក្រុមគ្រួសារអាចស្វែងរកភាពរឹងមាំ និង សេចក្ដីសុខសាន្ត តាមរយៈអំណាចបព្វជិតភាព ។
- របៀបដើម្បីជួយគ្រួសារនីមួយៗឲ្យទទួលបានបទពិសោធន៍ពីពរជ័យទាំងឡាយនៃបព្វជិតភាព ។
- របៀបដែលអស់អ្នកដែលកាន់កូនសោបព្វជិតភាពពង្រឹងគេហដ្ឋាន និងក្រុមគ្រួសារ ។
- របៀបដើម្បីបម្រើតាមគំរូទាំងឡាយនៃព្រះគ្រីស្ទ ។
- របៀបដើម្បីចិញ្ចឹមកូនចៅនៅក្នុងពន្លឺ និង សេចក្ដីពិត ។

លក្ខណៈពិសេសនៃគោលការណ៍ទាំងឡាយនៃដំណឹងល្អនៅក្នុង*ការពង្រឹងក្រុមគ្រួសារ និង សាសនាចក្រតាមរយៈបព្វជិតភាព* ក៏មានបង្រៀននៅក្នុង*ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* ដូច្នេះការរំឭកឡើងវិញនូវព័ត៌មានចេញពីក្បួនខ្នាត អាចជាជំនួយដ៏ធំក្នុងអំឡុងពេលសិក្សា និង ពិភាក្សា ។ ការមើលឡើងវិញ « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ក៏អាចបង្ហាញថាមានប្រយោជន៍ដែរ ។

ប្រធាន ហិនរី ប៊ី. អាវរិង ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ ពន្យល់ថា សារលិខិតដែលមាននៅក្នុង*ការពង្រឹងក្រុមគ្រួសារ និង សាសនាចក្រតាមរយៈបព្វជិតភាព* ត្រូវបាន « រៀបរៀងឡើងដើម្បីជួយយើងឲ្យរៀន តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នូវរបៀបដែលព្រះវរបិតាសួគ៌មានព្រះទ័យចង់ឲ្យយើងបម្រើ ជាពិសេសគឺនៅក្នុងក្រុមគ្រួសារ » ។ នោះគឺជាផ្នែកដ៏មានអនុភាពបំផុតនៅក្នុងការបំពាក់បំប៉ន—ភាគច្រើន មិនមែនជាវគ្គដែលនិយាយនៅក្នុងវីដេអូនោះទេ ប៉ុន្តែជាអ្វីដែលព្រះវិញ្ញាណបរិសុទ្ធបង្រៀនយើង នៅពេលដែលយើងសញ្ជឹងគិត និង ពិភាក្សាពីគោលការណ៍ទាំងឡាយដែលបានបង្រៀន ។

**ទីកន្លែងដើម្បីចែកចាយ**

បណ្ដាអ្នកដឹកនាំ សមាជិក និង ក្រុមគ្រួសារទាំងអស់គប្បីផ្ដល់ឱកាសដើម្បីស្ដាប់ ហើយពិភាក្សាពីសារលិខិតក្នុង*ការពង្រឹងក្រុមគ្រួសារ និង សាសនាចក្រតាមរយៈបព្វជិតភាព* មិនថាតាមឌី.វី.ឌី. ឬតាមអ៊ិនធើរណែតនោះទេ ។

សារលិខិតនេះប្រទានពរដល់ក្រុមគ្រួសារ នៅពេលពួកគេប្រើវាក្នុងរាត្រីជួបជុំគ្រួសារ និងសកម្មភាពគ្រួសារផ្សេងៗទៀត ។ នៅទីបំផុត ស្វាមី និងភរិយាទាំងឡាយគឺជាដៃគូស្មើភាពគ្នាក្នុងការដឹកនាំកូនចៅខ្លួន ។ អែលឌើរ អិម. រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់នៅក្នុងឌីវីឌីដែលមានចំណងជើងថា « នេះជាកិច្ចការទ្រង់ » ដូច្នោះថា « អាចនឹងមានពេលខ្លះ ដែលឪពុកឬម្ដាយម្នាក់ ត្រូវបង្រៀនគោលការណ៍មួយ ហើយពួកគាត់អាចប្រើធនធានទាំងនេះ នៅពេលដែលពួកគាត់ព្យាយាមជួយដល់កូនប្រុស ឬកូនស្រី នៅក្នុងជីវិត » ។ ហើយអែលឌើរ ដាល្លិន អេក. អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានធ្វើការកត់សម្គាល់ ថា « ទោះជាយ៉ាងណាក្ដី ការបង្រៀនដ៏សំខាន់នៃអ្នកប្រឹក្សាបព្វជិតភាពម្នាក់ ឬអ្នកប្រឹក្សាយុវនារីម្នាក់ គឺនៅក្នុងសាសនាចក្រ—ហើយយើងសង្ឃឹមថា វាមានប្រសិទ្ធភាពយ៉ាងខ្លាំង—ទោះ

**គោលការណ៍របស់ព្យាការី មកពីការបំពាក់បំប៉ន**

វគ្គវីដេអូមួយចំនួនដែលមាននៅក្នុង *ការពង្រឹងក្រុមគ្រួសារ និងសាសនាចក្រតាមរយៈបព្វជិតភាព*គឺមាននូវ ការបង្រៀនទាំងឡាយដែលងាយចងចាំ ។ ទាំងនេះគឺជាការបង្រៀនមួយចំនួន មកពីសមាជិកនៃកូរ៉ុមនៃពួកសាវ័កដប់ពីរនាក់ ៖

**អែលឌើរ អិល. ថម ភែរី** ដែលដឹកនាំការពិភាក្សាអំពីកូនសោបព្វជិតភាព ថ្លែងទីបន្ទាល់ថា « នេះគឺជាសាសនាចក្ររបស់ព្រះអង្គសង្គ្រោះ ដែលយើងចូលរួម។ ទ្រង់គឺជាអ្នកដឹកនាំ និង ជាអ្នកណែនាំ ហើយតម្រង់ទិសដល់ព្យាការីទ្រង់នៅលើផែនដី ។ ពុំមានអ្វីគួរឲ្យសង្ស័យនៅក្នុងគំនិតខ្ញុំឡើយថា ទ្រង់គឺជាសិរសានៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។

**អែលឌើរ រ័សុល អិម. ណិលសុន** បង្រៀនថា « គ្មានអ្វីសំខាន់សម្រាប់អនាគតអ្នកផ្សព្វផ្សាយសាសនា ជាងការទទួលបាននូវឥទ្ធិពលដ៏សុចរិតនៃបព្វជិតភាពនៅក្នុងផ្ទះរបស់ខ្លួន និងដកពិសោធនូវពរជ័យនៃឥទ្ធិពលនោះក្នុងជីវិតរបស់គេនោះឡើយ » ។

**អែលឌើរ ដាល្លិន អេក អូក** ប្រឹក្សាថា « អំណាចនៃបព្វជិតភាពពឹងផ្អែកទៅលើភាពសុចរិតផ្ទាល់ខ្លួន » ហើយថាពរជ័យនៃអំណាចបព្វជិតភាពគឺ « មានចំពោះទាំងបុរស និង ស្ត្រីដូចគ្នា » ។ លោកមានបន្ទូលថា ក្រុមគ្រួសារទាំងឡាយគឺជា « រូបរាងនិងរបស់នាំមុខនៃការលើកដំកើងនៅក្នុងនគរស្ថានសួគ៌ » ។

ហើយ**អែលឌើរ អិម. រ័សុល បាឡឺដ** ថ្លែងទីបន្ទាល់ថា « សិទ្ធិអំណាចបព្វជិតភាពអាចចងភ្ជាប់ក្រុមគ្រួសារជាមួយគ្នា តាមរយៈការផ្សារភ្ជាប់ ឬពិធីបរិសុទ្ធទាំងឡាយដែលមាននៅក្នុងដំណាក់នៃព្រះអម្ចាស់ » ។ លោកក៏ផ្ដល់ដំបូន្មានដែរថា « បងប្អូនប្រុសដែលដឹកនាំនៅក្នុងវួដ និងនៅក្នុងស្ដេក ត្រូវតែខិតជិតនឹងអំណាចដែលស្ត្រីនៃសាសនាចក្រ អាចនាំមក ដើម្បីកសាងនគររបស់ព្រះ » ។



*សារលិខិតដែលបានបង្រៀនក្នុងការពង្រឹងក្រុមគ្រួសារ និងសាសនាចក្រតាមរយៈបព្វជិតភាព អាចចែកចាយនៅក្នុងមជ្ឈដ្ឋានជាច្រើន ដូចជាក្រុមប្រឹក្សាស្តេក និងវួដ ។*

ជាវាមិនអាចមានប្រសិទ្ធភាពដូចជាគំរូរបស់ម្តាយ ឬរបស់ឪពុកម្នាក់ក្តី ។

ក្នុងការប្រជុំរបស់សាសនាចក្រមួយចំនួន សារលិខិតនេះអាចត្រូវប្រើប្រាស់ នៅ ក្នុងការប្រជុំគណៈប្រធានស្តេក និង គណៈប៊ីស្សព ការប្រជុំក្រុមប្រឹក្សាស្តេក និង វួដ ការប្រជុំគណៈកម្មាធិកាប្រតិបត្តិបព្វជិតភាព ការប្រជុំបំពាក់បំប៉នអង្គការជំនួយស្តេក ការប្រជុំគណៈប្រធាន ដោយរួមទាំងការប្រជុំគណៈប្រធានកូរ៉ុមបព្វជិតភាពអើរ៉ុន និងគណៈប្រធានថ្នាក់យុវនារី ការប្រជុំចូលគ្នានៃបព្វជិតភាព និង សមាគមសង្គ្រោះ នៅសប្តាហ៍ទីប្រាំ ការប្រជុំកូរ៉ុមនៅថ្ងៃអាទិត្យ និង ថ្នាក់អង្គការជំនួយ ការប្រជុំសន្និសីទស្តេក ឬ មណ្ឌល ( មិនមែននៅក្នុងសម័យប្រជុំទូទៅថ្ងៃអាទិត្យនោះទេ ) ហើយការប្រជុំសន្និសីទវួដ ឬសាខា ( មិនមែននៅក្នុងសាក្រាម៉ង់នោះដែរ ) ។

ការពិភាក្សាអាចមានទាំងរបៀបដើម្បីពង្រឹងយុវវ័យ និង មជ្ឈិមវ័យនៅលីវ ។ ពួកអ្នកដឹកនាំអាចផ្តល់នូវការចាត់តាំងដោយផ្អែកតាមការពិភាក្សា និង ការតាមដានទៅលើកិច្ចការដែលបានចាត់តាំងនោះជាទៀងទាត់ នៅក្នុងការប្រជុំក្រុមប្រឹក្សា ។

គោលបំណងនៃការសិក្សា និង ការពិភាក្សានូវសារលិខិតទាំងនេះ គឺដើម្បីជួយដល់បុគ្គលម្នាក់ៗ និងក្រុមគ្រួសារពង្រឹងជំនឿរបស់ខ្លួន ស្ថាបនាទីបន្ទាល់ខ្លួន និង ធ្វើឲ្យការផ្លាស់ប្រែចិត្តជឿរបស់ពួកគេទៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ កាន់តែខ្លាំង ។

ប្រធានអាវីង មានប្រសាសន៍ថា « សុវត្ថិភាព និង ជោគជ័យរបស់យើងគ្រាន់តែតម្រូវឲ្យ បំណងប្រាថ្នារបស់យើងស្របគ្នាទៅនឹង ព្រះរាជបំណងប្រាថ្នារបស់ព្រះ និង ទៅនឹងព្រះចេស្តាទ្រង់ប៉ុណ្ណោះ » ។ សារលិខិតទាំងនេះគឺជា « សេចក្តីណែនាំ និងការលើកទឹកចិត្ត ដើម្បីតម្រង់ទិស និងដើម្បីជួយដល់អ្នកដទៃ » ។

វគ្គ « ការបម្រ » ផ្តល់ឲ្យជាគំរូដ៏មានអនុភាពពី ការទៅសួរសុខទុក្ខរបស់ថ្នាក់ដឹកនាំបព្វជិតភាពទៅដល់បុគ្គល និង ក្រុមគ្រួសារទាំងឡាយ ដោយការបង្ហាញនូវរបៀបដែលការសួរសុខទុក្ខបែបនោះអាចជួយដល់ការសង្គ្រោះដល់សមាជិកមិនសូវសកម្ម ។

ប៊ីស្សពជាអធិបតី ហ្គែរី អ៊ី. ស្ទីវើនសុន នៅក្នុងវគ្គ « នេះជាកិច្ចការទ្រង់ » មានប្រសាសន៍ថា « កាលដែលយើងគិតអំពីទំនួលខុសត្រូវដែលយើងទទួលដើម្បីសង្គ្រោះដល់ជនទន់ខ្សោយ ដើម្បីជួយដល់ដៃដែលពាយ និង ដើម្បីចម្រើនដល់ក្បាលជង្គង់ដែលញ័រ នោះយើងពិតជាមិនអាចធ្វើបែបនោះបានប្រសើរជាង កាលទៅសួរសុខទុក្ខផ្ទះមួយៗ ដោយការផ្តល់នូវការបម្រើនេះ និងគំរូដែលព្រះយេស៊ូវគ្រីស្ទ បានប្រើនោះឡើយ » ។លោកមានប្រសាសន៍ថា « ខ្ញុំគិតថាប្រយោជន៍ពិតប្រាកដនឹងបានទទួល ពេលណាដែលយើងពិភាក្សា និង រៀន ហើយបន្ទាប់មក អនុវត្តតាមអ្វីដែលយើងបានរៀន » ។

## កម្លាំង និង ភាពសុខសាន្ត

ដរាបណាការបំពាក់បំប៉ននេះបន្តធ្វើនៅក្នុងសាសនាកច្រ នោះសមាជិកទាំងអស់នឹងទទួលបានពរជ័យជាច្រើន កាលណាពួកគេអនុវត្តតាមគោលការណ៍ដំណឹងល្អដែលបានបង្រៀន ។ អែលឌើរ បាឡាដ មានប្រសាសន៍ថា « បុត្រាបុត្រីរបស់ព្រះគ្រប់រូបនឹងត្រូវបានប្រទានពរ ប្រសិនបើពួកគេធ្វើតាមការបង្រៀន និងគំរូនៃបទបង្ហាញទាំងនេះ ។

តាមរយៈបព្វជិតភាព នោះស្វាមី និង ភរិយាទាំងឡាយ បិតាមាតា យុវវ័យ សមាជិកនៅលីវ កូរ៉ុមទាំងឡាយ និង ក្រុមប្រឹក្សា គឺកំពុងបម្រើដល់អ្នកដទៃ ហើយស្វែងរកការបំផុសគំនិត នៅពេលពួកគេធ្វើតាមគំរូនៃព្រះយេស៊ូវគ្រីស្ទ ។ នៅពេលពួកគេបន្តធ្វើដូច្នេះ នោះសេចក្តីសន្យាដែលបានសន្យានៅក្នុង *ការពង្រឹងក្រុមគ្រួសារ និង សាសនាចក្រតាមរយៈបព្វជិតភាព*នឹងបានឃើញច្បាស់ ។ សមាជិកទាំងឡាយនឹងបានឃើញការបំពេញនៃការសន្យារបស់ប្រធាន អាវីង ចេញពីវគ្គចុងក្រោយនៃវីដេអូ ៖ ថា ទោះបីជានៅពេលលំបាកក្តី « ក្រុមគ្រួសារអាចរឹងមាំ និង មាន ភាពសុខសាន្ត » ។ ■

រូបថតដោយ ឌេលេន ស៊ី. អាន់ឌើរសុន



# 9



រូបភាព ដោយ ក្រេហ្គ ដាយម៉ិន រីឌូជី បេល © IRI

អេមី អ័ដាមស៍ រស់នៅរដ្ឋវ៉ាស៊ីងតោន ស.ហ.រ. កំពុងតែខិតខំ សម្រេចចិត្តថាតើសកម្មភាពណាដែលល្អបំផុតសម្រាប់កូនតូចៗបីនាក់របស់គាត់ នៅពេលដែលមានការសន្ទនាមួយជាមួយនឹងម្ដាយរបស់គាត់បានផ្លាស់ប្ដូរចិត្តរបស់គាត់ ។ « ចុះតើអ្វីទៅដែលអ្នកផ្ដល់កូនរបស់អ្នកជាជាងការហ្វឹកហាត់ ខាងកីឡា ឬការរាំនោះ ? » ម្ដាយរបស់អេមីបានសួរ ។ « ចុះប្រសិនបើដោយការនៅផ្ទះ ពួកគេអាចរៀនមានអារម្មណ៍ព្រះវិញ្ញាណថែមទៀតឬ ? » រួចហើយម្ដាយរបស់គាត់បានរំលឹកគាត់អំពីអ្វីដែលប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរ នៅក្នុងគណៈប្រធានទីមួយ បានបង្រៀនអំពីអំណាចនៃការផ្ដោតទៅលើ ទំនាក់ទំនងចាំបាច់នៃជីវិត ( សូមមើល « អ្វីៗដែលសំខាន់បំផុត» *ទស្សនាវដ្ដីលីអាហូណា*និង *Ensign* ខែ វិច្ឆកាឆ្នាំ 2010 ទំព័រ19–22 ) ។

អេមី និងប្ដីរបស់គាត់ឈ្មោះប្រេត បានអធិស្ឋាន ហើយសញ្ជឹងគិតអំពីដំបូន្មាននេះហើយបានមានអារម្មណ៍ ថាវាគឺជាយោបល់ល្អ សម្រាប់គ្រួសាររបស់គេ ដើម្បីនឹងចំណាយពេលវេលាកាន់តែច្រើននៅក្នុងគេហដ្ឋាន ។ អស់រយៈមួយឆ្នាំហើយដែលពួកគេបានជ្រើសរើសដើម្បីបំភ្លេចចោលនូវការរាំ និង កីឡា ផ្ទុយទៅវិញ ពួកគេបានរៀបចំអាហារ រៀនបទចម្រៀងពីថ្នាក់បឋមសិក្សា ទៅទស្សនាសារវិច្ឆិកា និងការដើរលេងនៅខាងក្រៅ ។ អាមីនិយាយថា ៖ « កូនរបស់យើងអាចមានអារម្មណ៍ព្រះវិញ្ញាណ . . . ពីព្រោះ យើងបានចំណាយពេលដើម្បីនឹងឈប់ ហើយស្ដាប់ » ។ កូនរបស់ពួកគេប្រហែលជាមិនអាចក្លាយជាអ្នកស្ទាត់ជំនាញខាងកីឡា ឬការរាំ ឡើយ គាត់បាននិយាយថា « ប៉ុន្តែពួកគេមានទីបន្ទាល់អំពីព្រះសង្គ្រោះ » ។

អេមី និង ប្រេតបានអធិស្ឋាន ដើម្បីដឹងអំពីរបៀបដែលពួកគេត្រូវតែដើរតាម

# គោលការណ៍ប្រាំបួនយ៉ាង

## សម្រាប់អាពាហ៍ពិពាហ៍ និង ក្រុមគ្រួសារដែលជោគជ័យ

**ដោយ ចិននីហ្វឺរ ហ្គ្រេស យ៉ូនស៍**
ទស្សនាវដ្ដីសាសនាចក្រ



ដំបូន្មានរបស់ពួកព្យាការីបច្ចុប្បន្នដោយផ្ទាល់ ហើយដោយធ្វើបែបនេះអនុញ្ញាតពួកគេឲ្យទទួលការបំផុតគំនិតសម្រាប់ក្រុមគ្រួសាររបស់ពួកគេ ។ អេមីនិយាយថាការបំផុសគំនិតនេះបាននាំមកឲ្យនាងនូវ « ពេលដ៏មោទនភាពបំផុតក្នុងនាមជាម្ដាយម្នាក់ » ។

នៅក្នុង « គ្រួសារ៖ សេចក្ដីប្រកាសចំពោះពិភពលោក » ព្យាការីបច្ចុប្បន្ន នេះបានគូសបង្ហាញ នូវគោលការណ៍ ប្រាំបួនសម្រាប់ក្រុមគ្រួសាររឹងមាំ និង ផ្ដោតទៅលើដំណឹងល្អ ៖ « អាពាហ៍ពិពាហ៍ និង ក្រុមគ្រួសារដែលជោគជ័យ គឺត្រូវបានសាងឡើង និង រក្សាទុកនៅលើ គោលការណ៍នៃសេចក្ដីជំនឿ ការអធិស្ឋាន ការប្រែចិត្ត ការអភ័យទោស ក ការគោរព សេចក្ដីស្រឡាញ់ សេចក្ដីមេត្តាករុណា កិច្ចការហើយនិងសកម្មភាពលេងកំសាន្តល្អ ត្រឹមត្រូវ » ។ ( *ទស្សនាវដ្ដីលីអាហូណា* និង *Ensign* ខែ វិច្ឆិកាឆ្នាំ 2010 ទំព័រ 129 ) ។ ការបង្រៀនតទៅពីពួកអ្នកដឹកនាំសាសនាចក្រ គំរូពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ និង រូបភាពចុក្ខុវិស័យ ផ្ដល់ដល់យើងនូវការសម្លឹងមើលយ៉ាងជិតស្និទ្ធ ទៅលើគោលការណ៍ ទាំងប្រាំបួន នេះ និងរបៀបដែលយើងអាចយកគោលការណ៍នេះមកអនុវត្ត ។

## សេចក្ដីជំនឿ



**« សេចក្ដីជំនឿ គឺជាជំនឿចិត្ត និង ទំនុកចិត្តលើព្រះយេស៊ូវគ្រីស្ទ ដែលដឹកនាំមនុស្សម្នាក់ឲ្យគោរពទ្រង់ »។**

សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ, « Faith » scriptures.lds.org.

### ពីពួកអ្នកដឹកនាំសាសនាចក្រ

« ក្នុងនាមជាមាតាបិតា យើងត្រូវបានបញ្ជាឲ្យបង្រៀនកូនរបស់យើង ‹ យល់អំពីគោលលទ្ធិនៃ . . . សេចក្ដីជំនឿ នៅលើព្រះគ្រីស្ទ ព្រះរាជបុត្រានៃព្រះដ៏មានពព្រះជន្មរស់ › ( គ និង ស 68:25 ) ។ . . .

« គ្មានអ្វីផ្សេងទៀត ដែលនៅក្នុងនោះ ដែលយើងអាចមាននូវការបញ្ជាក់យ៉ាងឥតខ្ចោះឡើយ ។ ក៏គ្មានគ្រឹះនៃជីវិតឯណាទៀត ដែលអាចនាំមកនូវសេចក្ដីសុខ សេចក្ដីអំណរ ហើយនិង សេចក្ដីសង្ឃឹមដូចនេះឡើយ ។ នៅក្នុងពេលវេលា ដ៏សស្រពេចស្រពិល និង ពិបាក នោះសេចក្ដីជំនឿគឺពិតជាអំណោយទានខាងវិញ្ញាណយ៉ាងសក្ដិសមនៃការប្រឹងប្រែងដ៏ខ្ពស់បំផុតរបស់យើង ។ យើងអាចផ្ដល់ដល់កូនរបស់យើងនូវការអប់រំ មេរៀន កីឡាអត្តពលកម្ម និងសិល្បៈ និងទ្រព្យសម្បត្តិ ប៉ុន្តែប្រសិនបើយើងមិនផ្ដល់ដល់ពួកគេនូវសេចក្ដីជំនឿលើព្រះគ្រីស្ទនោះទេ នោះគឺយើងបានផ្ដល់តិចតួចណាស់ដល់ពួកគេ » ។

**អែលឌើរ យេរិន ដបុលយូ. ភាសុន នៃពួកចិតសិបនាក់ « សេចក្ដីជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ » *ទស្សនាវដ្ដីលីអាហូណា* និង Ensign ខែ ឧសភា ឆ្នាំ 2009 ទំព័រ 38 ។**



## ការប្រែចិត្ត



**« ការប្រែចិត្ត បញ្ជាក់ថាមនុស្សម្នាក់បែរចេញពីអំពើអាក្រក់ ហើយបែរដួងចិត្ត និង ឆន្ទៈខ្លួន ទៅរកព្រះ »។**

សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ “Repent, Repentance” scriptures.lds.org.

### ពីពួកអ្នកដឹកនាំនៃសាសនាចក្រ

« ប្រែចិត្តនៅថ្ងៃនេះគឺតែងតែប្រសើរជាងប្រែចិត្តនៅថ្ងៃស្អែក ។ . . . « ទោះបី បើយើងត្រូវបានអភ័យទោសឲ្យនៅពេលក្រោយក្ដី ព្រះអម្ចាស់មិនអាចស្ដារឡើងវិញនូវលទ្ធផលល្អឡើយ ការប្រែចិត្ត របស់យើងនៅថ្ងៃនេះប្រហែលជាអាចមានចំពោះអស់អ្នកដែលយើងស្រឡាញ់ និង គួរតែបម្រើ ។ នោះគឺជាការឈឺចាប់យ៉ាងខ្លាំងចំពោះមាតាបិតា ដែលមានកូនតូចៗ ។ កាលនៅវ័យក្មេង នោះមានឱកាសជាច្រើនសម្រាប់ការអប់រំ និង ការលើកស្ទួយខាងវិញ្ញាណដែលនឹងមិនអាចមាននាអនាគតទៀតឡើយ ។ ប៉ុន្តែ ក៏មានរួមទាំងលោកតា ដែលបានអាក់ខានមិនមានឱកាសជាមួយនឹងកូនៗរបស់ខ្លួនដោយការជ្រើសរើសប្រែចិត្ត ថ្ងៃនេះ ជួសជុលដល់ចៅនូវអ្វីមួយ ដែលគ្រាមួយនោះគាត់មិនបានធ្វើចំពោះមាតាបិតារបស់ពួកគេ » ។

**ប្រធាន ហិនរី ប៊ី អាវរីង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ “Do Not Delay” *Liahona* ខែមករា ឆ្នាំ 2000 ទំព័រ 40 ។**





ពីខាងឆ្វេង ៖ រចនារូបភាពដោយក្រេក ដាយមិន ឌូឌីបេល គ្រីស្ទីណា ស្មីធ © IRI THE LORD JESUS CHRIST ដោយដែល ដាស៊ុន © IRI

## ពីជីវិតរបស់ព្រះគ្រីស្ទ

នៅពេលព្រះអង្គសង្គ្រោះ បានបញ្ចប់ថ្ងៃដំបូងនៃការបម្រើរបស់ទ្រង់ចំពោះពួកសាសន៍នីហ្វៃ ទ្រង់បានសម្លឹងទៅមុខរបស់ប្រជាជន ហើយបានឃើថា « ពួកគេស្រក់ទឹកភ្នែក ហើយបានសម្លឹងរកព្រះអង្គយ៉ាងខ្ជាប់ខ្ជួន ហាក់បីដូចជាពួកគេសូមឲ្យទ្រង់នៅជាមួយនឹងគេបន្តិចទៀត » ។ ទ្រង់បានពោរពេញទៅដោយព្រះហឫទ័យអាណិតមេត្តា ហើយមានបន្ទូលថា « តើក្នុងចំណោមអ្នករាល់គ្នា មានអ្នកណាឈឺទេ ? . . . ចូរនាំអ្នកទាំងនោះមកទីនេះចុះ » ។

ហ្វូងមនុស្សទាំងអស់ក៏ដើរឆ្ពោះទៅមុខព្រមគ្នាជាមួយអ្នកឈឺរបស់គេ ហើយទ្រង់បានប្រោសឲ្យជាសះស្បើយគ្រប់ៗគ្នា ។ ហើយពួកគេទាំងអស់—មានបុរស ស្ត្រី និង ក្មេងតូចៗចំនួន 2,500នាក់—បានក្រាបចំពោះព្រះបាទទ្រង់ហើយបានថ្វាយបង្គំទ្រង់ ។

ហើយព្រះអង្គសង្គ្រោះបានបញ្ជាឲ្យគេនាំកូនក្មេងតូចៗមកអង្គុយ ជុំវិញ ព្រះអង្គ ហើយបានបញ្ជា ឲ្យហ្វូងមនុស្សលុតជង្គង់ចុះ ។ ទ្រង់បានលុតជង្គង់ក្នុងចំណោមក្មេងតូចៗ ហើយបានចាប់ផ្ដើមអធិស្ឋាន ។ ហ្វូនមនុស្សបានពោរពេញទៅដោយសេចក្ដីអំណរបន្ទាប់ពីបានឮការអធិស្ឋានរបស់ទ្រង់ ហើយពួកគេបានថ្លែងទីបន្ទាល់បែបនេះ ៖ « ភ្នែកមិនដែលឃើញសោះ ឯត្រចៀកក៏មិនដែលបានឮ រឿងដ៏មហិមានិង អស្ចារ្យ ដូចយើងបានឃើញ ហើយបានឮព្រះយេស៊ូវ ទ្រង់មានព្រះបន្ទូលទៅកាន់ព្រះវរបិតាឡើយ » ។ ( សូមមើលនីហ្វៃទី3 17:1–17 ) ។

### ការអធិស្ឋាន



« ការអធិស្ឋានគឺជាការអនុវត្តដែលដោយសារនោះ ព្រះហឫទ័យរបស់ព្រះវរបិតា និងឆន្ទៈរបស់កូនបាននាំចូលជាធ្លុង តែមួយ ។ គោលបំណងនៃការអធិស្ឋាន គឺមិនត្រូវបានផ្លាស់ប្ដូរព្រះហឫទ័យរបស់ព្រះឡើយ ប៉ុន្តែដើម្បីនឹងទទួលសម្រាប់ខ្លួនយើងនិងសម្រាប់អ្នកដទៃ នូវព្រះពរ ដែលព្រះអម្ចាស់ពិតជាប្រទានឲ្យប៉ុន្តែស្ថិតនៅក្នុងលក្ខខណ្ឌនៃការទូលសុំនូវអ្វីៗទាំងនេះ » ។

Bible Dictionary, “Prayer.”

## ការអភ័យទោស



**« ដើម្បីអភ័យទោសទូទៅមានអត្ថន័យមួយនៃទង្វើរពីរ ៖ (1) នៅពេលព្រះអម្ចាស់អភ័យទោសឲ្យមនុស្ស ទ្រង់លុបចោល ឬទុកទារណ្ឌកម្មតម្រូវសម្រាប់អំពើបានមួយឡែក. ។ . . . (2) ក្នុងពេលមនុស្សអភ័យទោសគ្នាទៅវិញទៅមក ពួកគេប្រព្រឹត្តិនឹងគ្នា ដោយសេចក្តីស្រឡាញ់ដូចជាព្រះគ្រីស្ទដែរ. » ។**

សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ "Forgive," scriptures.lds.org ។

### ពីជីវិតរបស់ព្រះយេស៊ូវ គ្រីស្ទ

ផនផារីស៊ីឈ្មោះ ស៊ីម៉ូន បានទូលសុំព្រះអង្គសង្គ្រោះឲ្យមកសោយអាហារពេលល្ងាច ។ នៅពេលដែលពួកគេកំពុងតែបរិភោគអាហារ មានស្ត្រីម្នាក់ដែលជាអ្នកមានបាប បានចូលមកឈរក្បែរព្រះយេស៊ូវ ហើយទួញយំ ។ នាងបានលត់ជង្គង់ចុះក្បែរព្រះបាទរបស់ព្រះអង្គសង្គ្រោះ ហើយបានលាងសំអាតជាមួយនឹងទឹកភ្នែករបស់នាង ហើយបានយកសក់របស់នាងមកជូតហើយបានចាក់ប្រេងក្រអូបលើ ។ ស៊ីម៉ូនបានឃើញស្ត្រីនេះហើយបានគិតក្នុងចិត្តថា « តើអ្នកនេះជាហោរាមែន នោះនឹងស្គាល់ស្ត្រីដែលពាល់ខ្លួន » ។

ព្រះអង្គសង្គ្រោះបានបែរទៅស៊ីម៉ូន ហើយបានបង្រៀនរឿងប្រៀបប្រដូចមួយដល់គាត់ ៖

« មាន២នាក់ជំពាក់អ្នកចងការម្នាក់អ្នក១ជំពាក់១០០រៀល ហើយ១នាក់ទៀត៥០រៀល

«ដោយព្រោះគេគ្មានអ្វីនឹងសង បានជាគាត់លែងទារពីអ្នកទាំង២ »

រួចហើយព្រះយេស៊ូវ បានសួរស៊ីម៉ូនថា « តើ [ អ្នកជាប់បំណុល ] ណាម្នាក់ដែលស្រឡាញ់ [ អ្នកចងការ ] ច្រើនជាជាង ? » ស៊ីម៉ូនបានឆ្លើយថា ប្រហែលជាអ្នកជាប់បំណុលដែលត្រូវបានអត់ឱនបំណុលច្រើនជាង ។ រួចហើយព្រះយេស៊ូវបានបែរទៅរកស្ត្រីនោះ ហើយមានបន្ទូលទៅស៊ីម៉ូនថា « អ្នកឃើញស្ត្រីនេះឬទេ ? បាបនាងដែលមានច្រើនទាំងម្លេះ បានអត់ទោសឲ្យនាងហើយដ្បិតនាងមានសេចក្តីស្រឡាញ់ជាច្រើន ប៉ុន្តែអ្នកណាដែលគេអត់ទោសឲ្យនោះក៏ស្រឡាញ់តិច » ។ រួចហើយទ្រង់បានសន្យាទៅស្ត្រីនោះថា « បាបនាងបានអត់ទោសឲ្យនាងហើយ ។ . . . សេចក្តីជំនឿរបស់នាងបានសង្គ្រោះនាង ហើយអញ្ជើញនាងទៅឲ្យប្រកបដោយសេចក្តីសុខចុះ » ។ ( សូមមើល លូកា 7:36–50 ។ )

### ចេញពីពួកអ្នកដឹកនាំ

« សូមចាំថាស្ថានសួគ៌ គឺមានពោរពេញ ទៅដោយអស់អ្នកដែលមានលក្ខណៈស្រដៀងគ្នា នេះ ៖ ពួកគេត្រូវអត់ទោសឲ្យ ។ ហើយពួកគេអភ័យទោស »។

**ប្រធានឌៀថើរ អេស្វ អុជដូហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ, « អ្នកមានចិត្ត អាណិតមេត្តា នឹងបានសេចក្តីមេត្តា,» *ទស្សនាវដ្តីលីអាហូណា*នឹង Ensign ខែឧសភា ឆ្នាំ 2012, 77 ។**



ពីខាងឆ្វេង ៖ រចនារូបភាព ដោយស្ទីវ បាន់ឌីសិន, ដាវីឌ វិនធើរ និងម៉ាថាយ រៀ ហាមថតចម្លង ដកស្រង់ពី JESUS WASHING THE FEET OF THE APOSTLES, BY DEL PARSON © IRI



## ដកស្រង់ចេញពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ

នៅពេលល្ងាចមុននឹងការឆ្លងរបស់ទ្រង់ និងនៅប៉ុន្មានម៉ោងមុននឹងការឈឺចាប់ក្នុងសួនច្បារគែតសេម៉ានី ព្រះអម្ចាស់បានធ្វើបុណ្យរំលងចុងក្រោយ ជាមួយពួកសាវករបស់ទ្រង់ ។ នៅពេលអាហារល្ងាចបានចប់រួចហើយ ព្រះយេស៊ូវ « ទ្រង់ជ្រាបថាពេលកំណត់ដែលទ្រង់ត្រូវចេញពីលោកីយនេះទៅឯព្រះវរបិតាវិញបានមកដល់ហើយ ដូច្នេះទ្រង់ក៏ចេះតែស្រឡាញ់ គេដរាបដល់ចុងបំផុត » ។ បន្ទាប់មក ព្រះសង្គ្រោះបានក្រោកឈរពីតុអាហារល្ងាច ហើយបានយកក្រមាមកក្រវាត់អង្គ ។ ទ្រង់បានចាក់ទឹកក្នុងចានក្លាំ ចាប់តាំងលាងជើងពួកសិស្ស ។ កាលទ្រង់បានលាងជើងគេរួចហើយ ទ្រង់បានប្រទានបញ្ញត្តិថ្មីមួយដល់គេ ៖

« ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំស្រឡាញ់អ្នករាល់គ្នាដែរ » . . .

« គេនឹងដឹងថាអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំដោយសារសេចក្ដីនេះឯង » ។ ( សូមមើល យ៉ូហាន 13:1–5, 34–35 ) ។

### សេចក្ដីស្រឡាញ់



**« ជាភក្ដីភាព និងការគាប់ចិត្តជាខ្លាំង ។ . . . ដំរាប់ដ៏ធំបផុត អំពីសេចក្ដីស្រឡាញ់ដែលព្រះមានដល់កូនចៅទ្រង់ គឺមាននៅក្នុងដង្វាយធួនដ៏និរន្តនៃព្រះយេស៊ូវគ្រីស្ទ » ។**

សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « សេចក្ដីស្រឡាញ់ »
scriptures.lds.org

## ពីពួកអ្នកដឹកនាំសាសនាចក្រ

**« សូមរាប់ភាពសក្តិសមទុក ជាការកោតសរសើរយ៉ាងខ្ពស់ »។**

Merriam-Webster's Collegiate Dictionary, 11th ed. (2003), "respect."

« នៅពេលដែលយើងជួបប្រទះ និងឆ្លងកាត់រឿងនូវអ្វីជាច្រើននៅក្នុងជីវិត និងបានឃើញពីភាពផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនៃពិភពលោកនេះ ដែលមិនស្ថិតថេរ នោះអំណរគុណរបស់យើងរីកលូតលាស់ចំពោះឱកាសដែលចូលរួមចំណែកជាមួយអ្វីមួយ ដែលមានអត្ថន័យសម្រាប់យើង—គេហដ្ឋាន និងក្រុមគ្រួសារ ហើយនិងភក្ដីភាពចំពោះមនុស្សជាទីស្រឡាញ់របស់ខ្លួន ។ យើងបានយល់ពីអត្ថន័យនៃចំណងដែលចងភ្ជាប់រួមគ្នាដោយភារកិច្ច ដោយការគោរព ដោយភាពជាម្ចាស់ ។ យើងរៀនថាគ្មានអ្វីដែលអាចមកជំនួស ពរជ័យនៃទំនាក់ទំនងក្នុងជីវិតក្រុមគ្រួសារបានពេញលេញនោះឡើយ » ។ . . .

« បងប្អូនប្រុសទាំងឡាយ សូមប្រព្រឹត្តិជាមួយនឹងភរិយារបស់យើងដោយសេចក្ដីថ្លៃថ្នូរ និងការគោរព ។ ភរិយារបស់យើងគឺជាដៃគូដ៏នៅអស់កល្បជានិច្ចរបស់យើង ។ បងប្អូនស្ត្រីទាំងឡាយ សូមគោរពស្វាមីរបស់អ្នក ។ ស្វាមីរបស់អ្នកត្រូវការស្ដាប់ឮនូវពាក្យសម្ដីផ្អែមល្ហែម ។ ស្វាមីរបស់អ្នកត្រូវការស្នាមញញឹមដ៏រាក់ទាក់ ។ ស្វាមីរបស់អ្នកត្រូវការការបង្ហាញនូវចំណាប់អារម្មណ៍នៃសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដ ។

**ប្រធានថូម៉ាស អេស ម៉នសុន, « សេចក្ដីស្រឡាញ់ ក្នុងផ្ទះ—ដំបូន្មានពីព្យាការីរបស់យើង » ទស្សនាវដ្ដី *លីអាហូណា* ខែសីហា ឆ្នាំ 2011 ទំព័រ 4 ។**

### ការគោរព





## សេចក្ដីមេត្តាករុណា



**« ពិតជាដើម្បីនឹងរង់ទុក្ខជាមួយ' ។ វាក៏មានន័យថា បង្ហាញចិត្តអាណិតអាសូរ និង សេចក្ដីមេត្តាចំពោះអ្នកឯទៀត »។**

សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ "Compassion," scriptures.lds.org។

### ពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ

ព្រះគម្ពីរមាននូវដំណើររឿងជាច្រើន ដែលព្រះសង្គ្រោះបានបង្ហាញនូវសេចក្ដីមេត្តាករុណា ចំពោះជនឯទៀត ។ ដោយមានព្រះទ័យមេត្តាករុណា ទ្រង់បានប្រោសមនុស្សខ្វាក់ពីរនាក់ឲ្យមើលឃើញវិញ ( សូមមើល ម៉ាថាយ 20:30–34 ) ទ្រង់បានប្រោសមនុស្សកើតឃ្លង់ជា ( សូមមើល ម៉ាកុស 1:40–41 ) ហើយបានធ្វើប្រោសឲ្យជាសះស្បើយគ្រប់ៗគ្នាក្នុងចំណោមហ្វូងសាសន៍នីហ្វៃ ( សូមមើល  នីហ្វៃទី 3 17:6–9 ) ។

នៅក្នុងដំណើររឿង ដោយគួរឲ្យចាប់អារម្មណ៍មួយ ព្រះយេស៊ូវបានយាងចូលដល់ កំផែង ក្រុងណាអ៊ីន ជាទីកន្លែងដែលទ្រង់បានឃើញបុណ្យសពរបស់បុរសវ័យក្មេងម្នាក់— « ជាខ្មោចកូនតែមួយដែលម្ដាយនៅមេម៉ាយ » ។ កាលព្រះអង្គសង្គ្រោះបានឃើញមនុស្សជាច្រើនពីក្រុង ដែលនៅជាមួយនឹងស្ត្រីនោះ ហើយបានឃើញទំនួញទុក្ខរបស់នាង ទ្រង់ « មានព្រះហឫទ័យ អាណិតអាសូរដល់នាង » ។ ទ្រង់យាងទៅពាល់ក្តារមឈូសជាកន្លែងផ្ទុកសពរបស់បុរសនោះ ហើយមានបន្ទូលថា « អ្នក កម្លោះអើយ ខ្ញុំបង្គាប់អ្នកថាចូរក្រោកឡើង » ។ ស្រាប់តែ អ្នកកម្លោះនោះបានក្រោកឡើងអង្គុយ ហើយចាប់ផ្ដើមនិយាយ ហើយព្រះអង្គសង្គ្រោះបានប្រគល់គាត់ដល់ម្ដាយវិញ ។ ( សូមមើល លីកា 7:11–15. )



## ការលេងកំសាន្ត



**សកម្មភាពផ្ដល់សុខភាពល្អ និង គុណធម៌ដែលផ្ដល់ជាកម្លាំង និង វិញ្ញាណចំពោះអស់អ្នកដែលចូលរួម ។**

### ចេញពីពួកអ្នកដឹកនាំសាសនាចក្រ

« ក ដូចជាការព្យាបាលដោយស្មោះស្ម័គ្រ ដែលផ្ដល់ដល់ការឈប់សម្រាក នូវភាពផ្អែមល្ហែម ការលេងកំសាន្តគឺជាមិត្ត និង ដៃគូដ៏ខ្ជាប់ខ្ជួននៃការងារដែរ ។ តន្ត្រី អក្សរសាស្ត្រ សិល្បៈ របាំ រឿងល្ខោន អត្តពលកម្ម—ទាំងអស់ អាចផ្ដល់នូវការកំសាន្ត ដើម្បីនឹងចម្រុងចម្រើនជីវិតរបស់នរណាម្នាក់ហើយ ញែកវាទុកបន្ថែមទៀតដែរ ។ ក្នុងពេលជាមួយគ្នានេះដែរ វាពិបាកនឹងនិយាយថា ការកំសាន្តភាគច្រើនសព្វថ្ងៃនេះក៏ជាការកំសាន្តដែលមានទៅដោយការថោកទាប ការអាប់អួរ ការឃោរឃៅ គួរឲ្យធុញទ្រាន់ និង ជាអសារឥតការ ។ ផ្ទុយទៅវិញ ជួនកាលតម្រូវនូវការខំធ្វើការដើម្បីនឹងរកឃើញនូវការកំសាន្តល្អត្រឹមត្រូវ ។ នៅពេលការកំសាន្តបែរចេញពីភាពស្អាតស្អំទៅភាពអបាយមុខ វាក្លាយទៅជាអ្នកបំផ្លាញជីវិតដែលបរិសុទ្ធ » ។

**អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ការសញ្ជឹងគិតទៅលើជីវិតដែលបានញែកចេញ »** ***លីអាហូណា*** **ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 17 ។**





ពីខាងឆ្វេង ៖ រចនារូបថតដោយ ស្ទី បាន់នីស័រ, ដាវីឌ វិនធើរ និងម៉ាថាយ រៀ © IRI / *I WILL BELIEVE* ដោយលីស រេមែរ ស្ទីនដល់ បោះពុម្ពផ្សាយ

## ចេញពីពួកអ្នកដឹកនាំសាសនាចក្រ

« គប្បីបង្រៀនកូនៗឲ្យរីករាយចំពោះការធ្វើការដោយស្មោះត្រង់ គឺជាអំណោយដ៏ធំធេងមួយ ដែលអ្នកអាចផ្ដល់ដល់ពួកគេ ។ ខ្ញុំជឿថាមូលហេតុមួយចំពោះការបាក់បែកគ្នារវាងប្ដីប្រពន្ធសព្វថ្ងៃនេះ គឺជាការបរាជ័យរបស់មាតាបិតាក្នុងការបង្រៀន និងបង្វឹកហាត់កូនប្រុសទាំងឡាយនៅក្នុងទំនួលខុសត្រូវរបស់គេ ដើម្បីនឹងផ្ដល់ និងថែទាំក្រុមគ្រួសាររបស់ពួកគេ ហើយរីករាយនឹងឧបសគ្គដែលទំនួលខុសត្រូវនេះនាំមក ។ យើងរាល់គ្នាជាច្រើនរូបក៏មានកំសោយ នៅក្នុងការបណ្ដុះបង្កើតនៅក្នុងកូនស្រីៗរបស់យើងនូវសេចក្ដីប្រាថ្នា ដើម្បីនឹងនាំមកនូវភាពល្អប្រិមប្រិយ និងរបៀបរៀបរយនៅក្នុងផ្ទះរបស់គេតាមរយៈមេរៀនវិជ្ជាមេផ្ទះ ។ . . .

« [ ឳពុករបស់ខ្ញុំ ] បានផ្ទុកនៅក្នុងខ្ញុំនូវសេចក្ដីអំណរ និង អំណរគុណចំពោះការងារដោយស្មោះត្រង់ ហើយបានរៀបចំខ្ញុំសម្រាប់ពេលវេលានោះនៅក្នុងជីវិតរបស់ខ្ញុំ នៅពេលដែលខ្ញុំនឹងមានទំនួលខុសត្រូវ សម្រាប់ការទំនុកបម្រុងគ្រួសារមួយ ។ គោលការណ៍ទាំងឡាយ ដែលខ្ញុំត្រូវបានបង្រៀនដោយឳពុកយ៉ាងឈ្លាសវៃ របស់ខ្ញុំគឺការធ្វើការដោយស្មោះត្រង់ ពុំខ្ជិលច្រអូស ចេះអប់រំខ្លួន ហើយនៃការសម្រេចការងារយ៉ាងពេញលេញគឺជាគ្រឹះនៃជោគជ័យរបស់ខ្ញុំ » ។ ■

**អែលឌើរ អិល ថម ភែរី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ «The Joy of Honest Labor» *Ensign* ខែ វិច្ឆិកា ឆ្នាំ 1986 ទំព័រ 62, 64 ។**

ធ្វើការ



**« ដើម្បីនឹងបញ្ចេញកម្លាំងកាយ និង ចិត្តជាពិសេសក្នុងការខំប្រឹងប្រែងសម្រាប់ គោលបំណងណាមួយ »។**

Merriam-Webster's Collegiate Dictionary, 11th ed. (2003), "work."

# យើងត្រូវអធិស្ឋាន—ឥឡូវនេះ !

គ្រួសាររបស់យើងកំពុងត្រឡប់មកពីវិស្សមកាលចុងសប្ដាហ៍នៅក្រុង ភីស រីវើរ ខេត្ត អាល់បរតា ប្រទេស កាណាដា ដែលចំណាយពេលធ្វើដំណើរប្រហែលប្រាំម៉ោងទៅប៉ែកខាងជើងនៃផ្ទះរបស់យើងនៅក្នុងទីក្រុង អែតម៉ុនថុន ។ វាបានងងឹតយូរដែរហើយ នៅតំបន់ប៉ែកខាងជើងនោះ ហើយទោះបីជាខ្យល់កំពុងបោកបក់ព្រិលយ៉ាងខ្លាំងកាត់ផ្លូវនៅចំពីមុខយើងក៏ដោយ ក៏អ្វីៗទាំងអស់ហាក់បីដូចជាសុខសាន្ត និង ស្ងប់ស្ងាត់នៅក្នុងឡានរបស់យើង ។

ភ្លាមនោះ ស្រាប់តែមានភ្លើងប្រកាសអាសន្នបានលេចឡើងនៅលើកុងទ័រឡាន ។ ខ្ញុំធ្លាប់បានឃើញភ្លើងនោះតែម្ដងគត់កាលពីច្រើនឆ្នាំកន្លងទៅ ហើយឥឡូវនេះខ្ញុំបារម្ភពីអ្វីដែលនឹងបម្រុងកើតឡើង ។ ខ្ញុំបានប្រញាប់បិទភ្លើងទាំងអស់ដែលមិនសំខាន់ ប៉ុន្តែភ្លាមនោះម៉ាស៊ីនបានរលត់ ។ ខ្ញុំបានដឹងថា យើងបានធ្វើដំណើរអស់បីបួនគីឡូម៉ែត្រ តាំងពីយើងបានបើកកាត់ទីក្រុងចុងក្រោយ ហើយវានៅច្រើនគីឡូម៉ែត្រទៀត ពីមុនយើងទៅដល់ទីក្រុងបន្ទាប់ទៀត ។ ខ្ញុំមិនអាចទាំងចាំបានផង ពីពេលចុងក្រោយដែលយើងបានជួបនឹងរថយន្តមួយ ដែលបើកទៅមកនោះ ។

នៅពេលយើងបានគិតដោយអស់សង្ឃឹមពីជម្រើសរបស់យើង នោះ ខាសាន់ កូនប្រុសរបស់យើងដែលមានអាយុ 11 ឆ្នាំ បាននិយាយថា « យើងត្រូវអធិស្ឋានឥឡូវនេះ ! » មិនដល់បីខែពីមុននេះ ខាសាន់ បានរន្ធត់ចិត្តជាខ្លាំង ដោយសារការបាត់បង់ប្អូនប្រុសរបស់គេដែលបានស្លាប់ដោយសារជំងឺមហារីក ។ តើមានការអធិស្ឋានចំនួនប៉ុន្មានទៅដែល ខាសាន់ បានបញ្ជូនទៅឋានសួគ៌ នៅពេលដែលគេពុះពារដើម្បីយល់ថា ហេតុអ្វីបានជាគេត្រូវបាត់បង់ប្អូនប្រុសតែម្នាក់គត់របស់គេនោះ ?

ភរិយាខ្ញុំ និង ខ្ញុំ មិនប្រាកដថា តើគេយល់បានដល់កម្រិតណានោះទេ ពីការពន្យល់របស់យើង ដែលថាការអធិស្ឋានរបស់យើងត្រូវសមស្របជាមួយនឹងព្រះបំណងរបស់ព្រះវរបិតាសួគ៌ ហើយមិនមែនចាំបាច់អាស្រ័យលើបំណងប្រាថ្នាផ្ទាល់ខ្លួនរបស់យើងឡើយ ។ ប៉ុន្តែ នេះគេបានបង្ហាញយើងថា យើងត្រូវតែងាកទៅរកព្រះវរបិតាសួគ៌ ហើយបន្តមានសេចក្ដីជំនឿលើទ្រង់ ។

មិនយូរប៉ុន្មាន បន្ទាប់ពីយើងបានបញ្ចប់ការអធិស្ឋាននោះភ្លើងហ្វា របស់រថយន្តដែលបើកឆ្ពោះមកយើងបានចាប់ផ្ដើមចាំងឡើងលើកញ្ចក់មើលទៅក្រោយរបស់យើង ។ មិនយូរប៉ុន្មាន ឡានដឹកទំនិញដ៏វែងមួយដែលធ្វើដំណើរទៅកាន់ទីក្រុង អែតម៉ុនថុន បានឈប់នៅពីមុខយើង ។

នៅពេលដែលតែកុងឡាន និង ខ្ញុំបានដើរមកជិតគ្នា នោះគាត់បានសួរខ្ញុំដោយមានតុងសំឡេងជាបារាំង-កាណាដាថា « តើអ្នកមានកូនក្មេងនៅក្នុងឡាននោះទេ ? » នៅពេលខ្ញុំបានប្រាប់គាត់ថា បាទមាន នោះគាត់និយាយថា គាត់បានបើកឡានកាត់រថយន្តដែលឈប់មួយផ្សេងទៀត ដែលនៅប្រហែលបួនប្រាំគីឡូម៉ែត្រពីនេះ ប៉ុន្តែគាត់មិនអាចឈប់ចតបានទេដោយសារតែអាកាសធាតុមិនល្អ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលគាត់បានមកដល់យើង នោះគាត់មានអារម្មណ៍បញ្ជាក់ដ៏ច្បាស់មួយថា យើងមានកូនក្មេងដែលត្រូវការជំនួយពីគាត់ ។ ហេតុដូច្នោះហើយ បានជាគាត់ឈប់ឡាន ។

មិនយូរប៉ុន្មាន គាត់បានស្ទូចរថយន្តរបស់យើងដាក់លើឡានដឹកទំនិញរបស់គាត់ ហើយបានធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុង អែតម៉ុនថុន ។ ពេលយើងធ្វើដំណើរត្រឡប់មកវិញនោះគឺវាត្រជាក់ណាស់ ប៉ុន្តែយើងបានទទួលភាពកក់ក្ដៅតាមរយៈការបញ្ជាក់ដ៏ផ្អែមល្ហែមថា ព្រះវរបិតាសួគ៌ពិតជាឮការអធិស្ឋានទាំងឡាយ ។ ពេលខ្លះចម្លើយបានមកតាមរបៀបដែលយើងនឹកស្មានមិនដល់ ហើយពេលខ្លះចម្លើយមានឥទ្ធិពលយ៉ាងខ្លាំង និង ចំៗជាងដែលយើងគិតស្មានដល់ ។ យើងគ្រាន់តែត្រូវមានសេចក្ដីជំនឿ និង ទុកចិត្តលើព្រះអម្ចាស់ប៉ុណ្ណោះ ។ ■

ជែហ្វ្រី អ័រ. ម៉ាក់ម៉ាហុន ខេត្ត អាល់បើរតា ប្រទេស កាណាដា



មិនយូរប៉ុន្មាន បន្ទាប់ពីយើងបានបញ្ចប់ការអធិស្ឋាននោះភ្លើងហ្វា របស់រថយន្តដែលបើកឆ្ពោះមកយើងបានចាប់ផ្ដើមចាំងឡើងលើកញ្ចក់មើលទៅក្រោយរបស់យើង ។

រចនារូបភាពដោយ យ៉ូសែប អេឡៃម៉ែន

# ខ្ញុំនឹងមិនទៅរាំម្តងទៀតឡើយ

នៅជាយទីក្រុង ឈីកាហ្គោ របស់យើងនៃរដ្ឋអិលលីណោយ ស.រ.អា. មានយុវវ័យនៃពួកបរិសុទ្ធថ្ងៃចុងក្រោយតិចជាង 20 នាក់ រៀននៅវិទ្យាល័យដែលមានសិស្សប្រហែល 4400នាក់ នៅទីតាំងពីរផ្សេងគ្នា ។ យើងមានភាពរីករាយជាមួយនឹងការសិក្សាដែលកូនប្រុសរបស់យើងបានទទួល ហើយមានក្រុមគ្រួសារល្អៗដែលមានបទដ្ឋានខ្ពស់រស់នៅក្នុងតំបន់របស់យើង ។

នៅក្នុងរដូវផ្ការីក ពេលកូនប្រុសយើងរៀននៅថ្នាក់ទី 11 នោះគេត្រូវបានអញ្ជើញឲ្យទៅការរាំនៅសាលារៀន ។ ដៃគូរបស់គេបានស្លៀកពាក់យ៉ាងស្អាត ជាសម្លៀកបំពាក់សមរម្យ ហើយយើងចង់ដឹងខ្លាំងណាស់ពីការទៅរាំរបស់ពួកគេនៅយប់នោះ ។ នៅពេលគាត់មកដល់ផ្ទះវិញ គាត់បាននិយាយថា « ខ្ញុំនឹងមិនទៅរាំនៅសាលារៀនម្តងទៀតឡើយ ! » គាត់បាននិយាយថា សិស្សទាំងឡាយបានចូលរួមក្នុងការរាំដែលស្រើបស្រាល ដែលអ្នកគ្រប់គ្រងមិនបានធ្វើអ្វីសោះ ដើម្បីបញ្ឈប់ពួកគេ ។ ខ្ញុំមានអារម្មណ៍រន្ធត់ ។

ខ្ញុំគឺជានិយោជិតក្រៅម៉ោងរបស់សង្កាត់នៃសាលារៀននេះ ហើយពីថ្ងៃបន្ទាប់ពីការរាំនោះមក ខ្ញុំបានព្យាយាមជួបជាមួយនាយករង ។ គាត់ជាមនុស្សម្នាក់ថ្លៃថ្នូរ ហើយខ្ញុំមានអារម្មណ៍ថា គាត់នឹងស្តាប់ពីកង្វល់របស់ខ្ញុំ ។ គាត់បានប្រាប់ខ្ញុំថា ឲ្យសរសេរសំបុត្រទៅកាន់នាយកវិទ្យាល័យនោះ ។

ខ្ញុំបានគិតពិចារណាដោយការអធិស្ឋានពីអ្វីដែលខ្ញុំត្រូវសរសេរ ហើយបានសម្រេចចិត្តដើម្បីប្រាប់ពួកគេថា ខ្ញុំមានការខកចិត្តជាមួយនឹងការរាំដែលមិនសមរម្យនោះ ហើយគ្មានវិធានការណាមួយដែលត្រូវបានធ្វើឡើង ដើម្បីបញ្ឈប់វាសោះ ។ បទដ្ឋានត្រូវបានលើកកម្ពស់សម្រាប់ការសិក្សា ហេតុអ្វីក៏មិនធ្វើសម្រាប់សកម្មភាពទាំងអស់ផង ?

បួនប្រាំខែកន្លងផុតទៅ ហើយខ្ញុំបានគិតថា សំបុត្ររបស់ខ្ញុំត្រូវបានគេមើលរំលងហើយ ។ ប៉ុន្តែនៅថ្ងៃមួយអំឡុងពេលចុះឈ្មោះចូលរៀនវិញ នាយករងសាលាបានសួរខ្ញុំថា « តើអ្នកជាម្តាយ ដែលបានសរសេរសំបុត្រអំពីការរាំនៅសាលានោះឬ ? »

ខ្ញុំបានតបថា « ចាស៎ ! គឺខ្ញុំនេះហើយ » ។

« ខ្ញុំចង់ប្រាប់អ្នកថា សំបុត្រដែលអ្នកបានសរសេរទៅនោះ បានធ្វើឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ! » គាត់បាននិយាយ ។

ខ្ញុំបានដឹងថា មាននាយកសាលាម្នាក់ពុំបានជឿជាក់ថា ការផ្លាស់ប្តូរត្រូវការធ្វើឡើងនោះទេ រហូតដល់គាត់បានសួរយោបល់ពីសិស្សពីរបីនាក់ ។សិស្សពីរបីនាក់នោះបានឆ្លើយដូចគ្នាថា ៖ « យើងនឹងមិនទៅរាំនៅសាលាម្តងទៀតឡើយ ! ការរាំទាំងនោះ គួរឲ្យខ្ពើមរអើមណាស់ ! »

បន្ទាប់មកអ្នកគ្រប់គ្រងបានអនុវត្តច្បាប់នៃភាពសមរម្យក្នុងការរាំ ដែលនឹងត្រូវចាប់អនុវត្តអំឡុងពេលការរាំលើកក្រោយ ។ នាយកសាលាបានជូនដំណឹងដល់សិស្សទាំងឡាយថា ពួកគេនឹងត្រូវបានស្នើសុំឲ្យចាកចេញ បើសិនពួកគេមិនគោរពតាមច្បាប់នោះ ។

ខ្ញុំបានរង់ចាំយ៉ាងអន្ទះសា ចំពោះការត្រឡប់មកវិញនៃកូនប្រុសរបស់យើង ពីការរាំនោះ ។ នៅពេលគេមកដល់ផ្ទះ គេបាននិយាយថា សិស្សទាំងឡាយដែលព្យាយាមប្រព្រឹត្តអាកប្បកិរិយាចាស់នោះត្រូវបានបណ្តេញចេញ ។ គេបាននិយាយថា វាគឺជាការរាំដ៏ល្អបំផុតដែលគេមិនធ្លាប់បានចូលរួមពីមុនមក ។

ខ្ញុំបានសរសេរសំបុត្រទៅកាន់អ្នកគ្រប់គ្រង ដោយថ្លែងអំណរគុណពួកគេដែលបានធ្វើឲ្យការរាំលើកនេះជាការរាំដ៏ល្អបំផុតនៅសាលា ដែលមិនធ្លាប់មានអស់ពេលជាយូរមកហើយ ។ នាយករងសាលាដែលខ្ញុំបានស្គាល់ បានឆ្លើយតបថា ៖ « សូមអរគុណសម្រាប់ការចាប់ផ្តើមការសន្ទនាកាលពីរដូវផ្ការីកមុន ។ បើគ្មានសំបុត្រមកពីអ្នកទេនោះយើងមិនអាចធ្វើការផ្លាស់ប្តូរបញ្ហានេះបានទេ » ។

តាំងពីនោះមក ខ្ញុំបានឃើញថា មានសាលាជាច្រើននៅក្នុងប្រទេសរបស់យើង បានធ្វើតាមច្បាប់រាំថ្មីទាំងនេះ ដូច្នេះ ឥឡូវនេះកូនសិស្សរាប់ពាន់នាក់នឹងអាចរីករាយជាមួយនឹងការរាំនៅសាលាបាន ។

ខ្ញុំអធិស្ឋានថា ព្រះអម្ចាស់នឹងប្រទានពរដល់យើងទាំងអស់គ្នា ដើម្បីស្វែងរកសេចក្តីក្លាហានក្នុងការនិយាយចេញមក និង តស៊ូមតិចំពោះអ្វីដែលយើងជឿ ។ ខ្ញុំដឹងថា មនុស្សម្នាក់អាចធ្វើឲ្យមានការផ្លាស់ប្តូរបាន ។ ■

វីនឌី វ៉ាន់ នុយ រដ្ឋ អិលលីណោយ ស.រ.អា.




បន្ទាប់ពីអ្នកគ្រប់គ្រងបានអនុវត្តច្បាប់នៃភាពសមរម្យក្នុងការរាំមក នោះខ្ញុំបានរង់ចាំយ៉ាងអន្ទះសាចំពោះការត្រឡប់មកវិញនៃកូនប្រុសរបស់យើង ពីការរាំនោះ ។

# ខ្ញុំបានអធិស្ឋានសម្រាប់អ្នក

កន្លងទៅថ្មីៗនេះ ខ្ញុំបានទៅព្រះវិហាររាងដូចជាយឺតបន្តិច ហើយប្រញាប់ចូលទៅក្នុងសាលាជំនុំអំឡុងពេលចម្រៀងបើក ។ នៅពេលខ្ញុំដើរចូលទៅក្នុងសាលាជំនុំ ខ្ញុំបានឃើញមានមនុស្សច្រើនជាងធម្មតា ។ នៅពេលខ្ញុំបានក្រឡេកមើលភ្ញៀវដ៏ច្រើនដែលនៅជុំវិញ នោះខ្ញុំបានកត់សម្គាល់ចំណុចពីរ ៖ នោះគឺជាកម្មវិធីរបស់ថ្នាក់បឋមសិក្សារបស់វួដយើង ហើយកៅអីដែលខ្ញុំអង្គុយរាល់ដងនោះមានគេអង្គុយហើយ ។

ខ្ញុំបានប្រញាប់អង្គុយចុះនៅកៅអីជួរមុខដែលមានមនុស្សអង្គុយពេញ គឺនៅចំពេលដែលខ្ញុំបានឃើញម្ដាយវ័យក្មេងម្នាក់បានមកដល់ ដោយកាន់ដៃកូនប្រុសអាយុពីរឆ្នាំ និង បីកូនស្រីអាយុប្រាំមួយខែរបស់គាត់ ។ ខ្ញុំបានសម្គាល់ឃើញថា ស្វាមីរបស់គាត់មិនបានចូលមកតាមជាមួយគាត់ទេ ។ នៅពេលខ្ញុំក្រឡេកមើលជុំវិញសាលាជំនុំ នោះខ្ញុំបានឃើញស្វាមីរបស់គាត់នៅលើវេទិកាអង្គុយនៅកន្លែងព្យាណូ—គាត់គឺជាអ្នកលេងព្យាណូសម្រាប់ថ្នាក់បឋមសិក្សា ។

ពេញមួយការប្រជុំនោះ ខ្ញុំរីករាយដែលបានជួយមើលក្មេងប្រុសនោះ និង ស្តាប់ក្មេងៗថ្នាក់បឋមសិក្សា ។

ដោយសារខ្ញុំនៅលីវ នោះខ្ញុំតែងតែអង្គុយជាមួយមិត្តភក្ដិជិតស្និទ្ធខ្ញុំម្នាក់ ។ ប៉ុន្តែនៅថ្ងៃនោះ មិត្តភក្ដិរបស់ខ្ញុំបានចេញទៅទីក្រុងផ្សេង ។ ខ្ញុំគិតថា វាប្រហែលជាការណ៍មួយល្អ ដើម្បីអង្គុយជាមួយម្ដាយវ័យក្មេង និង កូនៗរបស់គាត់វិញ ដូច្នេះខ្ញុំបានសួរគាត់ ថាខ្ញុំអាចអង្គុយជាមួយពួកគេបានទេ ។ អ្នកម្ដាយនោះ បានយល់ព្រម ។ ពេញមួយការប្រជុំនោះ ខ្ញុំរីករាយដែលបានជួយមើលក្មេងប្រុសនោះ និង ស្តាប់ក្មេងៗថ្នាក់បឋមសិក្សា ។

នៅពេលចប់ពិធីសាក្រាម៉ង់ ម្ដាយម្នាក់នោះបានឱនមករកខ្ញុំ ហើយនិយាយថា គាត់បានអធិស្ឋានសម្រាប់ខ្ញុំនៅពេលព្រឹកនោះ ។ ខ្ញុំបានចាំស្តាប់គាត់រៀបរាប់ប្រាប់ខ្ញុំ ។ គាត់បាននិយាយថា គាត់បានអធិស្ឋានថា ខ្ញុំនឹងមកព្រះវិហារ ហើយថាខ្ញុំនឹងអង្គុយជាមួយគាត់ ហើយជួយគាត់ ។ គាត់បានគិតថា គាត់មិនអាចមើលកូនៗតែម្នាក់ឯងរហូតដល់ចប់សាក្រាម៉ង់បានទេ ។ ខ្ញុំមានអារម្មណ៍ភាំងថា ខ្ញុំបានឆ្លើយតបចំពោះការអធិស្ឋានដ៏សាមញ្ញរបស់គាត់ដែលគាត់បានអធិស្ឋានសុំនៅព្រឹកនោះ ។

ខ្ញុំដឹងថា ព្រះអម្ចាស់ស្រឡាញ់យើងយ៉ាងជ្រាលជ្រៅច្រើនជាងដែលយើងអាចដឹងបានទៅទៀត ។ ការធ្វើជាសាក្សីដល់ចម្លើយចំពោះការស្នើសុំដ៏សាមញ្ញនេះ បានបង្រៀនខ្ញុំនូវមេរៀនដ៏មានអំណាចមួយ ហើយខ្ញុំប្រាកដថា បទពិសោធន៍នេះក៏បានបង្រៀនដល់ម្ដាយរូបនេះផងដែរ ។ នៅពេលដែលខ្ញុំសុំអង្គុយនៅក្បែរបងស្រីរូបនេះ នោះខ្ញុំមិនបានគិតថា វាជាចម្លើយចំពោះការអធិស្ឋានឡើយ—ខ្ញុំគ្រាន់តែបានធ្វើអ្វី ដែលខ្ញុំចង់ឲ្យនរណាម្នាក់ធ្វើសម្រាប់ខ្ញុំតែប៉ុណ្ណោះ បើសិនជាខ្ញុំនៅក្នុងស្ថានភាពដូចគាត់ ។

ពិតណាស់ ព្រះវរបិតាសួគ៌ស្តាប់ឮ និង ឆ្លើយតបចំពោះការអធិស្ឋានរបស់យើង សូម្បីតែហាក់ដូចជាកិច្ចការដ៏តូចតាចក៏ដោយ ។ ■

អាមី វ៉ាណាក់ ចនសុន រដ្ឋ អៃដាហូ
ស.រ.អា.



# អ្នកបានដកភាពសោកសៅរបស់ខ្ញុំចេញ

មានពេលខ្លះ ខ្ញុំសកម្មក្នុងការធ្វើកិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ។ ទោះយ៉ាងណាកាលដែលខ្ញុំបានរីវឌ្ឍទៅមុខក្នុងការស្រាវជ្រាវកិច្ចការនោះ ខ្ញុំបានដឹងថា ខ្ញុំមានឧបសគ្គក្នុងការស្វែងរកព័ត៌មានរបស់មនុស្សម្នាក់—គឺជីតាខាងម្ដាយខ្ញុំ ។

ឪពុករបស់ម្ដាយខ្ញុំមិនបានចិញ្ចឹមម្ដាយខ្ញុំទេ ហើយម្ដាយខ្ញុំបានបាត់ទំនាក់ទំនងជាមួយជីតាខ្ញុំ បងប្អូនបង្កើតគាត់ និង សាច់ញាតិខាងឪពុកគាត់ទាំងអស់ ។ ម្ដាយខ្ញុំគ្មានព័ត៌មានអ្វីដែលបញ្ជាក់ពីថ្ងៃខែឆ្នាំកំណើត ឬ ទីកន្លែងកំណើតរបស់ជីតាខ្ញុំទេ ហើយម្ដាយខ្ញុំមិនដឹងប្រាកដថាជីតាខ្ញុំស្លាប់នៅទីណា ឬ ពេលណានោះទេ ។ ខ្ញុំមានការសង្ស័យ ថាតើខ្ញុំអាចនឹងរកព័ត៌មានសំខាន់ៗនោះឃើញទេ ។

នៅថ្ងៃមួយ នៅពេលខ្ញុំកំពុងមើលសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ម្ដាយខ្ញុំ នោះខ្ញុំឃើញរូបថតមួយសន្លឹករបស់ជីតាខ្ញុំ ។ នៅពេលខ្ញុំបើកវាមើល នោះខ្ញុំបានឃើញថា គាត់បានចុះហត្ថលេខា និង ចុះកាលបរិច្ឆេទនៃរូបថត ហើយប្រាប់ពីអាយុរបស់គាត់នៅពេលនោះ ។ ឥឡូវនេះ ខ្ញុំមានថ្ងៃខែឆ្នាំកំណើតប្រហាក់ប្រហែលរបស់គាត់ហើយ ! ខ្ញុំបានស្រាវជ្រាវដោយក្ដីរំភើប រកឈ្មោះ និង ថ្ងៃខែឆ្នាំកំណើតរបស់គាត់នៅក្នុង FamilySearch ។ ខ្ញុំមានការអស្ចារ្យយ៉ាងខ្លាំងដោយខ្ញុំបានឃើញថា ពិធីបរិសុទ្ធរបស់គាត់ត្រូវបានធ្វើរួចរាល់អស់ហើយ ។ តើនរណាទៅ ដែលបានធ្វើកិច្ចការព្រះវិហារបរិសុទ្ធឲ្យជីតារបស់ខ្ញុំនោះ ?

ភ្លាមនោះ ខ្ញុំបានឃើញថា កិច្ចការនោះត្រូវបានធ្វើឡើងដោយឪពុកមាម្នាក់ខាងម្ដាយខ្ញុំ ដែលបាត់ដំណឹងពីគាត់យូរមកហើយ ។ ខ្ញុំបានស្វែងរកព័ត៌មានទំនាក់ទំនងរបស់គាត់ ហើយនៅទីបំផុតខ្ញុំបានរកឃើញលេខទូរស័ព្ទគាត់ ។

ខ្ញុំបានមានការភ័យបារម្ភក្នុងការទូរស័ព្ទទៅគាត់ ដោយសារគាត់ធ្លាប់បានជួបខ្ញុំកាលពី30 មុនមកម្ល៉េះ---គឺកាលខ្ញុំអាយុបានមួយឆ្នាំ ។ ខ្ញុំមិនដឹងថា គាត់នឹងមានប្រតិកម្មបែបណានោះទេ ។

តែទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំបានសម្រេចចិត្តទូរស័ព្ទទៅគាត់ ។ នៅពេលគាត់លើកទូរស័ព្ទ ខ្ញុំបានពន្យល់គាត់ពីរបៀបដែលខ្ញុំបានរកព័ត៌មានអំពីជីតាខ្ញុំ—គឺជាឪពុករបស់គាត់នោះឯង—ហើយបានប្រាប់គាត់ថា ខ្ញុំគឺជាក្មួយស្រីរបស់គាត់ ។

ខ្ញុំនឹងតែងតែចាំពីចម្លើយរបស់គាត់ថា « ក្មួយមិនអាចដឹងពីភាពសោកសៅ ដែលពូមានអំពីការបាត់ទំនាក់ទំនងជាមួយម្ដាយក្មួយឡើយ ។ ឥឡូវនេះ ក្មួយបានដកភាពសោកសៅនោះចេញពីពូហើយ ! »

ទោះបីជាយើងបានព្រាត់ប្រាសគ្នា ក៏យើងបានដឹងថា គ្រួសាររបស់គាត់ និង គ្រួសារខ្ញុំ បានជ្រមុជទឹក ហើយបានបញ្ជាក់ជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅពេលប្រហាក់ប្រហែលគ្នានោះ ហើយគ្រួសារយើងទាំងពីររឹងមាំនៅក្នុងដំណឹងល្អ ។ វាពិតជាឱកាសមួយដ៏ពោរពេញដោយក្ដីអំណរ និង ភាពក្ដុកក្ដួលសម្រាប់ពួកយើង ។

ខ្ញុំបានយល់ដឹងជាយូរមកហើយថា កិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធអាចភ្ជាប់ពួកយើងទៅនឹងបុព្វការីជនរបស់យើងដែលបានស្លាប់ទៅហើយ ប៉ុន្តែខ្ញុំមិនធ្លាប់គិតថា កិច្ចការនេះអាចភ្ជាប់ពួកយើងទៅនឹងសាច់ញាតិដែលនៅរស់របស់យើងផងដែរនោះទេ ។ ខ្ញុំមានអំណរគុណដែលខ្ញុំអាចជួយឲ្យគ្រួសារយើងជួបជុំគ្នាវិញតាមរយៈពង្សប្រវត្តិ—មិនត្រឹមតែនៅពិភពវិញ្ញាណប៉ុណ្ណោះទេ ប៉ុន្តែនៅអំឡុងពេលជីវិតនៅលើផែនដីរបស់យើងផងដែរ ។ ■

ឃីស៊ី រីឃ្វែម រ៉ូចាស ប្រទេស ឈីលី



នៅថ្ងៃមួយ នៅពេលខ្ញុំកំពុងមើលសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ម្ដាយខ្ញុំ នោះខ្ញុំឃើញរូបថតមួយសន្លឹករបស់ជីតាខ្ញុំ ។



ដោយ អែលឌើរ
ខេវីន ដបុលយូ. ភើសុន
នៃពួកចិតសិបនាក់

# ធ្វើឲ្យ ការអធិស្ឋានផ្ទាល់ខ្លួន របស់អ្នកកាន់តែប្រសើរឡើង

*តើការស្ដាប់ការអធិស្ឋានផ្ទាល់ខ្លួនរបស់អ្នក បង្ហាញអ្វីខ្លះពីអ្នក និង ទំនាក់ទំនងរបស់អ្នកជាមួយព្រះវរបិតាសួគ៌ ?*

ការអញ្ជើញដ៏ទេវភាពដើម្បីអធិស្ឋានទៅកាន់ព្រះវរបិតា នៅក្នុងព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាបញ្ញត្តិដែលបានលើកឡើងច្រើនបំផុតតែមួយគត់ នៅក្នុងព្រះគម្ពីរទាំងអស់ដែលបានកត់ត្រាទុក ហើយគឺជាទម្រង់ដែលជាមូលដ្ឋានគ្រឹះសំខាន់បំផុតនៃការថ្វាយបង្គំផ្ទាល់ខ្លួន ។ ប៉ុន្តែមានពួកយើងច្រើន ដែលមានបញ្ហាក្នុងការព្យាយាម ធ្វើឲ្យការអធិស្ឋានផ្ទាល់ខ្លួនមានអត្ថន័យ និង បង្ហាញឲ្យគេដឹង ។

ខ្ញុំត្រូវបានធ្វើឲ្យជឿថា ការអធិស្ឋានផ្ទាល់ខ្លួន គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គដ៏ធំបំផុតទាំងឡាយ ដែលប្រឈមចំពោះមុខសមាជិកទាំងឡាយនៃសាសនាចក្រ ជាពិសេសយុវវ័យ និង មជ្ឈិមវ័យនៅលីវ ។ ហើយដោយសារតែពួកគេមានបញ្ហាជាមួយការអធិស្ឋាននោះពួកគេក៏មានបញ្ហាខាងវិញ្ញាណដែរ ។

ការអធិស្ឋានផ្ទាល់ខ្លួនរបស់យើង គឺជាប្រដាប់វាស់ស្ទង់កម្លាំងខាងវិញ្ញាណរបស់យើង និង ជាកត្តាជម្រុញនៃសុខុមាលភាពខាងវិញ្ញាណរបស់យើង ។ ក្នុងនាមជាឪពុក ជាអ្នកដឹកនាំបព្វជិតភាព និង ជាប្រធានបេសកកម្មម្នាក់ ខ្ញុំបានរៀនថា ការស្ដាប់ដោយយកចិត្តទុកដាក់ចំពោះការអធិស្ឋានរបស់មនុស្សម្នាក់ទៀត អាចបង្ហាញអ្វីៗជាច្រើន ពីទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះ ។

តើការស្ដាប់ការអធិស្ឋានផ្ទាល់ខ្លួនរបស់អ្នក បង្ហាញអ្វីខ្លះពីអ្នក និង ទំនាក់ទំនងរបស់អ្នកជាមួយព្រះវរបិតាសួគ៌ ?



រូបថតដោយ ខ្រេស ឌីលសាន់



*ការអធិស្ឋានគឺជាកស្តុតាងដ៏មានអំណាច និង មានកម្លាំងនៃភាពពិតរបស់ព្រះ ជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ។ ការអធិស្ឋានផ្ទាល់ខ្លួន គឺជាការចាំបាច់ដោយខានមិនបាន ចំពោះការយល់ដឹងពីព្រះ និង ពីអត្តសញ្ញាណដ៏ទេវភាពរបស់យើង ។*

**គោលការណ៍នៃការអធិស្ឋានផ្ទាល់ខ្លួន**

ការអធិស្ឋាន គឺជាការនិយាយជាមួយព្រះ ជាព្រះវរបិតាអស់កល្បជានិច្ចនៃវិញ្ញាណរបស់យើង—មិនមែននិយាយដាក់ទ្រង់ទេ ប៉ុន្តែគឺនិយាយជាមួយនឹងទ្រង់ ។ ទ្រង់ស្រឡាញ់យើងគ្រប់គ្នាឥតចន្លោះ ហើយទ្រង់ពេញដោយក្តីមេត្តាករុណា និង ការយល់ចិត្ត ។ ទ្រង់ដឹងអ្វីៗគ្រប់យ៉ាងអំពីយើង ។ ទ្រង់ដឹងពីអ្វីដែលយើងត្រូវការ សូម្បីតែនៅពេលដែលយើងអាចមើលឃើញត្រឹមតែអ្វី ដែលយើងចង់បានក៏ដោយ ។ ទ្រង់មានអំណាច និង សមត្ថភាពដែលគ្មានដែនកំណត់ ដើម្បីគាំទ្រ និង ដឹកនាំយើង ។ ទ្រង់តែងតែមានព្រះបំណង ដើម្បីអភ័យទោសឲ្យយើង ហើយជួយយើងគ្រប់កិច្ចការទាំងអស់ ។

យើងអាចនិយាយជាមួយព្រះវរបិតាសួគ៌ដោយឮៗ ឬ ដោយការបង្កើតគំនិត និង ការសម្តែងឡើងនៅក្នុងគំនិត និង ដួងចិត្តរបស់យើង ។ ការអធិស្ឋានផ្ទាល់ខ្លួន គួរតែជាការបង្ហាញនូវអារម្មណ៍ដ៏ហ្មត់ចត់ ដ៏ពិសិដ្ឋ ពីការសរសើរតម្កើង និង ពីការដឹងគុណ ជាការស្នើសុំដោយស្មោះអស់ពីចិត្តសម្រាប់សេចក្តីត្រូវការ និង បំណងប្រាថ្នាជាក់លាក់ ជាការសារភាពដោយបន្ទាបខ្លួន ដោយទន់ទាប និង ជាការស្នើសុំសម្រាប់ការអភ័យទោសដ៏ជ្រះស្អាត ជាការទូលអង្វរសុំការលួងលោម ការណែនាំ និង វិវរណៈ ។ ជាញឹកញាប់ ការបង្ហាញអារម្មណ៍ទាំងនេះ អាចបណ្តាលឲ្យយើងចែកចាយអារម្មណ៍ និង គំនិតអស់ពីក្នុងដួងចិត្ត និង ព្រលឹងយើងដល់ព្រះវរបិតាសួគ៌ដ៏ជាទីស្រឡាញ់របស់យើង ។

ជាញឹកញាប់ ការអធិស្ឋានគឺជាការទាក់ទងខ្លីៗ ប៉ុន្តែវាក៏អាចជាការសន្ទនាដ៏បើកចំហ និង ជាការសន្ទនាដែលបន្តឥតដាច់ ទាំងថ្ងៃ និង យប់ ( សូមមើល អាលម៉ា 34:27 ) ។

**ការអធិស្ឋានផ្ទាល់ខ្លួនគឺចាំបាច់ណាស់**

នៅក្នុងផែនការដ៏ទេវភាពរបស់ព្រះវរបិតាសួគ៌របស់យើង ការបែកចេញនៃរូបកាយ និង វិញ្ញាណពីវត្តមានរបស់ទ្រង់គឺចាំបាច់ ។ ការអធិស្ឋានគឺចាំបាច់ណាស់ ហើយអាចភ្ជាប់ចំណងខាងវិញ្ញាណរវាងព្រះ និង មនុស្ស ។ បើគ្មានការអធិស្ឋានទេ នោះគ្មានរបៀបណាដែលអាចត្រឡប់ទៅព្រះវរបិតាវិញឡើយ ។ បើគ្មានការអធិស្ឋានទេ នោះសេចក្តីជំនឿគ្រប់គ្រាន់ ដើម្បីយល់ដឹង និង រក្សាបទបញ្ញត្តិទាំងឡាយ នោះគឺមិនអាចធ្វើបានឡើយ ។ បើគ្មានការអធិស្ឋានទេ នោះអំណាចខាងវិញ្ញាណដ៏ចាំបាច់ ដើម្បីចៀសវាងពីការល្បួង និង យកឈ្នះលើឧបសគ្គ និង ទុក្ខលំបាកទាំងឡាយ នឹងមិនអាចកើតមានឡើយ ។ បើគ្មានការអធិស្ឋានទេ នោះការប្រែចិត្ត ការអភ័យទោស និង អំណាចដែលជម្រះឲ្យស្អាតនៃដង្វាយធួន មិនអាចសម្រេចបានឡើយ ។ ជាមួយនឹងអំណាចនៃការអធិស្ឋានផ្ទាល់ខ្លួន នោះកិច្ចការគ្រប់យ៉ាងនឹងអាចធ្វើទៅបាន ។

ការអធិស្ឋានធ្វើឲ្យមានវិវរណៈផ្ទាល់ខ្លួន និង អំណោយទានទាំងឡាយខាងវិញ្ញាណ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ វាគឺជាបណ្តាញទាក់ទងខាងវិញ្ញាណ ដែលអាចមានចំពោះកូនចៅទាំងអស់របស់ព្រះ ដែលផ្តល់ដល់យើងនូវច្រកចូលទៅកាន់ព្រះវរបិតាដ៏នៅអស់កល្បជានិច្ចរបស់យើង ទៅកាន់ព្រះរាជបុត្រារបស់ទ្រង់ និង ព្រះវិញ្ញាណបរិសុទ្ធ ។ ការអធិស្ឋានគឺជាកស្តុតាងដ៏មានអំណាច និង មានកម្លាំងនៃភាពពិតរបស់ព្រះ ជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ។ ការអធិស្ឋានផ្ទាល់ខ្លួន គឺជាការចាំបាច់ដោយខានមិនបាន ដើម្បីយល់ដឹងពីព្រះ និង ពីអត្តសញ្ញាណដ៏ទេវភាពរបស់យើង ។

**ធ្វើឲ្យការអធិស្ឋានរបស់អ្នកកាន់តែប្រសើរឡើង**

***រៀបចំដើម្បីអធិស្ឋាន***

ជាញឹកញាប់ ការអធិស្ឋានផ្ទាល់ខ្លួនរបស់យើង ធ្វើឡើងមុនគេនៅពេលព្រឹកមុនពេលយើងភ្ញាក់ស្វាងមែនទែននោះ និង ដឹងខ្លួនពេញលេញ ឬ នៅយប់ជ្រៅ នៅពេលដែលយើងនឿយហត់ពេកណាស់ទៅហើយ ដើម្បីអធិស្ឋានឲ្យមានប្រសិទ្ធភាព ។ ការហត់នឿយខាងរូបកាយ ខាងសតិស្មារតី និង ខាងអារម្មណ៍របស់យើង អាចរារាំងយើងពីការអធិស្ឋានដ៏មានអត្ថន័យ ។

ការអធិស្ឋានគឺជាកិច្ចការខាងវិញ្ញាណ ដែលអ្វីដែលត្រូវធ្វើឡើងជាមុន គឺការរៀបចំខាងសតិស្មារតី និង ខាងវិញ្ញាណ ។ បើយើងមិនឆ្លៀតពេល ដើម្បីបន្ទាបខ្លួនយើង ហើយពិចារណាដោយយកចិត្តទុកដាក់ថា យើងបម្រុងនឹងអំពាវនាវទៅកាន់ព្រះ ជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងខកខានក្នុងការយល់ពីខ្លឹមសារដ៏សំខាន់បំផុតនៃគុំដ៏ទេវភាព ដែលត្រូវបានស្ថាបនាឡើងដើម្បីប្រទានពរជ័យដល់យើងហើយ ។

សូមដាក់កាលវិភាគពេលវេលាគ្រប់គ្រាន់ ដើម្បីទំនាក់ទំនងយ៉ាងយកចិត្តទុកដាក់ និង ដោយបន្ទាបខ្លួន ពីបំណងប្រាថ្នាដ៏ជ្រាលជ្រៅបំផុតនៃដួងចិត្តរបស់អ្នកជាមួយព្រះវរបិតាសួគ៌ ។ អញ្ជើញព្រះវិញ្ញាណបរិសុទ្ធដើម្បីជួយអ្នកឲ្យដឹងពីអ្វីដែលត្រូវអធិស្ឋាន ។ ការអធិស្ឋានឮៗ ជួយខ្ញុំឲ្យផ្តោតលើ

ការអធិស្ឋានរបស់ខ្ញុំ និង ស្តាប់ដល់ខ្លួនឯង ដោយមិនឲ្យសតិខ្ញុំអណ្តែតអណ្តូងឡើយ ។

សូមឲ្យខ្ញុំផ្តល់យោបល់ពីការរកពេល និង ទីតាំងមួយ ដែលអ្នកអាចពិចារណាយ៉ាងយកចិត្តទុកដាក់អំពីជីវិតអ្នក និង សេចក្តីត្រូវការរបស់អ្នក ។ សូមគិតពីអត្តសញ្ញាណដ៏ទេវភាពរបស់អ្នក និង ទំនាក់ទំនងទៅកាន់ព្រះ ។ សូមព្យាយាមស្រមៃពីព្រះវរបិតាសួគ៌នៅពេលអ្នករៀបចំនិយាយជាមួយទ្រង់ ។ សូមគិតពីព្រះអង្គសង្គ្រោះ ជាអង្គដែលអ្នកនឹងត្រូវអធិស្ឋាននៅក្នុងព្រះនាមទ្រង់ ។ការធ្វើបែបនោះ នឹងជួយអ្នកឲ្យផ្តោតការយកចិត្តទុកដាក់ និង រៀបចំដើម្បីអធិស្ឋាន ដោយដួងចិត្តរាបទាប និង អំណរគុណ ។

***រស់នៅដោយភាពសក្តិសម***

យើងមិនអាចមានទំនុកចិត្តនៅក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌បានឡើយ បើសិនយើងគ្មានភាពស្អាតស្អំខាងសីលធម៌នោះ ។ រូបអាសគ្រាម ការរំលងភាពបរិសុទ្ធខាងផ្លូវភេទ និង ការកម្សាន្តគ្រប់រូបភាពដែលចំអកដល់គុណធម៌ ឬ ជំរុញឲ្យមានភាពអសីលធម៌ អាចបំផ្លាញទំនុកចិត្តរបស់យើងក្នុងការអធិស្ឋាន និង រារាំងយើងពីការទទួលការបំផុសគំនិតខាងវិញ្ញាណ ។ ទោះបីជាយ៉ាងណា សូមចងចាំថា គឺមានតែសាតាំងម្នាក់គត់ដែលប្រាប់អ្នកថា អ្នកមិនអាច ឬ មិនគួរអធិស្ឋានឡើយ ។ ព្រះវិញ្ញាណបរិសុទ្ធតែងតែលើកទឹកចិត្តយើងឲ្យអធិស្ឋានជានិច្ច ទោះជាយើងមានបញ្ហាលំបាកជាមួយការគោរពតាម និង ភាពសក្តិសមផ្ទាល់ខ្លួនក៏ដោយ ។

***អធិស្ឋានដោយមានគោលបំណង***

ការអធិស្ឋានគឺចាំបាច់ចំពោះដំណើរការនៃវិវរណៈ ។ សំណួរដ៏បំផុសគំនិត នាំឲ្យមានការផ្តោតយកចិត្តទុកដាក់មានគោលបំណង និង មានអត្ថន័យដែលកាន់តែអស្ចារ្យចំពោះការអធិស្ឋានរបស់យើង ។ បើសិនអ្នកចង់ទទួលបានវិវរណៈផ្ទាល់ខ្លួនកាន់តែច្រើនតាមរយៈការអធិស្ឋានរបស់អ្នក នោះអ្នកអាចចង់គិតអំពីសំណួរអ្វីខ្លះដែលអ្នកកំពុងសួរ ។ ជាទូទៅ វិវរណៈមកជាការឆ្លើយតបទៅនឹងសំណួរមួយ ។ ដំណើរការនៃវិវរណៈ តម្រូវឲ្យយើងស្វែងយល់ព្រះគម្ពីរ ពិចារណាអំពីព្រះគម្ពីរ និង អនុវត្តព្រះគម្ពីរទៅនឹងជីវិតរបស់យើង ។ នៅពេលយើងធ្វើបែបនេះ ព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យបង្កើតនូវសំណួរដ៏បំផុសគំនិត ។

***សម្របឆន្ទៈរបស់អ្នក ជាមួយនឹងឆន្ទៈរបស់ព្រះវរបិតា***

ព្រះអង្គសង្គ្រោះបានបញ្ជាម្តងហើយម្តងទៀតដល់យើងថា « ត្រូវអធិស្ឋានដល់ព្រះវរបិតា ដោយនូវនាមនៃ [ ព្រះអម្ចាស់ ] ជានិច្ច » ( នីហ្វៃទី 3 18:19 ) ។ នៅពេលយើងអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ មានន័យថា « គំនិតរបស់យើងគឺជាគំនិតរបស់ព្រះគ្រីស្ទ ហើយបំណងប្រាថ្នារបស់យើងគឺជាបំណងប្រាថ្នារបស់ព្រះគ្រីស្ទ ។ . . . បន្ទាប់មកយើងសុំសម្រាប់អ្វីៗដែលព្រះអាចប្រទានដល់យើងបាន ។ មានការអធិស្ឋានជាច្រើននៅតែមិនទាន់បានទទួលចម្លើយ ដោយសារការអធិស្ឋានទាំងនោះមិនក្នុងព្រះនាមរបស់ព្រះគ្រីស្ទទាល់តែសោះ ការអធិស្ឋាននោះមិនបានតំណាងឲ្យគំនិតរបស់ទ្រង់ តែផ្តោតលើគំនិតអាត្មានិយមនៃដួងចិត្តមនុស្ស » (Bible Dictionary, “Prayer”) ។ ការអធិស្ឋានដែលធ្វើតាមគំរូនេះ តំណាងឲ្យក្តីសង្ឃឹមដែលឥតប្រយោជន៍ មិនមែនសេចក្តីជំនឿទេ ។

ការអធិស្ឋាន មិនមែនជាដំណើរការនៃការចរចារគ្នានោះទេ ។ ការអធិស្ឋាន គឺជាដំណើរការនៃការសម្របសម្រួលមួយ ។ យើងមិនបង្វិលព្រះឲ្យមកក្នុងទស្សនៈរបស់យើងឡើយ ។ ការអធិស្ឋាន គឺមិនសូវជាទាក់ទងទៅនឹងការផ្លាស់ប្តូរកាលៈទេសៈរបស់យើងនោះទេ តែអំពីការផ្លាស់ប្តូរយើងច្រើនជាង ។ ការអធិស្ឋានគឺការស្វែងរកឲ្យឃើញពីឆន្ទៈរបស់ទ្រង់ និង សុំជំនួយពីទ្រង់ ដើម្បីធ្វើអ្វីដែលយើងត្រូវការធ្វើ ។ នៅពេលយើងសម្របឆន្ទៈរបស់យើងជាមួយនឹងឆន្ទៈព្រះវរបិតាសួគ៌ា នោះចម្លើយ និង កម្លាំងខាងវិញ្ញាណនឹងហូរចូលមកកាន់តែងាយស្រួល ។ ការធ្វើតាមគំរូនេះ ធ្វើឲ្យយើងអធិស្ឋានដោយសេចក្តីជំនឿ ។

**តើព្រះវរបិតាសួគ៌ឮការអធិស្ឋានរបស់ខ្ញុំទេ ?**

ជិត 20 ឆ្នាំកន្លងទៅ កូនប្រុសទីប្រាំរបស់យើងឈ្មោះ បេនយ៉ាមីន បានកើតមក ។ ភរិយារបស់ខ្ញុំបានទទួលអារម្មណ៍ថា ភ្នែកទាំងគូរបស់ បេនយ៉ាមីន មិនប្រក្រតីទេ ។ យើងបានពិភាក្សាជាមួយមិត្តជិតស្និទ្ធម្នាក់ ដែលជាគ្រូពេទ្យឯកទេសខាងជំងឺភ្នែកនៅក្នុងវួដរបស់យើង ដែលបានបញ្ជាក់ពីកង្វល់របស់យើង និង ធ្វើរោគវិនិច្ឆ័យពីស្ថានភាពរបស់បេនយ៉ាមីន ថាមានដុះដុំសាច់ក្នុងភ្នែកដែលជាទម្រង់មហារីកភ្នែកមួយដែលកម្រកើតមាន ។ ដំណឹងនេះ គឺពិតជារន្ធត់ណាស់ ។

*ការអធិស្ឋានគឺ មិនសូវជាទាក់ទងទៅនឹងការផ្លាស់ប្តូរកាលៈទេសៈរបស់យើងនោះទេ តែអំពីការផ្លាស់ប្តូរយើងច្រើនជាង ។ វាគឺការស្វែងរកឲ្យឃើញពីឆន្ទៈរបស់ទ្រង់ និង សុំជំនួយពីទ្រង់ ដើម្បីធ្វើអ្វីដែលយើងត្រូវការធ្វើ ។*





ពីរបីសប្ដាហ៍ក្រោយមក បេនយ៉ាមីន ត្រូវបានទទួលការវះកាត់លើកដំបូងក្នុងចំណោមការវះកាត់ព្យាបាលជាច្រើនដងទៀត ។ មុនពេលវះកាត់ យើងបានជួបជាមួយគ្រូពេទ្យវះកាត់ ហើយបានប្រាប់គាត់ថា យើងជឿថា គាត់នឹងរកឃើញថាភ្នែករបស់បេនយ៉ាមីន នឹងបានជាសះស្បើយ ហើយមិនចាំបាច់យកចេញទេ ។ គ្រួសារយើងទាំងមូល និង សមាជិកវួដជាច្រើននាក់ទៀតបានតមអាហារ និង អធិស្ឋានសម្រាប់កូនប្រុសរបស់យើង ហើយយើងមានជំនឿយ៉ាងខ្លាំងថា បេនយ៉ាមីន នឹងបានជាសះស្បើយ ។

មួយម៉ោងក្រោយមក គ្រូពេទ្យវះកាត់បានត្រឡប់មកវិញ ហើយបញ្ជាក់ប្រាប់យើងថា ភ្នែកម្ខាងរបស់បេនយ៉ាមីន ត្រូវបានខូចខាតដោយសារកោសិកាមហារីកនោះ ហើយភ្នែកម្ខាងទៀតក៏មានមហារីកធ្ងន់ធ្ងរ ដែលត្រូវទទួលការព្យាបាលជាបន្ទាន់ ។ ខ្ញុំគាំង មិនអាចនិយាយអ្វីបានឡើយ ។ ពោរពេញដោយទុក្ខព្រួយ និង ដោយការមិនជឿ នោះខ្ញុំបានដើរចេញពីមន្ទីរពេទ្យទៅក្នុងសន្សើមនាពេលព្រឹកនៃទីក្រុង សាន់ហ្វ្រាន់ស៊ីស្កូ ហើយចាប់ផ្ដើមដើរ ទាំងយំដោយភាពល្វីងជូរចត់ ។

ខ្ញុំបានធ្វើអ្វីៗគ្រប់យ៉ាង ដែលគេបានបង្រៀនខ្ញុំឲ្យធ្វើ ។ យើងបានអធិស្ឋាន ហើយបានទទួលការបំផុសយ៉ាងខ្លាំងឲ្យជ្រើសរើសវេជ្ជបណ្ឌិតនេះ ។ យើងបានតមអាហារ និង អធិស្ឋាន ហើយមានអារម្មណ៍ប្រាកដថា កូនប្រុសតូចរបស់យើងនឹងបានជាសះស្បើយតាមរយៈសេចក្ដីជំនឿ និង អំណាចនៃបព្វជិតភាព ។ ប៉ុន្តែ ព្រះអម្ចាស់មិនបានធ្វើអន្តរាគមន៍សោះ ។ សេចក្ដីជំនឿរបស់យើង ហាក់បីដូចជាគ្មានអ្វីលើសពីសេចក្ដីសង្ឃឹមដ៏ឥតប្រយោជន៍នោះទេ ។ ខ្ញុំបានចាប់ផ្ដើមសង្ស័យពីអ្វីគ្រប់យ៉ាងដែលខ្ញុំធ្លាប់បានជឿ ។ នៅពេលខ្ញុំដើរ នោះខ្ញុំមានអារម្មណ៍ត្រូវគេក្បត់ និង ខឹងសម្បារ ។ ខ្ញុំពោរពេញដោយការឈឺចាប់ ។

ខ្ញុំមិនបានមានមោទនភាពចំពោះការសន្ទនាដែលខ្ញុំបានមានជាមួយព្រះវរបិតាសួគ៌ទេ នៅពេលដែលខ្ញុំដើរ និង យំនៅព្រឹកនោះ ។ បន្តិចក្រោយមក ខ្ញុំបានទប់អារម្មណ៍របស់ខ្លួនឯង ។ ខ្ញុំបានចាំពាក្យក្នុងចម្រៀងថ្នាក់បឋមសិក្សា ដែលបានចូលមកក្នុងគំនិតរបស់ខ្ញុំ ។ « ព្រះវរបិតាសួគ៌ ទ្រង់គង់ទីនោះឬ ? តើទ្រង់ឮ និង ឆ្លើយការអធិស្ឋានកុមារម្នាក់ៗឬ ? » ពីព្រោះទ្រង់ច្បាស់ជាមិនបានស្ដាប់ការអធិស្ឋានរបស់ទូលបង្គំ ឬ ប្រហែលជាទ្រង់ពិតជាមិនខ្វល់ខ្វាយពីទូលបង្គំ និង កូនប្រុសទូលបង្គំឡើយ ។ ( "A Child's Prayer," *Children's Songbook* ទំព័រ 12 ) ។

នៅពេលនោះ សេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់បានមក ។ នៅក្នុងគំនិត និង ដួងចិត្តរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ពីពាក្យទាំងនេះថា ៖ « ខេវីន គេក៏ជាកូនប្រុសរបស់យើងដែរ » ។ ភាពច្បាស់លាស់នៃការបំផុសនោះ គឺមិនអាចច្រឡំទេ ។ ខ្ញុំដឹងនៅគ្រានោះថា ខ្ញុំមិនបានយល់ពីគោលបំណងនៃការអធិស្ឋានទាល់តែសោះ ។ ខ្ញុំបានសន្មត់ថា ដោយសារតែខ្ញុំមានមូលហេតុដ៏សុចរិតមួយ នោះខ្ញុំអាចប្រើប្រាស់បព្វជិតភាព និង ការតមអាហារ និង ការអធិស្ឋាន ដើម្បីផ្លាស់ប្ដូរឆន្ទៈរបស់ព្រះបាន ។

ជាលើកដំបូងនៅក្នុងជីវិតរបស់ខ្ញុំហើយ ដែលខ្ញុំដឹងយ៉ាងពេញលេញថា ខ្ញុំមិនមែនជាអ្នកមើលការខុសត្រូវលើរឿងនេះឡើយ ។ខ្ញុំដឹងថា ខ្ញុំត្រូវតែចុះចូលទៅនឹងឆន្ទៈរបស់ព្រះវរបិតាសួគ៌ ។ ខ្ញុំមិនអាចមានអ្វីដែលខ្ញុំចង់បាន នៅពេលណា និង របៀបណាដែលខ្ញុំចង់បាន ដោយសារតែខ្ញុំកាន់តាមបញ្ញត្តិទាំងឡាយនោះឡើយ ។ គោលបំណងនៃការអធិស្ឋាន គឺមិនមែនដើម្បីប្រាប់ព្រះវរបិតាសួគ៌ពីអ្វីដែលត្រូវធ្វើនោះឡើយ ប៉ុន្តែគឺដើម្បីស្វែងរកឲ្យឃើញអ្វីដែលទ្រង់ចង់ឲ្យខ្ញុំធ្វើ និង រៀន ។ ខ្ញុំត្រូវតែសម្របឆន្ទៈរបស់ខ្ញុំ ឲ្យស្របនឹងឆន្ទៈរបស់ទ្រង់ ។

យើងនឹងត្រូវប្រឈមមុខនឹងឧបសគ្គដ៏ធ្ងន់ធ្ងររយៈពេលប្រាំមួយឆ្នាំទៀត កាលដែលយើងពុះពារព្យាបាលជំងឺរបស់កូនប្រុសតូចរបស់យើង ដើម្បីសង្គ្រោះភ្នែកម្ខាងទៀត និង ដើម្បីសង្គ្រោះជីវិតរបស់គេ ។ ប៉ុន្តែឥឡូវនេះ ខ្ញុំដឹងថាព្រះវរបិតាសួគ៌បានជ្រាបដឹង ហើយជាអ្នកមើលការខុសត្រូវលើរឿងនេះ ។ ហើយទោះបីជាមានរឿងអ្វីកើតឡើងនៅទីបំផុតក៏ដោយ ក៏ទ្រង់បានស្ដាប់ឮ ហើយឆ្លើយតបការអធិស្ឋានរបស់ខ្ញុំដែរ ។ សព្វថ្ងៃនេះ កូនប្រុសនៃអព្ភូតហេតុរបស់យើងនេះកំពុងបម្រើបេសកកម្មពេញម៉ោងនៅក្នុងប្រទេស អេស្ប៉ាញ ។

ខ្ញុំពិតជាមានភស្ដុតាងនៅក្នុងជីវិតផ្ទាល់របស់ខ្ញុំថា ព្រះគឺជាព្រះវរបិតាសួគ៌ដែលប្រកបដោយក្ដីស្រឡាញ់របស់យើង ហើយទ្រង់ពិតជាស្ដាប់ឮ និង ឆ្លើយតបការអធិស្ឋានរបស់យើង ។ នៅពេលអ្នកបន្តរៀន និង យល់ពីគោលការណ៍ដ៏ទេវភាពនៃការអធិស្ឋានផ្ទាល់ខ្លួន ដូចដែលព្រះអង្គសង្គ្រោះបានបង្រៀន នោះការអធិស្ឋាននឹងក្លាយជាប្រភពមួយនៃអំណាចខាងវិញ្ញាណ និង វិវរណៈដ៏អស្ចារ្យនៅក្នុងជីវិតរបស់អ្នក ។ ■

*ដកស្រង់មកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន ដែលបានផ្ដល់ឲ្យនៅឯសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់–ហាវ៉ៃ ថ្ងៃទី 17 ខែ ឧសភា ឆ្នាំ 2011 ។ សម្រាប់អត្ថបទទាំងមូលជាភាសាអង់គ្លេស សូមចូលទៅកាន់គេហទំព័រ* devotional.byuh.edu ។

# « បងប្រុសរបស់ខ្ញុំ មានបញ្ហានឹងរូបអាសគ្រាម ។ គាត់កំពុងតែដោះស្រាយជាមួយនឹងប៊ីស្សពរបស់យើងអំពីរឿងនោះ ដូច្នេះខ្ញុំចង់គាំទ្រគាត់ ប៉ុន្តែវាមានឥទ្ធិពលលើទំនុកចិត្តរបស់ខ្ញុំទៅលើគាត់ ។ តើខ្ញុំដោះស្រាយជាមួយរឿងនេះដោយរបៀបណា ? »

វាគឺជាការណ៍ល្អ ដែលអ្នកចង់គាំទ្របងប្រុសរបស់អ្នក ។ គាត់នឹងត្រូវការការលើកទឹកចិត្តពីអ្នក ។ ពីព្រោះបងប្រុសរបស់អ្នកបានធ្វើឲ្យអ្នកដឹងពីបញ្ហានេះនៅក្នុងជីវិតគាត់ ហើយអ្នកដឹងថា គាត់បានព្យាយាមប្រាប់វា នោះគាត់បានបោះជំហានយ៉ាងធំមួយឆ្ពោះទៅរកការទទួលទំនុកចិត្តពីអ្នកវិញរួចទៅហើយ ។ ជាញឹកញាប់ណាស់ ការយកឈ្នះលើភាពសម្ងាត់ និង ភាពមិនស្មោះត្រង់ ដែលទាក់ទងជាមួយនឹងបញ្ហានេះ គឺជាភស្តុតាងនៃការរីកចម្រើនយ៉ាងធំ ។ នេះអាចជួយឲ្យអ្នកចាប់ផ្ដើមដាក់ទីទុកចិត្តលើគាត់កាន់តែខ្លាំងឡើង ។ វាត្រូវការពេលវេលាសម្រាប់ការទុកចិត្តនោះ ដើម្បីឲ្យបានលូតលាស់ពេញលេញ ។ ប៉ុន្តែនោះមិនមែនមានន័យថា អ្នកមិនអាចនៅតែស្រឡាញ់គាត់នោះទេ ។ អ្នកអាចអធិស្ឋានសម្រាប់គាត់ ធ្វើគំរូល្អដល់គាត់ ហើយធ្វើអ្វីៗផ្សេងទៀតដើម្បីជួយគាត់ ។

សូមព្យាយាម កុំវិនិច្ឆ័យគាត់ ។ បើសិនគាត់មានអារម្មណ៍ថាត្រូវបានគេវិនិច្ឆ័យ នោះគាត់ប្រហែលជានឹងមានអារម្មណ៍កាន់តែមិនល្អអំពីបញ្ហារបស់គាត់ ហើយការណ៍នោះនឹងធ្វើឲ្យគាត់កាន់តែលំបាកឡើងក្នុងការផ្លាស់ប្ដូរ ។ មនុស្សគ្រប់គ្នាមានភាពទន់ខ្សោយ នោះគឺជាហេតុផលមួយ ដែលព្រះអង្គសង្គ្រោះបានប្រទានដង្វាយធួន ។ សូមទុកចិត្តលើព្រះអម្ចាស់ និង លើភាពពិតដែលថា តាមរយៈការប្រែចិត្ត នោះបងប្រុសរបស់អ្នកអាចផ្លាស់ប្ដូរ និងត្រូវបានអភ័យទោស ។

ដោយសារអ្នកដឹងថា បងប្រុសរបស់អ្នកកំពុងដោះស្រាយជាមួយប៊ីស្សពរបស់អ្នកអំពីបញ្ហានេះ នោះអ្នកអាចជជែកជាមួយប៊ីស្សពរបស់អ្នកអំពីស្ថានការណ៍នេះ ។ គាត់ និង ឪពុកម្ដាយរបស់អ្នក អាចជួយឲ្យអ្នកដឹងពីអ្វីដែលត្រូវធ្វើ ។ ក្នុងនាមជាគ្រួសារមួយ អ្នកអាចធ្វើការរួមគ្នាដើម្បីជួយបងប្រុសរបស់អ្នក ។ អ្នកអាចតមអាហារជាគ្រួសារដើម្បីជួយគាត់ ( សូមមើល ម៉ាថាយ 17:21 ) ដែលនឹងផ្ដល់ជាខែលទប់ទល់នឹងការល្បួង ។

*កំណត់សម្គាល់ ៖ យុវនារីជាច្រើន ក៏មានបញ្ហានឹងការញៀនរូបអាសគ្រាមផងដែរ ។ ដំបូន្មានដូចគ្នានេះ ក៏អនុវត្តចំពោះទំនាក់ទំនងជាមួយបងប្អូនស្រីដែរ ។*

## សូមបង្ហាញពីការសោកស្ដាយ ប៉ុន្តែមិនមែនការបដិសេធឡើយ



រូបអាសគ្រាម គឺមិនមែនជាបញ្ហាតូចតាចឡើយ ហើយវាឈឺចាប់ខ្លាំងណាស់ ដែលយើងដឹងថា មនុស្សម្នាក់ដែលយើងខ្វាយខ្វល់ មានបញ្ហាជាមួយវានោះ ។ សូមព្យាយាមអភ័យទោសឲ្យគាត់ មិនថាវាត្រូវចំណាយពេលយូរប៉ុណ្ណាទេ ។ សូមចងចាំផងដែរថា ការអភ័យទោស និង ការទុកចិត្ត គឺដាច់ដោយឡែកពីគ្នា ។ តាមរយៈសកម្មភាពរបស់គាត់ នោះបងប្រុសរបស់អ្នក អាចទទួលបានទំនុកចិត្តពីអ្នកឡើងវិញ ។ សូមបង្ហាញពីការសោកស្ដាយ ប៉ុន្តែមិនមែនការបដិសេធឡើយ ។ គាត់ត្រូវការមានអារម្មណ៍ថា គាត់មិននៅឯកោឡើយ ហើយគាត់ត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់គាត់ ។ នៅពេលអ្នកស្រឡាញ់គាត់ ទោះបីជាគាត់ញៀនក៏ដោយ នោះគាត់នឹងឃើញពីក្ដីសង្ឃឹម និង ទទួលកម្លាំងដើម្បីយកឈ្នះលើបញ្ហានេះ ។

*បេថានី អេ. អាយុ 18 ឆ្នាំ រដ្ឋ អារីហ្សូណា ស.រ.អា.*

## លើកទឹកចិត្តគាត់



ខ្ញុំដឹងថា វាជាការលំបាក នៅពេលអ្នកដាក់ទីទុកចិត្តយ៉ាងច្រើនទៅលើនរណាម្នាក់ ហើយបន្ទាប់មកគេរំលោភបំពានលើសេចក្ដីទុកចិត្តនោះ ។ អ្វីមុនគេដែលខ្ញុំនឹងធ្វើនោះគឺ អធិស្ឋាន ហើយសុំព្រះវរបិតាសួគ៌ប្រទានកម្លាំងដើម្បីនិយាយជាមួយបងប្រុសរបស់អ្នក ។ អ្នកអាចជជែកជាមួយគាត់រាល់សប្ដាហ៍អំពីសុខទុក្ខរបស់គាត់ ហើយរកខគម្ពីរនៅពេលអ្នកសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនដែលនឹងលើកទឹកចិត្តគាត់ឲ្យទទួលជំនួយ ។ ទោះបីជាគាត់បានធ្វើឲ្យអ្នកបាត់បង់ទំនុកចិត្តលើគាត់ក៏ដោយ ក៏ការគាំទ្រដល់គាត់ គឺជាការសំខាន់ណាស់ ។ សូមជួយគាត់ឲ្យដឹងថា ព្រះអម្ចាស់ស្រឡាញ់គាត់ ហើយនឹងអភ័យទោសឲ្យគាត់ ។ សូមរំឭកគាត់ពីទំនុកតម្កើងបទលេខ 187, “God Loved Us, So He Sent His Son” ។ សូមជួយឲ្យគាត់ដឹងថា ព្រះយេស៊ូវគ្រីស្ទបានធ្វើឲ្យធួននឹងអំពើបាបរបស់យើង ហើយបើសិនយើងប្រែចិត្ត នោះយើងអាចធ្វើបានកាន់តែប្រសើរឡើងបន្តិចម្ដងៗរាល់ថ្ងៃ ។

*ណាអូមី ប៊ី. អាយុ 16 ឆ្នាំ រដ្ឋ មីនីសូតា ស.រ.អា.*

## សូមគាំទ្រគាត់

សូមបង្ហាញគាត់ថា អ្នកស្រឡាញ់គាត់ ទោះបីជាគាត់បានជ្រើសរើសធ្វើអ្វីក៏ដោយ ។ សូមគាំទ្រគាត់គ្រប់ជំហានដែលគាត់ដើរ ហើយជួយឲ្យគាត់ដឹងថា អ្នករីករាយខ្លាំងប៉ុណ្ណា ដែលគាត់កំពុងដោះស្រាយបញ្ហានេះ ។ ទំនុកចិត្តនឹងមិនអាចវិលមកវិញយ៉ាងលឿនភ្លាមៗក្នុងពេលតែម្ដងនោះទេ ប៉ុន្តែគាត់កំពុងព្យាយាមដើម្បីទទួលបានទំនុកចិត្តនោះឡើងវិញ ។ គាត់កំពុងតែដើរលើផ្លូវត្រូវហើយ ហើយនៅពេលគាត់ដឹងពីរបៀបដែលគាត់



*ចម្លើយទាំងឡាយគឺមានបំណងទុកជាជំនួយ និង ជាទស្សនៈវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រនោះទេ ។*

អាចប្រែក្លាយខ្លួនឲ្យកាន់តែប្រសើរជាងនេះ នោះអ្នកអាចរៀនពីរបៀបដើម្បីទុកចិត្តលើគាត់ម្ដងទៀត ។

*គ្រីស្ទីន អិម. អាយុ 17 ឆ្នាំ រដ្ឋ ណស ខារ៉ូលីណា ស.រ.អា.*

### សូមផ្ដល់ការអភ័យទោស

បើសិនអ្នកអនុវត្តអំណាចនៃដង្វាយធួន នោះអំណាចនេះនឹងជួយបងប្រុសរបស់អ្នកឲ្យមានកម្លាំងដើម្បីប្រែចិត្ត ។ ដង្វាយធួនផ្ដល់ការព្យាបាលដល់អស់អ្នកដែលរងរបួសព្រមទាំងដល់អស់អ្នកដែលបានធ្វើការជ្រើសរើសដែលពោរពេញដោយការឈឺចាប់ ។ សូមផ្ដល់ការអភ័យទោសជានិច្ច ហើយព្យាយាមស្រឡាញ់ ជាជាងការប្រែទៅជាកំហឹង ។

*សេត ប៊ី. អាយុ 18 ឆ្នាំ រដ្ឋ មិសសួរី ស.រ.អា.*

### សូមអធិស្ឋានសម្រាប់ការណែនាំ

សូមលុតជង្គង់ចុះ ហើយទូលសុំការណែនាំពីព្រះវរបិតាសួគ៌របស់យើង ហើយនិយាយជាមួយបងប្រុសរបស់អ្នក ហើយអធិស្ឋានជាមួយគាត់ ។ នៅពេលយើងបន្ទាបខ្លួននៅចំពោះមុខព្រះវរបិតាសួគ៌របស់យើង នោះទ្រង់ « នឹងមិនឲ្យកើតមានសេចក្ដីល្បួងហួសកម្លាំងអ្នករាល់គ្នាឡើយ គឺនៅវេលាណាដែលអ្នកត្រូវល្បួង នោះទ្រង់ក៏រៀបចំផ្លូវឲ្យចៀសរួច ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន » ( កូរិនថូស ទី1 10:13 ) ។ ទ្រង់នឹងជួយបងប្រុសរបស់អ្នកឲ្យរឹងមាំ ដើម្បីទប់ទល់នឹងការល្បួង ហើយជ្រើសរើសត្រឹមត្រូវជានិច្ច ។

*អាឡេចានដ្រា ប៊ី. អាយុ 22 ឆ្នាំ រដ្ឋ កាលីហ្វ័រញ៉ា ស.រ.អា.*

### សូមកុំបោះបង់សេចក្ដីសង្ឃឹមឡើយ

សូមកុំបោះបង់សេចក្ដីសង្ឃឹមលើបងប្រុសរបស់អ្នកឡើយ ពីព្រោះនេះគឺជាពេលដែលគាត់ត្រូវការគ្រួសារគាត់ខ្លាំងបំផុត ។ ការយកឈ្នះលើបញ្ហារូបអាសគ្រាមគឺជាបញ្ហាលំបាកគ្រប់គ្រាន់មួយសម្រាប់គាត់ទៅហើយ ដោយមិនគិតពីការបាត់បង់ទំនុកចិត្តរបស់គ្រួសារគាត់លើរូបគាត់ផងនោះ ។ ខ្ញុំធ្លាប់មានបញ្ហាដូចគ្នា ហើយខ្ញុំបានដោះស្រាយដើម្បីប្រែចិត្ត ដើម្បីមានភាពសក្ដិសមដើម្បីទៅព្រះវិហារបរិសុទ្ធ ដើម្បីផ្សារភ្ជាប់ជាមួយគ្រួសាររបស់ខ្ញុំ ។ ខ្ញុំតែងតែភ័យព្រួយជានិច្ច ពីអ្វីដែលឪពុកម្ដាយរបស់ខ្ញុំនឹងនិយាយ ឬ ពីរបៀបដែលពួកគាត់នឹងធ្វើមកលើខ្ញុំ ។ ខ្ញុំមានការរំភើបចិត្ត នៅពេលខ្ញុំបានដឹងថា ពួកគាត់គាំទ្រខ្ញុំយ៉ាងខ្លាំង ហើយពួកគាត់ចង់ផ្ដល់ដំណោះស្រាយយ៉ាងខ្លាំង ដើម្បីជួយខ្ញុំឲ្យប្រែក្លាយខ្លួនកាន់តែប្រសើរឡើង ។ បើសិនបងប្រុសរបស់អ្នកកំពុងពិភាក្សាជាមួយប៊ីស្សពរបស់គាត់ ហើយធ្វើកិច្ចខិតខំដោយស្មោះត្រង់ នោះគាត់នឹងមានភាពរីកចម្រើន ។

*យុវវជនម្នាក់មកពី រដ្ឋ អាឡាស្កា ស.រ.អា.*

### សូមទុកចិត្តលើព្រះអម្ចាស់



ដង្វាយធួនគឺមិនគ្រាន់តែសម្រាប់អំពើបាបរបស់យើងទេ ប៉ុន្តែសម្រាប់ការលំបាក និង ការពុះពារទាំងឡាយរបស់យើងផងដែរ ។ ព្រះយេស៊ូវគ្រីស្ទដឹងយ៉ាងច្បាស់ពីអារម្មណ៍របស់អ្នក—ទ្រង់ធ្លាប់មានអារម្មណ៍នោះពីមុនមកហើយ ។ សូមឈោងទៅរកទ្រង់ ហើយអ្នកនឹងឃើញថា ព្រះហស្តទ្រង់រង់ចាំលើកអ្នកឡើង ។ សូមអធិស្ឋានដើម្បីសុំជំនួយទ្រង់ និង សុំអំណាចព្យាបាលនៃដង្វាយធួន ។ សូមទូលព្រះវរបិតាសួគ៌ពីគ្រប់កង្វល់របស់អ្នក សេចក្ដីបារម្ភ និងសេចក្ដីសង្ឃឹមចំពោះស្ថានការណ៍នេះ ។ អ្វីដែលសំខាន់បំផុតនោះ សូមកុំគ្រាន់តែរង់ចាំឲ្យអព្ភូតហេតុមួយកើតឡើងឡើយ—សូមធ្វើអ្វីមួយ ។ សូមសិក្សាព្រះគម្ពីរ ស្វែងរកប្រាជ្ញាដែលនឹងជួយអ្នក ហើយរក្សាសេចក្ដីជំនឿថា អ្វីៗគ្រប់យ៉ាងនឹងមានដំណើរការល្អ ។

*មេហ្គេន អេ. អាយុ 19 ឆ្នាំ រដ្ឋ អារីហ្សូណា ស.រ.អា.*



**ផ្លូវមួយដើម្បីធ្វើការកែប្រែ**

« ព្រះវរបិតាសួគ៌របស់យើងបានជ្រាបដឹងតាំងពីមុនពេលដែលយើងមកក្នុងជីវិតរមែងស្លាប់នេះម្ល៉េះ ថាកម្លាំងនៃភាពអវិជ្ជមាននឹងល្បួងយើង ឲ្យសាត់អណ្ដែតចេញពីផ្លូវរបស់យើង ‹ ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ › ( រ៉ូម 3:23 ) ។ អញ្ចឹងហើយបានជាទ្រង់បានរៀបចំផ្លូវមួយសម្រាប់យើងធ្វើការកែប្រែ ។ តាមរយៈដំណើរការដ៏មានក្ដីមេត្តាករុណានៃការប្រែចិត្តដ៏ពិត និង ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះអំពើបាបរបស់យើងអាចត្រូវបានអភ័យទោសឲ្យ ហើយយើងនឹង ‹ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ › ( យ៉ូហាន 3:16 ) » ។

ប្រធាន ឌៀថើរ អេស្វ. អុជដុហ្វ ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ "A Matter of a Few Degrees," *លីអាហូណា* និង *Ensign* ខែ ឧសភា ឆ្នាំ 2008 ទំព័រ 60 ។

## សំណួរបន្ទាប់

# « តើខ្ញុំគួរតែគិតអំពីអ្វីខ្លះ អំឡុងពេលប្រជុំសាក្រាម៉ង់នោះ ? »

សូមផ្ញើចម្លើយរបស់អ្នកត្រឹមថ្ងៃទី 15 ខែកក្កដា តាមគេហទំព័រ liahona.lds.org ដោយអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ ដោយផ្ញើសំបុត្រទៅកាន់ ៖

*Liahona,* Questions & Answers 7/13
50 E. North Temple St., Rm. 2420
Salt Lake City, UT 84150-0024, USA

ចម្លើយអាចនឹងត្រូវបានធ្វើការកែសម្រួលឡើងវិញ ដោយព្រោះវែងពេក ឬ ដើម្បីភាពច្បាស់លាស់ ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោម ត្រូវតែបញ្ចូលនៅក្នុងអ៊ីម៉ែល ឬ សំបុត្ររបស់អ្នក ៖ (1) ឈ្មោះពេញ (2) ថ្ងៃខែឆ្នាំកំណើត (3) វួដ ឬ សាខា (4) ស្តេក ឬ មណ្ឌល (5) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយបើសិនអ្នកមានអាយុក្រោម 18 ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកជាលាយលក្ខណ៍អក្សរ ( អ៊ីម៉ែល អាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។



**ដោយ អែលឌើរ ស្ទីវិន អ៊ី. ស្នូ**
អ្នកប្រវត្តិសាស្ត្រសាសនាចក្រ
និង សមាជិកនៃពួកចិតសិបនាក់

*ភស្តុតាងដ៏សន្ធឹកសន្ធាប់នៃប្រវត្តិសាស្ត្រសាសនាចក្រ គឺមានភាពវិជ្ជមាន និង ជំរុញសេចក្ដីជំនឿ ។ នៅក្នុងបរិបទនៃប្រវត្តិសាស្ត្រសាសនាចក្រទាំងមូល វាពិតជាបំផុសគំនិតយ៉ាងខ្លាំង ។*

# ការថ្លឹងថ្លែងឲ្យបានត្រឹមត្រូវពីប្រវត្តិសាស្ត្រសាសនាចក្រ

ខ្ញុំរីករាយដើម្បីអានដំណើររឿងប្រវត្តិសាស្ត្រនៃសមាជិកសាសនាចក្រកាលពីដំបូង ដែលបានចាកចេញពីគេហដ្ឋានរបស់ពួកគេ ហើយដោយការបូជាដ៏អស្ចារ្យ នោះបានប្រមូលផ្ដុំជាមួយពួកបរិសុទ្ធ ។ សម្រាប់ខ្ញុំរឿងទាំងនោះពោរពេញដោយឥទ្ធិពល ហើយខ្ញុំទទួលបានកម្លាំងយ៉ាងអស្ចារ្យពីការរៀនពីអ្វីៗដែលពួកគេបានឆ្លងកាត់ ដើម្បីរស់នៅ និង បង្ហាញពីសេចក្ដីជំនឿរបស់ពួកគេ ដោយការធ្វើតាមព្យាការី និង ធ្វើនូវការណ៍លំបាកៗជាច្រើន ។ នៅពេលអ្នកអានពីអ្វីដែល*ពួកគេ*បានធ្វើ នោះស្ថានភាពនៅក្នុងជីវិត*របស់អ្នក*ហាក់បីដូចជាមិនសូវលំបាកឡើយ ។

ខ្ញុំស្រឡាញ់ប្រវត្តិសាស្ត្រសាសនាចក្រ ។ ឥឡូវនេះខ្ញុំកំពុងអានវាកាន់តែច្រើនឡើង ជាងពេលមុនៗទៅទៀត ហើយខ្ញុំបានឃើញថា វាគួរឲ្យទាក់ចិត្ត និង ជំរុញសេចក្ដីជំនឿ ។ ជាឧទាហរណ៍ វាពិតជាអស្ចារ្យណាស់ពីអ្វីៗ ដែលពួកអ្នកផ្សព្វផ្សាយកាលពីដើមបានធ្វើសម្រេច ដោយគ្មានធនធានអ្វីផ្សេងទៀតក្រៅពីសេចក្ដីជំនឿ និង ទីបន្ទាល់ដ៏ខ្លាំងក្លា ដែលធ្វើឲ្យពួកគេធ្វើកិច្ចការដ៏អស្ចារ្យជាច្រើន ។ គំរូទាំងនោះជួយខ្ញុំឲ្យយល់ថា ខ្ញុំអាចធ្វើកិច្ចការពិបាកៗបាន បើសិនជាខ្ញុំបន្តចិញ្ចឹមបីបាច់សេចក្ដីជំនឿ និង ទីបន្ទាល់របស់ខ្ញុំនោះ ។ ពីពេលមួយទៅពេលមួយ ទីបន្ទាល់របស់ខ្ញុំត្រូវបានពង្រឹង នៅពេលខ្ញុំឃើញអ្វីដែលបានកើតឡើងជាមួយនឹងកិច្ចការដ៏អស្ចារ្យនេះ កាលដែលវាបានរីកចម្រើនឡើង ។

## ការមើលអតីតកាលមកពីបច្ចុប្បន្នកាល

ប្រវត្តិសាស្ត្រគឺជារបៀបមួយដ៏អស្ចារ្យ ដែលបំផុសគំនិតដើម្បីរៀបចំខ្លួនរបស់អ្នកខាងវិញ្ញាណ ។ នៅក្នុងប្រវត្តិសាស្ត្ររបស់យើង យើងអាចឃើញពីអស់អ្នកដែលរៀបចំខ្លួនរបស់គេខាងវិញ្ញាណ ហើយយកឈ្នះ និង អស់អ្នកដែលបានវង្វេងចេញ ដោយសារពួកគេមិនបានរៀបចំខ្លួនខាងវិញ្ញាណសម្រាប់អ្វីដែលបានកើតឡើង ។ យើង





រចនារូបភាពដោយ ខូឌី បែល

អាចរៀនថា ការលះបង់ចំពោះដំណឹងល្អ ការអធិស្ឋាន និង ទីបន្ទាល់អាចជួយយើងឲ្យធ្វើកិច្ចការអស្ចារ្យ ហើយថា យើងត្រូវតែចំណាយពេលវេលា ក្នុងការអភិវឌ្ឍន៍ខាងផ្នែកវិញ្ញាណរបស់យើង ឬ យើងនឹងត្រូវរងការឈឺចាប់នូវលទ្ធផលនោះ ។

មនុស្សនៅក្នុងប្រវត្តិសាស្ត្រសាសនាចក្ររបស់យើង គឺជាមនុស្សធម្មតាដូចជាយើងដែរ ដែលជាមនុស្សភាគច្រើនដែលបានធ្វើកិច្ចការដ៏អស្ចារ្យទាំងឡាយ ។ ខណៈដែលពួកគេទាំងអស់គ្នាស្វែងរកភាពល្អឥតខ្ចោះនោះពួកគេមិនបានល្អឥតខ្ចោះឡើយ ។ សមាជិកនៃសាសនាចក្រកាលពីដើមទាំងនោះ មានការលំបាករបស់ពួកគេ ហើយបានមានបញ្ហាជាមួយនឹងអ្វីៗជាច្រើន ដូចដែលយើងមាននាពេលបច្ចុប្បន្ននេះដែរ ។ ប៉ុន្តែខ្ញុំរកឃើញកម្លាំងដើម្បីដឹងថា ឧបសគ្គទាំងនោះ ការព្យាយាមស្វែងរកភាពល្អឥតខ្ចោះទាំងនោះ បានមានតាំងពីយូរមកហើយ ។



*ដូចជាអ្វីផ្សេងទៀតដែរ អ្នកត្រូវតែពិចារណាពីប្រវត្តិសាស្ត្រសាសនាចក្រដោយការថ្លឹងថ្លែងត្រឹមត្រូវ ។*

## ការឆ្លើយនឹងសំណួរទាំងឡាយ

**តើខ្ញុំត្រូវឆ្លើយយ៉ាងណា ទៅនឹងសំណួររបស់មិត្តខ្ញុំដែលនិយាយថា មានប្រវត្តិសាស្ត្ររបស់យើងខ្លះ គឺពិបាកជឿណាស់ ដូចជាអំពីទេវតា និង ផ្ទាំងមាសដែលបានកប់ក្នុងដីនោះ ?**

បើសិនមនុស្សមិនអាចគិតស្រមៃថាផ្នែកខ្លះៗរបស់ប្រវត្តិសាស្ត្រសាសនាចក្រពិតជាមានទេនោះ វាជាធម្មតាទេដែលពួកគេសង្ស័យនោះ ។ យើងគួរតែចង្អុលបង្ហាញថា វាស្របទៅតាមព្រឹត្តិការណ៍អស្ចារ្យផ្សេងទៀតនៅក្នុងទំនាក់ទំនងរវាងព្រះជាមួយនឹងមនុស្សក្នុងប្រវត្តិសាស្ត្រទាំងមូល ហើយយើងនឹងថ្លែងទីបន្ទាល់របស់យើងដល់ពួកគេ ហើយសុំឲ្យពួកគេសិក្សាពីចំណុចនោះសម្រាប់ខ្លួនពួកគេផ្ទាល់ ។ បន្ទាប់មកយើងនឹងអញ្ជើញពួកគេដើម្បីពិចារណា និង អធិស្ឋានសួរដល់ព្រះវរបិតាសួគ៌អំពីចំណុចនោះ « ដោយចិត្តស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ » ( មរ៉ូណៃ10:4 ) ។

បើសិនពួកគេមានឆន្ទៈដើម្បី « ធ្វើការពិសោធន៍ » នេះ ដើម្បី « អនុវត្តសេចក្តីជំនឿមួយភាគតូច » ( អាលម៉ា 32:27 ) ហើយសួរដល់ព្រះ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបង្ហាញសេចក្តីពិតដល់ពួកគេ ។

ជាការពិត ពិភពលោកបានផ្លាស់ប្តូរកាលពីតំណមុន ឬ ពីរតំណមុន ។ អ៊ិនធើណែតបានបញ្ចូលព័ត៌មានគ្រប់យ៉ាងដែលងាយស្រួលឲ្យយើងរកបាននៅនឹងចុងម្រាមដៃរបស់យើង—ទាំងល្អ អាក្រក់ ពិត ក្លែងក្លាយ—រួមទាំងព័ត៌មានអំពីប្រវត្តិសាស្ត្រសាសនាចក្រផងដែរ ។ អ្នកអាចអានប្រវត្តិសាស្ត្រសាសនាចក្រដ៏ច្រើនរបស់យើង ប៉ុន្តែវាសំខាន់ដើម្បីអានពីវា ហើយយល់ពីបរិបទរបស់វា ។ ភាពលំបាកជាមួយព័ត៌មានមួយចំនួននៅលើអ៊ិនធើណែត គឺថា វាចេញឆ្ងាយពីបរិបទ ហើយអ្នកពិតជាមិនអាចឃើញដំណើររឿងទាំងមូលឡើយ ។

ជាទូទៅ ព័ត៌មានដែលព្យាយាមធ្វើឲ្យសាសនាចក្រអាម៉ាស់នោះ គឺផ្អែកតែទៅលើគំនិតរបស់គេផ្ទាល់ ហើយវាមិនយុត្តិធម៌ទេ ។ យើងគួរតែស្វែងរកប្រភពព័ត៌មានទាំងឡាយណាដែលពិពណ៌នាដោយមិនលម្អៀង ពីជំនឿ និង ប្រវត្តិសាស្ត្ររបស់យើង ។ មានគេហទំព័រខ្លះមានបំណងអាក្រក់ ហើយរបៀបដែលគេបង្ហាញពីព័ត៌មាននោះ អាចបណ្តាលឲ្យមានជាវិវាទ ។ សូមស្វែងរកប្រភពព័ត៌មានទាំងឡាយណាដែលមានអ្នកកត់ត្រាប្រវត្តិសាស្ត្រដែលមានការទទួលស្គាល់ និង គោរព ទោះបីជាពួកគេជាសមាជិក ឬ មិនមែនសមាជិកនៃសាសនាចក្រក៏ដោយ ។

យុវវ័យមួយចំនួនមានការភ្ញាក់ផ្អើល និង រន្ធត់ ដោយសារព័ត៌មានប្រឆាំងនឹងពួកមរមន ដែលមាននៅលើអ៊ិនធើណែត ដោយសារពួកគេពុំបានធ្វើឲ្យខ្លួនឯងមានភាពរឹងមាំ ដើម្បីទប់ទល់នឹងព័ត៌មាននោះ ។ ប្រហែលជាពួកគេមិនបានចំណាយពេលគ្រប់គ្រាន់លើផ្នែកវិញ្ញាណ ដើម្បីរៀបចំ និង ពង្រឹងខ្លួនពួកគេសម្រាប់អ្វីដែលអាចកើតឡើង ។ នៅពេលបទពិសោធន៍លំបាកនៃជីវិតបានមកដល់ពួកគេ នោះវាជាការសំខាន់ថា ពួកគេធ្វើកិច្ចការគ្រឹះទាំងនោះ ដែលយើងតែងតែនិយាយនោះគឺ ៖ បន្តសិក្សាព្រះគម្ពីរ និង ធ្វើការអធិស្ឋានដ៏មានអត្ថន័យជាមួយព្រះវរបិតាសួគ៌ ។ កិច្ចការគ្រឹះទាំងនោះ រៀបចំមនុស្សសម្រាប់ទុក្ខលំបាកគ្រប់បែបយ៉ាង រួមទាំងអត្ថបទទាំងឡាយរបស់ពួកប្រឆាំងនឹងពួកមរមន ដែលពួកគេនឹងជួបនៅលើអ៊ិនធើរណែត ។



### សេចក្តីត្រូវការសម្រាប់ការថ្លឹងថ្លែងត្រឹមត្រូវ

ដូចជាអ្វីផ្សេងទៀតដែរ អ្នកត្រូវតែពិចារណាពីប្រវត្តិសាស្ត្រ



*បើអ្នកជ្រើសរើសដើម្បីចំណាយពេលរបស់អ្នកជាច្រើន ដើម្បីគ្រាន់តែសិក្សាពីផ្នែកវិវាទគ្នានៃប្រវត្តិសាស្ត្រសាសនាចក្ររបស់យើង នោះអ្នកនឹងឃើញថា អ្នកយល់បានតិចតួចពីចំណុចសំខាន់ៗនៃប្រវត្តិសាស្ត្រសាសនាចក្រ ប៉ុន្តែអ្នកនឹងមិនអាចរៀនអ្វីច្រើនទៀតពីប្រវត្តិសាស្ត្រសាសនាចក្រឡើយ ។*

សាសនាចក្រដោយការថ្លឹងថ្លែងត្រឹមត្រូវ ។ ជានិច្ចជាកាល សាសនាចក្រពិតមានចំនួនតិច ហើយវាហាក់បីដូចជាយើងគឺជាមុខព្រួញដែលគេធ្វើទុក្ខបុកម្នេញ ។ យើងតែងតែជួបប្រទះនឹងទុក្ខលំបាកជានិច្ច ហើយយើងប្រហែលជាស៊ាំនឹងការលំបាកទាំងនោះផងដែរ ។ របៀបដ៏ល្អបំផុតដើម្បីទប់ទល់នឹងការលំបាកនោះ គឺធ្វើឲ្យប្រាកដថា យើងមានភាពសក្ដិសមផ្ទាល់ខ្លួន ហើយថាទីបន្ទាល់របស់យើងរឹងមាំ ។ បើសិនអ្នកកំពុងចំណាយពេលទៅលើគេហទំព័រដែលរិះគន់ពីសាសនាចក្រ និងប្រវត្តិសាស្ត្រសាសនាចក្រ ច្រើនជាងការអានព្រះគម្ពីរនោះ អ្នកកំពុងតែចៀសចេញពីការថ្លឹងថ្លែងដោយត្រឹមត្រូវហើយ ហើយព័ត៌មានអវិជ្ជមានទាំងនោះប្រហែលមានឥទ្ធិពលយ៉ាងខ្លាំងក្រៃលែងលើអ្នក ។ បើសិនអ្នកមានការថ្លឹងថ្លែងសមរម្យ នោះព័ត៌មានទាំងនោះ នឹងពុំមានឥទ្ធិពលលើអ្នកឡើយ ។

កាលខ្ញុំនៅជាយុវវ័យ ខ្ញុំមិនបានយល់ច្បាស់លាស់ពីសារៈសំខាន់នៃការអភិវឌ្ឍន៍ខាងវិញ្ញាណនោះទេ ។ ប្រហែលជាខ្ញុំចាប់អារម្មណ៍ដើម្បីក្លាយជាអ្នកលេងបាល់ឱបដ៏ល្អម្នាក់ ច្រើនជាងដែលខ្ញុំចង់ក្លាយជាសិស្សល្អម្នាក់របស់ព្រះគម្ពីរមរមន ។ ដូចជាយុវជនជាច្រើនដែរ ខ្ញុំពុំមានអារម្មណ៍បែបនោះឡើយ រហូតដល់ពេលខ្ញុំទៅតំបន់បេសកកម្ម ទើបខ្ញុំមានការផ្លាស់ប្ដូរ ហើយយល់ពីអត្ថន័យពិតនៃសុភមង្គល ។ វាគឺជាក្ដីអំណរ ជាភាពសុខសាន្តដែលបានមកពីការបម្រើព្រះអម្ចាស់ មកពីការសិក្សា និងការអធិស្ឋាន ពីការស្រឡាញ់ និង ការជួយមនុស្សដទៃ ។ ខ្ញុំរកឃើញថា បើសិនខ្ញុំព្រងើយកន្តើយនឹងអ្វីៗទាំងនោះនៅក្នុងជីវិតខ្ញុំ នោះអ្វីៗទាំងនោះនឹងមិនទៅមុខរលូនដូចដែលវាគួរតែទៅនោះទេ ។ បើសិនខ្ញុំធ្វើអ្វីៗទាំងនោះ នោះគ្រប់យ៉ាងហាក់បីដូចជាមានតុល្យភាពល្អជាង ។

នៅពេលខ្ញុំរស់នៅដោយមានតុល្យភាព នោះខ្ញុំអាចមើលទៅប្រវត្តិសាស្ត្របានច្បាស់លាស់ដោយឥតលម្អៀង ហើយយល់ថា ខណៈដែលបុព្វការីជនភាគច្រើនរបស់យើង ទទួលបានការគោរពនោះ ពួកគេក៏ជាមនុស្សទូទៅ ហើយប្រព្រឹត្តកំហុសដែរ ។ មានព្រឹត្តិការណ៍ខ្លះគួរឲ្យសោកស្ដាយ ឬ យល់ច្រឡំនៅក្នុងប្រវត្តិសាស្ត្រសាសនាចក្រយើង ដែលយើងត្រូវស្វែងយល់ឲ្យបានប្រសើរជាងនេះ ប៉ុន្តែសំណួរមួយចំនួននៃសំណួរទាំងនេះប្រហែលជាមិនអាចត្រូវបានឆ្លើយតបនៅក្នុងជីវិតរមែងស្លាប់នេះឡើយ ។ ហើយវាមិនជាថ្វីនោះទេ ។

បើសិនមិត្តម្នាក់មកសួរខ្ញុំ ជាមួយនឹងសំណួរដ៏ស្មោះត្រង់អំពីបញ្ហាវិវាទរបស់ប្រវត្តិសាស្ត្រសាសនាចក្រ នោះខ្ញុំនឹងប្រឹងឲ្យអស់ពីសមត្ថភាពដើម្បីឆ្លើយ ។ ហើយបើសិនខ្ញុំឃើញថា គាត់កំពុងចំណាយពេលច្រើនសួរពីចំណុចនោះ សំណួរដំបូងដែលខ្ញុំចង់សួរគាត់នោះគឺ ៖ « តើអ្នកអានព្រះគម្ពីរមរមនទេ ? តើអ្នកអធិស្ឋានទេ ? តើអ្នករស់នៅដោយមានតុល្យភាព ដើម្បីអ្នកអាចការពារខ្លួនរបស់អ្នកតទល់នឹងព្យុះនៃជីវិតបានទេ ?

ភស្តុតាងដ៏សន្ធឹកសន្ធាប់នៃប្រវត្តិសាស្ត្រសាសនាចក្រ គឺមានភាពវិជ្ជមាន និង ជម្រុញសេចក្ដីជំនឿ ។ បើអ្នកជ្រើសរើសដើម្បីចំណាយពេលរបស់អ្នកជាច្រើន ដើម្បីគ្រាន់តែសិក្សាពីផ្នែកវិវាទគ្នានៃប្រវត្តិសាស្ត្រសាសនាចក្ររបស់យើង នោះអ្នកនឹងឃើញថា អ្នកយល់បានតិចតួចពីចំណុចសំខាន់ៗនៃប្រវត្តិសាស្ត្រសាសនាចក្រ ប៉ុន្តែអ្នកនឹងមិនអាចរៀនអ្វីច្រើនទៀតពីប្រវត្តិសាស្ត្រសាសនាចក្រឡើយ ។ ហើយអ្នកត្រូវតែយល់ពីដំណើររឿងទាំងមូលនៃប្រវត្តិសាស្ត្រសាសនាចក្ររបស់យើង ។ នៅក្នុងបរិបទនៃប្រវត្តិសាស្ត្រសាសនាចក្រទាំងមូល វាពិតជាបំផុសគំនិតយ៉ាងខ្លាំង ។

ឧទាហរណ៍ យ៉ូសែប ស្ម៊ីធ គឺជាមនុស្សអស្ចារ្យម្នាក់ ។ តើគាត់ជាមនុស្សល្អឥតខ្ចោះឬ ? ទេ ! ពួកយើងទាំងអស់គ្នានឹងស្លាប់ ។ ប៉ុន្តែ ពេលអានព្រះគម្ពីរមរនមន និង វិវរណៈនៅក្នុងគោលលទ្ធិ និង សេចក្តីសញ្ញា ហើយឃើញអ្វីដែលគាត់បានធ្វើ ដើម្បីស្ដារសាសនាចក្រឡើងវិញ នៅក្នុងរយៈពេលដ៏ខ្លី នោះគឺជាទីបន្ទាល់ដ៏អស្ចារ្យ ។ ព្យាការីទាំងឡាយជួបនឹងឧបសគ្គ និង ទុក្ខលំបាក ហើយវាមិនគួរឲ្យភ្ញាក់ផ្អើលសម្រាប់យើងនោះទេ ដែល យ៉ូសែប ស្ម៊ីធ ជួបនឹងទុក្ខលំបាក ហើយធ្វើឲ្យមនុស្សមួយចំនួនអាក់អន់ចិត្តនោះ ។ ប៉ុន្តែលោក គឺពិតជាព្យាការីម្នាក់របស់ព្រះមែន ។

## គ្មានពេលណាដូចពេលបច្ចុប្បន្នឡើយ

ខ្ញុំមិនអាចគិតស្រមៃថា មានពេលណាដែលអស្ចារ្យជាងការធ្វើជាសមាជិកនៃសាសនាចក្រឡើយ ។ ពេលភរិយាខ្ញុំ និង រូបខ្ញុំរៀបការ មានព្រះវិហារបរិសុទ្ធតែ 13 ប៉ុណ្ណោះនៅក្នុងសាសនាចក្រទាំងមូល ហើយយើងមានគោលដៅដើម្បីទៅលេងគ្រប់ព្រះវិហារបរិសុទ្ធទាំងនោះ ។ ឥឡូវនេះមានព្រះវិហារបរិសុទ្ធប្រហែល 140 នៅជុំវិញពិភពលោក ហើយយើងនឹងមិនអាចទៅលេងព្រះវិហារបរិសុទ្ធទាំងអស់នោះបានទេ ។ ផលផ្លែទាំងអស់នៃការស្ដារឡើងវិញនេះ—ព្យាការី និង សាវក, ព្រះវិហារបរិសុទ្ធ, បព្វជិតភាព, ព្រះគម្ពីរមរមន, វិវរណៈ—គឺជាពរជ័យដ៏មហិមាមួយនៅក្នុងជីវិតរបស់យើង ។ ហើយវាអាចកើតឡើងបាន ដោយសារព្រះអង្គសង្គ្រោះ ដោយសារដំណឹងល្អរបស់ទ្រង់ ដោយសារផែនការរបស់ព្រះវរបិតារបស់យើង ។

ប្រហែលជាខ្ញុំគឺជាមនុស្សសាមញ្ញម្នាក់ចំពោះរឿងអ្វីៗជាច្រើន ប៉ុន្តែខ្ញុំឆ្លាតវៃគ្រប់គ្រាន់ដើម្បីដឹងថាព្រះវរបិតាសួគ៌របស់ខ្ញុំ ទ្រង់ស្រឡាញ់ខ្ញុំ ។ ទ្រង់ស្រឡាញ់ពួកយើងទាំងអស់គ្នា ។ យើងពិតជាបុត្រា និង បុត្រីរបស់ទ្រង់ ។ ទ្រង់ពិតជាចង់ឲ្យយើងត្រឡប់ទៅកាន់ទ្រង់វិញ ។ ទ្រង់មិនគ្រប់គ្រងរឿងលម្អិតនៃជីវិតរបស់យើងនោះទេ ។ នោះគឺជាផ្នែកមួយនៃដំណើរការរីកចម្រើនរបស់យើង ។ ទ្រង់ចង់ឲ្យយើងរៀន ហើយអនុវត្តសិទ្ធិសេរីភាព និងដោះស្រាយនឹងទុក្ខលំបាក ។ ប៉ុន្តែ តាមពិត ខ្ញុំអាចឃើញព្រះហស្តទ្រង់នៅក្នុងជីវិតរបស់ខ្ញុំ និង គ្រួសាររបស់ខ្ញុំ ។ ហើយខ្ញុំមានអំណរគុណ ដែលយើងទទួលបទពិសោធន៍នៃជីវិតរមែងស្លាប់នេះ ពីព្រោះខ្ញុំស្រឡាញ់ជីវិតនេះ ។ មានអ្វីៗមិនល្អជាច្រើនបានកើតឡើង ប៉ុន្តែក៏មានអ្វីៗអស្ចារ្យជាច្រើនបានកើតឡើងក្នុងជីវិតនេះ ហើយខ្ញុំមានអំណរគុណ ដែលយើងជាវិញ្ញាណតែមានឱកាសដើម្បីមកលើផែនដី ហើយទទួលរូបកាយ និង រៀននូវអ្វីៗជាច្រើន ដែលនឹងជួយយើងរហូតឈានដល់ភាពអស់កល្បអស់កាលជានិច្ច ។

ប្រវត្តិសាស្ត្រផ្ដល់ពរជ័យដល់ជីវិតរបស់យើង ព្រោះវាផ្ដល់ឱកាសឲ្យយើងងាកទៅមើលអតីតកាល ។ ពេលខ្លះវាមានការលំបាកដើម្បីមើលជីវិតផ្ទាល់ខ្លួនយើងកាលពីអតីតកាល ប៉ុន្តែតាមរយៈប្រវត្តិសាស្ត្រ យើងអាចងាកមើលពីអតីតកាលនៅក្នុងជីវិតរបស់មនុស្សដទៃទៀត ហើយរៀនពីពរជ័យដែលបានប្រទានដល់ពួកគេ ។ ហើយយើងអាចជួយខ្លួនយើងចៀសវាងការធ្វើខុស ដោយធ្វើអ្វីៗដែលបានផ្ដល់ពរជ័យដល់បុព្វការីជនរបស់យើង ។ ■



ដោយ អែលឌើរ
ឌី. ថត គ្រីស្តូហ្វើសិន
នៃកូរ៉ុមនៃពួកសាវកដប់
ពីរនាក់



# ការបំផុសគំនិត

*ទីបន្ទាល់មួយអាចមានដល់មនុស្សទូទៅគ្រប់គ្នា មិនថាពួកគេនៅទីណានោះទេ ដោយសារព្រះវរបិតាសួគ៌របស់យើង និង ព្រះវិញ្ញាណបរិសុទ្ធស្គាល់យើងគ្រប់គ្នាម្នាក់ៗដោយផ្ទាល់ ។*

**ការស្វែងរកចម្លើយមួយនៅក្នុងព្រៃពិសិដ្ឋ**

កាលពីខ្ញុំនៅក្មេង ខ្ញុំមានឱកាសទៅទីក្រុង ប៉ាលម៉ៃរ៉ា រដ្ឋ នូវយ៉ោក នៅល្ងាចមួយនៃរដូវក្ដៅ ។ ខ្ញុំបានទៅក្នុងព្រៃពិសិដ្ឋតែម្នាក់ឯង ។ ខ្ញុំបានលុតជង្គង់ចុះអធិស្ឋាន ដោយសុំព្រះវរបិតាសួគ៌ ដើម្បីប្រទានភស្តុតាងមួយចំនួនដល់ខ្ញុំ ឬ បង្ហាញខ្ញុំអំពីអ្វី ដែលខ្ញុំពិតជាបានដឹងរួចទៅហើយថាបានកើតឡើងនៅក្នុងកន្លែងដ៏ពិសិដ្ឋនោះ ។ ខ្ញុំបានអធិស្ឋានដោយស្មោះអស់ពីចិត្តខ្ញុំយ៉ាងខ្លាំង អស់រយៈពេលយ៉ាងយូរ នៅក្នុងឥរិយាបថនៃគារវភាព ។ ហើយខ្ញុំគ្មានបានទទួលចម្លើយ ឬ ការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធអ្វីសោះឡើយ ។ គ្មានអ្វីកើតឡើងសោះ ។ ទីបំផុត ខ្ញុំបានបោះបង់ការអធិស្ឋាននោះ ហើយបានចាកចេញទាំងខកចិត្ត ដោយឆ្ងល់ថា « តើមានអ្វីខ្លះដែលខ្ញុំមិនបានធ្វើត្រឹមត្រូវនោះ ? ហេតុអ្វី ? តើខ្ញុំចាំបាច់ត្រូវការធ្វើអ្វីបន្ថែមទៀត ? » សម្រាប់ខ្ញុំ បរិយាកាសនៅទីនោះ វាហាក់បីដូចជាគ្មានកន្លែងណាផ្សេងទៀតប្រសើរជាងកន្លែងនេះ ដើម្បីទទួលចម្លើយចំពោះការអធិស្ឋានបែបនោះឡើយ ។

ខ្ញុំបានរៀនពីបទពិសោធន៍នោះថា យើងមិនអាចតម្រូវទាមទារអ្វីៗពីព្រះបាននោះទេ ។ យើងមិនអាចនិយាយថា « ទ្រង់ត្រូវតែឆ្លើយតបមកទូលបង្គំតាមវិធីនេះ ហើយឥឡូវនេះ » នោះទេ ។ វាអាស្រ័យលើទ្រង់ ដើម្បីសម្រេចពីរបៀប និង ពេលវេលា និង អ្វីដែលទ្រង់នឹងមានបន្ទូលមកកាន់យើង ។ ទំនួលខុសត្រូវរបស់យើង គឺត្រូវនៅក្នុងលក្ខខណ្ឌត្រឹមត្រូវជានិច្ច ដើម្បីទទួលការបំផុស ឬ ការខ្សឹបប្រាប់វិវរណៈ ការបំផុសគំនិតពីព្រះវិញ្ញាណ ។ ប៉ុន្តែទ្រង់នឹងធ្វើការសម្រេចព្រះហឫទ័យពីរបៀបណា និង ពេលណា ។

**ការទទួលចម្លើយនៅឯផ្ទះ**

អ្វីដែលខ្ញុំបានស្វែងរកនៅពេលនោះ—ដែលមិនទាន់បានទទួលចម្លើយនៅឡើយនៅពេលនោះ—នោះពិតជាបានឆ្លើយតបមកខ្ញុំនៅប្រាំ ឬ ប្រាំមួយសប្ដាហ៍ក្រោយមក ។ ខ្ញុំនៅផ្ទះកំពុងអានព្រះគម្ពីរមរមន ។ ហើយដោយទាំងពុំបានសួរផង នោះមានការបំផុសគំនិតដ៏ខ្លាំងមួយមកដល់ខ្ញុំ, ជាអារម្មណ៍ និង ការទំនាក់ទំនងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលបានបញ្ជាក់ពីការជឿ និង ពីទីបន្ទាល់របស់ខ្ញុំ ។

វាគឺជាទំនាក់ទំនងមួយដ៏ខ្លាំង ដែលបានធ្វើឲ្យខ្ញុំយំ ។ វាគឺពិតជាការទំនាក់ទំនងដ៏បរិសុទ្ធ ដែលវាមិនចាំបាច់ត្រូវតែចេញជាពាក្យសម្ដីឡើយ ។ ព្រះវិញ្ញាណមិនចាំបាច់



# យ៉ាងខ្លាំងពីព្រះវិញ្ញាណ



កំណត់ថា ត្រូវតែនិយាយចេញជាពាក្យសម្ដីនោះទេ ទ្រង់អាចទំនាក់ទំនងរវាងវិញ្ញាណ និង វិញ្ញាណ ជាមួយនឹងភាសាមួយយ៉ាងច្បាស់អស្ចារ្យ ពីព្រោះវាគ្មានពាក្យសម្ដីឡើយ ។ វាគឺជាទំនាក់ទំនងនៃការចេះដឹងពេញទី និងប្រាជ្ញាដែលមកពីព្រះវិញ្ញាណ ហើយខ្ញុំបានដឹងថា វាគឺពិតជារបៀបមួយដ៏ល្អបំផុតដើម្បីទទួលបានចំណេះដឹង ។ វាខ្លាំងជាង និង នៅជាប់លាប់ជាង ការប៉ះ ឬ ការឃើញទៅទៀត យើងអាចសង្ស័យខាងកាយវិញ្ញាណ ប៉ុន្តែយើងមិនអាចសង្ស័យបានទេ នៅពេលព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូលមកកាន់យើងនោះ ។ វាពិតជាសាក្សីដ៏ច្បាស់លាស់បំផុត ។ ដោយសារតែការណ៍នេះ អំពើបាបដែលពុំអាចអភ័យទោសឲ្យបាននោះ គឺការបដិសេធព្រះវិញ្ញាណបរិសុទ្ធ ឬ ទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធ ។

## ការទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់ និង ការយល់ចិត្តពីព្រះ

ខ្ញុំពិតជាមានអារម្មណ៍ថា មិនថ្វីទេ ដែលព្រះអម្ចាស់មិនបានប្រទានចម្លើយមកខ្ញុំនៅក្នុងព្រៃពិសិដ្ឋ ដោយសារប្រហែលជាខ្ញុំបានគិតថា មនុស្សម្នាក់ត្រូវតែទៅទីក្រុងប៉ាលម៉ៃរ៉ា ដើម្បីទទួលបានទីបន្ទាល់មួយអំពីព្យាការី

យ៉ូសែប ស្ម៊ីធ ។ ឥឡូវនេះខ្ញុំដឹងថា ទីបន្ទាល់នោះ អាចមកបានគ្រប់ទីកន្លែង ។ អ្នកមិនចាំបាច់ត្រូវទៅក្រុង យេរូសាឡិម ដើម្បីទទួលទីបន្ទាល់អំពីព្រះអម្ចាស់ យេស៊ូវគ្រីស្ទឡើយ ។ ទីបន្ទាល់នោះ អាចមានដល់មនុស្សទូទៅគ្រប់គ្នា មិនថាពួកគេនៅទីណានោះទេ ដោយសារព្រះវរបិតាសួគ៌របស់យើង និង ព្រះវិញ្ញាណបរិសុទ្ធស្គាល់យើងគ្រប់គ្នាម្នាក់ៗដោយផ្ទាល់ ។ ពួកទ្រង់ដឹងថា យើងនៅទីណា ហើយដឹងពីរបៀបស្វែងរកយើង ។ ហើយពួកទ្រង់មិនចាំបាច់ត្រូវការទិដ្ឋាការឡើយ ។ ពិតណាស់ពួកទ្រង់ស្គាល់ពិភពលោកទាំងមូល ! ពួកទ្រង់ស្គាល់អស់ហើយ ។

យុវវ័យអើយ ! ខ្ញុំសូមសន្យានឹងអ្នកថា បើសិនអ្នកនឹងបន្តស្មោះត្រង់ បន្តទូលសុំ នោះព្រះអម្ចាស់នឹងប្រទានចម្លើយដូចគ្នានោះ ទីបន្ទាល់ដូចគ្នានោះ ការបញ្ជាក់ដូចគ្នានោះដែលទ្រង់បានប្រទានឲ្យខ្ញុំ ដោយសារខ្ញុំដឹងថា ទ្រង់ស្រឡាញ់អ្នកគ្រប់គ្នាដូចទ្រង់ស្រឡាញ់ខ្ញុំដែរ ឬស្រឡាញ់ប្រធាន ថូម៉ាស អេស. ម៉នសុន ឬ មនុស្សណាក៏ដោយដែលជាកូនចៅរបស់ទ្រង់ ។

សេចក្ដីស្រឡាញ់របស់ព្រះ មានសម្រាប់មនុស្សគ្រប់គ្នា ហើយវាគ្មានដែនកំណត់ឡើយ ។ ទ្រង់ដឹងពីរបៀបដើម្បីទំនាក់ទំនងជាមួយមនុស្សគ្រប់គ្នា ។ ទ្រង់ដឹងថាអ្នកនៅទីកន្លែងណា ហើយដឹងពីរបៀបចូលទៅកាន់ដួងចិត្ត និង វិញ្ញាណរបស់អ្នក តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ សូមកុំឈប់អធិស្ឋានឡើយ ។ សូមកុំឈប់ទូលសួរឡើយ ។ សូមកុំឈប់គោរពតាមព្រះបញ្ញត្តិទាំងឡាយឡើយ ។ បើសិនចម្លើយនោះមិនទាន់មកទេ នោះវានឹងមកដល់ នៅពេលអ្នកនឹងទទួលទីបន្ទាល់ដ៏រឹងមាំនេះ ។ ហើយចម្លើយនោះ នឹងមិនគ្រាន់តែមកម្ដងនោះទេ ។ ប៉ុន្តែតាមរយៈសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ ចម្លើយនោះនឹងមកម្ដងហើយម្ដងទៀតពេញមួយជីវិតរបស់អ្នក ។

## បន្តទទួលសាក្សី

ការណ៍នេះបានកើតឡើងចំពោះខ្ញុំ ។ ខណៈខ្ញុំកំពុងបម្រើបេសកកម្មនៅក្នុងទីក្រុង ទូយូមែន ប្រទេស អាហ្សង់ទីន នោះខ្ញុំកំពុងបង្រៀនគ្រួសារមួយ ហើយថ្លែងទីបន្ទាល់អំពីទស្សនៈនិមិត្តដំបូងរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ។ គ្រួសារនោះ ពុំបានជឿលើទីបន្ទាល់នោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅខណៈដែលខ្ញុំបានថ្លែងទីបន្ទាល់របស់ខ្ញុំនោះ ខ្ញុំបានទទួលការបញ្ជាក់ផ្សេងមួយទៀតអំពីទីបន្ទាល់របស់ខ្ញុំ ។ ព្រះវិញ្ញាណមានព្រះបន្ទូលថា « ពាក្យសម្ដីនៃទីបន្ទាល់របស់អ្នកគឺពិត » ។ ទ្រង់បានថ្លែងទីបន្ទាល់មកកាន់ខ្ញុំ អំពីទីបន្ទាល់របស់ខ្ញុំ ។

ពេញមួយជីវិតរបស់អ្នក អ្នកនឹងទទួលការបញ្ជាក់ម្ដងហើយម្ដងទៀតថា ព្រះគង់នៅទីនោះ ថាទ្រង់គឺជាព្រះវរបិតាសួគ៌របស់យើង ថាទ្រង់មានព្រះជន្មរស់នៅ ថាទ្រង់បានហៅព្យាការី យ៉ូសែប ស្ម៊ីធ ដើម្បីបម្រើជាព្យាការីនៃការស្ដារឡើងវិញ ថាព្រះរាជបុត្រារបស់ទ្រង់មានព្រះជន្មរស់ ហើយថាព្រះគុណរបស់ទ្រង់គឺមានល្មមគ្រប់គ្រាន់ ដើម្បីសង្គ្រោះពួកយើង សម្អាតពួកយើង និងអភ័យទោសឲ្យពួកយើងទាំងអស់គ្នា ។ ទីបន្ទាល់នោះមកម្ដងហើយម្ដងទៀតពេញមួយជីវិតរបស់យើង ។

ខ្ញុំដឹងអំពីការណ៍ទាំងនេះ ។ ខ្ញុំគឺជាសាក្សីពិសេសមួយនៃការណ៍ទាំងនេះ ។ ខ្ញុំដឹងថា ព្រះអម្ចាស់របស់យើងមានព្រះជន្មរស់នៅ ថាទ្រង់ពិតជាអង្គដែលមានព្រះជន្មរស់ឡើងវិញ ថាទ្រង់ដឹកនាំ ហើយគឺជាប្រមុខនៃសាសនាចក្រនេះ ដែលមានព្រះនាមរបស់ទ្រង់ ហើយថានេះគឺជាសាសនាចក្ររបស់ទ្រង់ ហើយថាអ្នកគឺជាកូនចៀមរបស់ទ្រង់ ។ ■

*ដកស្រង់ចេញពីសុន្ទរកថា ដែលបានផ្ដល់ឲ្យទៅកាន់យុវវ័យនៅក្នុងទីក្រុង សាលតា ប្រទេស អាហ្សង់ទីន កាលពីខែ វិច្ឆិកា ឆ្នាំ 2011 ។*



# ឱ ផែនការនៃព្រះរបស់យើង ធំណាស់ហ្ន៎ !



*នៅពេលមួយនោះ ជាពេលដែលមានការឈឺចាប់ និង ឯកោយ៉ាងខ្លាំងនៅក្នុងដួងចិត្តរបស់ខ្ញុំ នោះ ចំណេះដឹងនៃដំណឹងល្អរបស់ខ្ញុំ បានផ្តល់ទំនុកចិត្តដល់ខ្ញុំ ដើម្បីបន្តដំណើរទៅមុខទៀត ។*

**ដោយ អាម៉ាសាណា អ៊ី.**

ខ្ញុំត្រូវបានចិញ្ចឹមបីបាច់នៅកន្លែងមួយដែលសាសនាចក្រមិនសូវមានគេស្គាល់ឡើយ—គឺជាទីក្រុងមួយដែលឥឡូវនេះគេហៅថា បើគ នៅប្រទេស ម៉ុងហ្គោលី ភាគខាងជើង ។ ខ្ញុំជាកូនទីពីរក្នុងចំណោមកូនប្រុសបីនាក់ ហើយចម្រើនវ័យធំឡើង ដោយរស់នៅជាមួយគ្នាគ្រប់ពេល ។ នៅពេលបងប្រុសរបស់ខ្ញុំបានទៅរៀននៅទីក្រុង នោះខ្ញុំនឹកគាត់ខ្លាំងណាស់ ។ ពីរឆ្នាំក្រោយមក គាត់បានត្រឡប់មកផ្ទះវិញក្នុងពេលវិស្សមកាលរដូវក្តៅរបស់គាត់ ។ នៅរដូវក្តៅនោះ គ្រួសាររបស់យើងបានទៅបរបាញ់សត្វអស់រយៈពេលបីខែនៅក្នុងព្រៃភ្នំ ។ វាគឺជាវិស្សមកាលរដូវក្តៅដ៏ល្អបំផុតមួយនៃជីវិតរបស់ខ្ញុំ ។

បងប្រុសរបស់ខ្ញុំបានចាប់ផ្តើមប្រាប់ខ្ញុំអំពីសាសនាចក្រមួយដែលគាត់បានចូលរួម ដែលគេហៅថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ កាលនោះខ្ញុំមិនបានចូលចិត្តព្រះវិហារសាសនាគ្រីស្តទេ ដូច្នេះខ្ញុំមិនបានយកចិត្តទុកដាក់ច្រើនប៉ុន្មានទេអំពីអ្វីដែលគាត់បានប្រាប់ខ្ញុំ ។

នៅថ្ងៃមួយនារដូវស្លឹកឈើជ្រុះ នៅពេលយើងមកដល់ផ្ទះវិញ បន្ទាប់ពីយើងមកពីបរបាញ់សត្វ នោះយើងបានឃើញភ្ញៀវមួយចំនួនមកពីទីក្រុង ។ ពួកគេមកពីព្រះវិហារដែលបងប្រុសរបស់ខ្ញុំបាននិយាយនោះ ។ គាត់បានត្រឡប់ទៅទីក្រុងវិញជាមួយពួកគេនៅយប់នោះ ។ បន្ទាប់មកយើងបានដឹងពីមូលហេតុដែលគាត់បានចេញទៅ ៖ គាត់បានទទួលការហៅបម្រើបេសកកម្ម ។ គាត់មិនបានទាំងប្រាប់ពួកយើងផងថា គាត់បានដាក់ពាក្យបម្រើបេសកកម្ម ! មិនយូរប៉ុន្មានក្រោយមក បងប្រុសរបស់ខ្ញុំបានចាកចេញទៅបេសកកម្មរបស់គាត់ទៅសហរដ្ឋអាមេរិក ។

### ការផ្លាស់ប្រែចិត្តជឿចំពោះដំណឹងល្អ

នៅពេលខ្ញុំបញ្ចប់វិទ្យាល័យ នៅឆ្នាំបន្ទាប់នោះ ខ្ញុំបានទៅទីក្រុងដើម្បីចូលរៀនមហាវិទ្យាល័យ ។ គ្រួសារដែលខ្ញុំស្នាក់នៅជាមួយនោះ គឺជាសមាជិកនៃសាសនាចក្រ ។ នៅព្រឹកថ្ងៃអាទិត្យមួយ ពួកគេបានអញ្ជើញខ្ញុំឲ្យទៅព្រះវិហារជាមួយពួកគេ ។ ដោយសារខ្ញុំធ្លាប់បានឮ

គំនូរគូរដោយ ស៊ីនថៃ ឡាក



## សូម្បីតែគ្រាដ៏លំបាកបំផុតក្នុងជីវិត ក៏អាចក្លាយជាពរជ័យមួយដែរ

« បើសិនយើងមានជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ក្នុងគ្រាដ៏លំបាកបំផុត ក៏ដូចជាគ្រាដែលស្រួលបំផុតនៅក្នុងជីវិត អាចជាពរជ័យមួយទៅវិញ ។ នៅគ្រប់ស្ថានភាពទាំងអស់ យើងអាចជ្រើសរើសត្រូវ ដោយមានការដឹកនាំពីព្រះវិញ្ញាណ ។ យើងមានដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដើម្បីដុសខាត់ និង ដឹកនាំជីវិតយើង បើសិនជាយើងជ្រើសរើសយកដំណឹងល្អ ។ ព្រមជាមួយនឹងអ្វីដែលព្យាការីបានបើកសម្ដែងដល់យើង អំពីកន្លែងរបស់យើង នៅក្នុងផែនការនៃសេចក្ដីសង្គ្រោះ នោះយើងអាចរស់នៅដោយមានក្ដីសង្ឃឹមដ៏ឥតខ្ចោះ និង អារម្មណ៍សុខសាន្ត » ។

**ប្រធាន ហិនរី ប៊ី. អាវរិង ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ « ភ្នំដើម្បីឡើង » *លីអាហូណា* និង *Ensign* ខែ ឧសភា ឆ្នាំ 2012 ទំព័រ 22 ។**

ជាច្រើនពីព្រះវិហារនេះ នោះខ្ញុំបានសម្រេចចិត្តថា ខ្ញុំនឹងសាកល្បងទៅលេងម្ដង ។

នៅទីបំផុត ខ្ញុំចូលរួមព្រះវិហារជាច្រើនដង ។ ខ្ញុំមិនអាចទប់មិនប្រាប់បានទេថា ខ្ញុំតែងតែមានអារម្មណ៍សុខសាន្តគ្រប់ពេលដែលខ្ញុំនៅទីនោះ ។ មនុស្សនៅទីនោះមានចិត្តល្អ ពួកគេតែងតែចាប់ដៃស្វាគមន៍ខ្ញុំជានិច្ច ។ សាសនាចក្រនេះ គឺវាផ្ទុយស្រឡះពីអ្វីដែលខ្ញុំបានគិត ។ មិនយូរប៉ុន្មាន ខ្ញុំបានចាប់ផ្ដើមរៀនជាមួយអ្នកផ្សព្វផ្សាយសាសនា ។ ខ្ញុំបានជួបជាមួយអ្នកផ្សព្វផ្សាយសាសនាអស់រយៈពេលស្មើរតែជិតពីរឆ្នាំ ។

ខ្ញុំបានដឹងថា ខ្ញុំចង់ជ្រមុជទឹក ប៉ុន្តែពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំត្រូវបានពន្យាពេល ដោយសារខ្ញុំនៅមានឧបសគ្គជាមួយនឹងច្បាប់គតិបណ្ឌិត ។ វាពិតជាលំបាកណាស់សម្រាប់ខ្ញុំ ប៉ុន្តែនៅទីបំផុត ខ្ញុំបានត្រៀមខ្លួនជាស្រេចសម្រាប់បុណ្យជ្រមុជទឹក ។ ខ្ញុំមានសំណាងណាស់ ដែលបានបងប្រុសរបស់ខ្ញុំជ្រមុជទឹកឲ្យខ្ញុំ ដែលគាត់បានត្រឡប់ពីបេសកកម្មរបស់គាត់វិញ តែប៉ុន្មានខែមុននោះប៉ុណ្ណោះ ។ នៅពេលខ្ញុំរំឭកពីពេលនោះ ពេលខ្លះធ្វើឲ្យខ្ញុំយំ ។ វាគឺជាពេលដ៏មានសុភមង្គលបំផុតនៃជីវិតរបស់ខ្ញុំ ។

បន្ទាប់ពីខ្ញុំបានចូលរួមក្នុងសាសនាចក្រ បងប្រុសរបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំពីកិច្ចការផ្សព្វផ្សាយសាសនាប្រាប់ខ្ញុំស្ទើរតែរាល់ថ្ងៃ ។ គាត់តែងតែលើកទឹកចិត្តខ្ញុំដើម្បីបម្រើបេសកកម្ម ។ ដោយមានជំនួយពីគាត់ នោះខ្ញុំបានបំពេញពាក្យស្នើសុំបម្រើបេសកកម្មរបស់ខ្ញុំ ។ ខ្ញុំនឹងមិនដែលភ្លេចពីភាពសប្បាយរីករាយដ៏ខ្លាំង ដែលបងប្រុសរបស់ខ្ញុំ និង រូបខ្ញុំបានមាននៅពេលនោះឡើយ ។

### បទពិសោធន៍មួយដែលគួរឲ្យរន្ធត់

នាល្ងាចមួយ បងប្រុសរបស់ខ្ញុំបានទូរស័ព្ទហៅខ្ញុំឲ្យមកជួបគាត់បន្ទាប់ពីចេញពីធ្វើការ ។ គាត់ចង់និយាយជាមួយខ្ញុំ អំពីអ្វីដែលទាក់ទងនឹងបេសកកម្មរបស់ខ្ញុំ ។ យើងបានណាត់ម៉ោងជួបគ្នានៅទីប្រជុំជនកណ្ដាលទីក្រុង ។

អំឡុងពេលនេះ គឺជាពេលនៃការបោះឆ្នោតរដ្ឋសភាត្រូវបានធ្វើឡើងនៅក្នុងប្រទេស ម៉ុងហ្គោលី ។ នៅពេលយើងបានជួបគ្នានៅទីប្រជុំជនកណ្ដាលទីក្រុង នោះប្រជាជនបានធ្វើបាតុកម្ម ដោយសារតែការបោះឆ្នោតនោះ ។ ប៉ូលីសបាននៅទីនោះ ប៉ុន្តែបាតុកម្មកាន់តែសាហាវ និង គួរឲ្យភ័យខ្លាច ហើយធ្វើឲ្យកាន់តែរីករាលដាលធំឡើងទៅជាកុប្បកម្ម ។ អគារធំៗ និង រថយន្តមួយចំនួនត្រូវបានដុតបំផ្លាញ ហើយមនុស្សម្នាស្រែកកងរំពង ។ វាគួរឲ្យរន្ធត់ណាស់ ។

បងប្រុសរបស់ខ្ញុំ និង ខ្ញុំបានជួបគ្នានៅឆ្ងាយពីកន្លែងបាតុកម្ម ប៉ុន្តែគាត់មានការព្រួយបារម្ភ ។ គាត់បានឲ្យលុយខ្ញុំជិះតាក់ស៊ី ហើយបានប្រាប់ខ្ញុំឲ្យទៅផ្ទះភ្លាម ។ គាត់បានប្រាប់ខ្ញុំថា ខ្ញុំនឹងជួបគាត់នៅថ្ងៃបន្ទាប់ទៀត ។ គាត់បានដាក់ផែនការត្រឡប់ទៅផ្ទះគាត់វិញ ដែលនៅជិត



កន្លែងធ្វើការរបស់គាត់ ។ ឡានតាក់ស៊ីបានមកដល់ ហើយយើងបាននិយាយលាគ្នាយ៉ាងលឿន មុនពេលខ្ញុំចាកចេញទៅ ។

ភ្លាមនោះខ្ញុំដឹងថា រដ្ឋាភិបាលបានបិទគ្រប់ផ្លូវទាំងអស់ ដោយសារតែកុប្បកម្ម ។ ដោយមិនអាចទៅផ្ទះខ្ញុំដែលនៅឯជាយទីក្រុងវិញបាន នោះខ្ញុំបានគេងនៅកន្លែងធ្វើការនៅយប់នោះ ។ រថយន្តយោធា និង កងប្រដាប់អាវុធបាននៅគ្រប់ទីកន្លែង ។ ការប្រយុទ្ធគ្នាកាន់តែសាហាវទៅៗ ហើយនៅយប់នោះច្បាប់ប្រកាសអាសន្នត្រូវបានបង្កើតឡើង ។ វាមានរយៈពេលបួនថ្ងៃ ។

នៅពេលដែលច្បាប់ប្រកាសអាសន្នត្រូវបានបញ្ចប់ បងថ្លៃប្រុសរបស់ខ្ញុំបានមកទទួលខ្ញុំ ។ យើងបានធ្វើដំណើរទៅផ្ទះរបស់គាត់ ដើម្បីជួបសាច់ញាតិទាំងអស់របស់យើង ដែលរង់ចាំនៅទីនោះ ។ ពួកគេទាំងអស់គ្នាបានយំ ។ ខ្ញុំបានដឹងថា បងប្រុសរបស់ខ្ញុំត្រូវបានគេបាញ់ នៅពេលគាត់កំពុងដើរមកផ្ទះវិញ ។

ដួងចិត្តរបស់ខ្ញុំ ហាក់បីដូចជាចង់ប្រេះធ្លាយបែក ។ បងប្រុសរបស់ខ្ញុំបានស្លាប់ ពេលគាត់អាយុ 24 ឆ្នាំ ដោយសារតែបាតុកម្មនោះ ។ ច្រើនថ្ងៃ បន្ទាប់ពីមរណភាពរបស់បងប្រុសខ្ញុំមក វាគឺជាពេលដ៏ជូរចត់ខ្លាំងបំផុតនៃជីវិតរបស់ខ្ញុំ ។

វាគឺជាអំឡុងពេលលំបាកនេះហើយ ដែលខ្ញុំបានទទួលការហៅបម្រើបេសកកម្មរបស់ខ្ញុំ ។ បន្ទាប់ពីបានឆ្លងកាត់ការប្រែចិត្តជឿរបស់ខ្ញុំ បុណ្យជ្រមុជទឹក និង ការរៀបចំពាក្យស្នើសុំបេសកកម្មជាមួយបងប្រុសរបស់ខ្ញុំមក នោះខ្ញុំត្រូវបានទុកឲ្យនៅតែម្នាក់ឯងដើម្បីបើកការហៅបម្រើបេសកកម្មរបស់ខ្ញុំ ។ ខ្ញុំមានក្ដីរំភើប ដែលខ្ញុំត្រូវបានហៅបម្រើនៅក្នុងប្រទេសកំណើតខ្លួនផ្ទាល់ ។

ទោះបីជាខ្ញុំនៅម្នាក់ឯងក៏ដោយ ខ្ញុំបានលុតជង្គង់ចុះនៅទីនោះ ហើយថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌របស់ខ្ញុំនៅក្នុងការអធិស្ឋាន ។ ហើយខ្ញុំបានអធិស្ឋានសម្រាប់បងប្រុសរបស់ខ្ញុំ ។ ខ្ញុំយំហើយយំទៀត នៅពេលខ្ញុំអធិស្ឋាន ។ នៅពេលនេះ នៅពេលដែលមានការឈឺចាប់ និង ភាពឯកោយ៉ាងខ្លាំងនៅក្នុងដួងចិត្តរបស់ខ្ញុំ នោះខ្ញុំមានអារម្មណ៍ពីព្រះវិញ្ញាណ ធ្វើជាសាក្សីពីផែនការនៃសេចក្ដីសង្គ្រោះកាន់តែជ្រាលជ្រៅឡើងចំពោះខ្ញុំ ហើយសេចក្ដីជំនឿរបស់ខ្ញុំត្រូវបានពង្រឹង ។

## ទីបន្ទាល់អំពីផែនការរបស់ទ្រង់

ទោះបីជាបងប្រុសរបស់ខ្ញុំមិនបាននៅទីនោះ ដើម្បីបើកការហៅបម្រើបេសកកម្មរបស់ខ្ញុំ ជាមួយខ្ញុំក៏ដោយ ក៏ខ្ញុំនឹងនៅតែមានអំណរគុណចំពោះគាត់ជានិច្ច ។ ខ្ញុំក៏តែងតែមានអំណរគុណផងដែរ ដែលព្រះបានប្រទានផែនការនៃសេចក្ដីសង្គ្រោះដល់យើង តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ វាគឺជាផែនការដ៏អស្ចារ្យបំផុត ។ បើសិនយើងធ្វើតាមផែនការនេះ នោះយើងនឹងមានអារម្មណ៍សុខសាន្តនៅក្នុងដួងចិត្តរបស់យើង ។

ព្រះគម្ពីរបានប្រាប់យើងថា ៖ « ឱ ផែនការនៃព្រះរបស់យើងធំណាស់ហ្ន៎ ! ត្បិត . . . ស្ថានបរមសុខនៃព្រះក៏ត្រូវប្រគល់វិញ្ញាណទាំងឡាយនៃពួកសុចរិត ឯផ្នូរវិញក៏ត្រូវប្រគល់រូបកាយទាំងឡាយនៃពួកសុចរិត ហើយវិញ្ញាណ និង រូបកាយក៏បានចូលរួមគ្នាវិញ ហើយមនុស្សលោកទាំងអស់ នឹងក្លាយទៅជាមិនពុករលួយ ហើយក្លាយទៅជាអមតៈ ហើយពួកគេជាព្រលឹងដែលមានជីវិត » ( នីហ្វៃទី 2 9:13 ) ។

ខ្ញុំដឹងថាបងប្រុសរបស់ខ្ញុំ កំពុងរស់នៅក្នុងភពវិញ្ញាណ ។ ចំណេះដឹងនេះ ផ្ដល់ទំនុកចិត្តដល់ខ្ញុំថា ខ្ញុំត្រូវតែធ្វើការឲ្យល្អនៅក្នុងបេសកកម្មខ្ញុំ ។ ខ្ញុំដឹងថាគាត់នឹងនៅជាមួយខ្ញុំអំឡុងពេលខ្ញុំជួបការលំបាក—ហើយទ្រង់ក៏នៅជាមួយខ្ញុំផងដែរ ។ ■





ពីឆ្វេងទៅស្ដាំ ៖ អាម៉ាសាណា និង បងប្អូនប្រុសរបស់គាត់ ដវស៊ូរេន និង អាម៉ាសៃខាន់



# របៀបប្រាំយ៉ាងដើម្បីធ្វើតាមដំបូន្មានរបស់អ្នកដឹកនាំបព្វជិតភាព

*ព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់សិស្សរបស់ទ្រង់ ហើយបានបង្រៀនមនុស្សនៅជំនាន់របស់ទ្រង់ ។ សព្វថ្ងៃនេះ ទ្រង់នៅតែបន្តធ្វើដូច្នេះដដែល ។*

ទោះបីជាព្រះអង្គសង្គ្រោះមិនមានរូបកាយនៅក្នុងចំណោមពួកយើងក៏ដោយ ក៏ទ្រង់បានហៅសមាជិកនៃសាសនាចក្ររបស់ទ្រង់ ដើម្បីដឹកនាំ និងណែនាំពួកយើង ហើយទ្រង់បានសុំឲ្យយើងធ្វើតាមការទូន្មានរបស់ពួកគេ នៅពេលពួកគេទទួលការទូន្មាននោះតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

## តើនរណាជាអ្នកទទួលវិវរណៈដែលមានប្រសិទ្ធភាពចំពោះខ្ញុំ ?

វិវរណៈអាចមកកាន់អ្នកផ្ទាល់តាមរយៈព្រះវិញ្ញាណ ហើយវិវរណៈក៏អាចមកតាមរយៈអ្នកដឹកនាំបព្វជិតភាពទាំងឡាយ ដែលបានញែកចេញសម្រាប់ការហៅបម្រើជាក់លាក់នានា ដើម្បីជួយពួកគេឲ្យទទួលបានការណែនាំសម្រាប់អស់អ្នកដែលត្រូវបានផ្ទុកផ្ដាក់ឲ្យពួកគេថែរក្សា ។

ព្យាការីទទួលវិវរណៈសម្រាប់សាសនាចក្រទាំងមូល គណៈប្រធានតំបន់របស់អ្នក ទទួលវិវរណៈសម្រាប់តំបន់របស់អ្នក ប្រធានស្តេករបស់អ្នកទទួលវិវរណៈសម្រាប់ស្តេករបស់អ្នក ហើយប៊ីស្សពរបស់អ្នកទទួលវិវរណៈសម្រាប់វួដរបស់អ្នក ។ វិវរណៈមានដល់បុគ្គលទាំងនេះតាមការហៅបម្រើរបស់ពួកគេ ប៉ុន្តែវិវរណៈទាំងនោះ គឺមកពីប្រភពតែមួយ ៖ គឺព្រះវរបិតាសួគ៌ ។

## តើការគាំទ្រអ្នកដឹកនាំរបស់យើង មានន័យដូចម្ដេច ?

ការលើកដៃស្ដាំរបស់យើងឡើងជារាងកែង នៅពេលគាំទ្រមនុស្ស គឺជាការបង្ហាញខាងរូបកាយថា យើងសន្យាដើម្បីផ្ដល់កិត្តិយស គោរព និង គ្រាំទ្រពួកគេ ខណៈដែលពួកគេព្យាយាមតម្កើងការហៅបម្រើរបស់ពួកគេ ។ ការធ្វើតាមដំបូន្មានរបស់អ្នកដឹកនាំរបស់យើង គឺជារបៀបមួយដែលយើងអាចគាំទ្រដល់ពួកគេ ។ អ្នកដឹកនាំមានប្រាជ្ញា និង ទស្សនៈវិស័យ ហើយការណែនាំរបស់ពួកគេគឺជាមធ្យោបាយ ដើម្បីជួយពួកយើងឲ្យរស់នៅតាមដំណឹងល្អ ។ តាមរយៈការគោរពប្រតិបត្តិតាមដំបូន្មានរបស់ពួកគេ នោះយើងនឹងបង្កើននូវសេចក្ដីជំនឿ និងពង្រឹងទីបន្ទាល់របស់យើង ។

នេះជារបៀបប្រាំយ៉ាង ដែលអ្នកអាចធ្វើតាមដំបូន្មានរបស់អ្នកដឹកនាំបព្វជិតភាពរបស់អ្នកបាន ៖

1. *ចូលរួមសន្និសីទទូទៅ សន្និសីទស្តេក និងសន្និសីទវួដ ។* អ្នកប្រហែលជាចង់យកក្រដាស និង ប៊ិចទៅជាមួយដើម្បីកត់ត្រាចំណាំ ។ នៅពេលអ្នកស្ដាប់អ្នកដឹកនាំបព្វជិតភាពរបស់អ្នក នោះសូមកត់ត្រាការបំផុសគំនិតណាក៏ដោយ ដែលអ្នកទទួលអារម្មណ៍ អ្វីៗដែលអ្នកគួរធ្វើ ឬ ការផ្លាស់ប្ដូរដែលអ្នកគួរធ្វើនៅក្នុងជីវិតរបស់អ្នក ។ សូមប្រាកដថា អ្នកកត់ចំណាំនៅពេលពួកគេនិយាយមកកាន់អ្នក នៅក្នុងការប្រជុំសាសនាចក្រផ្សេងៗ ឬ ការសម្ភាសន៍ផងដែរ ។
2. *អធិស្ឋានដើម្បីទទួលទីបន្ទាល់អំពីដំបូន្មានដែលពួកគេផ្ដល់ឲ្យ ។* ព្រះវិញ្ញាណបរិសុទ្ធអាចធ្វើទីបន្ទាល់ដល់អ្នកថា ដំបូន្មានដែលបានផ្ដល់ឲ្យគឺជាបំណងរបស់ព្រះវរបិតាសួគ៌ ។
3. *សូមធ្វើផែនការជាក់លាក់ពីរបៀបដែលអ្នកនឹងបញ្ចូលការទូន្មាននោះ នៅក្នុងជីវិតរបស់អ្នក ។* ឧទាហរណ៍ ព្យាការីបានទូន្មានសមាជិកទាំងឡាយនៃសាសនាចក្រថា ឲ្យទទួលការ

## អ្នកអាចគាំទ្រអ្នកដឹកនាំក្នុងមូលដ្ឋានអ្នកដោយ ៖

- ទទួលការហៅបម្រើ ។
- ផ្ដល់ជំនួយ នៅពេលត្រូវបានស្នើសុំឲ្យជួយ ។
- រៀបចំមេរៀន ដោយអានមេរៀននោះទុកជាមុន ។
- អធិស្ឋានសម្រាប់អ្នកដឹកនាំរបស់អ្នក ។
- ចូលរួមនៅក្នុងថ្នាក់រៀន ។

អប់រំ ។ តើផែនការរបស់អ្នកមានអ្វីខ្លះ ? តើអ្នកនឹងទៅរៀនមហាវិទ្យាល័យ ឬ សាលាវិជ្ជាជីវៈ ឬទេ ? តើអ្នកនឹងរៀនអ្វី ? តើអ្នកនឹងទៅរៀននៅពេលណា ? តើអ្នកកំពុងធ្វើអ្វីខ្លះនៅពេលនេះ ដើម្បីរៀបចំខ្លួនអ្នក ដើម្បីអ្នកនឹងត្រូវបានទទួលឲ្យចូលរៀនក្នុងកម្មវិធីដែលអ្នកចង់រៀននោះ ?

4. *សូមស្វែងរកព័ត៌មានថ្មីៗសម្រាប់ខ្លួនអ្នកជានិច្ច* ។ សូមរៀនពីការទូន្មានថ្មីៗរបស់អ្នកដឹកនាំសាសនាចក្រ តាមរយៈការអានឯកសារទាំងឡាយរបស់សាសនាចក្រ ។ សៀវភៅ *ដើម្បីកម្លាំងនៃយុវជន*គឺជាធនធានមួយដ៏អស្ចារ្យ ។ *លីអាហូណា*មានពាក្យសម្ដីរបស់ព្យាការី និងសាវកទាំងឡាយ ។ បើសិនវួដ ឬ សាខារបស់អ្នកមាននូវក្ដារប្រកាសព័ត៌មាន មួយ នោះសូមអានសារលិខិតទាំងឡាយណាដែលបានផ្ដល់ឲ្យដោយអ្នកដឹកនាំបព្វជិតភាពក្នុងមូលដ្ឋានរបស់អ្នក ។ អ្វីដែលសំខាន់បំផុតនោះ គឺរំឭកពីអ្វីដែលអ្នកដឹកនាំបានមានប្រសាសន៍នៅក្នុងសន្និសីទទូទៅនាពេលថ្មីៗ ។

5. *សូមចាប់ផ្ដើមពីពេលនេះភ្លាម* ។ ពេលខ្លះយើងត្រូវបានល្បួង ឲ្យពន្យារពេលក្នុងការធ្វើតាមការទូន្មានរបស់អ្នកដឹកនាំរបស់យើង ។ បន្ទាប់ពីអ្នកបានធ្វើផែនការជាក់លាក់ ដើម្បីបញ្ចូលការទូន្មាននោះហើយ សូមធ្វើវាភ្លាម ។ ■



## ខ្ញុំបានធ្វើតាមការអញ្ជើញរបស់គណៈប៊ីស្សព

**ពេល**ជិតចុងឆ្នាំសិក្សានៃថ្នាក់ទីប្រាំពីររបស់ខ្ញុំ ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍ថា ខ្ញុំមិនបានធ្វើអ្វីមួយចំនួន ។ ខ្ញុំបានអធិស្ឋានរាល់យប់ ហើយបានចូលរួមនឹងកិច្ចការព្រះវិហារ ប៉ុន្តែវាហាក់បីដូចជាមិនគ្រប់គ្រាន់សោះ ។ ខ្ញុំបានគិតអំពីការអានព្រះគម្ពីរមរមន ហើយរកមើលថា តើសាសនាចក្រនេះពិតជាសាសនាចក្រពិតមែនឬ ប៉ុន្តែខ្ញុំមានការភ័យខ្លាចក្នុងការឈានចេញពីស្ថានភាពដែលខ្ញុំមានភាពងាយស្រួល ដើម្បីទៅធ្វើឲ្យប្រាកដថា សាសនាចក្រគឺពិត ។

គណៈប៊ីស្សពរបស់ខ្ញុំ បានអញ្ជើញក្រុមយុវវ័យរបស់យើង ឲ្យអានព្រះគម្ពីរដោយផ្ទាល់ខ្លួនឲ្យបានទៀងទាត់ ។ ខ្ញុំមានបំណងដើម្បីធ្វើតាម ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំគ្មានពេលគ្រប់គ្រាន់ឡើយ ។

បន្ទាប់មកខ្ញុំមានអារម្មណ៍មួយយ៉ាងខ្លាំងថា ខ្ញុំ ត្រូវតែអានព្រះគម្ពីរមរមន ហើយរកមើលថា តើព្រះគម្ពីរនេះពិតទេ ។ ខ្ញុំនៅតែមានអារម្មណ៍ថា ខ្ញុំមិនអាចស្វែងរកភាពសុខសាន្តបានទេ បើសិនខ្ញុំមិនបានអានវា ។

ខ្ញុំបានចាប់ផ្ដើមអាន ហើយស្ទើរតែមិនបានប្រហែលជាពាក់កណ្ដាលជំពូកទីមួយផង នៅពេលដែលខ្ញុំមានអារម្មណ៍ពីព្រះវិញ្ញាណយ៉ាងខ្លាំង គឺខ្ញុំមិនធ្លាប់មានពីមុនមកទេ ។ វាពិតជាអារម្មណ៍នៃភាពសុខសាន្ត ខ្ញុំចង់ឲ្យអារម្មណ៍នោះនៅជាមួយខ្ញុំជារៀងរហូត ។

ខ្ញុំមានអំណរគុណចំពោះអ្នកដឹកនាំរបស់ខ្ញុំ ដែលត្រូវបានបំផុសគំនិត ឲ្យអញ្ជើញពួកយើងអានព្រះគម្ពីរមរមន ។ ពួកគេតែងតែត្រៀមខ្លួនរួចជាស្រេចដើម្បីជួយ នៅពេលខ្ញុំមានបញ្ហាខាងវិញ្ញាណ ។ ខ្ញុំដឹងថា ដំណឹងល្អគឺពិត ត្បិតដំណឹងល្អបានផ្ដល់ពរជ័យដល់ខ្ញុំយ៉ាងច្រើន ។

**ខាមរីន ជី. រដ្ឋ យូថាហ៍ ស.រ.អា.**

ខាងឆ្វេង ៖ រចនារូបថតដោយ ស្ទីវ ប៊ុនឌើរសាន់ ហាមថតចម្លង នៅខាងស្ដាំផ្លាយ ៖ រចនារូបថតដោយ អែលឌុន លីនខូធិន

**មេរៀនថ្ងៃអាទិត្យ**

ប្រធានបទសម្រាប់ខែនេះ ៖

បព្វជិតភាព និង កូនសោបព្វជិតភាព

## សូមចូលរួមការសន្ទនានេះ



**ពេញ**មួយខែ មិថុនា អ្នកនឹងសិក្សាអំពីបព្វជិតភាពនៅក្នុងថ្នាក់យុវនារីរបស់អ្នក និង ថ្នាក់សាលាថ្ងៃអាទិត្យរបស់អ្នក និង កូរ៉ុមបព្វជិតភាពរបស់អ្នក ។ សូមពិចារណាពីសំណួរដែលអ្នកមានអំពីបព្វជិតភាព តើវាជះឥទ្ធិពលអ្វីខ្លះមកលើជីវិតរបស់អ្នក និង ពីរបៀបដែលអ្នកអាចគាំទ្រអ្នកដឹកនាំបព្វជិតភាពរបស់អ្នក ។ សូមចែកចាយសំណួរទាំងឡាយរបស់អ្នក ជាមួយឪពុកម្ដាយ ឬ អ្នកដឹកនាំយុវវ័យរបស់អ្នក ដើម្បីពួកគេអាចជួយអ្នកយល់កាន់តែច្បាស់ពីគោលលទ្ធិនៃបព្វជិតភាព នៅក្នុងមេរៀនរបស់អ្នកនៅក្នុងខែនេះ ។ អ្នកប្រហែលជាចង់គិតអំពីបទពិសោធន៍ទាំងឡាយ ដែលអ្នកមាននៅពេលបព្វជិតភាពផ្ដល់ពរជ័យដល់ជីវិតអ្នកផងដែរ ។ សូមកត់ពីអារម្មណ៍របស់អ្នកទុក ហើយសូមពិចារណាអំពីការចែកចាយអារម្មណ៍នោះជាមួយអ្នកដទៃទៀតដែលនៅផ្ទះ នៅព្រះវិហារ ឬ តាមបណ្ដាញសង្គម ។



**ដោយ ដេវីឌ អេល. បេ៊ក**
ប្រធានយុវជនទូទៅ

# ការដឹងគុណ

*យើងគ្រប់ៗគ្នានឹងកាន់តែមានភាពរីករាយ បើសិនជាយើងចេះដឹងគុណ ។*

**នៅ**ក្នុងរដូវក្តៅនៃឆ្នាំ 2011 ខ្ញុំបានមានអភ័យឯកសិទ្ធិដោយបានជួបជាមួយនឹង ចូសហ៍ ឡាសុន នៅឯវាលចិញ្ចឹមសត្វ ហ្វីលម៉ោនស្កោត នៅក្នុងរដ្ឋនូវ ម៉ិកស៊ីកូ សហរដ្ឋអាមេរិក ។ ពីរបីខែក្រោយមក ចូសហ៍បានជួយឪពុករបស់គាត់សំអាតឃ្លាំងដាក់ឥវ៉ាន់ ។ ដោយមិនបានដឹងជាមុន ប្រវ៉ាក់ដែលចងសសរធ្នឹមដែលមានទម្ងន់ 1480 ផោន ( 670 គីឡូក្រាម ) បានដាច់ ហើយបានធ្លាក់ធ្នឹមនោះលើ ចូសហ៍ ដោយសង្កត់គាត់ពីករហូតដល់ចុងជើងទាំងពីររបស់គាត់ ។ សំណាងល្អ ឪពុករបស់ចូសហ៍អាចរមៀលធ្នឹមនោះចេញពីកូនរបស់គាត់បាន ។ គាត់បានធ្វើចលនាចង្វាក់បេះដូង ( CPR ) របស់កូនគាត់ ដើម្បីឲ្យបេះដូងនៅដើរ រហូតដល់ពេលបុគ្គលិកសង្គ្រោះបន្ទាន់បានមកដល់ដើម្បីដឹកចូសហ៍ទៅកាន់មន្ទីរពេទ្យ ដែលគាត់គ្មានដកដង្ហើមផងនោះ ។

ចូសហ៍បានស្ថិតក្នុងសភាពធ្ងន់ធ្ងរអស់រយៈពេលជាច្រើនថ្ងៃ ។ វេជ្ជបណ្ឌិតបានខំប្រឹងយ៉ាងខ្លាំងដើម្បីព្យាបាលលលាដក្បាលដែលស្រាំ ប្រហោងឆ្អឹងថ្ពាល់បាក់ និង របួសធ្ងន់ធ្ងរដទៃទៀតជាច្រើនទៀត ។ បន្ទាប់ពីការវះកាត់ជាច្រើនកន្លែង ទីបំផុតចូសហ៍បានដឹងខ្លួនឡើងវិញ ។ បន្ទាប់ពីនោះមក គាត់បានជាសះស្បើយបន្តិចម្តងៗអស់រយៈពេលដ៏យូរ ។

សព្វថ្ងៃនេះ ចូសហ៍ក៏នៅមានភាពមិនសូវស្រួលជាច្រើនដែលបណ្តាលមកពីគ្រោះថ្នាក់នោះ ។ គាត់ត្រូវពិការភ្នែកម្ខាង ត្រចៀកម្ខាងថ្លង់ និង មានត្រូវផ្ទុកបន្ទះដែកមួយបន្ទះនៅក្នុងក្បាលរបស់គាត់ ។ ទោះជាយ៉ាងនោះក្តី គាត់បានជ្រើសរើសដោយគិតថា ការសាកល្បងរបស់គាត់នោះជាពរជ័យមួយទៅវិញ ។ គាត់ដឹងថា គាត់ជំពាក់ដលព្រះវរបិតា និង ការគាំទ្រពីអ្នកទាំងឡាយដែលនៅជុំវិញគាត់ ចំពោះជីវិត និងការជាសះស្បើយរបស់គាត់ ។ ដួងចិត្តរបស់គាត់ពេញដោយការដឹងគុណ ។

### ការដឹងគុណក្នុងគ្រាមានទុក្ខ

ថ្មីៗនេះ នៅក្នុងសន្និសីទយុវវ័យ ចូសហ៍បាននិយាយអំពីការអធិស្ឋាន និង ការតមអាហារ ដែលបានធ្វើឡើងដោយក្រុមគ្រួសារ មិត្តភក្តិ អ្នកជិតខាង និង អ្នកដឹកនាំក្នុងវួដ ហើយនិង ស្តេក ៖ « ខ្ញុំកំពុងរាប់ពរជ័យរបស់ខ្ញុំ ។ ការអធិស្ឋានត្រូវបានឆ្លើយតប ។ ខ្ញុំគិតថា នេះគឺជាពរជ័យជាជាងគិតថាជាការសាកល្បង ។ ខ្ញុំស្រឡាញ់អ្នកទាំងអស់គ្នា » ។

ចូសហ៍គឺជាគំរូមួយអំពីការបង្រៀននៅក្នុង*ដើម្បីកម្លាំងនៃយុវជន* ៖« រស់នៅដោយមានអារម្មណ៍នៃការ





*ការជាសះស្បើយរបស់ចូសហ៍មានរយៈវែង និងជាយឺតៗ ។ គាត់មិនបានជាសះស្បើយទាំងស្រុងពីគ្រោះថ្នាក់នោះទេ ប៉ុន្តែគាត់គិតថា គ្រោះថ្នាក់នោះគឺជាពរជ័យច្រើនជាងការសាកល្បង ។*





## យោបល់សំខាន់ៗអំពីការដឹងគុណ

« ព្រះអម្ចាស់សព្វព្រះទ័យឲ្យអ្នកមានវិញ្ញាណនៃការដឹងគុណក្នុងគ្រប់អ្វីទាំងអស់ដែលអ្នកនិយាយ និង ធ្វើ ។ . . .

« នៅក្នុងការអធិស្ឋានរបស់អ្នក ចូរបង្ហាញដួងចិត្តរបស់អ្នកទៅរកព្រះវរបិតារបស់អ្នកដែលគង់នៅឯនគរស្ថានសួគ៌នៅក្នុងការថ្លែងអំណរគុណចំពោះពរជ័យទាំងឡាយដែលបានទទួល ។ . . .

« . . . ចូរបង្ហាញការដឹងគុណរបស់អ្នកដល់អ្នកដទៃសម្រាប់អ្វីជាច្រើនដែលពួកគេបានប្រទានពរជ័យដល់ជីវិតរបស់អ្នក »។

*ដើម្បីកម្លាំងនៃយុវជន* ( កូនសៀវភៅ ឆ្នាំ 2011 ) ទំព័រ 18 ។

រចនារូបភាពនៃ វីហ្គី ឡាសុន និង សេវាកម្ម បោះពុម្ពសាសនាចក្រ

ថ្លែងអំណរគុណ ហើយអ្នកនឹងមាននូវសុភមង្គល និង ភាពរីករាយកាន់តែច្រើនឡើង ។ . . . សូម្បីតែនៅពេលដ៏លំបាកបំផុត នោះអ្នកអាចឃើញនូវអ្វីជាច្រើនដែលត្រូវថ្លែងអំណរគុណ ។ »[1]

ការដឹងគុណអាចបង្វែរការសាកល្បងជាច្រើនឲ្យក្លាយទៅជាពរជ័យវិញ ទោះជាការសាកល្បងនោះធ្ងន់ធ្ងរក្ដី ។ វាតម្រូវឲ្យមានការប្រឹងប្រែង ដើម្បីអនុវត្តការដឹងគុណ និង មានគំនិតសុទិដ្ឋិនិយមចំពោះជីវិតរស់នៅ ។ ទោះបីជាព្រះអម្ចាស់ពិតជាប្រទានពរជ័យដល់យើងក៏ដោយ ក៏សេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់របស់ទ្រង់មិនគួរត្រូវបានគេបំភ្លេច ឬ មិនមានសេចក្ដីអំណរនោះដែរ ។ ព្យាការីម៉ូរ៉ូណៃ នៅក្នុងព្រះគម្ពីរមរមន រំឭកយើងអំពីសារៈសំខាន់នៃការដឹងគុណ និង លើកទឹកចិត្តដល់យើងឲ្យ « នឹកឃើញថា តើព្រះអម្ចាស់ទ្រង់មានសេចក្ដីមេត្តាករុណាយ៉ាងណា ដល់កូនចៅមនុស្ស ចាប់តាំងពីកំណើតលោកអ័ដាមមករហូតដល់ពេលដែលអ្នករាល់គ្នា បានទទួលការណ៍ទាំងនេះ ហើយសូមរំពឹងគិតនៅក្នុងចិត្តអ្នកចុះ » ( ម៉ូរ៉ូណៃ 10:3) ។

### ជំនួយពីព្រះវិញ្ញាណបរិសុទ្ធ

នៅក្នុងជីវិតដ៏មមាញឹករបស់យើង វាងាយស្រួលដើម្បីមើលរំលង និង បំភ្លេចការណែនាំរបស់ព្រះវរបិតាសួគ៌នៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់យើង ។ ព្រះវិញ្ញាណបរិសុទ្ធរំឭកយើងឲ្យចងចាំថា យើងមានរឿងជាច្រើនដែលត្រូវដឹងគុណ ។ ប្រធាន ហិនរី ប៊ី. អាវរិងទីប្រឹក្សាទីមួយ នៅក្នុងគណៈប្រធានទីមួយ បានបង្រៀនថា « នោះគឺជាព្រះវិញ្ញាណបរិសុទ្ធដែលទ្រង់ជួយយើងឃើញនូវអ្វីដែលព្រះបានធ្វើសម្រាប់យើង » ។ ទ្រង់បានជំរុញយើង « ដើម្បីស្វែងរកនូវរបៀបដើម្បីដឹង និង ចងចាំដល់សណ្ដានចិត្តរបស់ព្រះ » ។[2]

នៅពេលយើងអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធរំឭកយើងអំពីសណ្ដានចិត្ត និង សេចក្ដីស្រឡាញ់របស់ព្រះចំពោះយើង នោះយើងនឹងពោរពេញដោយអារម្មណ៍នៃការដឹងគុណ ។ អារម្មណ៍ទាំងនេះនឹងធ្វើឲ្យយើងថ្លែងអំណរគុណដល់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌នៃយើង ។ *ពិតចំពោះសេចក្ដីជំនឿ* បង្រៀនថា ៖ « សូមថ្លែងអំណរគុណចំពោះព្រះវរបិតាសួគ៌សម្រាប់សណ្ដានចិត្តរបស់ទ្រង់ចំពោះអ្នក ។ អ្នកអាចនឹងសម្ដែងនូវការដឹងគុណរបស់អ្នកចំពោះព្រះដោយការទទួលស្គាល់នៃការចូលរួមរបស់ទ្រង់នៅក្នុងគ្រប់កិច្ចការទាំងអស់សូមថ្លែងអំណរគុណដល់ទ្រង់ចំពោះអ្វីៗទាំងអស់ដែលទ្រង់បានប្រទានដល់អ្នក ដោយការរក្សារាល់បទបញ្ញត្តិរបស់ទ្រង់ និង ការបម្រើអ្នកដទៃ ។ . . . ធ្វើការដោយការដឹងគុណ អ្នកនឹងរកឃើញថា វាផ្ដល់នូវលទ្ធផលដ៏ប្រសើរដល់អ្នក » ។[3]

> ***អារម្មណ៍នៃការដឹងគុណទាំងនេះ នឹងបំផុសគំនិតដល់យើង ដើម្បីនឹងធ្វើតាមព្រះអម្ចាស់ និង រស់នៅក្នុងជីវិតនៃការបម្រើ ។***

នៅពេលយើងដឹងពីពរជ័យរបស់យើង នោះទីបន្ទាល់របស់យើងនឹងរីកចម្រើន ។ នៅពេលយើងកាន់តែមើលឃើញពីព្រះហស្តរបស់ទ្រង់នៅក្នុងជីវិតរស់នៅរបស់យើង នោះយើងកាន់តែខិតជិតទ្រង់ ។ របៀបដ៏ល្អបំផុតមួយដែលយើងអាចបង្ហាញការដឹងគុណរបស់យើងចំពោះព្រះវរបិតាដែលគង់នៅស្ថានសួគ៌ គឺតាមរយៈការបង្ហាញនូវអំណរគុណចំពោះទ្រង់ និង ចំពោះអ្នកដទៃពីរបៀបដែលទ្រង់ និង ពួកគេធ្វើឲ្យជីវិតរបស់យើងទទួលនូវអារម្មណ៍ដ៏កក់ក្ដៅ ។[4]

អារម្មណ៍នៃការដឹងគុណទាំងនេះនឹងបំផុសគំនិតដល់យើង ដើម្បីនឹងធ្វើតាមព្រះអម្ចាស់ និង រស់នៅក្នុងជីវិតនៃការបម្រើ—ជាជីវិតដែលបំផុសដល់អ្នកដទៃដែលនៅជុំវិញយើង និង ធ្វើឲ្យមានការផ្លាស់ប្ដូរទៅរកចំណុចវិជ្ជមានមួយ ។ ■

**កំណត់សម្គាល់**

1. *ដើម្បីកម្លាំងនៃយុវជន* ( កូនសៀវភៅ ឆ្នាំ 2011 )ទំព័រ 18 ។
2. ហិនរី ប៊ី. អាវរិង « O Remember, Remember » ទស្សនាវដ្ដី*លីអាហូណា*និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2007 ទំព័រ 67–68 ។
3. *ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងដំណឹងល្អ* ( ឆ្នាំ 2004 ) ទំព័រ 79 ។
4. សូមមើល *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 18 ។



# អំណោយមួយសម្រាប់លោកយាយ

ដោយ គីមបឺលី សាបិន ភ្លាំប៍

*សំបុត្រដ៏សាមញ្ញមួយច្បាប់ដើម្បីនិយាយថា អរគុណបានមានអត្ថន័យដ៏ខ្លាំងចំពោះលោកយាយរបស់ខ្ញុំ ។*

កាលពីខ្ញុំនៅពីក្មេង លោកយាយរបស់ខ្ញុំតែងតែហៅខ្ញុំ និង បងប្អូនជីដូនមួយខ្ញុំឲ្យមកជុំគ្នា ។ ពួកយើងមានគ្នាប្រហែលជា 14នាក់ ហើយពួកយើងតែងតែមានអារម្មណ៍រំភើប នៅពេលលោកយាយបានប្រាប់ពួកយើងឲ្យទទួលទានបាយពេលល្ងាច សម្រាកនៅទីនោះ លេងហ្គេមពេលយប់ និង មានថ្ងៃឈប់សម្រាកជុំគ្នា ។ ផ្ទះរបស់លោកយាយគឺជាកន្លែងសម្រាប់ភាពរីករាយទាំងនោះ !

រាល់សកម្មភាពនៅផ្ទះលោកយាយទាំងអស់សុទ្ធតែសប្បាយៗ ។ ប៉ុន្តែខ្ញុំមិនដែលបានគិតអំពីពេលវេលា និង កិច្ចការទាំងអស់ដែលបានចំណាយក្នុងសកម្មភាពនីមួយៗនោះទេ ។ ខ្ញុំគ្រាន់តែគិតថា អ្វីដែលលោកយាយរបស់ខ្ញុំធ្វើ គឺខ្ញុំចូលចិត្តទាំងអស់ !

បន្ទាប់ពីមានការនឹករឭកនូវភាពរីករាយជាមួយនឹងបងប្អូនជីដូនមួយអស់រយៈពេលច្រើនឆ្នាំ គ្រួសាររបស់យើងបានផ្លាស់ប្ដូរផ្ទះទៅឆ្ងាយ ។ ក្រោយមកលោកយាយរបស់ខ្ញុំបានមកចំណាយពេលជាមួយនឹងពួកយើងនៅផ្ទះថ្មីរបស់ពួកយើងនៅក្នុងថ្ងៃពិសេសៗ ។ គ្រួសាររបស់ខ្ញុំបានគិតយ៉ាងយូរ និង ពិបាកដើម្បីរកអំណោយដ៏ល្អមួយសម្រាប់គាត់ ។ លោកយាយមានរបស់របរច្រើនជាងនរណាៗទាំងអស់ដែលខ្ញុំស្គាល់ ។ តើយើងអាចទិញអ្វីសម្រាប់លោកយាយដែលគាត់មានអ្វីៗគ្រប់យ៉ាងទាំងអស់ហើយនោះ ?

ខ្ញុំបានសួរយោបល់ពីលោកប៉ារបស់ខ្ញុំ ហើយគាត់បានប្រាប់ខ្ញុំនូវអ្វីដដែលៗដូចជារាល់ឆ្នាំដែរថា ៖ « ហេតុអ្វីបានជាកូនមិនសរសេរសំបុត្រដ៏ល្អមួយសម្រាប់លោកយាយទៅ ? » ខ្ញុំគ្មានគំនិតអ្វីសោះ ដូច្នេះនៅព្រលឹមស្អែកឡើង ពីមុនគេគ្រប់គ្នាភ្ញាក់ឡើង ខ្ញុំបានអង្គុយនៅនឹងតុក្នុងផ្ទះបាយ ហើយសរសេរសំបុត្រដ៏ពិសេសមួយជូនលោកយាយ ដោយជើងរបស់ខ្ញុំជាន់លើកំរាលឥដ្ឋដ៏ត្រជាក់ ។

ពីដំបូងខ្ញុំបានគិតថា តើខ្ញុំអាចសរសេរអ្វីបាន ក្រៅពីសរសេរថា « លោកយាយអស្ចារ្យណាស់ » ។ អរគុណសម្រាប់អ្វីៗគ្រប់យ៉ាង » ។ នៅខណៈដែលខ្ញុំបានសំឡឹងមើលតាមបង្អួចទៅដើមដូង និង ផ្ទៃមេឃខាងក្រៅ ខ្ញុំបានគិតនូវអ្វីៗជាច្រើនដែលលោកយាយបានធ្វើសម្រាប់យើងអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ។ ខ្ញុំបានចាំថា ខ្ញុំមិនដែលបានប្រាប់លោកយាយរបស់ខ្ញុំថា ពេលវេលាដែលយើងបានមានជាមួយគ្នាក្នុងនាមជាក្រុមគ្រួសារនោះមានអត្ថន័យចំពោះខ្ញុំនោះទេ ។

នៅក្នុងសំបុត្ររបស់ខ្ញុំ ខ្ញុំបានប្រាប់លោកយាយរបស់ខ្ញុំថា ខ្ញុំស្រឡាញ់គាត់ ហើយខ្ញុំបានអរគុណគាត់សម្រាប់អនុស្សាវរីយ៍ដ៏ពិសេសទាំងអស់នោះ ។ ខ្ញុំបានប្រាប់គាត់ឲ្យដឹងនូវសារៈសំខាន់នៃអនុស្សាវរីយ៍ទាំងនោះដែលនៅតែមានចំពោះខ្ញុំ ទោះបីជាច្រើនឆ្នាំកន្លងផុតទៅហើយក្ដី ។ បន្ទាប់មកខ្ញុំបានដាក់សំបុត្រនោះនៅក្នុងស្រោម ដោយមានចងបូពណ៌ក្រហម ហើយបានត្រឡប់ចូលទៅក្នុងបន្ទប់ក្រាលព្រំដ៏កក់ក្ដៅរបស់ខ្ញុំវិញ ។

ពេលវេលានៃការជូនអំណោយដល់លោកយាយបានមកដល់ ខ្ញុំបានទាញសំបុត្ររបស់ខ្ញុំចេញយ៉ាងយឺតៗ ។ ខ្ញុំមិនដឹងថាមានអារម្មណ៍យ៉ាងណាអំពីការឲ្យអំណោយនេះទៅលោកយាយនោះទេ ។



**បង្ហាញសេចក្ដីស្រឡាញ់ដោយពាក្យសម្ដី និង ទង្វើ**

« ដោយមានការដឹងគុណនៅក្នុងដួងចិត្តរបស់យើង សូមឲ្យយើងធ្វើកិច្ចការរបស់យើង—តាមដែលយើងអាចធ្វើទៅបាន—ដោយធ្វើនូវរឿងទាំងឡាយណាដែលមានសារសំខាន់បំផុត ។ សូមឲ្យយើងការពារដល់អ្នកដែលយើងស្រឡាញ់ និង បង្ហាញសេចក្ដីស្រឡាញ់របស់យើងជាពាក្យសម្ដី និង ទង្វើទៅកាន់ពួកគេ » ។

ប្រធាន ថូម៉ាស អេស. ម៉នសុន « Finding Joy in the Journey » *លីអាហូណា*និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 87 ។

លោកយាយហាក់បីដូចជារំភើប នៅពេលខ្ញុំបានជូនសំបុត្រនោះទៅគាត់ ។ ខ្ញុំបានសំឡឹងយ៉ាងយកចិត្តទុកដាក់ នៅពេលដែលគាត់បានហែកសំបុត្រ ហើយបានទាញសំបុត្រក្រដាសពណ៌ផ្កាឈូកដ៏ណែននោះចេញមក ។ នៅពេលគាត់អានសំបុត្រនោះ គាត់បានចាប់ផ្ដើមញញឹម ហើយស្រក់ទឹកភ្នែក ។ ពីមុនមកខ្ញុំមិនដែលឃើញលោកយាយរបស់ខ្ញុំយំទេ ។ គាត់បានសំឡឹងមករកខ្ញុំយ៉ាងយឺតៗ ហើយបើកភ្នែកដែលមានពណ៌ត្នោតដ៏ស្រទន់មករកខ្ញុំ ។ គាត់បានខ្សឹបថា « អរគុណ អរគុណ ។ យាយគិតថា មិនមាននរណាម្នាក់ចាំទេ » ។

លោកយាយដែលអ្នកបានធ្វើអ្វីៗជាច្រើនដើម្បីស្ថាបនាទំនាក់ទំនងក្រុមគ្រួសារដ៏រឹងមាំ មិនបានដឹងថាខ្ញុំនៅចងចាំ ឬនៅមានក្ដីអំណរចំពោះពេលវេលាដែលបានមានជាមួយគ្នានោះ ។ គាត់បានជូតទឹកភ្នែករបស់គាត់ ហើយបាននិយាយថា « គីមបឺលី យាយអរគុណចៅហើយ ។ នោះគឺជាអំណោយដ៏ពិសេសបំផុតក្នុងចំណោមអំណោយទាំងអស់ដែលគេរាល់គ្នាបានឲ្យមកយាយ » ។

ខ្ញុំបានឱបលោកយាយយ៉ាងខ្លាំង ដោយមានអារម្មណ៍ថាស្បែកដ៏ស្រទន់របស់គាត់ប៉ះនឹងថ្ពាល់របស់ខ្ញុំ ហើយនឹងក្លិន « លោកយាយ » ដែលមានលាយជាមួយនឹងម្សៅកូនក្មេង និង គ្រឿងក្រអូប ។ ខ្ញុំបានមានសេចក្ដីអំណរចំពោះយោបល់របស់លោកប៉ារបស់ខ្ញុំ ឲ្យសរសេរសំបុត្រជូនលោកយាយ ។ ខ្ញុំមិនបានដឹងថា ពាក្យនៃការដឹងគុណ និង សេចក្ដីស្រឡាញ់មានអត្ថន័យចំពោះលោកយាយរបស់ខ្ញុំច្រើនជាងគ្រឿងអនុស្សាវរីយ៍ គ្រឿងក្រអូប និង កន្ទ្រក់ផ្លែឈើដែលលុយអាចទិញបានទៅទៀត ។ ■

*អ្នកនិពន្ធ រស់នៅក្នុងរដ្ឋ កាលីហ្វូញ៉ា សហរដ្ឋអាមេរិក ។*

# វីដេអូអាក្រក់

*នៅពេល អេវលីនបានឃើញចំណងជើងភាពយន្ត នោះគាត់បានចាប់ផ្ដើមបុកពោះ ។*



**ដោយ ដូលៀ វូដប៊ីរី**
ទស្សនាវដ្ដីសាសនាចក្រ

ផ្អែកទៅលើដំណើររឿងពិតមួយ

« *ខ្ញុំនឹងអាន ហើយនឹងមើលតែអ្វីដែលធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យប៉ុណ្ណោះ* » ( បទដ្ឋានដំណឹងល្អរបស់ខ្ញុំ ) ។

**នៅ**ពេលដែលគាត់បានដើរមកខាងមុខបន្ទប់រៀន លោកស្រី ថេលើរ បាននិយាយថា « អ្នកទាំងអស់គ្នា ខ្ញុំមានអ្វីមួយដើម្បីធ្វើឲ្យអ្នកភ្ញាក់ផ្អើល » ។

អេវលីន បានសំឡឹងមើលក្រដាសប្រឡងរបស់នាងដោយញញឹម ។ មានអក្សរ « A+ » ធំនៅពីលើគេ ។

កំពុងតែសរសេរចំណងជើងភាពយន្តបីនៅលើក្ដារខៀន លោកស្រី ថេលើរបាននិយាយថា « អ្នកទាំងអស់គ្នាធ្វើបានល្អណាស់ចំពោះការប្រឡង ដូច្នេះយើងនឹងមើលភាពយន្តមួយរឿងជារង្វាន់ » ។ គ្រប់គ្នាកំពុងតែអរសប្បាយ នោះគាត់បាននិយាយថា « នេះគឺជាជម្រើសសម្រាប់អ្នកទាំងអស់គ្នាបោះឆ្នោត » ។

អេវលីនបានមានអារម្មណ៍មិនស្រណុកនៅកៅអីអង្គុយរបស់គាត់ ដោយចាំព្យាយាមមើលថាតើចំណងជើងរឿងនោះជារឿងអ្វី ។ ចំណងជើងនៃរឿងពីរដំបូងជារឿងដែលនាងចូលចិត្ត នាងបានឱនទៅរកមិត្តភក្ដិរបស់នាងឈ្មោះ ខាធី ។ « តើឯងនឹងបោះឆ្នោតយករឿងមួយណា ? »

ខាធីបាននិយាយថា « ប្រាកដជាទីបីហើយ » ។ « ឪពុកម្ដាយរបស់ខ្ញុំនឹងមិនអនុញ្ញាតឲ្យមើលរឿងហ្នឹងនៅផ្ទះនោះទេ ដូច្នេះខ្ញុំមិនដែលបានមើលវាទេ » ។

អេវលីនបានសំឡឹងមើលក្ដារខៀនម្ដងទៀត ហើយបានឃើញចំណងជើងរឿងទីបី ។ នាងបានចាប់ផ្ដើមបុកពោះ ។ អេវលីនបានឮអំពីរឿងនេះ ហើយនាងបានដឹងថា រឿងនោះនឹងធ្វើឲ្យនាងមានអារម្មណ៍មិនល្អដើម្បីនឹងមើលវានោះទេ ។ តើមានអ្វីកើតឡើង ប្រសិនបើសិស្សក្នុងថ្នាក់នឹងបោះឆ្នោតយករឿងនោះ ។

លោកស្រី ថេលើរ បានសួរថា ៖ « តើនរណានឹងបោះឆ្នោតសម្រាប់រឿងទីមួយ ? »

អេវលីនបានលើកដៃឡើងយ៉ាងខ្ពស់ ហើយបានសំឡឹងមើលជុំវិញ ។ នាងបានខាំបបូរមាត់របស់នាងទាំងភ័យអរ ។ មានតែមនុស្សពីរនាក់ផ្សេងទៀតប៉ុណ្ណោះដែលកំពុងបោះឆ្នោត ។

លោកស្រីថេលើរបានគូសចំនួននៅលើក្ដារខៀន ។ « ជំរើសទីពីរ ? »

អេវលីនអស់សង្ឃឹម ។ មានតែបីនាក់ប៉ុណ្ណោះបានលើកដៃឡើង ។

« ចុះចំណែកជំរើសទីបីវិញ ? »

ដប់ប្រាំនាក់បានលើកដៃឡើង ។ អេវលីនបានក្រាបចុះនៅនឹងតុរបស់នាង ដោយនាងមានអារម្មណ៍មិនសូវស្រណុកចិត្តទេ ។ តើនាងអាចនឹងមិនមើលភាពយន្តនោះបានដោយរបៀបណា ប្រសិនបើគ្រប់ៗគ្នាចង់មើលនោះ ?

នៅពេលនាងបានត្រឡប់ទៅផ្ទះវិញ អេវលីនបាន

រចនារូបភាពដោយ ប្រាដ ធា






« ដើម្បីជួយដល់អ្នកដទៃ នោះយើងខ្លួនឯងត្រូវការសេចក្ដីក្លាហានខាងវិញ្ញាណ និង ខាងសាច់ឈាមដើម្បីតស៊ូនឹងសេចក្ដីអាក្រក់ដែលយើងឃើញគ្រប់ពេលវេលានោះ » ។

**ប្រធាន ថូម៉ាស អេស. ម៉នសុន** « Three Goals to Guide You »*លីអាហូណា*និង *Ensign* **ខែ វិច្ឆិកា ឆ្នាំ 2007 ទំព័រ 119 ។**

សំដៅទៅរកបន្ទប់របស់នាង ហើយបានទំលាក់កាបូបស្ពាយពីក្រោយរបស់នាងទៅលើឥដ្ឋមួយ *ទំហឹង* ។ អារម្មណ៍មិនស្រណុកស្រួលនោះបាននៅជាមួយនាងពេញមួយថ្ងៃ ។ នាងបានគិតថា « ខ្ញុំចង់ឈឺ » ។ « ដូច្នេះ ខ្ញុំនឹងមិនចាំបាច់ទៅរៀននៅថ្ងៃស្អែកទេ » ។

អេវលីនបានទាញក្រដាសប្រឡងរបស់នាងចេញពីកាបូបស្ពាយ ហើយបានសំឡឹងមើលវា ហើយបានផ្ទួលវាក្នុងដៃនាង ។ « ភាពយន្តនោះគួរតែជារង្វាន់មិនមែនជាការដាក់ពិន័យនោះទេ ! » ។ នាងបានគិតបែបនោះ នៅពេលដែលនាងផ្ទួលក្រដាសប្រឡងនោះទាំងខឹង ហើយញុកវាចូលទៅក្រោមពូក ។ ទឹកភ្នែកបានហូរចេញពីភ្នែករបស់នាង ។ នាងបានលុតជង្គង់ចុះនៅក្បែរគ្រែដេករបស់នាង ហើយបានចាប់ផ្ដើមយំ ។ ហើយបន្ទាប់មក នាងបានចាប់ផ្ដើមអធិស្ឋាន ។ នាងនិយាយទាំងត្រដឹតត្រដកមិនត្រូវពាក្យ សុំឲ្យព្រះវរបិតាយកចេញនូវបញ្ហានេះចេញ ប៉ុន្តែមួយសន្ទុះក្រោយមកការអធិស្ឋានរបស់គាត់ត្រូវបានផ្លាស់ប្ដូរ ។ « សូមជួយឲ្យខ្ញុំអាចធ្វើកិច្ចការនេះកាន់តែប្រសើរផង ។ ខ្ញុំមិនចង់មើលភាពយន្តណាដែលនឹងធ្វើឲ្យខ្ញុំមានអារម្មណ៍មិនសូវល្អនោះទេ ហើយខ្ញុំសង្ឃឹមថា មិត្តភក្ដិ និង គ្រូរបស់នឹងយល់ » ។

អេវលីនបានបញ្ចប់ការអធិស្ឋានរបស់នាង ។ ការភ័យ និង អារម្មណ៍មិនសូវស្រួលនោះបានសាយបាត់ទៅ ។ នាងមិនមានអារម្មណ៍ថាភ័យខ្លាចទៀតទេ ។

លោតឡើង អេវលីនបានរត់ចេញពីបន្ទប់របស់នាងទៅរកម្ដាយ ។ នាងបានមានគំនិតមួយ ។

នៅថ្ងៃបន្ទាប់ អេវលីនបានដើរចូលទៅក្នុងថ្នាក់រៀន ។ នៅក្នុងដៃម្ខាង នាងបានកាន់ក្រដាសដែលបានពន្យល់ពីម្ដាយរបស់នាង ពីការដែលមើលភាពយន្តធ្វើឲ្យនាងមិនអារម្មណ៍មិនសូវស្រណុកចិត្ត ។ នៅក្នុងដៃម្ខាងទៀត នាងបានកាន់ភាពយន្តបីដែលនាងចូលចិត្ត ។ អេវលីនបានហុចក្រដាសនោះទៅឲ្យលោកស្រី ថេលើរ និង មើលគាត់អានក្រដាសនោះ ។

លោកស្រី ថេលើរ បាននិយាយថា « អរគុណណាស់ដែលបានប្រាប់ខ្ញុំឲ្យដឹងអំពីអារម្មណ៍របស់អ្នក » ។

អេវលីនបាននិយាយថា « ម៉ាក់ខ្ញុំប្រាប់ថា វាមិនអីនោះទេសម្រាប់ខ្ញុំដើម្បីទៅអង្គុយនៅក្នុងថ្នាក់មួយទៀតខណៈដែលភាពយន្តនោះកំពុងតែបញ្ចាំង » ។ « ប៉ុន្តែខ្ញុំក៏បានយកភាពយន្តមួយចំនួនផ្សេងទៀតមកដែរក្រែងមាននរណាម្នាក់នឹងចង់មើលរឿងណាមួយក្នុងចំណោមរឿងទាំងអស់នេះ ជាជាងរឿងនោះ » ។

លោកស្រី ថេលើរ បានញញឹម ហើយបានលូកដៃយកភាពយន្តទាំងនោះ ។ នាងបាននិយាយថា « ភាពយន្តមិនមែនជារង្វាន់មួយទេ បើសិនជាយើងទាំងអស់គ្នាមិនរីករាយមើលវានោះ » ។

លោកស្រី ថេលើរ បានសរសេរចំណងជើងថ្មីនៅលើក្ដារខៀន ។ « សិស្សទាំងអស់គ្នា ខ្ញុំចង់ឲ្យបោះឆ្នោតម្ដងទៀត សម្រាប់ភាពយន្តថ្ងៃនេះ ។ ខ្ញុំមានជំរើសថ្មីមួយចំនួនទៀតសម្រាប់អ្នកកាល់គ្នា » ។

អេវលីនបានទៅអង្គុយនៅកៅអីរបស់នាងទាំងរីករាយ ដោយនឹងមិនបាត់រង្វាន់ក្នុងថ្នាក់របស់នាង ។ ប៉ុន្តែរង្វាន់ដ៏ល្អបំផុតក្នុងចំណោមរង្វាន់ទាំងនោះគឺ ការដឹងថា ព្រះវរបិតាបានដកយកនូវសេចក្ដីភ័យខ្លាចរបស់នាង ហើយបានប្រទានសេចក្ដីក្លាហានដើម្បីធ្វើអ្វីដែលត្រឹមត្រូវ ។ ■



**ដោយ អែលឌើរ ឃ្វីនធិន អិល. ឃុក**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*

# តើ ព្រះវរបិតាស្រឡាញ់ សមាជិកនៃសាសនាចក្រ ជាងទ្រង់ ស្រឡាញ់ មនុស្សដទៃទៀតឬ ?



ព្រះស្រឡាញ់កូនចៅ ទាំងអស់របស់ទ្រង់ ។

ទ្រង់ចង់ឲ្យពួកគេ ទាំងអស់គ្នាត្រឡប់ទៅ ទ្រង់វិញ ។

យើងក៏គួរស្រឡាញ់ និង គោរពមនុស្សទាំងអស់ ផងដែរ ។

យើងអាចជួយដល់អ្នក ទាំងនោះ ដែលមិនបាន ដឹងថា ព្រះស្រឡាញ់ពួក គេ ។

នោះពួកគេអាចនឹងមាន សេចក្តីអំណរដ៏មហិមា !

រចនារូបភាពដោយ សៀន ស៊ុលលីវ៉ាន់



កែសម្រួលចេញពី « ត្រូវនឹងទំនុកតន្ត្រីនៃសេចក្តីជំនឿ » *លីអាហូណា* និង Ensign, ខែមិថុនា ឆ្នាំ 2012 ទំព័រ 37–40 ។

ដោយ អែលឌើរ ហូសេ អិល. អាឡូនសូ
នៃពួកចិតសិបនាក់

# ការអធិស្ឋានដោយអំណត់



ខ្ញុំបានធំឡើងនៅក្នុងប្រទេស ម៉ិកស៊ិកូ ដែលមានបងប្អូនបង្កើតរបស់ខ្ញុំ ម្ដាយខ្ញុំ និងលោកយាយរបស់ខ្ញុំ ។ រាល់ថ្ងៃបន្ទាប់ពីធ្វើកិច្ចការសាលា និងកិច្ចការផ្ទះរួច ខ្ញុំលេងបាល់ទាត់ ។ ខ្ញុំស្រឡាញ់បាល់ទាត់ ! ខ្ញុំបានប្រើជើងខាងស្ដាំរបស់ខ្ញុំធ្វើជាក្រុមមួយ និង ជើងខាងឆ្វេងជាក្រុមមួយទៀត ។

នៅថ្ងៃមួយខ្ញុំបានកំពុងលេងបាល់ទាត់ ភ្លាមៗនោះខ្ញុំពិបាកនឹងដកដង្ហើមណាស់ ។ ខ្ញុំបានឈប់សម្រាកពីរបីនាទី ប៉ុន្តែខ្ញុំនៅតែមានបញ្ហាក្នុងការដកដង្ហើមនេះ ។ ខ្ញុំបានឈឺយ៉ាងខ្លាំងដែលខ្ញុំត្រូវទៅកាន់មន្ទីរពេទ្យ ។

នៅក្នុងបន្ទប់មន្ទីរពេទ្យបានមានក្មេងៗជាច្រើន ដូច្នេះក្រុមគ្រួសាររបស់ខ្ញុំមិនអាចចូលបាន ហើយខ្ញុំបានមានអារម្មណ៍ឯកកោមែនទែន ។ ថ្វីបើ ខ្ញុំមិនទាន់ជាសមាជិកនៅឡើយក្ដី ប៉ុន្តែខ្ញុំបានជឿទៅលើព្រះ ។ ជារៀងរាល់ថ្ងៃ ខ្ញុំបានអធិស្ឋានសូមឲ្យខ្ញុំបានជា ប៉ុន្តែផ្ទុយទៅវិញជំងឺរបស់ខ្ញុំកាន់តែខ្លាំងឡើងៗ ។ វេជ្ជបណ្ឌិតបានគិតថា ខ្ញុំប្រហែលជានឹងមិនរស់ទេ ។

ទីបញ្ចប់វេជ្ជបណ្ឌិតបានបញ្ជូនខ្ញុំពីមន្ទីរពេទ្យត្រឡប់មកផ្ទះវិញ ប៉ុន្តែខ្ញុំត្រូវសំរាកនៅតែលើគ្រែអស់រយៈពេលមួយឆ្នាំ ។ ខ្ញុំបានទទួលទានថ្នាំជាច្រើន និង ចាក់ថ្នាំពីរម្ដងជារៀងរាល់ថ្ងៃ ។ ហើយខ្ញុំនៅតែមានការអធិស្ឋាននៅក្នុងគំនិត និង ដួងចិត្តរបស់ខ្ញុំ ។ ខ្ញុំបានទូលប្រាប់ទៅព្រះវរបិតាថា បើសិនជាខ្ញុំជាសះស្បើយ ខ្ញុំនឹងបម្រើទ្រង់អស់មួយជីវិតរបស់ខ្ញុំ ។

បន្ទាប់មក នៅថ្ងៃមួយពេលដែលខ្ញុំកំពុងអានសៀវភៅគេងនៅលើគ្រែ ចៃដន្យខ្ញុំបានធ្លាក់សៀវភៅទៅលើឥដ្ឋ ។ នៅពេលដែលខ្ញុំបានឱនឈោងរើសសៀវភៅនោះ ខ្ញុំបានដឹងថា ខ្ញុំបានដកដង្ហើមធម្មតាឡើងវិញ ។ ខ្ញុំបានទម្លាក់សៀវភៅម្ដងទៀត ។ ខ្ញុំអាចរើសសៀវភៅជាថ្មីម្ដងទៀតដោយមិនមានបញ្ហាអ្វីទាំងអស់ !

ខ្ញុំបានងើបចេញពីគ្រែ ។ ជាដំបូងខ្ញុំវិលមុខ ពីព្រោះខ្ញុំមិនដែលបានដើរដោយខ្លួនឯងដូច្នេះជាយូរមកហើយ ។ ខ្ញុំបានឆ្លុះកញ្ចក់ ហើយឃើញរូបខ្ញុំកំពុងញញឹម ។ ខ្ញុំបានដឹងថា ខ្ញុំបានទទួលការឆ្លើយតបពីព្រះវរបិតាសួគ៌ ។

ចាប់តាំងពីពេលនោះមក ជារៀងរាល់ថ្ងៃខ្ញុំព្យាយាមធ្វើអ្វីម៉្យាងដើម្បីបង្ហាញការដឹងគុណរបស់ខ្ញុំចំពោះព្រះវរបិតាសួគ៌ ។ នៅពេលខ្ញុំធំឡើង ខ្ញុំបានក្លាយទៅជាវេជ្ជបណ្ឌិត ដើម្បីជួយឆ្លើយតបដល់ការអធិស្ឋានរបស់កុមារដទៃទៀត ។ ហើយឥឡូវនេះ ខ្ញុំកំពុងតែព្យាយាមដើម្បីបម្រើព្រះវរបិតាសួគ៌ជាមួយនឹងការហៅរបស់ខ្ញុំនៅក្នុងសាសនាចក្រ ។

ចម្លើយចំពោះការអធិស្ឋានមិនតែងតែមកដោយស្រួលៗនោះទេ ហើយចម្លើយនោះក៏មិនតែងតែមកក្នុងពេលភ្លាមៗដែរ ។ ប៉ុន្តែខ្ញុំដឹងថាព្រះវរបិតាសួគ៌ឆ្លើយតបចំពោះការអធិស្ឋានរបស់យើង ។ ទ្រង់ដឹងពីសេចក្ដីត្រូវការរបស់យើង ហើយទ្រង់ដឹងថាអ្វីដែលល្អបំផុតសម្រាប់យើង ។ ■

រចនារូបភាព ដោយ ដាន ប៊ឺ

# ខ្ញុំនឹងធ្វើតាមផែនការរបស់ព្រះវរបិតាសួគ៌តាមរយៈការទទួលបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់

អ្នកអាចប្រើមេរៀន និងសកម្មភាពនេះ ដើម្បីរៀនសូត្របន្ថែមទៀតពីបាវចនានៃថ្នាក់កុមារសម្រាប់ខែនេះ ។

ព្រះគម្ពីរមរមន ប្រាប់យើងអំពីមនុស្សមួយក្រុមដែលបានប្រមូលផ្ដុំគ្នានៅក្នុងព្រៃមួយហៅថា មរមន ។ ពួកគេចង់ស្ដាប់ការបង្រៀនរបស់អាលម៉ាអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ បន្ទាប់ពីអាលម៉ាបានបង្រៀនពួកគេជាច្រើនថ្ងៃមក គាត់បានសួរពួកគេ បើសិនជាពួកគេចង់ចុះសេចក្ដីសញ្ញាដើម្បីនឹងបម្រើព្រះ និង កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ គាត់បានប្រាប់ទៅពួកគេថា ប្រសិនបើពួកគេទទួលបុណ្យជ្រមុជទឹក នោះព្រះវិញ្ញាណនឹងគង់នៅជាមួយនឹងពួកគេជានិច្ច ( សូមមើល ម៉ូសាយ 18:7–10 ) ។

នៅពេលពួកគេបានឮពាក្យទាំងនេះ ប្រជាជនមានសេចក្ដីរីករាយយ៉ាងខ្លាំង ហើយពួកគេ « បានទះដៃដោយសេចក្ដីអំណរ » ( ម៉ូសាយ 18:11 ) ។ អាលម៉ាបានជ្រមុជទឹកមនុស្សប្រហែលជា 200 នាក់នៅក្នុងទឹកមរមន ។ ប្រជាជនទាំងនេះបានគិតថា ព្រៃមរមននេះគឺជាកន្លែងដ៏ស្រស់ស្អាតមួយ ពីព្រោះទីនោះជាកន្លែងដែលពួកគេបានរៀនអំពីព្រះអង្គសង្គ្រោះ និង ត្រូវបានជ្រមុជទឹក ( សូមមើល ម៉ូសាយ 18:30 ) ។

ក៏ដូចជាប្រជាជនអាលម៉ាផងដែរ យើងមានអារម្មណ៍នៃក្ដីអំណរនៅពេលយើងរង់ចាំ ឬចងចាំអំពីការជ្រមុជទឹកនោះ ។ ដូចគ្នានឹងប្រជាជននេះដែរ នៅពេលយើងត្រូវបានជ្រមុជទឹក យើងបានធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះ ។ យើងសន្យាដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ និង បម្រើទ្រង់ ។ យើងលើកដាក់មកលើខ្លួនរបស់យើងនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ និង ក្លាយទៅជាសមាជិកនៃសាសនាចក្ររបស់ទ្រង់ ។ នៅពេលយើងត្រូវបានបញ្ជាក់ យើងទទួលបាននូវការសន្យាដ៏អស្ចារ្យដូចគ្នានឹងប្រជាជនអាលម៉ាទទួលដែរ ៖ ថាព្រះវិញ្ញាណនឹងគង់នៅជាមួយនឹងយើងជានិច្ច បើសិនជាយើងកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។ ■



រចនារូបភាពដោយ ដានី ចូនស៍

## សូមស្ដាប់តាមសំឡេងដ៏តូចរហៀង

សូមសុំឲ្យឪពុក ឬ ម្ដាយរបស់អ្នក ឬ មនុស្សពេញវ័យណាម្នាក់ជួយកាត់រូបភាពនៅលើទំព័រនេះ និង ដាក់រូបទាំងនោះនៅក្នុងថង់មួយ ។ សូមដាក់វេនគ្នាម្នាក់ម្ដងក្នុងការជ្រើសរើសរូបភាពទាំងនោះពីក្នុងថង់ ។ សូមស្វែងរកប្រយោគ និង ខគម្ពីរដែលត្រូវគ្នានឹងរូបភាពនិមួយៗ និង អានវាឮៗ ។




ព្រះវិញ្ញាណបរិសុទ្ធជួយយើងដឹងពីសេចក្ដីស្រឡាញ់របស់ព្រះវរបិតា និង អារម្មណ៍ល្អដទៃទៀត ដូចជាសេចក្ដីអំណរ សុភាពរាបសា និង ចិត្តល្អ ។ ជាធម្មតា ទ្រង់មានបន្ទូលមកកាន់ដួងចិត្ត និង គំនិតរបស់យើងតាមរយៈសំឡេងដ៏តូចរហៀង ( សូមមើល កាឡាទី 5:22–23 ) ។

ព្រះវិញ្ញាណបរិសុទ្ធព្រមានយើងអំពីគ្រោះថ្នាក់ និង ជួយយើងឲ្យដឹងនៅពេលណាដែលយើងត្រូវប្រយ័ត្ន ( សូមមើល គ. និង ស. 9:9 ) ។



« ព្រះវិញ្ញាណបរិសុទ្ធគឺជាគ្រូបង្រៀន » ។ ទ្រង់បង្រៀនយើងអំពីព្រះយេស៊ូវគ្រីស្ទ និង ជួយយើងចងចាំពីអ្វីទាំងអស់ដែលយើងបានរៀន ពីឪពុកម្ដាយ គ្រូបង្រៀន និង បទគម្ពីរទាំងឡាយរបស់យើង ( សូមមើលយ៉ូហាន 14:26 ) ។



ព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើង និង ជួយយើងឃើញច្បាស់ពីអ្វីមួយដើម្បីធ្វើការសម្រេចចិត្តដែលនឹងនាំយើងត្រឡប់ទៅជួបព្រះវរបិតាសួគ៌វិញ ( សូមមើលនីហ្វៃទី 2 32:5 ) ។



ជូនកាលព្រះវិញ្ញាណបរិសុទ្ធត្រូវបានហៅថាជាព្រះដ៏ជាជំនួយ។ ទ្រង់ជួយយើងមានអារម្មណ៍នៃសុវត្ថិភាព និង សេចក្ដីសុខសាន្ដដូចជាភួយដ៏ទន់ល្មើយ ( សូមមើល យ៉ូហាន 14:16 និង 27 ) ។



### ចូរយើងពិភាក្សា

សូមសួរនរណាម្នាក់ដែលបានជ្រមុជទឹក និង បញ្ជាក់រួចហើយ ឲ្យរៀបរាប់នូវអារម្មណ៍របស់គាត់អំពីថ្ងៃដ៏ពិសេសនោះ ។ បើសិនជាអ្នកបានទទួលបុណ្យជ្រមុជទឹករួចហើយ សូមចែកចាយពីអារម្មណ៍ដែលអ្នកមាន នៅពេលអ្នកទទួលបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ជាមួយនឹងនរណាម្នាក់ទៀត ។

### ព្រះគម្ពីរ និង ចម្រៀង

- ម៉ូសាយ 18:8–11
- « When I Am Baptized » ( *សៀវភៅចម្រៀងរបស់កុមារទំព័រ* 103 )

រចនារូបភាពដោយ ថូម៉ាស អេស. ឆាល



# ពរជ័យនៃបុណ្យជ្រមុជទឹក

*ការជ្រមុជចូលទៅក្នុងទឹកតែងតែធ្វើឲ្យ ទ្រេវី មានអារម្មណ៍ភ័យខ្លាច ។ តើគាត់អាចជ្រមុជទឹកបានដោយរបៀបណា ?*

**ដោយ ខាសី អាយ**

**ទ្រេវី** បានអង្គុយចុះនៅលើសាឡុង និងយកដៃច្រត់ចង្កា ។ បងប្អូនប្រុសឯទៀតរបស់គាត់កំពុងលេងជាមួយនឹងលោកតា ។ គាត់ក៏មានបំណងចង់សប្បាយដែរ ប៉ុន្តែគាត់មិនអាចឈប់ព្រួយបារម្ភអំពីពិធីបុណ្យជ្រមុជទឹករបស់គាត់បានឡើយ ។

ម៉ាក់បានអង្គុយជិតគាត់ ហើយយកដៃចូកសក់របស់គាត់ ។ ម៉ាក់បានសួរថា « មានរឿងអ្វីហ្នឹងកូន ? » « តើកូនអត់ចង់ទៅលេងនឹងគេទេឬ ? »

ទ្រេវី គ្រវីក្បាលទាំងទឹកមុខមិនសប្បាយចិត្ត ។

ម៉ាក់បានសំឡឹងមើលមុខគាត់មួយសន្ទុះ ក្រោយមកម៉ាក់បានឱបគាត់ ។ « តើកូននៅតែព្រួយបារម្ភអំពីការជ្រមុជចូលទៅក្នុងទឹកទៀតមែនទេ ? »

ទ្រេវីបានងក់ក្បាល ។

ការជ្រមុជចូលទៅក្នុងទឹក តែងតែជាគំនិតមួយដែលធ្វើឲ្យទ្រេវីភ័យខ្លាច ។ នៅពេលគាត់មានអាយុបីឆ្នាំ គាត់បានធ្លាក់ចូលទៅក្នុងអាងហែលទឹក ។ គាត់

រូបភាពដោយ ខារិន ឃើល



មិនដែលភ្លេចនូវអារម្មណ៍ភ័យខ្លាចដែលគាត់បានមាននៅពេលគាត់បានលិចចូលទៅក្នុងទឹកជ្រៅទៅៗ រហូតដល់មាននរណាម្នាក់បានទាញគាត់ចេញ ។ ចាប់តាំងពីពេលនោះមក គាត់មានអារម្មណ៍ខ្លាចទឹកណាស់ ។

ទ្រេវី បានសួរថា ៖ « ហេតុអ្វីបានជាគ្មានអ្វីជួយសោះអញ្ចឹង ? » « យើងបានទាំងអធិស្ឋាន ហើយបានទៅមើលអាងទឹកទៀត ។ គ្មានអ្វីបានជួយខ្ញុំសោះ ! » ទ្រេវី លោតចុះពីសាឡុង ហើយរត់ចូលទៅក្នុងបន្ទប់របស់គាត់ ។

បិទទ្វារបន្ទប់របស់គាត់យ៉ាងខ្លាំង ហើយទ្រេវីបានក្រាបលើពូករបស់គាត់ ។ ភ្លាមៗនោះ គាត់បានឮសំឡេងគោះទ្វារតិចៗ ។

ទ្រេវីបានងើបឡើង ខណៈដែលប៉ាបានអង្គុយចុះនៅក្បែរគាត់ ។ ប៉ាបាននិយាយថា ៖ « ម៉ាក់បានប្រាប់ប៉ាថា កូននៅតែមានអារម្មណ៍ខ្លាចអំពីការជ្រមុជទឹក » ។

ទ្រេវី បានងក់ក្បាល ។ « កូនបានបន្តអធិស្ឋាន ប៉ុន្តែអារម្មណ៍ភ័យខ្លាចនោះនៅតែមានដដែល » ។

ប៉ាបានគិតមួយសន្ទុះ ។ « ជួនកាលនៅពេលយើងអធិស្ឋានសុំអ្វីមួយ វាមិនកើតឡើងភ្លាមៗទេ ។ កូនអាចនៅមានអារម្មណ៍ភ័យខ្លាចឥឡូវនេះ ប៉ុន្តែនៅថ្ងៃស្អែកប្រហែលជាកូននឹងមានអារម្មណ៍ល្អជាងនេះ » ។

ទ្រេវីបានងក់ក្បាលរបស់គាត់ តែក្រោយមកគាត់បាននឹងចាំពីពេលដែលគាត់មានអារម្មណ៍ភ័យខ្លាចនៅពេលគាត់ចូលរៀនដំបូងកាលពីឆ្នាំមុន ។ ប៉ាបានផ្តល់ការប្រសិទ្ធិពរជ័យដល់គាត់ ។ ប្រហែលការប្រសិទ្ធិពរអាចជួយគាត់ឲ្យទទួលបុណ្យជ្រមុជទឹក ។ គាត់បានសំឡឹងមើលប៉ា ។ « តើលោកប៉ាគិតថា លោកប៉ា និង លោកតាអាចផ្តល់ការប្រសិទ្ធិពរមួយឲ្យកូនបានទេ ? »

ប៉ាបានងក់ក្បាល ។ « ប៉ាគិតថា នេះជាគំនិតល្អ » ។

បន្តិចក្រោយមក ទ្រេវីបានអង្គុយចុះនៅនឹងកៅអីមួយក្នុងបន្ទប់ជាគ្រួសារមួយ ។ ប៉ា និង លោកតាបានដាក់ដៃរបស់ពួកគាត់លើក្បាលរបស់គាត់ ។ ប៉ាបានប្រសិទ្ធិពរដល់គាត់ដោយនិយាយថា បើសិនជាគាត់មានសេចក្តីជំនឿ ព្រះវរបិតាសួគ៌អាចជួយគាត់មានអារម្មណ៍ស្ងប់ស្ងាត់ និង សុខសាន្ត ។

មួយថ្ងៃបន្ទាប់មក ខណៈដែលទ្រេវីអង្គុយនៅក្នុងពិធីបុណ្យជ្រមុជទឹករបស់គាត់ដោយពាក់សម្លៀកបំពាក់ពណ៌ស នោះទ្រេវីនៅតែមានអារម្មណ៍ភ័យខ្លាច ។ គាត់ត្រេកអរដោយបានទទួលនូវការប្រសិទ្ធិពរមួយ តែគាត់នៅតែភ័យខ្លាច តើធ្វើយ៉ាងណា ? តើគាត់នឹងទទួលបុណ្យជ្រមុជទឹកដោយរបៀបណាទៅ ?

បន្ទាប់ពីបានស្តាប់ការនិយាយអំពីបុណ្យជ្រមុជទឹក ប៉ាបានឱនទៅរកគាត់ ។ ប៉ាបាននិយាយថា ៖ « វាដល់ពេលទៅអាងជ្រមុជទឹកហើយ » ។ ទ្រេវីងក់ក្បាល ហើយដើរតាមប៉ាទៅឯអាងទឹក ។ប៉ាបានចុះទៅមុន ។

វាដល់ពេលទ្រេវីម្តង ។ គាត់ស្ទាក់ស្ទើរ ប៉ុន្តែក្រោយមកគាត់បាននឹកចាំអំពីពរជ័យរបស់គាត់ ។ គាត់បានអធិស្ឋានក្នុងចិត្តដោយស្ងៀមស្ងាត់ថា ៖ « ព្រះវរបិតាអើយ សូមជួយទូលបង្គំឲ្យមានសេចក្តីជំនឿផង » ។

ទ្រេវី បានដាក់ជើងម្ខាងចូលទៅក្នុងទឹកយឺតៗ ។ ទឹកនោះថ្លាក្តៅអ៊ុនៗ ។ ទ្រេវី ឈានជើងម្ខាងទៀត ។

ជាមួយនឹងការបោះជំហានទៅមុខនីមួយៗ នោះគាត់អាចមានអារម្មណ៍ថា ការព្រួយបារម្ភ និង ការភ័យខ្លាចបានបាត់ចេញពីដួងចិត្តរបស់គាត់ ។ ប៉ាបានចាប់ដៃគាត់ ហើយញញឹម ។ « រួចនៅកូន ? »

ទ្រេវីបានមានអារម្មណ៍កក់ក្តៅ និង សុខស្រួល ។ នេះគឺជាអារម្មណ៍ដែលព្រះវរបិតាបានសន្យាថានឹងប្រទានដល់គាត់ ។ គាត់បានងក់ក្បាល ។ « រួចហើយ » ។

ប៉ាបានលើកដៃស្តាំរបស់គាត់ឡើង ហើយបាននិយាយនូវកាអធិស្ឋាននៃពិធីបុណ្យជ្រមុជទឹក ។ នៅពេលដែលប៉ាបានជ្រមុជទ្រេវីចុះទៅក្នុងទឹក គាត់មិនមានអារម្មណ៍ភ័យខ្លាចនោះទេ ។ អ្វីដែលគាត់មាននោះគឺ អារម្មណ៍ដ៏ស្ងប់ស្ងាត់ សុខសាន្ត ដែលកើតមានធំឡើងៗ ។

ទ្រេវីបានងើបចេញពីទឹកវិញទាំងស្នាមញញឹម ។ គាត់បានដឹងថា សេចក្តីជំនឿរបស់គាត់បានជួយគាត់យកឈ្នះលើសេចក្តីភ័យខ្លាចរបស់គាត់ ដូច្នេះគាត់អាចជ្រមុជទឹកបាន ។ គាត់បានដឹងថា ព្រះវរបិតានឹងតែងតែជួយគាត់ នៅពេលណាដែលគាត់ព្យាយាមជ្រើសរើសអ្វីដែលត្រូវ ។ ■

*អ្នកនិពន្ធ រស់នៅក្នុងរដ្ឋ ណាវ៉ាដា សហរដ្ឋអាមេរិក ។*



« នៅពេលណាយើងជ្រើសរើសដើម្បីដើរតាមព្រះគ្រីស្ទ ជាជាងការជ្រើសរើសដើរតាមផ្លូវផ្សេងដោយសេចក្តីភ័យខ្លាច នោះយើងនឹងមានពរជ័យ » ។

**អែលឌើរ ឃ្វីនធិន អិល. ឃុក កូរ៉ុមនៃពួកសាវកដប់ពីរនាក់ « រស់ដោយសេចក្តីជំនឿ មិនមែនដោយសេចក្តីភ័យខ្លាចទេ »** ***លីអាហូណា*** **និង** ***Ensign*** **ខែ វិច្ឆិកា ឆ្នាំ 2007 ទំព័រ 73 ។**

# សួស្តី ! ខ្ញុំឈ្មោះ អ៊ិនចិន អេ.

## មកពីប្រទេស ម៉ុងហ្គោលី



ខ្ញុំមិនមានសត្វចិញ្ចឹមទេ ទោះជាយ៉ាងនោះក្តីខ្ញុំចង់បានកូនឆ្កែមួយ ។ ជួនកាលយើងទៅលេងនៅតាមជនបទ ជាកន្លែងដែលខ្ញុំឃើញសត្វគោ ចៀម អូដ សេះ និង ពពែ ។ នៅក្នុងរដូវរងា ខ្ញុំចូលចិត្តសង់មនុស្សព្រិល នៅទីនោះ ។ នេះជាខ្ញុំជាមួយនឹងបងប្រុសខ្ញុំ និង មិត្តភក្តិនៅ អណ្តើកថ្ម ក្នុងឧទ្យានជាតិ ធេរើលី ។

**តើ** អ្នកចូលចិត្តធ្វើអ្វីជាមួយនឹងក្រុមគ្រួសាររបស់អ្នក ? អ៊ិនចិន អេ. អាយុ 8 ឆ្នាំ មកពីប្រទេស ម៉ុងហ្គោលី ចូលចិត្តទៅលេងតាមជនបទជាមួយនឹងគ្រួសាររបស់នាង និង ចូលចិត្តរើសផ្លែបេរីព្រៃ និង ផ្លែស្ត្របេរី ។

ខ្ញុំមានអារម្មណ៍រីករាយ នៅពេលគ្រួសាររបស់យើងចំណាយពេលជុំគ្នា ។ យើងរីករាយនឹងមានរាត្រីជួបជុំក្រុមគ្រួសារ និង ការទៅព្រះវិហារជារៀងរាល់សប្តាហ៍ ។ យើងក៏បានអានព្រះគម្ពីរមរមន និង អធិស្ឋានជុំគ្នាជារៀងរាល់ថ្ងៃផងដែរ ។ កិច្ចការទាំងនេះ ជួយឲ្យគ្រួសាររបស់ខ្ញុំរឹងមាំ ។







ខ្ញុំបានរស់នៅជាមួយនឹងម៉ាក់ ប៉ា និង បងប្អូនប្រុសពីរនាក់ទៀតក្នុងទីក្រុង អូឡានបាតា ជារដ្ឋធានីរបស់ប្រទេសម៉ុងហ្គោលី ។ មានមនុស្សមួយលាននាក់រស់នៅក្នុងទីក្រុងរបស់យើង ! យើងរស់នៅក្នុងអគារជួលជាន់ទី 12 ។



ក្នុងរូបនេះ ខ្ញុំកំពុងអានរឿងឲ្យប្អូនប្រុសខ្ញុំស្ដាប់ ។ ខ្ញុំចូលចិត្តអាន ! ខ្ញុំរៀននៅថ្នាក់ទីបី ។ ខ្ញុំក៏ចូលចិត្តគណិតវិទ្យា និង គំនូរដែរ ។ មិត្តរួមថ្នាក់ម្នាក់របស់ខ្ញុំម្នាក់មិនមែនជាសមាជិកនៃសាសនាចក្រទេ ប៉ុន្តែខ្ញុំបង្រៀននាងអំពី ពាក្យសំដីនៃប្រាជ្ញាវាងវៃ ហើយប្រាប់នាងឲ្យញ៉ាំទឹកដោះគោ ជំនួសឲ្យកាហ្វេ និង តែ ។ ខ្ញុំក៏បានបង្រៀននាងអំពីរបៀបអធិស្ឋានទៅព្រះវរបិតាសួគ៌ តាំងពីនាងមិនទាន់ចេះអធិស្ឋានម្ល៉ះ ។ ខ្ញុំក៏បានអញ្ជើញនាងទៅចូលរួមក្នុងរាត្រីជួបជុំក្រុមគ្រួសារនៅផ្ទះរបស់ខ្ញុំទៀតផង ។

## ចំណង់ចំណូលចិត្តរបស់ អ៊ិនចិន ៖

ម្ហូប—ភីហ្សា និង ដំឡូងបារាំងកិន ។

ព្រះគម្ពីរ—នីហ្វៃទី1 3:7

ចម្រៀង— « ផ្ទុំក្នុងស្នូក » « រឿងព្រះគម្ពីរមរមន »

រូបភាពរបស់ក្រុមគ្រួសារ អ៊ិនចិន រចនារូបភាពដោយ ប្រាដ ធា

# អ្នកគង្វាល និង ចៀមដែលបាត់

ដោយ ម៉ាហ្គោ មៃ រដ្ឋ យូថាហ៍ សហរដ្ឋអាមេរិក



ព្រះយេស៊ូវបានបង្រៀនប្រជាជនដោយមានបន្ទូលប្រាប់ពួកគេជារឿង ។ នាថ្ងៃមួយ ទ្រង់បានមានបន្ទូលប្រាប់រឿងមួយអំពីអ្នកគង្វាលម្នាក់ដែលមានចៀមចំនួន 100 ក្បាល ។ អ្នកគង្វាលនោះជាមនុស្សល្អ និង មានចិត្តល្អ ។ គាត់រក្សាចៀមរបស់គាត់ឲ្យមានសុវត្ថិភាពពីក្រុមសត្វព្រៃ ។ គាត់បានចាំយាមចៀមទាំងនោះពេលយប់ ។

រចនារូបភាពដោយ ជើង ហាប៊ឺន



មានថ្ងៃមួយ មានចៀមមួយបាត់ ។ អ្នកគង្វាលបានទុកចៀម 99 ទៀតឲ្យនៅកន្លែងមានសុវត្ថិភាព ហើយចេញទៅរកចៀមមួយដែលបាត់ ។ គាត់បានស្វែងរកនៅតាមទីខ្ពស់ក្នុងច្រកភ្នំ និងទីឆ្ងាយៗនៅតាមទីវាល ។

ទីបំផុត នៅពេលដែលគាត់រកឃើញចៀមរបស់គាត់ អ្នកគង្វាលនោះត្រេកអរជាខ្លាំង ។ គាត់បានលើកចៀមនោះដាក់លើស្មារបស់គាត់ ហើយបានលីវាត្រឡប់មកផ្ទះវិញ ។



អ្នកគង្វាលនោះបានហៅមិត្តភក្តិរបស់គាត់មកជុំគ្នា ហើយបានប្រាប់ពួកគេអំពីរបៀបដែលគាត់បានរកឃើញចៀមរបស់គាត់វិញ ។ ពួកគេជប់លៀងជាមួយគ្នា ។

នៅក្នុងរឿងនេះ ព្រះយេស៊ូវដូចជាអ្នកគង្វាលម្នាក់នោះ ហើយយើងដូចជាកូនចៀមនោះ ។ ព្រះយេស៊ូវមើលថែយើង និង ជួយការពារយើងពីគ្រោះថ្នាក់ ។ ទ្រង់មិនដែលបោះបង់យើងឡើយ នៅពេលដែលយើងបានធ្វើកំហុស ។ ហើយទ្រង់មានក្តីអំណរ នៅពេលយើងកែប្រែចិត្ត ហើយត្រឡប់ទៅរកដំណឹងល្អរបស់ទ្រង់វិញ ។ ដោយហេតុនេះហើយបានជាព្រះគម្ពីរហៅទ្រង់ថា អ្នកគង្វាលល្អ ។ ■

*ដកស្រង់ចេញពី ម៉ាថាយ 18:12–14 និង លូកា 15:3–7 ។*



ព្រះយេស៊ូវបង្រៀនរឿងប្រដូចអំពីចៀមដែលបាត់

*« ក្នុងចំណោមពួកអ្នករាល់គ្នា បើអ្នកណាមានចៀមមួយរយ តែបាត់មួយ តើមិនទុកចៀមកៅសិបប្រាំបួន ឲ្យនៅទីរហោស្ថាន ដើម្បីទៅតាមរកចៀមមួយដែលបាត់ ទាល់តែឃើញទេឬអី ? » ( លូកា 15:4 ) ។*

រចនារូបភាព ដោយ ជ៉ារ៉េត ប៊េក ស្ត្រង់

10686_258_Gen News Jun 4/4/13 11:37 AM Page 74

# ព័ត៌មានអំពីសាសនាចក្រ

*សូមមើលគេហទំព័រ news.lds.org សម្រាប់ព័ត៌មាន និង ព្រឹត្តិការណ៍បន្ថែមទៀតរបស់សាសនាចក្រ ។*

## ប្រវត្តិសាស្ត្រសាសនាចក្រមានការផ្លាស់ប្តូរអំឡុងពេលនៃការបម្រើរបស់ប្រធាន ម៉នសុន

អំឡុងពេលប្រាំឆ្នាំកន្លងទៅនេះ ក្រោមការដឹកនាំរបស់ប្រធាន ថូម៉ាស អេស. ម៉នសុន នោះប្រវត្តិសាស្ត្រសាសនាចក្រមានការផ្លាស់ប្តូរជាច្រើនដែលបានជះឥទ្ធិពលដល់សមាជិកទូទាំងសាកលលោក ។ ស្នាដៃដ៏អស្ចារ្យដែលប្រធានទី 16 របស់សាសនាចក្របានធ្វើអាចបញ្ជាក់បាន តាមរយៈការប្រកាសសំខាន់ៗជាច្រើន និង ការអនុវត្តន៍គោលនយោបាយថ្មីៗ ចាប់តាំងពីកិច្ចការផ្សព្វផ្សាយសាសនា និង ការប្រជុំបំពាក់បំប៉នថ្នាក់ដឹកនាំបព្វជិតភាព រហូតដល់ការកសាងព្រះវិហារបរិសុទ្ធយ៉ាងច្រើន ។

គោលនយោបាយ និង ការប្រកាសជាច្រើនបានត្រូវបង្ហាញ អំឡុងការបម្រើរបស់ប្រធាន ម៉នសុន ដែលបានបានជះឥទ្ធិពលដល់សាកលលោក—ពីព្រោះ មូលដ្ឋានគ្រឹះទាំងនោះត្រូវបានរៀបចំឡើងដើម្បីបម្រើ និង ថែរក្សាបុគ្គលម្នាក់ៗ ។ ការខ្វល់ខ្វាយពេញមួយជីវិតរបស់លោកសម្រាប់បុគ្គលម្នាក់ៗ គឺជាភស្តុតាងនៅក្នុងប្រវត្តិសាស្ត្រនីមួយៗក្នុងពេលនេះ ។

នេះគឺជាការដកស្រង់មួយចំនួនពីការព្យាការនៃពាក់កណ្តាលទស្សវត្សរ៍ដំបូងរបស់ប្រធាន ថូម៉ាស អេស. ម៉នសុន ៖

- ដើម្បីបង្កើន ឱកាសសម្រាប់សមាជិកវ័យក្មេងរបស់សាសនាចក្រ ឱ្យបម្រើបេសកកម្មពេញម៉ោង ប្រធាន ម៉នសុន បានប្រកាសកាលពីថ្ងៃទី 6 ខែ តុលា ឆ្នាំ 2012 ថា បុរសអាចចាប់ផ្តើមបម្រើនៅអាយុ 18 ឆ្នាំ ហើយស្ត្រីនៅអាយុ 19 ឆ្នាំ ។ ការប្រកាសរបស់លោកបានធ្វើឡើងអំឡុងពេល បើកសម័យប្រជុំសន្និសីទទូទៅពាក់កណ្តាលឆ្នាំ លើកទី 182 របស់សាសនាចក្រ ហើយបានបង្កើនចំនួនដ៏ច្រើនអស្ចារ្យ ដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ ចាប់តាំងពីការប្រកាសនោះមក នាយកដ្ឋានអ្នកផ្សព្វផ្សាយសាសនារបស់សាសនាចក្របានទទួលពាក្យបម្រើបេសកកម្មច្រើនជាងមុនដោយមានទាំងយុវជន និង យុវនារីដែលចង់បម្រើបេសកកម្មយ៉ាងខ្លាំង ។
- នៅក្នុងសំបុត្រមួយដែលចុះហត្ថលេខារួមគ្នា ដោយទីប្រឹក្សានៅក្នុងប្រធានទីមួយ—ប្រធាន ហិនរី ប៊ី. អាវរិង និង ប្រធាន ឌៀថើរ អេហ្វ. អុជដូហ្វ—ប្រធាន ម៉នសុន បានប្រកាសការអនុវត្តន៍សម្រាប់ឆ្នាំ 2013 នៃការរៀបចំកម្មវិធីសិក្សាថ្មីសម្រាប់យុវវ័យ « ដើម្បីពង្រឹង និង សាងសេចក្តីជំនឿ ការប្រែចិត្តជឿ និង ទីបន្ទាល់ » នៅក្នុងយុវវ័យរបស់សាសនាចក្រ ។ កម្មវិធីសិក្សាថ្មីនេះ បានផ្តល់នូវអន្តរកម្មនៃការបង្រៀនបន្ថែមទៀតនៅថ្នាក់បព្វជិតភាពអើរ៉ុន យុវនារី និង ថ្នាក់សាលាថ្ងៃអាទិត្យយុវវ័យ បានធ្វើតាមគំរូដែលព្រះអង្គសង្គ្រោះបានបង្រៀនអំឡុងការបម្រើរបស់ទ្រង់លើផែនដីនេះ ។ ថ្នាក់រៀនជាប្រចាំសប្តាហ៍ទាំងនេះ ប្រើប្រាស់ធនធានទំនើបតាមអ៊ីនធើរណែតជាច្រើនរបស់សាសនាចក្រ នោះបានធ្វើឱ្យយុវវ័យរីករាយចូលរួម និង ជិតដិតកាន់តែប្រសើរ ។
- ក្រោមការដឹកនាំរបស់ប្រធាន ម៉នសុន និង គណៈប្រធានទីមួយ នោះសាសនាចក្របន្ត ផ្តល់ការប្រជុំបំពាក់បំប៉នថ្នាក់ដឹកនាំទូទាំងពិភពលោក ដើម្បីជួយអ្នកដឹកនាំបព្វជិតភាព និង អ្នកដឹកនាំទាំងឡាយនៃអង្គការជំនួយ និង ក្រុមគ្រួសារនៅក្នុងមូលដ្ឋាន នៅក្នុងកិច្ចខិតខំរបស់ពួក ដើម្បីបម្រើសមាជិក និង ប្រែចិត្តជឿឱ្យកាន់តែខ្លាំង ។ ការប្រជុំបំពាក់បំប៉ននេះ ធ្វើឱ្យអ្នកដឹកនាំ និង សមាជិកក្នុងមូលដ្ឋាន ទទួលការណែនាំមកពីសមាជិកទាំងឡាយនៃគណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ពួកអ្នកមានសិទ្ធិអំណាចទូទៅផ្សេងទៀត និង អ្នកដឹកនាំអង្គការជំនួយទូទៅ ។ ការប្រជុំបំពាក់បំប៉នទូទាំងពិភពលោកបានរួមបញ្ចូលពីសេចក្តីណែនាំ ស្តីពីការប្រើប្រាស់ក្បួនខ្នាតថ្មី (បានណែនាំនៅក្នុង ឆ្នាំ 2010) បំពាក់បំប៉នអំពីការដឹកនាំការប្រជុំក្រុមប្រឹក្សាឱ្យកាន់តែមានប្រសិទ្ធិភាព និង ពង្រឹងក្រុមគ្រួសារ និង សាសនាចក្រតាមរយៈបព្វជិតភាព ។
- នៅក្នុងឆ្នាំ 2010 គណៈប្រធានទីមួយ បានចាប់ផ្តើមចាត់តាំងសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដើម្បីដឹកនាំការប្រជុំអន្តរជាតិថ្មីពីរយ៉ាង—សន្និសីទថ្នាក់ដឹកនាំបព្វជិតភាព និង ការពិនិត្យតំបន់ឡើងវិញ ។ អំឡុងពេលសន្និសីទថ្នាក់ដឹកនាំបព្វជិតភាពនីមួយៗ គណៈប្រធានស្តេក ប៊ីស្សព និង ប្រធានសាខាទាំងឡាយដែលនៅក្នុងតំបន់ដែលបានរើសតាំងនៃសាសនាចក្រត្រូវបាននាំមកជុំគ្នាសម្រាប់ការបំពាក់បំប៉ននោះ ។ នៅក្នុងការពិនិត្យមើលតំបន់នីមួយៗឡើងវិញ អ្នកដឹកនាំទាំងឡាយផ្តោតសម្លឹងមើលលើអ្វីដែលកំពុងកើតឡើងជាមួយសាសនាចក្រ ទៅតាមអ្វីៗដែលសាសនាចក្របានផ្តល់ឱ្យ ហើយពិនិត្យមើលចំណុចទាំងននោះឡើងវិញដូចជា សេវាកម្មមនុស្សធម៌ តម្រូវការសុខុមាលភាព កិច្ចការផ្សព្វផ្សាយសាសនា និង កិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ។
- អំឡុងពេលនៃការបម្រើរបស់ប្រធាន ម៉នសុន នោះព្រះវិហារបរិសុទ្ធថ្មីចំនួន 31 ត្រូវបានប្រកាសទូទាំងពិភពលោក ។ ព្រះវិហារបរិសុទ្ធចំនួនដប់ប្រាំមួយ

10686_258_Gen News Jun 4/4/13 11:38 AM Page 75



រូបថតដោយ អ័រគើស មីល័រ *ឃាយប្រយ៏ រយឿ*

*ប្រធាន ថូម៉ាស អេស. ម៉នសុន មានប្រសាសន៍ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ នៅការប្រកាសនៃគណៈប្រធានទីមួយនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ កាលពីថ្ងៃច័ន្ទ ទី 4 ខែ កុម្ភៈ ឆ្នាំ 2008 ។*

ត្រូវបានឧទ្ទិសឆ្លង ហើយព្រះវិហារបរិសុទ្ធចំនួនប្រាំទៀតត្រូវបានឧទ្ទិសឡើងវិញបន្ទាប់ពីបានធ្វើការជួសជុលហើយ ។ ប្រធាន ម៉នសុន ផ្ទាល់ជាគណៈអធិបតីនៃការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនៅ ទីក្រុង កាល់ហ្គារី, អាល់ប៊ើរតា, ប្រទេស កាណាដា, ទីក្រុង ស៊ីប៊ូ ប្រទេស ហ្វីលីពីន, ទីក្រុង យើរីទីបា ប្រទេស ប្រេស៊ីល, ទីក្រុង ឃីអីវ ប្រទេស អ៊ុយក្រែន, ទីក្រុង ប៉ាណាម៉ា ប្រទេស ប៉ាណាម៉ា, ទីក្រុង វ៉ានគូវើរ, ប្រ៊ីតធីស កូឡុំប៊ី ប្រទេស កាណាដា និង ទីក្រុង ត្រាបភើរ រដ្ឋ យូថាហ៍, ទីក្រុង ខាន់សាស រដ្ឋ មិសសួរី, ទីក្រុង រ៉េចប៊ើក រដ្ឋ អៃដាហូ, ទីក្រុង យ័រដាន់ភាគខាងត្បូង រដ្ឋ យូថាហ៍, ទីក្រុង ហ្គាលីវ៉ាលី រដ្ឋ អារីហ្សូណា និង ទីក្រុង ធ្វីន ហ្វល រដ្ឋ អៃដាហូ ស.រ.អា. និង នៅឯការឧទ្ទិសឆ្លងឡើងវិញនៃព្រះវិហារបរិសុទ្ធនៅទីក្រុង មិកស៊ីកូ ប្រទេស មិកស៊ីកូ និង ទីក្រុង អាត្លង់តា រដ្ឋ ចចចារ, ទីក្រុង ប៉យស៊ី រដ្ឋ អៃដាហូ និង ទីក្រុង ឡាអ៊ីអេ រដ្ឋ ហាវ៉ៃ ស.រ.អា. ។

- ប្រធាន ម៉នសុន ក៏បានធ្វើជាគណៈអធិបតីនៅចំពេលមួយនៃការប្រើប្រាស់ធនធានទាំងឡាយរបស់សាសនាចក្រតាមអ៊ីនធើរណែតបានកាន់តែច្រើនជាងមុន ដែលផ្ដល់ប្រសាសន៍របស់ព្យាការី និង កម្មវិធីទាំងឡាយរបស់សាសនាចក្រទៅកាន់សមាជិកប្រហែលជា 14 លាននាក់នៅជុំវិញពិភពលោក ។ ការដកស្រង់សំខាន់តាមអ៊ីនធើរណែតរួមមានវីដេអូដែលសាសនាចក្របានផលិតជាច្រើន ព្រមទាំងវីដេអូភាគដែលបានដកស្រង់ចំណុចសំខាន់ៗពីព្រះគម្ពីរសញ្ញាថ្មី ។
- ក្រោមការដឹកនាំរបស់គណៈប្រធានទីមួយ សាសនាចក្របានផលិតសៀវភៅថ្មីមួយ ដែលមានចំណងជើងថា *Daughters in My Kingdom: The History and Work of Relief Society* ។ សៀវភៅនេះមានបំណងធ្វើជាធនធានផ្ទាល់ខ្លួន និង គ្រួសារដើម្បីពង្រឹងស្ត្រីនៅក្នុងការទទួលខុសត្រូវទាំងឡាយរបស់ពួកគេ ។
- ក្រោមការដឹកនាំរបស់ប្រធាន ម៉នសុន នោះសាសនាចក្របានឆ្លើយតបចំពោះគ្រោះធម្មជាតិនៅទូទាំងពិភពលោក ដោយឈោងទៅរក និង ជួយអស់អ្នកណាដែលត្រូវការជំនួយ ។ ការឆ្លើយតបជំនួយមនុស្សធម៌ធំៗមួយចំនួននៅក្នុងប្រាំឆ្នាំកន្លងទៅនេះ រួមមានកិច្ចខិតខំដើម្បីជួយបន្ទាប់ពីការរញ្ជួយដីនៅប្រទេស ហៃទី ការរញ្ជួយដី និង រលកស៊ូណាមី នៅក្នុងប្រទេស ជប៉ុន និង ទឹកជំនន់នៅក្នុងប្រទេស ថៃ ។ សាសនាចក្រក៏បានឆ្លើយតបដល់វិបត្តិអត់អាហារដ៏ធ្ងន់ធ្ងរនៅទូទាំងប្រទេស អាហ្វ្រិកខាងកើត បានជួយចាក់វ៉ាក់សាំងការពារដល់កូនក្មេងនៅក្នុងប្រទេសជាច្រើន ហើយបានផ្ដល់ទឹកស្អាតដល់ភូមិឆ្ងាយដាច់ស្រយាលជាច្រើន ។ ក្រៅពីនេះទៀត សាសនាចក្របានឧទ្ទិសឆ្លងដីថ្មីមួយដែលមានផ្ទៃក្រឡា 570,391 ហ្វូត (53,000 ម៉ែត្រការ៉េ) សម្រាប់អគារសុខុមាលភាពនៅក្នុងទីក្រុង សលត៍លេក រដ្ឋ យូថាហ៍ ស.រ.អា. ។ ■

10686_258_Gen News Jun 4/4/13 11:38 AM Page 76

# អ្នកដឹកនាំសាសនាចក្រពិភាក្សាគ្នាពី « ការបង្ហើយការឱ្យបានឆាប់ »

**ដោយ សារ៉ា ជេន វើវើរ**

*ព័ត៌មានសាសនាចក្រ*

អំឡុងការផ្លាស់ប្ដូរដែលតម្រូវឱ្យយុវវ័យនៃពួកបរិសុទ្ធថ្ងៃចុងក្រោយទទួលនូវតួនាទីដ៏អស្ចារ្យក្នុងការរៀបចំធ្វើជាអ្នកផ្សព្វផ្សាយសាសនា កិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ និង ការណែនាំថ្ងៃអាទិត្យ នោះអ្នកដឹកនាំបាននិយាយដល់យុវវ័យនៃសាសនាចក្រថា « ត្រូវបានហៅឱ្យធ្វើសកម្មភាព » និង សុំឱ្យ « ក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ » (គ. និង ស. 115:5)

អែលឌើរ ប៉ូល ប៊ី. ផៃបភើរ នៃពួកចិតសិបនាក់បានមានប្រសាសន៍ថា ការផ្លាស់ប្ដូរនេះធ្វើឱ្យមានការច្បាស់លាស់មួយគឺថា ៈ « ព្រះអម្ចាស់មានអ្វីៗដែលទ្រង់ចង់ធ្វើ » ។

ថ្មីៗនេះ អែលឌើរ ផៃបភើរ នាយកប្រតិបត្តិនៃនាយកដ្ឋានបព្វជិតភាព បានចូលរួមនៅក្នុង *ព័ត៌មានសាសនាចក្រ* ដោយបានពិភាក្សាគ្នាជាក្រុមស្ដីអំពីការផ្លាស់ប្ដូរដែលនឹងជះឥទ្ធិពលដល់យុវវ័យតាមរបៀបជាច្រើន ។ អែលឌើរ អាលែន អែហ្វ. ផាកកឺ នៃពួកចិតសិបនាក់ និង ជានាយកប្រតិបត្តិនៃនាយកដ្ឋានពង្សប្រវត្តិ, អែលឌើរ វិលលាម្ស អ័រ. វ៉កឃើរនៃពួកចិតសិបនាក់ និង ជានាយកប្រតិបត្តិនៃនាយកដ្ឋានព្រះវិហារបរិសុទ្ធ, អែលឌើរ ដបុលយូ. ហ្វ្រេក ស្ទីក នៃពួកចិតសិបនាក់ និង ជំនួយការនាយកប្រតិបត្តិនៃនាយកដ្ឋានអ្នកផ្សព្វផ្សាយសាសនា,អែលឌើរ ផល វី. ចនសុន នៃពួកចិតសិបនាក់ និង អ្នកតំណាងនៃការអប់រំរបស់សាសនាចក្រ, អែលឌើរ ដានីស ស៊ី. ប្រ៊ីមហល ពួកចិតសិបនាក់ប្រចាំតំបន់ និង នាយកចាត់ការនៃនាយកដ្ឋានពង្សប្រវត្តិ និង លីនដា ខេ. ប៊ើរតុន ប្រធានសមាគមសង្គ្រោះទូទៅ ក៏បានចូលរួមប្រជុំជាក្រុមនោះផងដែរ ។

ការបន្ថយអាយុរបស់យុវជន និង យុវនារីដែលអាចចាប់ផ្ដើមកិច្ចការផ្សព្វផ្សាយសាសនា សម្រាប់កម្មវិធីសិក្សាថ្មី និង សម្រាប់សំបុត្ររបស់គណៈប្រធានទីមួយ បានស្នើសុំថា យុវវ័យធ្វើការស្រាវជ្រាវពង្សប្រវត្តិ និង យកឈ្មោះរបស់គ្រួសារទៅកាន់ព្រះវិហារបរិសុទ្ធ, អែលឌើរ ផៃបភើរ បាននិយាយថា គាត់មិនបានកត់សម្គាល់ថា « មានការផ្លាស់ប្ដូរដល់ទៅបីជាមួយគ្នា » ពីមុនសន្និសីទឡើយ ។ « ខ្ញុំចាំថាខ្ញុំនឹងទៅសន្និសីទ . . . ហើយសួរខ្លួនឯងថា ‹ តើអ្វីៗទាំងអស់នោះទាក់ទងគ្នាយ៉ាងដូចម្ដេចទៅ ? ពិតណាស់វាបានកើតឡើងដោយព្រះហស្តទ្រង់ › » ។

អែលឌើរ ស្ទីក បាននិយាយថា ព្រះបន្ទូលរបស់ព្រះអម្ចាស់គឺច្បាស់លាស់គឺថា ៈ « យើងនឹងបញ្ឈើនកិច្ចការរបស់យើង ឱ្យឆាប់កើតនៅពេលកំណត់ » (គ.និង ស. 88:73) ។ គាត់បានបន្ថែមទៀតថា « ព្រះអម្ចាស់ទ្រង់ផ្ទាល់កំពុងមើលការខុសត្រូវលើកិច្ចការទាំងនេះ ។ ខ្ញុំមិនគិតថា ធ្លាប់មានជំនាន់របស់យុវវ័យដែលត្រូវបានរៀបចំសម្រាប់កម្មវិធីសិក្សាបែបនេះ ដូច [ យុវវ័យ ] សម័យនេះឡើយ ។ ខ្ញុំមិនធ្លាប់គិតថា មានក្រុមនៃយុវវ័យដែលបានធ្វើបុណ្យជ្រមុជទឹកបានច្រើន ឬ ពិធីបរិសុទ្ធសម្រាប់មរណជនច្រើនជាងនេះ . . . [ឬ] ថាធ្លាប់មានភាពជិតស្និតដើម្បីធ្វើកិច្ចការព្រះវិហារបរិសុទ្ធ និង អ្វីៗផ្សេងទៀតដូចក្រុមនេះឡើយ ។ ហើយពិតណាស់ អ្វីៗទាំងអស់នោះ . . . រៀបចំពួកគេសម្រាប់កិច្ចការផ្សព្វផ្សាយសាសនា និង កសាងគ្រឹះដ៏ខ្ជាប់ខ្ជួន សម្រាប់ការទទួលខុសត្រូវបន្ថែមទៀតនៅក្នុងប៉ុន្មានឆ្នាំនៃបេសកកម្មរបស់ពួកគេ » ។

អែលឌើរ ប្រ៊ីហល បាននិយាយថា វាជាសារលិខិតដ៏មានអំណាចដែលថា ព្រះទុកចិត្តដល់យុវវ័យរបស់ទ្រង់ ។

អែលឌើរ ចនសុន បាននិយាយថា « នៅពេលព្រះអម្ចាស់ធ្វើអ្វីៗនោះអ្វីៗទាំងនោះនឹងកើតមានឡើងតាមកាលកំណត់ ហើយនោះគឺជាអ្វីដែលបានកើតឡើងចំពោះរឿងនេះ ដោយកត់សម្គាល់ថាអស់អ្នកដែលកំពុងធ្វើតាមកម្មវិធីសិក្សាថ្មីរបស់យុវវ័យនេះ ពុំបានដឹងថានឹងមានការផ្លាស់ប្ដូរអាយុនៅពេលអ្នកផ្សព្វផ្សាយសាសនាអាចចាប់ផ្ដើមបម្រើឡើយ » ។

អែលឌើរ វ៉កឃើរ បាននិយាយពីសំបុត្រគណៈប្រធានទីមួយ ដែលបានលើកទឹកចិត្តឱ្យយុវវ័យបំពេញពង្សប្រវត្តិរបស់ពួកគេ ហើយយកឈ្មោះទាំងនោះទៅព្រះវិហារបរិសុទ្ធ ។ គាត់បាននិយាយថា « យុវវ័យអាចមានការកំណត់ផ្ទាល់ខ្លួនពួកគេដើម្បីប្រើប្រាស់អនុសាសន៍នោះ..នោះពិតជាអ្វីមួយដែលអស្ចារ្យណាស់ ។ « យុវវ័យ [ មាន ] ចិត្តអន្ទះសារចង់ធ្វើកិច្ចការនៅក្នុងព្រះវិហារបរិសុទ្ធ ហើយយល់ពីគោលលទ្ធិ ។ . . . នោះពិតជាជួយពួកគេឱ្យរៀបចំខ្លួនខាងវិញ្ញាណសម្រាប់អ្វីៗដែលអស្ចារ្យទាំងនោះ ដែលមានសម្រាប់ពួកគេ » ។

អែលឌើរ ផាកឃើរ បាននិយាយថា ថ្មីៗនេះគាត់បានឮថាមានយុវនារីម្នាក់បានឈរ ហើយចែកចាយទីបន្ទាល់របស់នាងពីកិច្ចការពង្សប្រវត្តិ ។



ព័ត៌មានសាសនាចក្រ

10686_258_Gen News Jun 4/4/13 11:38 AM Page 77

នាងបាននិយាយថា « នេះគឺជាអ្វីដែលរីករាយកាន់តែខ្លាំងឡើង ដែលមនុស្សចាស់ៗបាននិយាយថាវានឹងកើតឡើង » ។

អែលឌើរ រ៉ាកឃើរ បាននិយាយថា « នោះគឺជាវិញ្ញាណនៃលោកអេលីយ៉ា ។ នោះគឺការបង្វែរដួងចិត្តរបស់កូនទៅរកឪពុក និង ដួងចិត្តឪពុកទៅរកកូន » ។

*អ្នកដឹកនាំសាសនាចក្រយល់ស្របថា ព្រះអម្ចាស់កំពុងបង្កើនកិច្ចការរបស់ទ្រង់ ហើយថាយុវវ័យរបស់សាសនាចក្រត្រូវបានហៅឱ្យធ្វើការ ។*



អែលឌើរ ផាកឃើរ បានបន្ថែមថា កិច្ចការពង្សប្រវត្តិ នឹងផ្លាស់ប្ដូររបៀបដែលយុវវ័យធ្វើការសម្រេចចិត្ត និង របៀបដែលពួកគេមានអារម្មណ៍អំពីបញ្ហាទាំងឡាយ ។ គាត់បាននិយាយថា ពួកគេប្រហែលគិតថា « បើសិនជីតាខ្ញុំបានធ្វើការនេះ នោះខ្ញុំក៏អាចធ្វើវាបានដូចគ្នា » ។

គាត់បាននិយាយថា ប្រធានព្រះវិហារបរិសុទ្ធ បានរាយការណ៍មកថា នៅពេលយុវវ័យឈរខ្លួនជំនួស នៅក្នុងពិធីបុណ្យជ្រមុជទឹកសម្រាប់ឈ្មោះណាមួយនោះ ពួកគេបានងើបចេញពីទឹកមកវិញទាំងញញឹម « ប៉ុន្តែនៅពេលពួកគេបានធ្វើវាសម្រាប់ជីដូនជីតាណាម្នាក់ នោះពួកគេបានយំ ។ ពួកគេមានអារម្មណ៍ក្ដុកក្ដួលជាងពួកគេគេមានអារម្មណ៍ពិសេសជាង » ។

អែលឌើរ ផែបភើរ បាននិយាយថា ការជួយយុវវ័យឱ្យទទួលបានទស្សនវិស័យនេះ គឺជាគោលបំណងមួយនៃកម្មវិធិសិក្សាថ្មីរបស់យុវវ័យ—ដែលធនធានសិក្សាទាំងនេះជំនួសឱ្យសៀវភៅមេរៀន ។ កម្មវិធីសិក្សានេះនឹងធ្វើឱ្យអ្នកដឹកនាំយុវវ័យសម្រេចពីអ្វីដែលពួកគេត្រូវការដើម្បីកសាងខ្លួនដើម្បីទទួលបទពិសោធន៍ពីសប្ដាហ៍នីមួយៗ ដើម្បីរៀបចំយុវវ័យសម្រាប់កិច្ចការព្រះវិហារបរិសុទ្ធ និង ពង្សប្រវត្តិ និង កិច្ចការផ្សព្វផ្សាយសាសនា ។

អែលឌើរ ផាកឃើរ បាននិយាយថា « អិម.ធី.ស៊ី.ថ្មីនោះគឺជាផ្ទះហើយ ។ មជ្ឈមណ្ឌលពង្សប្រវត្តិថ្មីនោះ គឺជាផ្ទះហើយ ។ កម្មវិធីសិក្សាថ្មីនឹងជួយទាំងយុវវ័យ និង ឪពុកម្ដាយបំពេញតួនាទីនោះ » ។

សារលិខិតសម្រាប់ឪពុកម្ដាយគឺថា « អ្នកដឹកនាំសាសនាចក្រទុកចិត្តអ្នកថាជាឪពុកម្ដាយ និង ទុកចិត្តយុវជន និង យុវនារីទាំងនេះ ដែលត្រូវបានចិញ្ចឹមនៅក្នុងផ្ទះរបស់អ្នក » អែលឌើរ ស្ទីក បាននិយាយ ។

អែលឌើរ ចនសុន បាននិយាយថា ការផ្លាស់ប្ដូរទាំងអស់ធ្វើឱ្យ « សាសនាចក្រនឹងទៅកន្លែងដែលសាសនាចក្រត្រូវទៅកន្លែងដែលបានព្យាករទុក ។ ព្រះអម្ចាស់ដឹងពីអនាគតកាល ហើយ . . . នេះគឺគ្រាន់តែរឿងមួយនៃរឿងជាច្រើនដែលទ្រង់កំពុងធ្វើដើម្បីសម្រេចបាននគរនោះ ដើម្បីជួយវាឱ្យរមៀលចេញទៅ » ។

អែលឌើរ ផែបភើរ បាននិយាយថា នៅពេលអ្វីៗទាំងនោះបានកើតឡើង អំឡុងពេលសន្និសីទទូទៅនៅក្នុងខែតុលានេះ គាត់បានឃើញថា « ព្យាការីដែលមានកូនសោរ បានបើកទ្វារ ហើយមានប្រសាសន៍ថា « សូមចូលមក » ។ យើងសូមអញ្ជើញអ្នកឱ្យមក ហើយធ្វើកិច្ចការនេះ ។ ឥឡូវនេះគឺជាពេលវេលារបស់ព្រះអម្ចាស់ ។ យើងទាំងអស់គ្នាដឹងថាដូច្នេះ ។ យើងទាំងអស់គ្នាបានមានអារម្មណ៍នេះ ។ សមាជិកសាសនាចក្រកំពុងមានអារម្មណ៍នេះ ។ ពិតមែនហើយ វានឹងអាចធ្វើទៅបាន » ។ ■

10686_258_Gen News Jun 4/4/13 11:38 AM Page 78

# អែលឌើរ គ្រីស្តូហ្វឺសិន បានទូន្មានសមាជិកទាំងឡាយនៅក្នុងប្រទេស អាមេរិកភាគកណ្ដាល

**ដោយ អែលឌើរ ជុន អែល. ស្បេរល៍**

អ្នកផ្ដល់ព័ត៌មានឲ្យ *ព័ត៌មានសាសនាចក្រ*

កិច្ចការរបស់សាសនាចក្រសព្វថ្ងៃនេះ គឺរៀបចំមនុស្ស ដែលនឹងត្រៀមខ្លួន ដើម្បីទទួល និង បម្រើព្រះអម្ចាស់ នៅពេលទ្រង់យាងមក អែលឌើរ ឌី. ថត គ្រីស្តូហ្វឺសិន នៃ កូរ៉ុមនៃពួកសាវកដប់ពីរនាក់បានប្រាប់សមាជិកនៃស្តេក អារាយជែន ប៉ាណាម៉ា នៅថ្ងៃទី 20 ខែ មករា ឆ្នាំ 2013 ។

វាគឺជាប្រធានបទដែលអែលឌើរ គ្រីស្តូហ្វឺសិន បានថ្លែងជាច្រើនដងអំឡុងពេលទស្សនកិច្ចនៅប្រទេស អាមេរិកភាគកណ្ដាល ចាប់ពីថ្ងៃទី 11 ដល់ថ្ងៃទី 20 ខណៈពេលនិយាយទៅកាន់យុវវ័យ មជ្ឈិមវ័យវ័យក្មេងនៅលីវ អ្នកផ្សព្វផ្សាយសាសនា អ្នកដឹកនាំក្នុងមូលដ្ឋាន និង សមាជិកនៅក្នុងការប្រជុំសន្និសីទស្តេក ។

***អែលឌើរ ឌី. ថត គ្រីស្តូហ្វឺសិន បានស្វាគមន៍យុវនារីបន្ទាប់ពីការប្រជុំនៅក្នុងប្រទេស ប៉ាណាម៉ា នៅក្នុងខែ មករា ។***



ថតរូបដោយ ជេមស៍ ដែលវីអេល © IRI

អែលឌើរ គ្រីស្តូហ្វឺសិន បានអមដំណើរដោយភរិយារបស់លោកគឺ ខេធី គ្រីស្តូហ្វឺសិន និង អែលឌើរ រីឆាដ ជេ. មេណេស នៃគណៈប្រធាននៃពួកចិតសិបនាក់ និង ភរិយារបស់លោក គឺ ណានស៊ី មេណេស ។ នៅពេលលោកបានធ្វើដំណើរមុនគេទៅកាន់ កូស្តារីកា បន្ទាប់មកទៅ ហ្គាតេម៉ាឡា ហើយចុងក្រោយគេទៅប្រទេស ប៉ាណាម៉ា អែលឌើរ គ្រីស្តូហ្វឺសិន បានចូលរួមកន្លែងជាច្រើន ជាមួយនឹងសមាជិកនៃគណៈប្រធានតំបន់ ៖ អែលឌើរ ជេមស៍ ប៊ី. ម៉ាទីណេ ជាប្រធាន អែលឌើរ ខាលូស អេច. អាម៉ាដូ ជាទីប្រឹក្សាទីមួយ និង អែលឌើរ ខេវីន អ័រ. ដូខេន ជាទីប្រឹក្សាទីពីរ ។

អែលឌើរ មេណេស បានធ្វើដំនើរទៅកាន់ ហុនឌូរ៉ាស និង បេលីស៊ី ផងដែល ដើម្បីសួរសុខទុក្ខអ្នកដឹកនាំ និង សមាជិកនៅទីនោះ ។

អែលឌើរ គ្រីស្តូហ្វឺសិន បាននិយាយទៅកាន់យុវវ័យរាប់រយនាក់ដែលជួបជុំគ្នានូវសន្និសីទដើម្បីកម្លាំងនៃយុវជន នៅក្នុងប្រទេស កូស្តារីកា និង ប៉ាណាម៉ា និយាយទៅកាន់អ្នកផ្សព្វផ្សាយសាសនានៅប្រទេស សាន់ ហូសេ កូស្តារីកា ទីក្រុង ហ្គាតេម៉ាឡា និង ទីក្រុង ប៉ាណាម៉ា និយាយទៅកាន់មជ្ឈិមវ័យវ័យក្មេងនៅក្នុងប្រទេសទាំងបី និង និយាយទៅកាន់ក្រុមអ្នកដឹកនាំបព្វជិតភាព និង អង្គការជំនួយ ។

លោកក៏បានជួបជាមួយប្រធានាធិបតីនៃប្រទេស កូស្តារីកា និង ហ្គាតេម៉ាឡា ដើម្បីជួយពង្រឹងទំនាក់ទំនងឲ្យរឹងមាំជាមួយរាជរដ្ឋាភិបាល ។

នៅក្នុងប្រទេស កូស្តារីកា អែលឌើរ គ្រីស្តូហ្វឺសិន បានជម្រុញឲ្យយុវវ័យ និង មជ្ឈិមវ័យវ័យក្មេងគោរពតាមព្រះបញ្ញត្តិ ឲ្យចងចាំថាព្រះវរបិតាសួគ៌ ស្គាល់ និង ស្រឡាញ់ពួកគេ ហើយឲ្យអានព្រះគម្ពីររាល់ថ្ងៃ និង ស្វែងរកការទទួលបាននូវព្រះវិញ្ញាណដែលនឹងប្រទានឲ្យពួកគេនៅពេលពួកគេអាន ។

លោកបានថ្លែងទីបន្ទាល់យ៉ាងរឹងមាំពីព្យាការី យ៉ូសែប ស៊្មីធ និង ព្រះយេស៊ូវគ្រីស្ទ ។ លោកបានមានប្រសាសន៍ និង បន្ថែមទៀតថា « ខ្ញុំសូមប្រទានពរជ័យដល់អ្នក ថាអ្នកនឹងអាចទទួលបាននូវទីបន្ទាល់ដូចគ្នានេះ ដែលខ្ញុំបានមានថា [ ព្រះយេស៊ូវគ្រីស្ទ ] ពិតជាមានមែន ។ ខ្ញុំអធិស្ឋានឲ្យពរជ័យរបស់ទ្រង់មានសម្រាប់អ្នកយប់នេះ » ។

នៅក្នុងប្រទេស ហ្គាតេម៉ាឡា លោកបានគូសបញ្ជាក់ពីសារៈសំខាន់របស់គ្រួសារ ។

លោកបានមានប្រសាសន៍ថា « ដើម្បីបង្កើតគ្រួសារមួយនោះយើងបានបំពេញនូវគោលបំណងដ៏ចម្បងបំផុតរបស់យើងនៅលើផែនដីនេះហើយ » ។

លោកបាននិយាយទៅកាន់យុវវ័យនៅក្នុងប្រទេស ប៉ាណាម៉ា ហើយថ្លែងទីបន្ទាល់ថា « អ្នកដឹកនាំនៃសាសនាចក្រនេះ គឺជាព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើង ។ ទ្រង់គឺជាអ្នកដឹកនាំយ៉ាងជិតដិត និង សកម្មផ្ទាល់នៅក្នុងការដឹកនាំសាសនាចក្ររបស់ទ្រង់ » ។

សន្និសីទថ្នាក់ដឹកនាំបព្វជិតភាព បានបង្ហាញដោយមិនគ្រាន់តែផ្ដោតលើកិច្ចការ និង ការរវីរវល់នោះទេ ប៉ុន្តែស្ដីពីលទ្ធផលនៃការបម្រើរបស់បព្វជិតភាព ការផ្លាស់ប្រែចិត្តជឿដ៏សំខាន់របស់បុគ្គលម្នាក់ៗ ។

អែលឌើរ មេណេស ក៏បានធ្វើជាគណៈអធិបតីនៅក្នុងការប្រជុំជាច្រើន រួមទាំងការប្រជុំមជ្ឈិមវ័យវ័យក្មេង និង ការប្រជុំអ្នកផ្សព្វផ្សាយសាសនា នៅក្នុងទីក្រុង បេលី និង ហុនឌូរ៉ាស ហើយបានផ្ដល់ការទូន្មាន និង ការណែនាំខាងវិញ្ញាណ ដល់សមាជិករាប់រយនាក់នៅក្នុងទឹកដីនៅ អាមេរិកភាគកណ្ដាលនោះ ។ ■

*ជេសុន ស្វីនសិន បានផ្ដល់របាយការណ៍នេះ ។*

10686_258_Gen News Jun 4/4/13 11:38 AM Page 79



## វិទ្យាល័យសាសនាចក្រនៅក្នុងប្រទេស មិកស៊ិក្ទូ ក្លាយជា អិម.ធី.ស៊ី. ថ្មី

កាលពីថ្ងៃទី 29 ខែ មករា មានការប្រកាសមួយបានធ្វើឡើង ថាវិទ្យាល័យ បិនីមេរិត្ទូ ឌឺ ឡា អាមេរិខេនដែលជាវិទ្យាល័យរបស់សាសនាចក្រ នៅក្នុង ទីក្រុង មិកស៊ិក្ទូ ប្រទេស មិកស៊ិក្ទូ នឹងត្រូវបានប្ដូរទៅជាមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាវិញ ។

អែលឌើរ រ័សុល អិម. ណិលសុន និង អែលឌើរជែហ្វ្រី អ័រ. ហូឡិន ដែលជាកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានធ្វើជាគណៈអធិបតី ហើយបាននិយាយនៅក្នុងការប្រជុំថ្ងៃទី 29 ខែ មករា នៅក្នុងបរិវេណវិទ្យាល័យ បិនីមេរិត្ទូ ដែលគ្រោងសម្រាប់ពេលអនាគតធ្វើជា អិម.ធី.ស៊ី ត្រូវបានប្រកាសប្រាប់ ។ ការផ្លាស់ប្ដូរពីសាលារៀនទៅជា អិម.ធី.ស៊ី. ត្រូវបានរំពឹងថានឹងធ្វើឡើងនៅចុងឆ្នាំសិក្សាបន្ទាប់របស់សាលា បិនីមេរិត្ទូ នៅខែ មិថុនា ឆ្នាំ 2013 ។ អស់រយៈពេលច្រើនជាងបួនទស្សវត្សរ៍ អគារសាលា បិនីមេរិត្ទូ ឌឺ ឡា អាមេរិខេន ត្រូវបានប្រើជាកន្លែងស្នាក់អាស្រ័យរបស់សិស្ស—ដូច្នេះ កន្លែងសិស្សស្នាក់នៅ និង អគារដែលចាំបាច់ផ្សេងទៀតសម្រាប់ អិម.ធី.ស៊ី. បានមានរួចស្រេចហើយ ។

អិម.ធី.ស៊ី. ថ្មីនេះ នឹងបំពាក់បំប៉ន អែលឌើរ ស៊ីស្ទើរ និង អ្នកផ្សព្វផ្សាយសាសនាជាគូទាំងឡាយ ដែលមិនគ្រាន់តែបម្រើនៅក្នុងប្រទេស មិកស៊ិក្ទូ តែប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់អ្នកដែលទៅបម្រើទៅប្រទេសផ្សេងទៀតទៅ អាមេរិក ខាងជើង កណ្ដាល និង ខាងត្បូងផងដែរ ។ សូម្បីតែអ្នកផ្សព្វផ្សាយសាសនាដែលមកពី សហរដ្ឋ ដែលត្រូវហៅបម្រើឱ្យនិយាយភាសា អេស្ប៉ាញ នៅក្នុងប្រទេសផ្ទាល់ខ្លួនរបស់ពួកគេក៏ដោយ ក៏អាចត្រូវបានបំពាក់បំប៉ននៅក្នុងទីក្រុង មិកស៊ិក្ទូបានផងដែរ ។ អិម.ធី.ស៊ី. នៅក្នុងទីក្រុង ប្រូវ៉ូ រដ្ឋ យូថាហ៍ នឹងបន្តផ្ដល់ការបំពាក់បំប៉នភាសា អេស្ប៉ាញសម្រាប់អ្នកផ្សព្វផ្សាយសាសនាជាច្រើនទៀតផងដែរ ។

## ក្រុមចម្រៀងរោងឧបោសថបានសម្រេចជោគជ័យក្នុងការថតសំឡេង និង ដាក់បង្ហាញនៅលើអ៊ីនធើរណែត

នៅឆ្នាំចុងក្រោយបង្អស់នៃច្បាប់ចេញផ្សាយរបស់ទស្សនាវដ្ដី *Billboard* ដែលជាផលិតកម្មថតសំឡេង បានបង្កើតតារាងចុងឆ្នាំសម្រាប់ឆ្នាំ 2012 ។ ក្នុងចំណោមតារាងចុងឆ្នាំទាំងនោះ ក្រុមចម្រៀងរោងឧបោសថ ជាមួយនឹងក្រុមតន្ត្រីវិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធ ត្រូវបានដាក់ទាមថាជាប់ចំណាត់ថ្នាក់លេខមួយនៃអាល់ប៊ុមសិល្បៈចម្រៀងប្រពៃណីបុរាណ ។

© IRI



*ក្រុមចម្រៀងរោងឧបោសថមរមន និង ក្រុមតន្ត្រីវិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធ មានការគាំទ្រច្រើននៅក្នុងតារាងចុងឆ្នាំពីទស្សនាវដ្ដី Billboard និង មានអ្នកគាំទ្រច្រើនជាងបីលាននាក់នៅលើប៉ុស្ដិ៍ YouTube នៅចុងឆ្នាំ 2012 នេះ ។*

សរុបមក ក្រុមចម្រៀង និង ក្រុមតន្ត្រី ត្រូវបានដាក់នៅក្នុងបញ្ជីទីប្រាំ នៃបញ្ជីចុងឆ្នាំ និង បានដាក់ពីរដងនៅក្នុងបញ្ជីអាល់ប៊ុម ។ វាបានជាប់ចំណាត់ថ្នាក់លេខ 3 និង 9 នៅក្នុងអាល់ប៊ុមចម្រៀងប្រពៃណីបុរាណ (សម្រាប់អាល់ប៊ុមបទ *Glory!* (*សូមថ្វាយសេរីរុងរឿង !*) *Music of Rejoicing* (*តន្ត្រីនៃសេចក្ដីរីករាយ*) និង *This Is the Christ* (*នេះគឺជាព្រះគ្រីស្ទ*) ផ្សេងៗពីគ្នា; ចំណាត់ថ្នាក់លេខ 4 នៅក្នុងអាល់ប៊ុមចម្រៀងប្រពៃណីបុរាណ Imprint; ចំណាត់ថ្នាក់លេខ 5 នៅក្នុងអាល់ប៊ុមចម្រៀងប្រពៃណីបុរាណ Label; និង ចំណាត់ថ្នាក់លេខ 12 នៅក្នុងអាល់ប៊ុម Classical Crossover (សម្រាប់អាល់ប៊ុម *Glad Christmas Tidings* (*ដំណឹងរីករាយនៃបុណ្យគ្រីស្ទម៉ាស់*) ច្រៀងដោយ David Archuleta) ។

ក្រៅពីការថតសំឡេងបានជោគជ័យ នោះក្រុមចម្រៀងត្រូវបានគេមើលរហូតដល់ទៅមួយលាននាក់នៅលើប៉ុស្ដិ៍ YouTube កាលពីថ្ងៃទី 17 ខែ មករា ដែលបានដាក់ក្នុងប៉ុស្ដិ៍នោះមិនបានដល់ទៅបីខែមុននេះផង គឺបានដាក់នៅថ្ងៃទី 30 ខែ តុលា ឆ្នាំ 2012 ។ ប៉ុស្ដិ៍នេះត្រូវបានគេសន្និដ្ឋានថា នឹងមានគេមើលរហូតដល់ 3.23 លានទាទី រហូតដល់ចុងឆ្នាំ 2012 ។ ដើម្បីអាចមើលប៉ុស្ដិ៍នោះបាន សូមមើលគេហទំព័រ www.YouTube.com/user/MormonTabChoir ។



## ចិញ្ចឹមឱ្យរស់ដោយព្រះបន្ទូល

ដោយព្រឹត្តិការបោះពុម្ពនៃ *លីអាហូណា* បានក្លាយជាបទពិសោធន៍ស្អាងឡើងយ៉ាងខ្លាំងសម្រាប់ខ្ញុំ ។ ខ្ញុំបានចែកចាយសំឡេងដែលខ្ញុំបានទាញចេញពីអ៊ីនធើរណែតជាមួយសមាជិកម្នាក់ដែលមើលអត់ឃើញ ជាមួយម្នាក់ទៀតដែលជាអ្នកបើកបរជំនាញ និង មិត្តម្នាក់ទៀតដែលពិបាកអានអក្សរ ។

ថ្មីៗនេះ ខ្ញុំកំពុងរៀនថ្នាក់ក្រោយឧត្ដម ដែលនៅឆ្ងាយពីផ្ទះប្រហែល 200 គីឡូម៉ែត (130 ម៉ាយ) ហើយកំពុងស្ដាប់ទស្សនាវដ្ដី ដែលបានធ្វើឱ្យការជិះឡានក្រុងវាប្រែជាលឿន ហើយគួរជាទីពេញចិត្ត ។ នៅពេលខ្ញុំបានព្យួរច្បាប់ចេញផ្សាយរបស់សន្និសីទទូទៅ ខ្ញុំមានអារម្មណ៍ថា ខ្ញុំកំពុងបានរស់នៅក្នុងជំនាន់យ៉ាកុប ដែលត្រូវបាន « ចិញ្ចឹមឱ្យរស់ដោយព្រះបន្ទូលដ៏ល្អនៃព្រះអស់ទាំងថ្ងៃ » (យ៉ាកុប 6:7) ។

**ហ្វ្រានស៊ីស្កូ ឃ្លារ៉ែយូ ឌីណា កាទ្រីរ ប្រទេស ប្រេស៊ីល**

## បំផុសគំនិត លើកទឹកចិត្ត និង ពង្រឹង

ខ្ញុំស្រឡាញ់ *លីអាហូណា* ! លីអាហូណាបំផុសគំនិត និង លើកទឹកចិត្តខ្ញុំ ឱ្យបន្តដើរនៅលើផ្លូវត្រូវ ។ លីអាហូណាបានជួយខ្ញុំ ក្នុងការបម្រើរបស់ខ្ញុំក្នុងថ្នាក់យុវជន ។ នៅពេលអ្វីៗប្រែជាលំបាក ហើយខ្ញុំមានអារម្មណ៍បាក់ទឹកចិត្ត នោះខ្ញុំបានបើកព្រះគម្ពីរមរមន និង *លីអាហូណា* ។ ព្រះគម្ពីរមរមន និង លីអាហូណា ពង្រឹងទីបន្ទាល់របស់ខ្ញុំថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទស្រឡាញ់ និង ខ្វល់ខ្វាយចំពោះយើងម្នាក់ៗ ។

**ជេមស៍ អ៊ើរ៉ុន អេស. ពេរ៉េស ស៊ីប៊ូ ប្រទេស ហ្វីលីពីន**

# សេចក្តីជំនឿនៃអ្នករស់នៅលើកោះ

**ដោយ យូស្វេ ជេ. ភីខី**
ទស្សនាវដ្ដីសាសនាចក្រ



*ប្រជាជនលើកោះដែលខ្ញុំបានជួបនោះទទួលយកនូវអ្វីដែលពួកគេដឹងថាជាការពិត និង ទុកឲ្យបញ្ហានោះផុតរលត់ទៅ ។*

ក្នុងដំណើរថ្មីៗនេះពីសហរដ្ឋទៅកាន់កោះ ម៉ាស្បែល និង តុងហ្គា ខ្ញុំបានជាប់រវល់ជាមួយនឹងពួកអ្នកមានសេចក្ដីជំនឿដ៏បរិសុទ្ធ ដែលខ្ញុំបានជួប ។ ចំពោះរូបខ្ញុំជាទូទៅសេចក្ដីជំនឿរបស់ពួកគេច្បាស់លាស់តាមនិយមន័យដែលផ្លាស់ប្ដូរនៃសង្គមលោកខាងលិចពីសីលធម៌ និង សេចក្ដីពិត ។ សេចក្ដីជំនឿរបស់ប្រជាជនលើកោះគឺរឹងមាំ ដូចដែលបានរៀបរាប់ដោយអតីតប្រធានបេសកកម្មនៅកោះតុងហ្គា អែលឌើរ ចន អេច. ហ្គ្រូប៊ឺគ ( នៃពួកចិត្តសិបនាក់ ឆ្នាំ 1976–2005 ) ។ សេចក្ដីជំនឿនោះបានចាក់ឫសទៅក្នុងដង្វាយធួន និង ផែនការនៃសេចក្ដីសង្គ្រោះ ។ សេចក្ដីជំនឿដូច្នេះធ្វើឲ្យលែងមានសំណួរដែលបានរៀនដោយព្រះវិញ្ញាណបរិសុទ្ធ ។

ដោយរបៀបណាមួយនោះ ជីវិតរស់នៅលើកោះប៉ាស៊ីហ្វិកមានសន្ទុះយ៉ាងលឿនជាងកាលដែលខ្ញុំធ្លាប់នៅទៅនោះ ។ ទោះបីជាអ្នករស់នៅលើកោះនោះមាន ឡាន និង ទូរទស្សន៍ ភាពយន្ត និង អ៊ិនធើណែត កីឡា និង សកម្មភាពមួយចំនួនផ្សេងទៀតក៏ដោយ ទាំងនេះហាក់បីដូចជាមិនសូវលេចធ្លោដូចអ្នកទាំងឡាយណាដែលនៅក្នុងវប្បធម៌ជាច្រើនទៀត រួមទាំងសហរដ្ឋផងនោះ ។

ជាការពិត ប្រជាជននៅលើកោះនោះប្រឈមនូវការលំបាករបស់ពួកគេផ្ទាល់ដែរ ។ ដូចជាខ្ញុំអញ្ចឹងដែរ ពួកគេស្វែងរករបៀបមួយដើម្បីផ្ដល់អាហារ និង ជម្រក ក៏ដូចជាថែរក្សា និង ការពារទីបន្ទាល់របស់ពួកគេដែរ ។ ខ្ញុំសូមធ្វើជាសាក្សីម្ដងហើយម្ដងទៀត ចំពោះសេចក្ដីជំនឿរបស់អ្នកទាំងនោះដែលមិនបានងាករេទៅតាមសំពាធនៃឧបសគ្គ ឬ ធ្លាក់ចេញពីផ្លូវដោយសារភាពមមាញឹក ឬ ការធ្វេសប្រហែសនោះឡើយ ។ ផ្ទុយទៅវិញ ពួកគេបានដឹងថា ព្រះអម្ចាស់ចាំជួយពួកគេក្នុងជីវិតរស់នៅរបស់ពួកគេជានិច្ច ។ ដូចដែល អែលឌើរ ដេវីឌ អេស. បាស្ទើរ នៃពួកចិត្តសិបនាក់ ( និងជាអតីតប្រធានបេសកកម្មតំបន់ប៉ាស៊ីហ្វិក ) បានពន្យល់ថា « ពួកគេជឿទៅលើអព្ភូតហេតុ ពួកគេសង្ឃឹមដើម្បីទទួលបានអព្ភូតហេតុ ហើយពួកគេទទួលបានពិតមែន » ។

នៅពេលខ្ញុំត្រឡប់ទៅផ្ទះជាមួយនឹងបទពិសោធន៍របស់ខ្ញុំនៅក្នុងតំបន់ប៉ាស៊ីហ្វិកភាគខាងត្បូងវិញ ខ្ញុំបានសញ្ជឹងគិតអំពីសំណួរមួយចំនួន ៖ ហេតុអ្វីបានជាមនុស្សមួយចំនួនបន្តរឹងមាំនៅក្នុងសេចក្ដីជំនឿរបស់ពួកគេ ខណៈដែលអ្នកដទៃទៀតអនុញ្ញាតឲ្យសំណួរ និង ការសង្ស័យរំខានដល់គំនិតរបស់ពួកគេដូច្នេះ ? ដោយទទួលបាននូវទីបន្ទាល់មួយ ហេតុអ្វីបានជាមនុស្សមួយចំនួនអនុញ្ញាតឲ្យបញ្ហានោះកំសោយ ឬ ធ្វើឲ្យសេចក្ដីជំនឿរបស់ពួកគេទន់ជ្រាយទៅវិញ ? នៅពេលមនុស្សមួយចំនួនបានធ្វើសាក្សីអំពីជំនួយរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់ពួកគេ ហេតុអ្វីបានជាពួកគេត្រូវបានភ្ញាក់ផ្អើល ?

ប្រហែលជាចម្លើយគឺនៅជាមួយនឹងសេចក្ដីអង់អាចរបស់មនុស្សណាម្នាក់ជាមួយព្រះអម្ចាស់ ។ ដោយសារតែប្រជាជនលើកោះដែលខ្ញុំបានជួប នោះការសម្រេចចិត្តហាក់មិនមែនជាអ្វីមួយដែលធ្វើ ឬ ធ្វើឡើងវិញជាញឹកញាប់នោះទេ ។ ការស្ថាបនាសេចក្ដីជំនឿរបស់ពួកគេនៅលើសិលានៃព្រះដ៏ប្រោសលោះរបស់ពួកគេ គឺជាគ្រឹះដ៏ខ្ជាប់ខ្ជួនដែលមនុស្សជាច្រើនលែងមានសំណួរ ពួកគេបានបដិសេធក្នុងការដែលមិនធ្វើឲ្យទីបន្ទាស់របស់គេមានភាពរង្គោះរង្គើរផងដែរ ។ ពួកគេទទួលយកនូវអ្វីដែលពួកគេដឹងថាជាការពិត ហើយទុកឲ្យបញ្ហាទាំងនោះផុតរលុតទៅ ។

នោះគឺជាលក្ខណៈខ្ញុំចង់ឲ្យឥតខ្ចោះ ។ នៅពេលការលំបាកចំពោះជំនឿខ្ញុំកើតឡើង ខ្ញុំចង់មានលទ្ធភាពធ្វើនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ឲ្យអូលីវើរ ខៅឌើរី ធ្វើ ៖ « ចូរដាក់គំនិតទៅលើយប់ដែលអ្នកបានអំពាវនាវដល់យើង ក្នុងដួងចិត្តរបស់អ្នក ដើម្បីឲ្យអ្នកអាចដឹងនូវសេចក្ដីពិតអំពីការណ៍ទាំងឡាយនេះ ។ តើយើងពុំបាននិយាយដោយភាពសុខសាន្តដល់គំនិតរបស់អ្នកអំពីការណ៍នេះទេឬអី ? តើអ្នកអាចមានសាក្សីឯណា ដែលអស្ចារ្យជាងសាក្សីមកពីព្រះ ? » (គ. និង ស. 6: 22–23 ) ។ ការចងចាំបែបនេះដឹកនាំទៅរកសេចក្ដីជំនឿដែលមិនងាករេ ។

សេចក្ដីជំនឿប្រភេទនេះគឺបរិសុទ្ធ និង មានសេរីភាពពីការរំខានទាំងឡាយ ។ វាគឺជាការលះបង់ និង ការទទួលយក ។ ខ្ញុំដឹងថា ៖ វាជាការពិត » ។ ខ្ញុំពុំចាំបាច់ត្រូវសួរជាថ្មីទៀតនោះទេ » ។

ការអនុវត្តនូវសេចក្ដីជំនឿបែបនេះទៅលើព្រះវរបិតាសួគ៌ និង ផែនការរបស់ទ្រង់ អនុញ្ញាតឲ្យព្រះចេស្ដារបស់ទ្រង់មានប្រសិទ្ធភាពនៅក្នុងជីវិតរស់នៅរបស់យើង ។ វាមិនធ្វើឲ្យកើតមានការវាយប្រហារទៅលើសេចក្ដីជំនឿរបស់យើង ធ្វើឲ្យនឿយហត់ ឬអ្វីមួយដែលមិនបានដឹងនោះទេ ។ វាអនុញ្ញាតឲ្យយើងអាចនិយាយថា ៖ « ទ្រង់មានព្រះជន្មរស់ ! » ហើយសម្រាប់ខ្ញុំនោះ គឺគ្រាប់គ្រាន់ហើយ ។ ■

ថតរូបដោយ យូស្វេ ជេ. ភីខី



រូបភាពដោយ រ៉ូប៊ើត ធី. បារ៉េត

# ឡូរ៉ែនសូ ស្នូ

**ឡូរ៉ែនសូ ស្នូ** ធ្វើដំណើរជុំវិញពិភពលោកដើម្បីផ្សព្វផ្សាយដំណឹងល្អ ។ នៅពេលគាត់កំពុងធ្វើដំណើរតាមទូកទៅកាន់កោះហាវ៉ៃ មាន**ព្យុះ** មួយបោកបក់មកលើទូករបស់គាត់ ។ ឡូរ៉ែនសូ បានទុកចិត្តទៅលើព្រះអម្ចាស់ ហើយត្រូវបានសង្គ្រោះពីការលិចលង់ ។ ខណៈពេលកំពុងតែនិយាយនៅឯ **រោងឧបោសថ នៅ សេន ចច**ក្នុងឆ្នាំ 1899 ប្រធាន ឡូរ៉ែនសូ ស្នូ បានទទួលនូវការបំផុសគំនិតឲ្យបង្រៀនអំពីសារៈសំខាន់នៃការបង់ដង្វាយមួយភាគក្នុងដប់ពេញលេញ ។ នៅពេលដែលសមាជិកបានចាប់ផ្ដើមបង់ **ដង្វាយមួយភាគក្នុងដប់** នោះហិរញ្ញវត្ថុរបស់សាសនាចក្រកាន់តែមានស្ថេរភាពជាងមុន ។ ពួកបរិសុទ្ធថ្ងៃចុងក្រោយបានបង់ជាលុយនៅពេលពួកគេមាន និងបង់ជារបស់របរដូចជា ស៊ុត ទឹកដោះគោ និងជាសត្វគោក្របីនៅពេលពួកគេគ្មានលុយ ។



គណៈប្រធានទីមួយ និងកូរ៉ុមសាវកដប់ពីរនាក់សរសេរនៅក្នុង « សេចក្តីប្រកាសចំពោះពិភពលោកអំពីគ្រួសារថា » « ក្រុមគ្រួសារគឺជាផ្នែកសំខាន់មួយនៃផែនការរបស់ព្រះដ៏បង្កបង្កើត សម្រាប់គោលដៅដ៏ដ៏អស់កល្បជានិច្ចនៃកូនចៅរបស់ព្រះអង្គ » ។ សេចក្តីប្រកាសគូសបង្ហាញនូវគោលការណ៍ប្រាំបួនយ៉ាងចំពោះការពង្រឹងអាពាហ៍ពិពាហ៍ និង ក្រុមគ្រួសារ ៖ « សេចក្តីជំនឿ ការអធិស្ឋាន ការប្រែចិត្ត ការអភ័យទោស សេចក្តីគោរព សេចក្តីស្រឡាញ់ សេចក្តីមេត្តាករុណា ការងារ ហើយនិងសកម្មភាពលេងកំសាន្តដ៏ល្អត្រឹមត្រូវ » ។ សូមមើល អត្ថបទនៅលើទំព័រ 26 សម្រាប់ការយល់ដឹងជ្រៅជ្រះអំពីគោលការណ៍នីមួយៗនៃគោលការណ៍ទាំងប្រាំបួននេះ ។

CAMBODIAN
4 02107 86258 9

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ